

# ណក៉ាម៉ារី

ប្រែសម្រួលដោយ

**ចន្ទ បុផល**

(អាថ៌កំបាំងក្នុងវាំងស្តេចខ្មែរ)

បណ្ណាគារអង្គរ




ក្រុងភ្នំពេញ៖ ត្តសំណប់ព្រះករុណាព្រះស៊ីសុវត្ថិព្រះចៅក្រុងកម្ពុជា

រឿង **«សារ៉ាម៉ានី»** និពន្ធដោយជនជាតិបារាំង ឈ្មោះ "រ៉ូឡង់ ម៉ីសែរ" ចាងហ្វាងវិចិត្រសិល្បៈប្រចាំប្រទេសកម្ពុជា កាលជំនាន់ប្រទេសយើង ស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ ដោយដាក់ចំណងជើងថា **«SARAMANI, DANSEUSE KHMERE»** បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩១៩ ។ "រ៉ូឡង់ ម៉ីសែរ" ធ្លាប់រស់នៅក្នុងប្រទេសយើងអស់ពេលដ៏យូរ ធ្លាប់ចេញ-ចូលវាំងស្តេចខ្មែរជាញឹកញាប់ ទើបអាច ស្គាល់ និង ដឹង ជីវភាពស្តេចបានជាក់លាក់ល្អយ៉ាងនេះ ។ សោតឯដំណើររឿង ខ្ញុំបានសាកសួរចាស់ទុំច្រើននាក់ ដែលធ្លាប់រស់នៅក្នុងវាំង ឃើញថា សុទ្ធសឹងជារឿងពិត រហូតដល់តួអង្គក្នុងរឿង ក៏សុទ្ធជាមនុស្សដែលធ្លាប់បានរស់នៅកាលជំនាន់នោះមែន ។ . . . ៕


ការផ្សាយរបស់ទស្សនាវដ្ដីអង្គរវត្ត ◆ បោះពុម្ពផ្សាយដោយបណ្ណាគារអង្គរ

ដកល់ទុកនៅបណ្ណាល័យជាតិបារាំងក្រុងប៉ារីស និង នៅបណ្ណាល័យខ្មែរក្រុងភ្នំពេញ

**ISBN 10 : 99950-59-03-7**
**ISBN 13 : 978-99950-59-03-3**

និពន្ធដោយ
**រ៉ូឡង់ ម៉ឺយែរ**

គ.ស. ១៩៧១
ព.ស. ២៥១៨
រក្សាសិទ្ធិ

ប្រែសម្រួលដោយ
**ចន្ទ បូផល**



# កំណត់ ការបោះពុម្ព

**សារ៉ាម៉ានី** ជាប្រលោមលោកនិពន្ធដោយ *Roland MEYER* ជាភាសាបារាំង ***"SARAMANI, DANSEUSE KHMÈRE"*** បោះពុម្ពផ្សាយនៅ ភ្នំពេញ នាឆ្នាំ ១៩១៩ ។ **លោក រ៉ូឡង់ ម៉ីយែរ** ជាចាងហ្វាងវិចិត្រសិល្បៈ ប្រចាំប្រទេសកម្ពុជា ធ្វើការនៅស្រុកខ្មែរ ធ្លាប់ ចេញ ចូល វាំងស្ដេចខ្មែរ និង បានរស់នៅយ៉ាងយូរ នៅស្រុកខ្មែរ ។ នេះជាកត្តាដ៏សំខាន់ អនុញ្ញាតឲ្យលោកនិពន្ធសៀវភៅនេះឡើង ប្រកបដោយខ្លឹមសារដ៏ល្អ រៀបរាប់ពីជីវភាពព្រះរាជវង្ស នៃ ព្រះមហាក្សត្រខ្មែរ នៅក្នុងវាំង ពីជីវភាពរាស្ត្រខ្មែរ ពីសង្គមខ្មែរនៅសម័យនោះ ពីចំណាប់អារម្មណ៍ នៃ **សារ៉ាម៉ានី** នារីខ្មែរសាមញ្ញម្នាក់ ដែលបានធ្វើដំណើរតាមកប៉ាល់ទឹក ឆ្លងកាត់មហាសាគរ ច្រើនថ្ងៃ ច្រើនយប់ មុននឹងបានមកដល់ និង ស្នាក់អាស្រ័យមួយរយៈពេលដ៏ខ្លី នៅស្រុកបារាំង ។

សៀវភៅនេះ ជាកញ្ចក់មួយ ដែលជនជាតិបារាំងម្នាក់ ហ៊ាននិយាយពីសង្គមខ្មែរ ក្នុងរជ្ជកាល **ព្រះបាទ ស៊ីសុវត្ថិ** (១៩០៤ - ១៩២៧) ក្នុងរយៈពេលដែលប្រទេសខ្មែរយើង កំពុងស្ថិតនៅក្រោមអាណាព្យាបាលបារាំង នៅឡើយ ។

ដើម្បីសង្កត់ន័យទៅលើខ្លឹមសារ នៃ សៀវភៅនេះ ដែល **អ្នកស្រី ចន្ទ បូផល** បានបកប្រែជាភាសាខ្មែរដ៏ល្អ និង បានបោះពុម្ពផ្សាយនៅ ភ្នំពេញ ពីឆ្នាំ ១៩៧១ **ឧស្សាហ៍ដ្ឋី អង្គរវត្ត** បានផ្សាយឡើងវិញនៅ ប៉ារីស នៅឆ្នាំ ១៩៩៦ និង រៀបចំបោះពុម្ពជាសៀវភៅផ្សាយនៅឆ្នាំនេះ ដោយមានដាក់បញ្ចូលរូបថតស្រុកខ្មែរមួយចំនួន ថតនៅរជ្ជកាល នៃ ព្រះមហាក្សត្រខ្មែរ **ព្រះបាទ នរោត្តម** និង **ព្រះបាទ ស៊ីសុវត្ថិ** ។ គឺ សៀវភៅនេះតែមួយគត់ ដែល **សម្ដេច នរោត្តម សីហនុ** បានយកទៅតាមព្រះអង្គ ពេលដែល ព្រះអង្គ បានការអនុញ្ញាតពី **ប៉ុល ពត** ឲ្យ ព្រះអង្គ យាងចេញ ពីក្រុងភ្នំពេញ ទៅក្រុងប៉េកាំង នៅ ថ្ងៃទី ៦ មករា ១៩៧៩ ដើម្បីទៅការពារ អាសនៈ **"កម្ពុជា ប្រជាធិបតេយ្យ"** នៅ អង្គការសហប្រជាជាតិ ពេលដែល ទ័ពយួនវាយលុក និង កាន់កាប់ កម្ពុជា មួយរយៈពេលនោះ ។ ការបោះពុម្ពនៅប៉ារីសនេះ កើតឡើងបានដោយការខ្នះខ្នែងរបស់ **លោក ឌិន ប៊ុន ហេង** ជាអ្នកបង្កើតតួអក្សរខ្មែរផ្ទាល់តែម្ដង ព្រមជាមួយការ រៀបចំទំព័រ ខំសំអិតសំអាង ផ្ដល់គុណភាពដ៏ល្អដល់សៀវភៅនេះឡើង ៕

*បោះពុម្ពផ្សាយនៅ ខែ កក្កដា គ.ស. ២០០០ ព.ស. ២៥៤៤ ដោយ* **ឧស្សាហ៍ដ្ឋី អង្គរវត្ត**

ANGKOR BOOK SHOP
#143Eo, rue Khémarak Phoumin (St.130), Phsar Chas, Phnom Penh
Angkor Vat, angkorvat1@aol.com
ISBN: 2-9524557-9-1 ISSN : 1162-1660




ព្រះបាទនរោត្តម ថតនៅឆ្នាំ១៨៦៣



ព្រះបាទនរោត្តមនិងព្រះរាជបុត្រច័ន្ទលេខា




ព្រះបាទស៊ីសុវត្ថិពេលអភិសេកគ្រងរាជ្យនៅឆ្នាំ១៩០៦



បូជនីយដ្ឋាននៅវត្តភ្នំក្រុងភ្នំពេញ

ការរំលឹកសន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧

3 3090 02120 2165



ព្រះបាទស៊ីសុវត្ថិទ្រង់គ្រងជាយោធា



ព្រះបាទស៊ីសុវត្ថិ  ថតនៅប៉ារីសខែមិថុនា១៩០៦





ព្រះអង្គម្ចាស់មុនីវង្សយាងមកប៉ារីសបានចូលរៀនសាលាយោធា Saint Maixen

អ្នកទី២ខាងស្តាំគឺព្រះអង្គម្ចាស់សុរាម្រឹត





ស្នំព្រះបាទនរោត្តម



អ្នកបកប្រែភាសាខ្មែរ-បារាំង



ស្ត្រីខ្មែរមកលេងបុណ្យអុំទូក



ស្ត្រីស្នំព្រះបាទស៊ីសុវត្ថិ៦នាក់

សាលាខ្មែរ-បារាំង
រូបដែលស្ថិតនៅផ្លូវខាងក្រោយគឺព្រះវិហារ ព្រះកែវមរកត



Ecole Franco - Khmère
au fond, la Pagode d'Argent

កំពង់ផែភ្នំពេញ



Port de Phnom Penh

មន្ទីរគយ និង រដ្ឋាករ
ទីតាំងបច្ចុប្បន្ន ខាងកើតវត្តភ្នំ



មន្ទីរគយ និង រដ្ឋាករ





Hôtel du Résident Supérieur et les musiciens

សួនច្បារនៅវត្តភ្នំ



Jardin du Phnom



វត្តភ្នំ (មើលពីស្ពាននាគ)



Le Phnom, vu du pont des Nagas

ស្ពាន FABRE ឆ្លងកាត់ព្រែកពងពាយ, មើលពីឆ្នេរមេគង្គ
ឆ្ងាយទៅក្រោយមានភូមិ និងព្រះវិហារកាតូលិក



Pont Fabre, sur prék Pongpeay, vu du bored du Mékong
au fond, village catholique et son égglise

វិថី VERNEBILLE
នៅឆ្ងាយបន្តិចគឺស្ពាននាគ



ស្ពានដែកឆ្លងទៅផ្សារចាស់ ឈើឆ្លាក់ខ្នងកញ្ជែងខ
នៅឆ្ងាយ គឺស្ពាននាគ និងវិមានមីន



tral (actuel Phsar Chas)
Nagas et la maison des mines

ស្ពាន FABRE
នៅឆ្ងាយបន្តិចមានព្រះវិហារកាតូលិក



Pont Fabre
au loin, l'église catholique

# បុព្វកថា

ក្រោយពីបានចុះផ្សាយ ចប់សព្វគ្រប់តាមទំព័រ នៃ សារពត៌មានរដ្ឋ «*ប្រយោជន៏ខ្មែរ*» ផៀងរាល់ថ្ងៃ ចាប់តាំងពីលេខ ១៥៩ ចេញថ្ងៃទី ១៥ តុលា ១៩៧០ រហូតដល់លេខ ២៥១ ចេញថ្ងៃទី ២២ មករា ១៩៧១ ខ្ញុំក៏បានរៀបចំចងក្រងរឿង «**សារ៉ាម៉ានី**» នេះ ជាសៀវភៅឡើង ដើម្បីជាកិច្ចគោរពតាមសំណូមពរ នៃ អស់លោក-មិត្តអ្នកអាន ជាច្រើន ដែលបានយកចិត្តទុកដាក់អានរឿងនេះជាប់រហូតមក ហើយបានផ្ញើលិខិតមកសុំឲ្យខ្ញុំរៀបចំបោះពុម្ពផ្សាយជាសៀវភៅ ដើម្បីស្រួលរក្សាទុក ។

រឿង «**សារ៉ាម៉ានី**» និពន្ធដោយជនជាតិបារាំង ឈ្មោះ "រ៉ូឡង់ ម៉ីសែរ" ចាងហ្វាងវិចិត្រសិល្បៈប្រចាំប្រទេសកម្ពុជា កាលជំនាន់ប្រទេសយើង ស្ថិតនៅក្រោមអាណាព្យាបាលបារាំងនៅឡើយ ដោយដាក់ចំណងជើងថា «SARAMANI, DANSEUSE KHMERE» បោះពុម្ពផ្សាយក្នុងឆ្នាំ ១៩១៩ ។ "រ៉ូឡង់ ម៉ីសែរ" ធ្លាប់រស់នៅក្នុងប្រទេសយើងអស់ពេលដ៏យូរ ធ្លាប់ចេញ-ចូលវាំងស្តេចខ្មែរជាញឹកញាប់ ទើបអាច ស្គាល់ និង ដឹង ជីវភាពស្តេចបានជាក់លាក់ល្អយ៉ាងនេះ ។ សោតឯដំណើររឿង ខ្ញុំបានសាកសួរចាស់ទុំច្រើននាក់ ដែលធ្លាប់រស់នៅក្នុងវាំង ឃើញថាសុទ្ធសឹងជារឿងពិត រហូតដល់តួអង្គក្នុងរឿង ក៏សុទ្ធជាមនុស្សដែលធ្លាប់បានរស់នៅកាលជំនាន់នោះមែន ។

ឆ្លៀតឱកាសនេះ ខ្ញុំសូមជម្រាបបញ្ជាក់ជាថ្មីម្តងទៀតថា ក្នុងការប្រែសម្រួលពីភាសាបារាំងមកជាភាសាជាតិយើង តែងតែមានការឆ្អែ ពាក្យ-ពេចន៍ ឃ្លា ប្រយោគ ខ្លះជាធម្មតា ប៉ុន្តែទោះជាយ៉ាងណា ក៏ខ្ញុំឥតមានថែមថយសាច់រឿង ឬ ពន្លើសពាក្យសំដី ដើម្បីញ៉ាំងសាច់រឿងឲ្យឃើញសម្បើមនោះដែរ ។

**ចន្ទ បូរីល**



*គង ពីរអន្ទូងលាន់ឮឡើង ដោយមានស្នូរអែន្ទូងទៀតឮខ្លាំងជាងមុនបន្តិច បន្ទឹតាមក្រោយ... ស្វាត់មួយរយៈ ហើយបន្ទាប់មកសម្លេងភ្លេងពិណ្យពាទ្យដ៏សែនលន្ទង់លន្លោច ប្រៀបបានសម្លេងទិព្វ រសាត់ចេញពីវាំងចតុមុខមកបញ្ចោសអង្លែលសង្កាត់កំពង់ផែទាំងមូល ឲ្យដេកលង់លក់ស្ងាត់ឈឹងកណ្តាលរាត្រីដ៏ភ្លឺត្រចះត្រចង់ ។*

*សារ៉ាម៉ានីអង្គុយលើគ្រែនាងនួន កំពុងចាក់ជ័រអាវយ៉ាងស្ងៀមស្ងាត់ក្បែរចង្កៀងប្រេងកាត ។ នាងងើបមុខឡើង ត្រចៀកប្រុងស្តាប់ ទឹកមុខញញឹម ហើយនាងទម្លាក់ដៃទាំងពីរដែលកាន់ប្រដាប់ចាក់នោះទៅលើជង្គង់ ។ នៅពេលឮសម្លេងភ្លេងពិណពាទ្យ អនុស្សាវរីយ៍ នៃ រឿងរ៉ាវពីអតីតកាលទាំងប៉ុន្មាន ក៏លេចឡើងយ៉ាងច្បាស់នៅចំពោះមុខនាង ញ៉ាំងចិត្តនាងឲ្យប្រែជាស្រពោនភ្លាមមួយរំពេច ។ នាងពោលឡើងដោយសម្លេងញ័រៗ :*

*~ ពួកល្ខោនមកប្រជុំគ្នានៅលើឆាកហើយ... ខ្ញុំស្រណោះកាលខ្ញុំនៅរាំណាស់ !*

*កម្លោះក៏ដូចជាភ្ញាក់បន្តិចដែរ នៅពេលតន្ត្រីចាប់ប្រគុំឡើង ។ គេដាក់ស្លាបប៉ាកកាចុះ តៀសសៀវភៅដាក់នៅលើតុ ដែលជាកន្លែងធ្វើការ និង ជាកន្លែង នៃ ពន្លឺភ្លើសង្ឃឹមតែមួយគត់របស់គេចេញពីមុខបន្តិច... ហើយចោលក្រសែភ្នែករំលងក្បាលភរិយា បាញ់ឆ្ពោះទៅរក្សបថតព្យួរជាប់នឹងជញ្ជាំងស្លឹក ដែលជារូបសារ៉ាម៉ានី កាលនាងទើបនឹងមានវ័យដប់បួនឆ្នាំនៅឡើយ ស្លៀកពាក់ជាអ្នករាំល្ខោនហ្លួង ពាក់មកុដមាសស្អាតប្រិមប្រិយ៍ ដូចទេពអប្សរក្នុងរឿងព្រេងនិទាន ។*

*ឥឡូវប្អូនឆ្នាំកន្លងផុតមកហើយ ចាប់តាំងពីពេលដែលសារ៉ាម៉ានី ចាកចេញពីវាំងមក បន្ទុកជាស្ត្រីមេផ្ទះបានធ្វើឲ្យចរិតនាងប្រែប្រួលប្លែកពីមុនស្ទើរតែទាំងអស់ ។*

*កម្លោះ និង សារ៉ាម៉ានី គូស្វាមី-ភរិយាវ័យក្មេងនេះ បានមកសង់ផ្ទះនៅជិតវាំងហ្លួង ក្នុងសង្កាត់កំពង់ផែ ដែលជាកេរ្តិ៍ដំណែលដ៏មានតម្លៃ រកអ្វីមកប្រៀបឲ្យស្មើពុំបាន នៃ ភូមិខ្មែរបុរាណ ហើយគេទាំងពីរនាក់ អង្គុយធ្វើការទល់មុខគ្នាក្បែរចង្កៀងប្រេងកាតនៅក្នុងផ្ទះស្លឹកតូចច្រឡឹងនេះ ដោយមានលាក់ទុកក្នុងផ្ចិតគំនិត នូវរឿងដ៏មានតម្លៃបំផុត ពុំងាយនឹងមាននរណាបានដឹងឡើយ គឺរឿងពិត នៃ បុគ្គលម្នាក់មានឋានៈជាស្តេចគ្រប់គ្រងប្រទេសជាតិ ហើយដែលត្រូវបានអ្នកដទៃគោរពស្មើព្រះអាទិទេព ។*

*ពេលនេះ ជាខែភទ្របទ... ពិធីបុណ្យចំរើនព្រះជន្មស្តេច បានទាក់ទាញនាម៉ឺនយ៉ាងច្រើនកុះករ មកពីគ្រប់ ខេត្ត-ខ័ណ្ឌ ឲ្យមកជួបជុំគ្នាក្នុងរាជធានី ដើម្បីផឹកទឹកសម្បថ និង ចូលរួមក្នុងពិធីបុណ្យតាំងតុ ។*

*ល្ងាចនេះ មានរាំល្ខោនហ្លួងនៅខាងក្រៅវាំង ជូនសាធារណជនទស្សនាកំសាន្តផង ។*

កម្លោះ បើកចំហសៀវភៅត្រង់ទំព័រមួយ ដែលសរសេរមិនទាន់ចប់នៅឡើយ ហើយបណ្ដែតអារម្មណ៍ឲ្យសាត់អណ្ដែតទៅឆ្ងាយ... ឆ្ងាយឥតព្រំដែនក្នុងពិភព នៃ ក្ដីស្រមៃដ៏ធំល្វឹងល្វើយ ។

~ លោក! (សាវ៉ាម៉ានី ខុទានតិចៗ ទម្លាយបរិយាកាសស្ងប់ស្ងាត់ ដោយសណ្ដូកដៃទន់រលូនទៅលើតុ) លោកគិតពីរឿងអីហ្នឹង ? លោកនឹកទៅដល់រឿងរ៉ាវចាស់ដូចខ្ញុំដែរឬអ្វី ? លោកញញឹមស្ងួតអញ្ចឹងបានសេចក្ដីថា លោកស្រឡាញ់ខ្ញុំមែនទែន ឬមួយក៏ លោករឭកទៅស្រុកកំណើតរបស់លោក ? ខ្ញុំឃើញតែលោកគិត, ឃើញតែលោកសរសេរ! លោកគូសក្រវេមក្រវាមដូចជើងក្អាម ក្នុងសៀវភៅធំនេះរាប់ឆ្នាំហើយ តើលោកធ្វើការដើម្បីនរណា ? លោកសម្លឹងមើលទៅឆ្ងាយលន្លង់លន្លោចអញ្ចឹង ខ្ញុំអត់យល់អីសោះទេ... យីអើ! កាលណាទើបលោកបង្រៀនឲ្យខ្ញុំចេះភាសាលោក គ្រាន់នឹងខ្ញុំអាចអង្គុយកំដរមើលលោកធ្វើការពេលយប់បានផង ?

សាវ៉ាម៉ានី អង្គិលខ្លួនទៅចុងគ្រែ នាងយកដៃទាញស្បៃស្ដើងដែលគ្របដណ្ដប់លើខ្លួនចេញ បង្ហាញនូវគល់សុដនសរលោងដូចម្នាងសិលា ប្រកបទៅដោយសរសៃខៀវលេចឡើងយ៉ាងច្បាស់ ។ ក្រសែភ្នែកកម្លោះ ប៉ះទង្គិចគ្នានឹងក្រសែភ្នែកនាង ដែលបញ្ចេញរស្មីស្រទន់ជាតំណាង នៃ ទឹកចិត្តស្អាតបរិសុទ្ធ និងសេចក្ដីស្នេហាស្មោះត្រង់ ។ កម្លោះ ដាក់ដៃចុះទៅលើគំនរក្រដាសដោយកាយវិការខ្ជិលច្រអូស ហើយពោលឡើង :

~ នាង! នាងមិនចាំបាច់ដឹងថាខ្ញុំសរសេរពីអ្វី, មិនចាំបាច់រៀនភាសាបារាំងទេ ។ ភាសានេះជាថ្នាំពុលដ៏សាហាវបំផុតចំពោះស្ត្រីខ្មែរ វានឹងនាំឲ្យនាងស្គាល់ កាយវិការ និង អាកប្បកិរិយាច្រងេងច្រងាង ដែលនាងមិនធ្លាប់ដឹង វានឹងនាំឲ្យនាងកើតគំនិត និង ពុតត្បុតអាក្រក់ ដែលភាសានាងពុំអាចថ្លែងចេញជាពាក្យសំដីបាន ។ កម្រមានស្ត្រីខ្មែរណាដែលអាចទប់ទល់នឹងថ្នាំពុលនេះបានណាស់!... ខ្ញុំសរសេរដើម្បីអ្វី ? នាង! ខ្ញុំគិតដើម្បីអ្វី ? ខ្ញុំបាននិយាយប្រាប់នាងច្រើនដងហើយតើ! ខ្ញុំបាននិយាយប្រាប់នាងថា ខ្ញុំចង់សរសេររៀបរាប់ ពីសម្រស់, ពីសីលធម៌ នៃ ពូជសាសន៍របស់នាង ដើម្បីបង្ហាញឲ្យពិភពលោកឃើញច្បាស់នូវតម្លៃពូជខ្មែរដ៏ចាស់យូរអង្វែងណាស់មកហើយ, ហើយនរណាអាចដឹងបាននាង ? ថ្ងៃណាមួយ ក្រែងលោទេវតាលោកប្រទានរង្វាន់ចំពោះការខំប្រឹងប្រែងរបស់យើង ដោយផ្ដល់ជាកិត្តិយស និង ជាទ្រព្យសម្បត្តិ ហើយដល់ពេលនោះ យើងនឹងចាកចេញពីខ្ទមស្លឹក ដើម្បីទៅសង់ផ្ទះក្បឿង សសរថ្មីកមួយ នៅមាត់ទន្លេ ដោយមានដាំដើមស្វា និង ដើមឈើដទៃទៀត សម្រាប់ជាម្លប់ត្រជាក់ដល់ដីភូមិយើងផង ។

~ ណ្ហើយ! (សាវ៉ាម៉ានី ឱនមុខចុះ ដកដង្ហើមធំ) ខ្ញុំមិនចង់បានទ្រព្យសម្បត្តិដែលនាំឲ្យលោកត្រឡប់ទៅស្រុកបារាំងវិញទេ ។ ខ្ញុំចង់ឲ្យលោកក្រដូចសព្វថ្ងៃអញ្ចឹងរហូតទៅ ដើម្បីឲ្យលោកនៅតែស្មោះត្រង់នឹងខ្ញុំ ។ ខ្ញុំមិនចង់ឃើញទ្រព្យសម្បត្តិដែលមកធ្វើឲ្យលោកល្អក់ចិត្ត មកបណ្ដាច់លោកពីជីវភាពដ៏សុខសាន្តដូចយើងរស់នៅសព្វថ្ងៃ ហើយបែរទៅស្រឡាញ់ស្រីសស្គុសដូចសំឡី ទៅរស់នៅក្នុងវិមានដ៏ល្អឆើតឆាយក្នុងប្រទេសរបស់លោកវិញនោះទេ... លោកស្ដាប់ខ្ញុំណា! ខ្ញុំចង់និយាយប្រាប់លោកពីទុក្ខវេទនារបស់ខ្ញុំមុនពេលបានមករៀបការជាមួយលោក ។ ខ្ញុំចូលចិត្តចង់ឲ្យប្រវត្តិដ៏ខ្លោចផ្សាររបស់ខ្ញុំ ស្ថិតនៅគង់វង្សជានិច្ចសម្រាប់ជាអនុស្សាវរីយ៍ចំពោះរូបលោក កាលណាខ្ញុំស្លាប់ទៅ...។

សាវ៉ាម៉ានី ឈប់ស្ងៀមមួយសន្ទុះ... សម្លេងតន្ត្រីសាត់មកតាមកម្លាំងជំនោររាត្រី បបោសអង្អែលសង្កាត់កំពង់ផែ ឲ្យស្រងេះស្រងោចលន្លង់លន្លោច ប្រៀបបានសម្លេងទិព្វ ហើយអតីតអ្នករបាំយើង យកចិត្តទុកដាក់ស្ដាប់បទភ្លេងសម្លេងស្រួយស្រិបនេះ ដែលពីដើមវាជាមេដែកអាចទាញកាយវិការនាង ឲ្យ



ពត់ពេនទន់ភ្លន់ ទៅតាមចង្វាក់ដំណើរទេពអប្សរ ដោយចិត្តរំជើបរំជួលស្ទើរតែទប់ខ្លួនពុំជាប់ ។

~ លោក! (សាវ៉ាម៉ានី ពោលបន្តទៅទៀត) ពេលនេះហាក់ដូចជាមានប្រផ្នូលអ្វីធ្វើឲ្យដឹងថា យើងនឹងព្រាត់គ្នានៅពេលឆាប់ៗខាងមុខនេះហើយ ទើបខ្ញុំចង់និយាយរឿងរ៉ាវទាំងអស់ប្រាប់លោក ដែលជាអ្នកគ្រប់គ្រងតែមួយគត់លើជីវិតខ្ញុំ ជាស្ត្រីកំព្រា ចង់មិនកកាយបង្ហាញលោកនូវកំណាប់អនុស្សាវរីយ៍ នៃ ជីវិតខ្ញុំដែលលោកពុំទាន់ដឹងនៅឡើយ...។

ពេលស្ដាប់ឮសំដីនេះ កម្លោះភ្ញាក់ព្រើត ហើយស្រមោល នៃ គំនិតរវើរវាយមិនល្អ ក៏ចាប់គ្របសង្កត់លើបេះដូងគេឲ្យតឹងស្ទើរប្រេះភ្លាមមួយរំពេច ។ ប៉ុន្តែ សម្លេងភ្លេងពិណពាទ្យលាន់ឡើងយ៉ាងច្បាស់ ក្នុងសភាពស្ងាត់ជ្រងំ នៃ រាត្រីកាល គឺជាសម្លេងទិព្វ អាចរម្ងាប់អស់នូវអារម្មណ៍តានតឹងគ្រប់បែបយ៉ាង ហើយកម្លោះ ប្រមូលបានសេចក្ដីក្លាហានបន្តិចឡើងវិញ ខំរក្សាសម្លេងឲ្យនឹងន និយាយតបទៅភរិយាវិញថា !:

~ អូន និយាយចុះ ខ្ញុំចាំស្ដាប់ហើយ!...

សាវ៉ាម៉ានី ផ្អែកខ្នងទៅនឹងជញ្ជាំង ហើយចាប់ផ្ដើមនិទានរឿងនាង ដូចតទៅនេះ ៖

នាដ្យការីឯក




Danseuse étoile

**កាល**នោះ ស្ដេចសុវណ្ណកោដ្ឋ[១] ឡើងសោយរាជ្យលើប្រទេសកម្ពុជា បានសែសិបប្លាយឆ្នាំហើយ។

មុនមកនៅភ្នំពេញ ខ្ញុំចាំថា ខ្ញុំធ្លាប់បានរស់នៅលើទូកអស់រយៈពេលដ៏យូរ។ ពុកម៉ែ ហើយនិង ខ្ញុំ យើងធ្វើដំណើរតាមផ្លូវទឹកពីតំបន់មួយទៅតំបន់មួយ គ្មានទីដៅជាក់លាក់ឡើយ។ ពូប៉ុល, ពូម៉ែន, ពូកៅ បងប្អូនជីដូនមួយខ្ញុំពីរនាក់ឈ្មោះ មីប៊ុន និង មីហ៊ុន និង ម្ដាយវាឈ្មោះ មីងអ៊ួច ឧស្សាហ៍រួមដំណើរជាមួយយើងណាស់ ជួនកាលជិះទូកតែមួយ ជាមួយគ្នាទាំងអស់ ជួនកាលគេជិះលើទូកមួយផ្សេងទៀត។

កាលនោះ ខ្ញុំនៅតូចពេក ពុំអាចចាំរឿងរ៉ាវសព្វគ្រប់ទាំងអស់ទេ... ខ្ញុំប្រហែលជាមានអាយុប្រាំពីរឆ្នាំ ដំណាលគ្នានឹងបងប្អូនជីដូនមួយខ្ញុំឈ្មោះ ប៊ុន នោះហើយមើលទៅ។ យើងទាំងពីរនាក់ អង្គុយលេងជាមួយគ្នាលើក្ដារកម្រាលទូក ហើយឲ្យតែកើតមានរឿងទាស់ចិត្តបន្តិច ខ្ញុំស្ទុះទៅក្រញៅវា ដាច់មុខ ដាច់មាត់ ភ្លាមមួយរំពេច ព្រោះខ្ញុំនេះឆ្នាស់រកលេខដាក់គ្មាន តាំងពីតូចមក។

ពុកចែវខាងមុខ ទុកឲ្យម៉ែ ចែវខាងក្រោយ យើងធ្វើដំណើរលក់ដូរ ផ្លែឈើស្រស់ និង ថ្នាំជក់ តាមបណ្ដោយមាត់ទន្លេ ហើយយើងទិញមកវិញនូវ អង្ករ និង ត្រីងៀត សម្រាប់ទុកជាស្បៀងបរិភោគ...។

ពីមួយឆ្នាំទៅមួយឆ្នាំ ដីច្រាំងភូមិព្រែកថ្មីរបស់យើង បាក់ធ្លាក់ចុះទៅបាតទន្លេទាំងផ្ទាំងៗ ដើមស្វាយដែលខ្ញុំបានដាំផ្ទាល់ដៃ និង ផ្ទះដែលខ្ញុំធ្លាប់រស់នៅជួបជុំគ្រួសារទាំងអស់គ្នា ក៏វិនាសសាបសូន្យអស់ទៅ សល់នៅតែអនុស្សាវរីយ៍ដ៏មានតម្លៃកាត់ថ្លៃមិនបាន ដែលស្ថិតជាប់ក្នុងអារម្មណ៍ខ្ញុំរហូតទល់ថ្ងៃស្លាប់។

លើផ្ទៃដីដែលជីតាខ្ញុំបោសជ្រះសំអាតរាល់ថ្ងៃ ខ្ញុំលួសមែកឈើតូចៗមកសង់ធ្វើរោងរបាំ សម្រាប់រាំលេងជាមួយពួកម៉ាក ពីព្រោះនេះជាល្បែងដែលខ្ញុំចូលចិត្តជាងគេ។ ក្មេងស្រីៗខ្លះទៀត ចូលចិត្តលេងធ្វើការប្ដី-ប្រពន្ធ, លេងបិទពួន ឬ កាត់ធាងចេកមកធ្វើជាសេះរត់បំផាយហុយដីទ្រលោម។ មានតែខ្ញុំម្នាក់ឯងគត់ ដែលស្រឡាញ់របាំ ចូលចិត្តឲ្យមីងខ្ញុំផាត់ម្សៅឲ្យ ហើយរាំឲ្យឪពុកម្ដាយខ្ញុំមើល។ ពុកញញឹមសម្លឹងមើលខ្ញុំ ហើយនិយាយថា:

~ ចាំពុកយកកូនឯងទៅឲ្យនៅហាត់រាំក្នុងវាំង ក្រែងលោបានធ្វើ លោកយុទ នឹងគេ។

ពួពុកនិយាយអញ្ចឹង ពូម៉ែន និយាយចំអកថា គាត់ទុកឲ្យកូនស្រីគាត់នៅធ្វើការផ្ទះ គ្រាន់នឹងបានបំរើទឹកក្ដៅ ទឹកត្រជាក់ នៅពេលគាត់ចាស់ជរា ប៉ុន្តែពុកបែរជាស្ដីឲ្យ ពូម៉ែន ថាជាមនុស្សអាត្មានិយម ហើយថែមទាំងទាយទុកថា ថ្ងៃណាមួយ កូនគាត់នឹងក្លាយមកជាអ្នកបំរើខ្ញុំមិនខាន។ តទៅថ្ងៃក្រោយ រឿងនេះ

---

[១] សុវណ្ណកោដ្ឋ ជាមរណនាម នៃ ព្រះបាទ នរោត្ដម។



មានដំណើរស៊ើងតែដូចពាក្យទំនាយពុកទាំងអស់។

ក្រោយបន្តិចមក យើងចាកចេញពីព្រែកថ្មី ដើម្បីចេញដើរលក់ដូរអីវ៉ាន់ជាថ្មីម្ដងទៀតនៅម្ដុំទន្លេសាប។ ទូកយើងមានដឹក ចេក និង ពោត ហើយដួលសណ្ដោងទៅនឹងកប៉ាល់ចិន ធ្វើដំណើរឆ្ពោះទៅខែត្រកំពង់ឆ្នាំង។ នៅនឹងផែកំពង់ឆ្នាំងនេះ យើងយក ចេក, ពោត, ដូរជាមួយឆ្នាំងដី ដែលពុកគិតថា នឹងយកមកលក់បន្តទៀតបានចំណេញច្រើនណាស់។

ពេលត្រឡប់មកវិញ ខ្យល់រហើយបក់បោកឥតឈប់ឈរ ហើយនៅកន្លែងខ្លះដែលផ្ទៃទន្លេរីកធំ ទូលាយដូចដៃសមុទ្រនោះ រលកធំៗចាប់ផ្ដើមបោក រុញច្រានទូកទាំងឡាយឲ្យរេចុះរេឡើង ប៉ះទង្គិចគ្នាពេញទន្លេ។ ទូកយើងក៏សោត់ចង់ទៅប៉ះនឹងទូកប៉ុកចាយដឹកទំនិញមួយដែរ ប៉ុន្តែសំណាងល្អបានម្ចាស់ ទូកធំនោះហៅយើងឲ្យឡើងជិះជាមួយគាត់ទម្រាំស្ងប់ខ្យល់។

ម្ចាស់ទូក ជាអ្នកជំនួញខ្មែរឈ្មោះ ដង្កៅរស់ រកស៊ីដួញឈើដឹកតាមក្បូន ពីស្រុកបរិបូណ៌ និង លង្វែក ទៅលក់ ប៉ុន្តែគាត់មានផ្ទះសម្បែងនៅគៀនស្វាយឯណោះទេ។ គាត់មានកូនប្រុសជំទង់មួយ ទើបនឹងបំបួសនេន ដើម្បីសងគុណឪពុកម្ដាយ។ ដង្កៅរស់ អួតសរសើរពីកូនប្រុសតែមួយរបស់គាត់ខ្លាំងណាស់ ហើយគាត់បានទាំងនិយាយស្ទើរលេងស្ទើរមែន ស្ទើចង់ធ្វើដន្លងជាមួយពុកទៀតផង។

មកដល់ភ្នំពេញ ទូកបែកខ្ញែកគ្នាអស់ យើងក៏លា ដង្កៅរស់ បត់ក្បាលទូកទៅឈប់ត្រង់កំពង់វត្តស្វាយពពែ ដើម្បីចូលលេងផ្ទះឪពុកធំខ្ញុំម្នាក់ឈ្មោះ អ៊ុម ដែលធ្វើជានាម៉ឺនធំក្នុងវាំង មានងារជាអគ្គមហាសេនា។ ពុកប្រាប់ឲ្យ ម៉ែ និង ខ្ញុំ នៅចាំក្នុងទូក គាត់ឡើងទៅតែម្នាក់ឯង មានយួរកន្ត្រកដាក់ផ្លែឈើពេញទៅជាមួយផង សម្រាប់ជាបញ្ញើ។ ប៉ុន្តែ ខ្ញុំមានគំនិតខូច លួចរត់តាមពីក្រោយគាត់ជាប់រហូត មិនឲ្យគាត់ដឹងខ្លួនឡើយ។

ផ្ទះលោកអគ្គមហាសេនា អ៊ុម ស្ថិតនៅមិនឆ្ងាយប៉ុន្មានពីមាត់ទន្លេ មានរបងថ្មព័ទ្ធជុំវិញ និង សួនច្បារពីមុខផង។ ផ្ទះនោះធ្វើពីឈើ មានរានហាល មានតសំយាកចេញជារោងតូចៗច្រើនទៀត និង រោងធំមួយជាបន្ទប់ពិសេសសម្រាប់ក្រុមល្ខោនរបស់គាត់រាំ។ បន្ទាប់ពីក្រុមល្ខោនហ្លួង មានតែក្រុមល្ខោនលោកអគ្គមហាសេនាអ៊ុម នេះហើយ ដែលល្បីល្បាញជាងគេក្នុងស្រុកខ្មែរ។

ពុកដើរឡើងជណ្ដើរ ឆ្លងកាត់រានហាលទៅអង្គុយចាំត្រង់មាត់ទ្វារបន្ទប់ទទួលភ្ញៀវ។ ខ្ញុំអង្គុយចុះពីក្រោយខ្នងគាត់ ប៉ុន្តែពុកនៅតែមិនដឹងថា ខ្ញុំមកតាមគាត់ដដែល។ លោកអគ្គមហាសេនា អង្គុយលើកៅអីលាបពណ៌មាស មានសាច់ញាតិអ្នកមកពឹងបុណ្យមួយហ្វូងធំ អង្គុយបត់ជើងលើកន្ទេលត្រៀបត្រាពីក្រោយខ្នង។ គ្រាន់តែឃើញផ្ទះធំទូលាយ របៀបរៀបរយ សួនច្បារអីប៉ុណ្ណឹង ខ្ញុំសប្បាយចិត្តចង់រស់នៅក្នុងទីនេះស្រេចទៅហើយ។ ខ្ញុំអង្គុយបត់ជើងពួនក្រវៀនក្រោយខ្នងពុក លួចសម្លឹងមើលមុខលោកអគ្គមហាសេនាភ្លៀកៗ... គាត់ចាស់កោងខ្នង សក់ស្កូវសក្បុសកាត់ជ្រងខ្លី ស្បែកមុខជ្រីវជ្រួញ ពាក់អាវបំពង់សដៃខ្លី ស្លៀកសារុងសូត្រ។ គាត់និយាយរាក់ទាក់មកកាន់ពុកថា:

~ យិនឯង យកផ្លែឈើអស់ហ្នឹងមកផ្ញើអញហ្អែ? ប្រពន្ធ-កូនឯង សុខសប្បាយជាទេ?... អឺ, ហ្នឹងឯងយកកូនមកឲ្យនៅហាត់រាំជាមួយអញឬអី?

- ប្របាទម្ចាស់, (ពុកឆ្លើយ) កូនខ្ញុំនៅចាំក្នុងទូកឯណោះ... ខ្ញុំមកពីលក់អីវ៉ាន់ ត្រឡប់ទៅព្រែកថ្មីវិញ គ្រាន់តែផៀងចូលមកលេងនឹងព្រះគុណម្ចាស់មួយភ្លែតប៉ុណ្ណឹងទេ។

- ម៉េចអញ្ចឹង? កូនឯងវានៅក្រោយខ្នងនេះនែ៎, ឯងមើលទៅមើល៍! (លោកអគ្គមហាសេនា

និយាយខ្លាំងៗ ព្រមទាំងផ្ទុះសំណើចកាច់កកាច់សុរង)។

ពុកបែរមកក្រោយឃើញខ្ញុំអង្គុយច្រងុក ស្រាប់តែបើកភ្នែកធំៗសម្លក់ម្ទែរ ឥតចេញស្តីថាម៉េចទាំងអស់។ សើចអស់ចិត្ត ទើបលោកអគ្គមហាសេនា សួរខ្ញុំ:

~ អើនែ, មេនាងឯងចង់ត្រឡប់ទៅព្រែកថ្មីវិញ ឬក៏ ចង់នៅជាមួយអ៊ុំ, ហ្អាមេនាង ?

~ ខ្ញុំចង់... នៅ... (ខ្ញុំឆ្លើយទាំងអឹមអៀម)

ដើម្បីកុំឲ្យបែក ឪពុក-ម្តាយ លោកអ៊ុំបានឲ្យពុកសង់ផ្ទះតូចមួយនៅបណ្តោះអាសន្ន ក្បែរសួនច្បារគាត់។

លោកអគ្គមហាសេនា គាប់ចិត្តនឹងខ្ញុំជាងគេ គាត់ស្រឡាញ់ខ្ញុំដូចកូនបង្កើតអញ្ចឹង។ គាត់ទិញសំពត់ខៀវ កាត់អាវជៀលភ្លៀកកំណាត់សូត្រ សម្រាប់ឲ្យខ្ញុំស្លៀកពាក់ហាត់រាំរាល់ថ្ងៃ មួយគំនរធំ។ លោកអ៊ុំរកឈ្មោះដាក់ឲ្យខ្ញុំ នេះមិនពិរោះ នោះមិនពិរោះ ទីបំផុតក៏ហៅខ្ញុំថា យ៉ៃមៗ ជាប់រហូតមក។ ប៉ុន្តែខ្ញុំមិនរវល់នឹងរឿងរ៉ាវកំប៉ិកកំប៉ុកអស់នេះទេ មួយថ្ងៃៗខ្ញុំគិតតែដើរបេះបោចដំណាំក្នុងសួនច្បារ ឬ សម្ងំពួននៅក្រោមផ្ទះ ទុកឲ្យគេដើររកវឹកវរ។ ម្តងនោះ ខ្ញុំធ្វើឲ្យជ្រុះបែកកញ្ចក់ដែលគេតាំងលំអនៅក្នុង បន្ទប់ទទួលភ្ញៀវ ប៉ុន្តែលោកអ៊ុំឥតមានស្តីបន្ទោស ឬ វាយខ្ញុំទេ។ ខ្ញុំឥតខ្លាចលោកអ៊ុំទាល់តែសោះ គឺខ្ញុំស្រឡាញ់គាត់ទុកស្មើឪពុក។ ខ្ញុំសប្បាយចិត្តណាស់ ដែលបានធ្វើជាកូនអ្នកធំ បានស្គាល់ភាពថ្លៃថ្នូរ នៃ ការរស់នៅក្នុងទីក្រុង បានស្លៀកពាក់ សំពត់-អាវ ល្អៗ បានពាក់មាសពេជ្រស្រោចខ្លួន និង ជាពិសេស បានហាត់រាំយ៉ាងនេះ។ ខ្ញុំចង់ក្លាយទៅជា លោកយុទ មានរូបសម្បត្តិស្អាតដូចទេពកញ្ញា ធ្វើឲ្យប្រុសៗមើលឃើញតែពីចម្ងាយ ហើយចាប់ចិត្តលួចស្រឡាញ់វង្វេងភ្លេចស្មារតីគ្រប់គ្នា ។ គំនិតរវើរវាយបែបនេះ ធ្វើឲ្យខ្ញុំញញឹមនឹកឃើញសប្បាយតែម្នាក់ឯងដូចមនុស្សឆ្កួត។

ក្រុមល្ខោនលោកអគ្គមហាសេនា មានគ្រូសៀមបីនាក់ ជាអ្នកបង្ហាត់ និង ជាប្រពន្ធគាត់ទាំងបីនាក់តែម្តង គឺ អ្នកគ្រូជាម, អ្នកគ្រូម៉ាឡៃ និង អ្នកគ្រូយឹម។ បន្ទាប់មកមាន អ្នកភ្លេង, អ្នកចម្រៀង និង កូនល្ខោន ទាំងក្មេង ទាំងចាស់ សុទ្ធតែស្ទាត់ជំនាញដូចៗគ្នាទាំងអស់។ បូករួមទាំងអស់ ក្រុមនេះមានគ្នាដល់ទៅជាងមួយរយនាក់។

អ្នកគ្រូយឹម ជាអ្នកទទួលភារៈបង្ហាត់ខ្ញុំ។ រាល់ព្រឹក ខ្ញុំស្លៀកសំពត់ចងក្បិន ពាក់អាវជៀលភ្លៀក មានសៀតផ្កាកុលាបមួយទងនៅនឹងត្រចៀក ពាក់កងជើងមាសធំៗ ដើម្បីហាត់រាំតាមបញ្ជាអ្នកគ្រូ។ អ្នកគ្រូពេញចិត្តនឹងខ្ញុំជាកូនសិស្សពេកណាស់ សមបានដឹងថា លោកអ៊ុំស្រឡាញ់ខ្ញុំដូចកូនបង្កើតផង គាត់រឹតតែយកចិត្តទុកដាក់បង្ហាត់ខ្ញុំជាងនរណាទាំងអស់។ ប៉ុន្តែ កាលណាខ្ញុំមិនសូវប្រឹងប្រយ័ត្នធ្វើតាមគាត់ ឬ ពត់ដៃជើងមិនបានទន់ភ្លន់ដូចគាត់ គាត់យកក្រចកចុច ឬ ក្តិចទាល់តែខ្ញុំស្រក់ទឹកភ្នែក យំអណ្តឹតអណ្តក់ភ្លាមមួយរំពេច។ ជាដំបូង ខ្ញុំត្រូវហាត់ធ្វើឲ្យទន់ ក, ស្មា, សន្លាក់ដៃ, ចង្កេះ, ជង្គង់ និង កជើង។ ជងខ្លួនត្រូវ ពត់អែនចុះ អែនឡើង ទាល់តែទន់ដូចវល្លិ៍ បណ្តាលឲ្យខ្ញុំអស់កម្លាំងស្ទើរទប់ខ្លួនឈរមិននឹង។ជួនកាលខ្ញុំត្រូវឈរជើងមួយបន្ទន់ជង្គង់ទៅមុខបន្តិច ជើងមួយទៀតបត់ទៅក្រោយលើកខ្ពស់ ដៃលើកខ្ពស់ហួសជងខ្លួន ថែមទាំងមាន កាន់ដាវ ឬ ផ្កា ដោយពត់កដៃមកក្រោយទាល់តែចុងក្រចកប៉ះនឹងសាច់កំភួនដៃទៀតផង។ ខ្ញុំសំគាល់ឃើញថា ពីគ្រូមួយ ទៅគ្រូមួយ ក្បាច់របាំតែងមានការខុសគ្នាបន្តិចៗជានិច្ច គឺម្នាក់ៗចេះតែឆ្នៃបន្ថែមបន្ថយទៅតាមការនឹកឃើញរបស់ខ្លួន។ ខ្ញុំបណ្តោយឲ្យអ្នកគ្រូយឹម កាច់, ពត់ ដៃជើងតាមចិត្ត ប៉ុន្តែកាលណាគាត់កាច់ឈឺខ្លាំងពេកទ្រាំមិនបាន ខ្ញុំក៏ទ្រហោយំរងោងឡើង។ កាលណាហាត់ចប់ម្តងៗ អ្នកគ្រូ ឬ ម៉ែ គក់ច្របាច់រឹតស្បែតឲ្យខ្ញុំសព្វដៃជើងខ្លួនប្រាណ ដើម្បីស្រួលសាច់ដុំ។

ពួកយើងជាអស់លោកយុទ ដែលបានហាត់រាំតាំងពីក្មេងអញ្ចឹង យើងពុំបានទុកដាក់ខ្លួនដូចជាស្ត្រីសាមញ្ញធម្មតាទេ។ ការរស់នៅក្នុងវាំង ឃ្លាតដាច់ស្រឡះពីភពខាងក្រៅ បានធ្វើឲ្យយើងផ្លាស់ប្តូរ ចិត្តគំនិតតាំងខ្លួនជាវត្ថុមានតម្លៃ ទម្រន់ខ្ជិលធ្វើការ សូម្បីឃ្លុកខ្ទ្រកទៅផ្សារក៏មិនសូវចេះផង មួយថ្ងៃៗគិតតែសប្បាយរាំច្រៀង និង សំអិតសំអាងតែងខ្លួនតែប៉ុណ្ណោះ។

ប៉ុន្មានអាទិត្យសោះ ខ្ញុំអាចរៀនចប់ក្បាច់ឆាបបញ្ចុះ និង អាចរាំចូលជាមួយភ្លេងត្រូវឥតខ្ចោះ។ អ្នកគ្រូសៀម ញញឹមបិទមាត់មិនជិត ដើរអួតសរសើរពីខ្ញុំប្រាប់គេប្រាប់ឯងគ្រប់គ្នា។ មកដល់អាយុប្រាំបីឆ្នាំ ខ្ញុំហាត់ដើរតួបានពីរ គឺមួយជាតួឆ្មា និង មួយទៀតធ្វើជាស្តេចដោះពាក់មុខអាក្រក់អាក្រីឫខ្លាច។ ខ្ញុំអាចគ្រវីដំបងវិលខ្ទាល់ដូចកង្ហារយ៉ាងស្ទាត់ជំនាញ ពុំដែលរបូតចេញពីដៃដល់ម្តងណាឡើយ។

ល្ងាចមួយនោះ លោកអគ្គមហាសេនា អនុញ្ញាតឲ្យអ្នកភូមិចូលមើលរបាំដល់ក្នុងបរិវេណផ្ទះគាត់ជាសាធារណៈ។ មនុស្សច្រើនកុះករប្រជ្រៀតគ្នាពេញសួនច្បារ ហៀរទៅដល់ក្រៅរបង, ពុក និង ម៉ែ ក៏បាននាំ យាយកែម ពីព្រែកថ្មី ឲ្យមកមើលខ្ញុំរាំនឹងគេដែរ។ លើសពីនេះទៅទៀត លោកអ៊ុំបានអញ្ជើញអ្នករបាំក្នុងវាំង ឲ្យមកមើលក្រុមល្ខោនគាត់រាំទៀតផង។ គេទាំងអស់គ្នាបេក្រសែភ្នែកតាមសម្លឹងមើលខ្ញុំគ្រប់កាយវិការ ព្រមទាំងជញ្ជក់មាត់សរសើរគ្រប់គ្នា។ នេះជាជោគជ័យលើកទីមួយរបស់ខ្ញុំ!... ចាប់តាំងពីពេលនោះមក លោកអ៊ុំរឹតតែស្រឡាញ់ខ្ញុំលើសដើម ទៅណាមួយជំហាន ក៏យកខ្ញុំទៅតាមជាប់ជានិច្ច ហើយគាត់ហាមថា តទៅថ្ងៃក្រោយមិនឲ្យខ្ញុំទៅណាចោលគាត់ជាដាច់ខាត។ គាត់ឧស្សាហ៍នាំខ្ញុំទៅលេងនឹងសម្តេចឧបរាជ[២] ដែលគង់នៅឯវាំងខាងជើងជារឿយៗ ។ ហើយគាត់និយាយប្រាប់ខ្ញុំថា សព្វថ្ងៃសម្តេចឧបរាជ ចង់សោយរាជ្យខ្លាំងណាស់។

ថ្ងៃមួយ ពុកម៉ែ និង ខ្ញុំ នាំគ្នាមកសំណាក់លេងនៅព្រែកថ្មីបាន ពីរ-បីថ្ងៃ ទើបនាំគ្នាត្រឡប់មកវិញដោយមានបេះផ្លែស្វាយល្អៗដាក់កន្ទះទូក ទុកសម្រាប់យកមកផ្ញើលោកអ៊ុំ។ ប៉ុន្តែមកដល់ត្រឹមភ្នំពេញ មាននរណាម្នាក់ស្រែកហៅពុកឲ្យឈប់ ហើយប្រាប់ថា លោកអគ្គមហាសេនា ស្លាប់ទៅហើយ!... មរណភាព នៃលោកអគ្គមហាសេនា ប្រៀបបានទៅនឹងការរលំរលាយ នៃ បង្គោលដែលជាទីពឹងពាក់អាស្រ័យដ៏កក់ក្តៅសម្រាប់គ្រួសារខ្ញុំយ៉ាងនោះដែរ...។

[២] សម្តេចឧបរាជ គឺជាងារ ស្តេចស៊ីសុវត្ថិ មុនពេលបានឡើងសោយរាជ្យ ។

ច្រើនខែកន្លងទៅ... យើងចាកចេញពីផ្ទះនៅក្បែរវត្តស្វាយពពែ មកទិញផ្ទះស្លឹកតូចមួយនៅម្តុំកំពង់ផែវិញ។ រាល់ថ្ងៃ ពុកបោសសំអាតតុបតែងផ្ទះ និង ដីភូមិ មិនឲ្យខ្ញុំខ្មាសកូនអ្នកជិតខាង ដែលគេមានសុទ្ធតែផ្ទះក្បឿងសសរថ្មើកនោះទេ។

ដោយសារខ្មោចលោកអ៊ុំមានផ្តាំផ្ញើទុកនឹងគេ ពុកក៏បានចូលធ្វើការនៅក្នុងវាំង ហើយឆ្លៀតពេលទំនេរគាត់តែងជួយធ្វើការជូនអស់លោកនាម៉ឺនក្នុងវាំង ដែលជាហេតុអាចឲ្យគាត់រកប្រាក់បានច្រើនគួរសម បន្ថែមលើប្រាក់ខែបន្តិចបន្តួចនោះ សម្រាប់យកមកផ្គត់ផ្គង់គ្រួសារ។

ខ្ញុំមានអាយុមិនទាន់ទាំងគ្រប់ដប់ឆ្នាំស្រួលបួលផង។ ខ្ញុំមិនដឹងថា ជីវភាពនៅក្នុងវាំង សប្បាយ ឬ លំបាកវេទនាយ៉ាងណាទេ ប៉ុន្តែខ្ញុំចេះតែចង់ទៅនៅក្នុងវាំង ព្រោះខ្ញុំចង់ហ៊ឺហាស្លៀកសំពត់អាវរបាំតែប៉ុណ្ណោះ។ ខ្ញុំទៅជាធុញទ្រាន់ លែងចង់រស់នៅក្នុងខ្ទមស្លឹក លែងចង់រស់នៅជាមួយ ឪពុក-ម្តាយ ទោះបីពុកផ្គត់ផ្គង់ខ្ញុំគ្រប់សព្វ មិនដែលឲ្យខ្វះខាតយ៉ាងណាក៏ដោយ។

ប៊ុន និង ហ៊ុន ឧស្សាហ៍មកពីព្រែកថ្មី មកលេងនឹងយើងខ្ញុំណាស់ ជួនកាលមកនៅ ពីរ-បីអាទិត្យ ទើបត្រឡប់ទៅវិញក៏មាន។ ពូប៉ុល និង ពូម៉ែន ជាអ្នកបញ្ជិះទូកនាំវាមក ព្រមទាំងនាំយកដំណឹងផ្សេងៗពីស្រុកមកប្រាប់ ពុក-ម៉ែ ផង។ ប៉ុន្តែ ពុកមិនចូលចិត្តឲ្យ ពូប៉ុល និង ពូម៉ែន នៅយូរទេ ពីព្រោះណាមួយផ្ទះក៏ចង្អៀត ណាមួយពុកស្អប់ត្រង់គាត់ចូលចិត្តស្លៀកពាក់ខោអាវច្រឡូកច្រឡំ ឲ្យតែពុកមិននៅ គាត់យកអាវពុកព្យួរនៅនឹងស្នែងក្តាន់ពាក់ដើរលេងផ្សារមួយរំពេច។ ចំណែកម៉ែវិញ គាត់ស្រឡាញ់ បង-ប្អូន ជាងប្តីទៅទៀត សុខចិត្តលក់បញ្ចាំរបស់ទ្រព្យឯងយកលុយឲ្យគេខ្ចី ហើយអ្នកខ្ចីនោះ គឺខ្ចីរហូត មិនដែលឃើញសងវិញឡើយ។

ពេលថ្ងៃទំនេរ មិនដឹងធ្វើអី ខ្ញុំជួយដាំបាយម៉ែ ខ្ញុំងូតទឹកដុះសាប៊ូលាបម្សៅតមួយថ្ងៃ ដប់-ម្ភៃដង ទាល់តែពុករកលុយទិញសាប៊ូឲ្យសឹងតែមិនទាន់។ មនុស្សដើរទៅមកតាមផ្លូវកំពង់ផែ តែងត្រូវខ្ញុំចំអកឡកឡឺយឲ្យ ឬ ជួនកាលខ្ញុំហ៊ានដល់ទៅជេរប្រាស់ឆ្លេះឲ្យគេទៀតផង។ ម្ល៉ោះហើយ នរណា ក៏ខ្លាចរអា ក៏ស្អប់ខ្ញុំដែរ គេចាត់ទុកខ្ញុំដូចជាខ្មោចបិសាចនៅក្នុងភូមិអញ្ចឹង។

មានរឿងរ៉ាវខ្លះក្នុងជីវិតដែលគេពុំអាចបំភ្លេចបានឡើយ... ថ្ងៃដែលខ្ញុំចាកចេញពីគ្រួសារ ចាកចេញពីខ្ទមកំសត់ដែលខ្ញុំធ្លាប់រស់នៅបានទទួលក្តីស្នេហាពី ឪពុក-ម្តាយ បានទទួលក្តីសប្បាយរីករាយ នៃ ភាពកុមារ ថ្ងៃនោះផ្តិតជាប់ច្បាស់ក្រឡែតក្នុងអារម្មណ៍ខ្ញុំ ហាក់ដូចជានៅថ្មីៗនៅឡើយ។

ម៉ែបានទៅពឹង នាងរឿក ជាអ្នករបាំនៅក្នុងវាំង អាយុបងខ្ញុំដប់ឆ្នាំ ឲ្យមកជួយចាត់ចែងនាំខ្ញុំទៅគាល់



ហ្លួង។ នាងរឿកនាំយកមកនូវ សំពត់ម៉ុដ្ឋពណ៌ស្វាយ អាវរៀលក ដៃខ្លីពណ៌ខ្មៅ ប៉ាក់ជរផង ជាសម្លៀកបំពាក់សម្រាប់ហាត់រាំ ផាហ៊ុំពណ៌លឿង ពានាព័ទ្ធឡៀង ទម្លាក់ជាយម្ខាងមកត្រឹមចង្កេះ រយ៉ាមួយគូ ចិញ្ចៀនពើន និង កងជើងមាសធ្ងន់ដូចគេដាក់ខ្នោះជើង។

ស្លៀកពាក់អញ្ចឹងទៅ ខ្ញុំដូចជាហ៊ឺហាក្នុងចិត្ត ចុះជណ្តើរយឺតៗយ៉ាងប្រយ័ត្នប្រយែង ខំធ្វើឫកឲ្យដូចជាអស់អ្នកក្នុងវាំងមែនទែន។ ខ្ញុំដើរចន្លោះកណ្តាល ម៉ែ និង បងរឿក បំពង់កស្ងួតចែសរកទឹកមាត់លេបគ្មានដោយក្តីរំជួលចិត្ត, អារម្មណ៍អណ្តែតត្រសែតចេញពីរាងកាយទៅកាន់ពិភព នៃ ក្តីស្រមៃមើលឃើញតែភាពរុងរឿងថ្លៃថ្នូរ។ បន្តិចទៀតខ្ញុំនឹងក្លាយខ្លួនជាអ្នករបាំរបស់ហ្លួង រាស្ត្រសាមញ្ញលែងហ៊ានហៅខ្ញុំ "មី" គេនឹងហៅខ្ញុំថា អ្នក ឬ នាង មិនខាន។ ខ្ញុំនឹងមាន មាសពេជ្រ, សំពត់អាវសម្បូណ៌ហូរហៀរ មានខ្ញុំបំរើសម្រាប់យួរកន្ត្រកដើរតាមក្រោយ, មានរទេះ, មានដំរី, មានទូកបិទដំបូលសម្រាប់ជិះដើរលេងកំសាន្ត, មានអ្វីៗទាំងអស់ សម្រាប់បំពេញសេចក្តីត្រូវការ។

នាឡិកាប៉ោលធំៗនៅក្នុងទីនាំងស្តេច បន្លឺស្នូរប្រាំមួយអន្ទងយ៉ាងយឺតៗរបៀបខ្សិលច្រអូស ហាក់ធុញទ្រាន់នឹងបំពេញមុខការដដែលៗនេះតាំងពីច្រើនឆ្នាំមកហើយ។ មកដល់ត្រង់ក្លោងទ្វារ ងងឹតព្រាលៗ នរណាម្នាក់លាន់មាត់និយាយមកកាន់យើង :

- យើ! កូនអ្នកណាហ្នឹង ស្អាតមើលតែទេវតាវ៉ី?
- កូនខ្ញុំណាំ! (ម៉ែប្រញាប់ឆ្លើយទៅវិញយ៉ាងពេញចិត្ត) ខ្ញុំនាំវាទៅថ្វាយហ្លួង។

ខ្ញុំមិនដឹងថា ពាក្យទាំងនេះមានន័យសរសើរមែនទែន ឬ ជាពាក្យចំអកទេ ប៉ុន្តែគ្រាន់តែឮគេនិយាយអ៊ីចឹង ខ្ញុំទៅជាចេញទឹកមាត់។

ខ្ញុំខំលេបវាទៅវិញកុំឲ្យហៀរមកប៉ះម្សៅលាបមុខ ហើយធ្វើមិនឮដើរតាមចន្លោះទេវាវិនិច្ឆ័យ ដែលជាកន្លែងដំកល់បល្ល័ង្កស្តេច និង រោងរបាំ ឆ្ពោះទៅកាន់កន្លែងយាម ត្រង់មាត់ទ្វារព្រលប់។

ពីដើម, កាលនៅក្នុងរាជ្យស្តេច សុវណ្ណកោដ្ឋ តែពេលព្រលប់ភ្លាម គេលែងឲ្យចេញចូលតាមទ្វារនេះហើយ។ ប៉ុន្តែសព្វថ្ងៃនេះ ទាល់តែបាញ់កាំភ្លើងម៉ោងប្រាំបីយប់[៣] ទើបគេលែងឲ្យ ចេញ-ចូល ហើយគេក៏មិនសូវតឹងតែងប្រយ័ត្នណាស់ណាដែរ។

ក្រុមវាំងចាស់ៗដែលនៅយាមទ្វារ នាំគ្នាស្ទុះងើបឡើង នៅពេលឃើញយើងទៅដល់ ហើយបន្ទន់ខ្លួនក្រួនៗគោរពម៉ែ ដោយឃើញគាត់ដើរជាមួយ បងរឿក ដែលជាកូនស្មោនយុទព្រះញាតិ។ គេប្រញាប់បើកទ្វារឲ្យយើងចូល ដោយឥតហ៊ានសួរនាំអ្វីឡើយ។

ខ្ញុំចុះជណ្តើរថ្ម ពីរ-បីកាំ ហើយឈប់មឹងមាំង ភ្នែកសម្លឹងមើលផ្លូវដីស្ងាត់ជ្រងំក្រាលថ្មយ៉ាងស្អាត អមសង្ខាងទៅដោយរបងដែក សួនច្បារ អាងទឹក និង ដើមឈើល្អត្រកាល ប្លែកភ្នែកគួរឲ្យចង់គយគន់។ ស្ត្រីចាស់កោងខ្នងម្នាក់ បោះជំហានយឺតៗតម្រង់ទៅរកទ្វារចេញ មានអ្នកបំរើមួយហ្វូងធំកាន់ថាសដាក់ចង្ហាន់យកទៅប្រគេនព្រះសង្ឃវត្តព្រះកែវ ដើរតាមហូរហែពីក្រោយ។ បងរឿក កេះម៉ែខ្សិបប្រាប់ថា ស្ត្រីចាស់ដើរមុខគេនេះជាស្តេច ហើយម៉ែក៏លើកដៃសំពះយ៉ាងគួរសមក្រៃលែង។ ឆ្ងាយពីនេះទៅទៀត នៅខាងមុខផ្លូវ ដើមគគីរធំខ្ពស់ដុះតម្រៀបគ្នាជាជួរ មើលពីក្រោមកឃើញតែស្លឹកស៊ុបទ្រុបគ្របលើវាំងទាំងមូល។

អស់អ្នក អស់នាង ឬ អ្នករបាំ ឥតពាក់អាវទេ មានតែស្បៃស្តើងដណ្តប់ខ្លួន ដើរលេងប្រសេចប្រសាចពេញសួនច្បារ។ ខ្លះទៀតប្រជុំគ្នាជាក្រុមៗ ជក់បារីជជែកគ្នាអែប្រម៉ែ និង ខ្លះទៀតដើរទៅដើរមក ញាប់ជើង

---

(៣) កាំភ្លើងបាញ់ម៉ោងប្រាំបីយប់នេះ ជាសញ្ញាប្រាប់ម៉ោងពេល ដូចជាស៊ីរ៉ែនម៉ោង ១២ ថ្ងៃត្រង់។

ទំនងជាមានការអីសំខាន់ហើយមើលទៅ។

ដំណាក់ឈើមួយសង់ទាបនឹងដី ប្រកបដោយរានហាលព័ទ្ធជុំវិញ ក៏ស្ថិតនៅជិតដំណាក់ហ្លួង ដូចមហាមន្ទីរដែរ គឺស្ថិតនៅត្រង់កែងផ្លូវធំ និង ផ្លូវក្រាលថ្មមួយទៀត។ កន្លែងនេះ ពិតជាកន្លែងសំខាន់ជាងគេនៅក្នុងវាំង ព្រោះមនុស្សមានមកប្រជុំគ្នាអូអរ សោតឯដំណាក់នានាជាច្រើនទៀត ក៏សុទ្ធតែសង់នៅក្បែរនេះដែរ។

ក្រុមវាំងដើរក្រឡឹងជុំវិញដំណាក់ហ្លួង ដៃកាន់ឈើច្រត់ប្រាក់ ជូនកាលរត់ឆ្លងឆ្លាទៅនេះបន្តិច ទៅនោះបន្តិច ដើម្បីបញ្ជូនបន្តទៅកន្លែងផ្សេងៗ នូវពាក្យបញ្ជាដែលស្ត្រីក្មេងៗអង្គុយផ្ទុករណែលនៅត្រង់មាត់ទ្វារបន្ទប់ហ្លួងនោះ នាំយកមកប្រាប់។ នៅកន្លែងនេះ គេនិយាយគ្នាតិចៗ បញ្ចេញឬកថ្លៃថ្នូរបែបចម្លែក គួរឲ្យខ្ញុំនឹកខ្មាសខ្លួនឯងណាស់ ដែលមានឫកពារជាអ្នកស្រែសុទ្ធសាធ។ មិនអីទេ! ខ្ញុំនឹងខំរៀនឲ្យទាល់តែចេះរបៀបថ្លៃថ្នូរដូចគេមិនខាន។

ឆ្ងាយបន្តិចទៅទៀត នៅពីក្រោយប្រាសាទបាញ់យ៉ុង ខ្ញុំឃើញផ្ទះឈើធំៗសង់យ៉ាងខ្ជីខ្ជាបំផុត ទុកសម្រាប់ឲ្យពួកកូនល្ខោនរបស់យុទព្រះញាតិ សំណាក់នៅ។ គ្រាន់តែឃើញនៅជិតនោះ មានដើម ស្វាយ, ដើមល្មុត ខ្ញុំលួចញញឹមក្នុងពោះ ក្រឡួចមាត់ទុកមុខឡូចស្រេចទៅហើយ។ ក្រឡេកទៅខាងណាក៏ឃើញតែបុប្ផារីកស្គុសស្គាយ ឃើញតែម្លប់ត្រជាក់ នៃ ដើមរុក្ខជាតិធំៗ ឃើញតែក្បាលម៉ាស៊ីនទឹក ដែលបញ្ចេញមកនូវទឹកថ្លាឆ្វង់ដូចកញ្ចក់ ឃើញតែផ្លូវថ្លាស្អាតរលីងធេងគ្មានសំរាមមួយទង ផ្ទុយស្រឡះពីវាលចំការដែលខ្ញុំធ្លាប់រត់លេងរាល់ថ្ងៃ។

គេនាំយើងចូលដល់ក្នុងដំណាក់ យុទព្រះញាតិ ដែលមានឋានៈជាចាងហ្វាងទីពីរ នៃ ក្រុមល្ខោនហ្លួង។ ដំណាក់របស់យុទធ្វើអំពីឈើប្រក់ក្បឿង ហើយទូលាយណាស់។ យុទចាស់ជ្រួលបន្តិចទៅហើយ បើសន្និដ្ឋានទៅតាមការដែលអ្នកផងនុនលំទោនគោរពគាត់គ្រប់គ្នានេះ ឃើញថា យុទព្រះញាតិ ជាមនុស្សមានមុខមានមាត់សម្បើមណាស់។ យើងសំពះសួរយុទ រួចថយដើរនុនទៅអង្គុយលើកន្ទេល ឆ្ងាយពីកន្លែងយុទ អ្នកបំរើយក កន្តោរស្ពោះទឹកមាត់ និង ហិបស្លាដ៏មានតម្លៃ មកដាក់ជូនចៅហ្វាយ ហើយថយទៅវិញសុទ្ធតែប្រើអាកប្បកិរិយាត្រូនៗបែបនេះដូចគ្នាទាំងអស់។ ខ្ញុំរវល់តែជក់ភ្នែកគយគន់មើលរបៀបរៀបចំក្នុងផ្ទះ ពុំបានស្តាប់ម៉ែនិយាយថាអ្វីខ្លះជាមួយយុទទេ...។

គេយកជើងពានមាសដាក់ បាច់ផ្កា និង កម្រងផ្កា មកឲ្យខ្ញុំ ហើយទាញដៃខ្ញុំចេញទៅក្រៅ និយាយពន្យល់ថា កាលណាគេកេះឲ្យសញ្ញា ខ្ញុំត្រូវយកជង្វាយនេះទៅដាក់ក្បែរព្រះបាទហ្លួង ដោយលត់ជង្គង់ចុះទៅលើកន្ទេល។ ម៉ែ និង បងរឿក ខ្សឹបប្រាប់ខ្ញុំថា កាលណាហ្លួងសួរខ្ញុំជាភាសាសៀម ខ្ញុំត្រូវឆ្លើយថា៖ "ព្រះពរម្ចាស់ ខ្ញុំចេះនិយាយតែខ្មែរទេ" ហើយគាត់ឲ្យខ្ញុំអង្គុយលើកាំជណ្តើរទីនាំងមេខលា ចាំទម្រាំហ្លួងចេញពីសោយអាហៀក្នុងបន្ទប់នេះមកវិញ។ ខ្ញុំអង្គុយលុតជង្គង់ ងាកមើលទៅក្រោយឥតឃើញម៉ែ ដូចជាភ័យស្រាលខ្លួន ទំនងអស់សង្ឃឹមបន្តិចផង។ បងរឿកក្តិចភ្លៅខ្ញុំ ហើយខ្សឹបថា:

~ ងើបឡើងមេនាង! ទៅថ្វាយបង្គំហ្លួងភ្លាមទៅ!

សភាពអ៊ូអរសិបសៀវក៏កើតមានឡើងក្នុងចំណោម នាម៉ឺន និង ស្រីៗ ដែលប្រមូលផ្តុំគ្នាត្រៀបត្រានៅមុខទីនាំងមេខលា អង្គុយបត់ជើង កាច់ចង្កេះរៀចក្រវេងវមកម្ខាង ដៃលើកសំពះ។ អ្នកដែលអង្គុយលើកាំជណ្តើរ និង នៅក្នុងបន្ទប់នោះ ក៏ធ្វើកាយវិការដូចគ្នានេះដែរ។

ហ្លួងសុវណ្ណកោដ្ឋ យាងមកដល់មាត់ទ្វារបន្ទប់ដែលមានពន្លឺព្រិលៗ ហើយក្រសែភ្នែកមើលហ្លួង



"កូនចៅ" មួយគ្រួស។ ហ្លួងចាស់ចំណាស់ទៅហើយ រាងស្គមកំព្រឹង ខ្នងកោងបន្តិច ទ្រោបខ្លួនទៅលើឈើច្រត់ស្រោបមាស ខ្លួនទទេមានពានាផាហ៊ុំព័ទ្ធធៀងពីស្មាឆ្វេង ទម្លាក់ជាយមកចង្កេះខាងស្តាំ ចង្កេះរៀវស្ងួច ស្លៀកសំពត់សូត្រសម្បុរស្រអាប់ សក់កាត់ជ្រុងខ្លី។

ខ្ញុំខាំមាត់ប្រមូលសេចក្តីក្លាហានងើបឈរឡើង ហើយដើរនុនៗទៅលុតជង្គង់ដាក់ជើងពានផ្កាក្បែរជើងព្រះអង្គ... ខ្ញុំហាក់ដូចជាដឹងថា ហ្លួងនុនមុខឈ្ងោកសម្លឹងខ្ញុំ។ នៅពេលដែលព្រះអង្គនិយាយពាក្យអ្វីញ៉ែវៗពីរ-បីមាត់ រកតែខ្ញុំស្តាប់មិនបាន ខ្ញុំក៏ឆ្លើយតបទៅវិញថា:

~ ព្រះពរម្ចាស់ ខ្ញុំម្ចាស់ចេះនិយាយតែភាសាខ្មែរទេ។

~ ហាំ ! ហាំ ! (ហ្លួងសើចតិចៗ) វាកូនអ្នកណាហ្នឹង, រួចវាចង់បានអី?

បងរឿក ឆ្លើយជំនួសខ្ញុំភ្លាម ដោយខ្លាចក្រែងខ្ញុំនិយាយមិនបានសមរម្យ:

~ ក្រាបទូល! នាងហ្នឹងកូន នាយយិន ធ្វើទាហានហ្លួង និង នាងឯម, នាងមកសុំចូលរាំល្ខោនព្រះករុណា។

~ ហាំ! ហាំ! ឲ្យវាចូលជិតបន្តិចមក អញមើលឲ្យច្បាស់បន្តិច។

ខ្ញុំងើបឈរឡើង ហ្លួងទាញសក់អួសខ្ញុំឲ្យទៅឈរពីមុខកញ្ចក់ ដែលអាចឲ្យខ្ញុំមើលឃើញរូបហ្លួងក្តាប់សក់ឬងជុករបស់ខ្ញុំជាប់ ។ ហ្លួងសើចរលាក់ញ័រអស់ផងខ្លួន ហើយសួរខ្ញុំថា:

~ ឯងស្រឡាញ់អញទេហាំ?

នាងស្រឡាញ់ព្រះអង្គណាស់ក្រាបទូល (បងរឿក ឆ្លើយកាត់ម្តងទៀត ជារបៀបសរសើរលើកដំកើង)។

បងរឿកភរទេ! តាមពិតខ្ញុំខ្លាចហ្លួងស្ទើរភាគនោមទៅហើយ ខ្ញុំចង់ឲ្យតែឆាកនេះឆាប់ចប់ស្រឡះទៅប៉ុន្តែខ្ញុំក៏មិនហ៊ានបម្រះដែរ បណ្តោយឲ្យហ្លួងផ្ទៀងផ្ទង់មើលតាមចិត្ត។ លោកបង្គាប់ថា:

~ ហំ! ឲ្យគេយកប្រាក់បួនណែនមកឲ្យក្មេងនេះ ហើយឲ្យគេចុះឈ្មោះវាក្នុងបញ្ជីកូនល្ខោនរបស់យុទថាន់ផង។ អើនែ! ដាក់ឈ្មោះវាថា "ដកណាមយ៉ែម" ណាំ!។

ស្រីម្នាក់ ជាអ្នកកាន់កូនសោ ហើយដែលក្រោយមកខ្ញុំដឹងថាឈ្មោះម៉មឡយ ជាអ្នកគាប់នឹងហ្លួងជាងគេ ប្រញាប់ទូលគាត់ភ្លាម:

~ ក្រាបទូល! ឲ្យតែបីណែនគ្រាន់ហើយ ព្រោះវានៅក្មេងណាស់។

ឃើញថា ហ្លួងនៅស្ងៀមសម្តែងការយល់ស្រប គាត់ក៏ងើបដើរចេញទៅក្រៅមួយភ្លែត ហើយត្រឡប់មកវិញ ព្រមទាំងពោលមកកាន់ខ្ញុំថា:

~ អាយុប៉ុនឯង គេឲ្យតែពីរណែនទេ ប៉ុន្តែហ្លួងគាប់ព្រះទ័យនឹងឯងហើយ បានជាប្រទានបីណែនអញ្ចឹង, ម៉េចក៏មិនលុតជង្គង់ថ្វាយបង្គំអរព្រះគុណព្រះអង្គភ្លាមទៅ!។

ទោះបីខ្ញុំត្រូវខាតបង់មួយណែន ដោយសារមានអ្នកទូលទាស់យ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែយល់ថាប្រាក់បីណែននេះ ជាព្រះរាជអំណោយមានតម្លៃច្រើនពេកណាស់។ ខ្ញុំលុតជង្គង់ចុះប្រុងថ្វាយបង្គំ ប៉ុន្តែហ្លួងយាងចេញទៅដោយបញ្ជាក់ម្តងទៀត:

~ យកវាទៅឲ្យនៅជាមួយ នួន ណាំ! ព្រោះគេធ្វើការម៉ឺងម៉ាត់ជាង ញ៉ុក។

នួន ជាឈ្មោះរបស់យុទថាន់ គ្រូល្ខោនក្រុមទីមួយ ចំណែកឯ ញ៉ុក ជាឈ្មោះយុទព្រះញាតិ។ សំដីបង្ហាញឲ្យឃើញថា ហ្លួងមិនសូវទុកចិត្តលើអ្នកដែលបានជួយជ្រោមជ្រែងខ្ញុំប៉ុន្មានទេ។ បងរឿក ទាញដៃខ្ញុំទៅក្រៅ លួងលោមពន្យល់ថា:

– កុំទៅនៅជាមួយ យុនថាន់អី នៅជាមួយ យុនព្រះញាតិ ហ្នឹងហើយ, ឯងកុំភ្លេចណា! គាត់ជាអ្នកនាំឯងមកថ្វាយហ្លួង ។

ពួកល្ខោននាំគ្នាមកចោមរោមខ្ញុំដោយចិត្តច្រណែនឈ្នានិស ចំណែកឯចាស់ៗធ្មេញក្រហមវិញ ខំសរសើរខ្ញុំ ក្រែងបានម្លូស្លា ។ ពួកម៉ាកស្រីរបស់ខ្ញុំម្នាក់ឈ្មោះ ស៊ុន មានផ្ទះនៅជិតខ្នាងកំពង់ផែ វាចូលមកនៅវាំងមុនខ្ញុំមួយឆ្នាំ, វាសំដែងទឹកមុខមិនពេញចិត្តខ្លាំងណាស់ ដែលឃើញហ្លួងប្រទានលុយខ្ញុំលើសវាមួយណែន ។

ម៉ែចេញមកពីកន្លៀតណាមក មុខញញឹមពព្រាយ ស្រវាយកលុយទុក អររេខិបរេខុបនាំខ្ញុំទៅជម្រាបលា យុនព្រះញាតិ ។ យុនផ្ដាំថា ស្អែកព្រឹកឲ្យម៉ែនាំខ្ញុំមកម្ដងទៀត ។

នៅពេលដែល ម៉ែ និង ខ្ញុំ ឆ្លងផុតក្លោងទ្វារ នៃ កំផែងសីមា ទីលានកំពង់ផែដ៏ធំទូលាយ លេចឡើងនៅចំពោះមុខខ្ញុំ កណ្ដាលផ្ទៃអន្ធការ នៃ រាត្រីកាល ។

ហាក់ដូចជាទម្ងន់អ្វីមួយរបូតខ្សាកចេញពីទ្រូង បណ្ដាលឲ្យខ្លួនខ្ញុំប្រែជាស្រាលស្ទើរដូចជាន់ខុសដី ។ បន្តិចទៀតខ្ញុំនឹងបានឡើងឋានៈជាលោកយុន ខ្ញុំនឹងក្លាយទៅជាមនុស្សម្នាក់ផ្សេងទៀត ពុំមែនដូចខ្ញុំសព្វថ្ងៃនេះទេ ។ ហ្លួងចិត្តទូលាយប្រទានប្រាក់ច្រើនម្ល៉េះៗ មិនយូរមិនឆាប់ ឪពុកម្ដាយខ្ញុំគង់នឹងបានខ្ពស់មុខខ្ពស់មាត់ ពុកអាចនឹងមានលុយទិញអាវ កត្រង់ ខ្សែប្រាក់ ពាក់ដូចគេមិនខាន ។

សម្រាប់រូបខ្ញុំ ខ្ញុំឥតត្រូវការចង់បានអ្វីទាំងអស់ ខ្ញុំចង់តែម្យ៉ាង គឺថ្ងៃណាមួយខ្ញុំនឹងបានឡើងធ្វើជាតួឯកល្ខោនហ្លួង រាំនៅចំពោះមុខទស្សនិកជនតែប៉ុណ្ណោះ ។ ខ្ញុំស្រមៃឃើញអនាគតភ្លឺស្វាង ប្រកបទៅដោយកិត្តិយស និង ជោគជ័យ ហើយខ្ញុំភ្លេចអស់រលីងនូវរឿងរ៉ាវអតីតកាល ដែលខ្ញុំធ្លាប់ជួបប្រទះកាលរស់នៅឯព្រែកថ្មី ។

នៅលើចុងសសរផងកើ ទង់ក្រហមបក់រវិចទៅតាមកម្លាំងវាយោ ។ ហ្លួងភ្លែកហើយត្រឡប់មកកាន់ទ្រនំវិញ បញ្ចេញសំឡេងកោកកាកទ្រហឹងអឹងអាប់... ។

♥ ♥

♥



ស្អែកឡើង ខ្ញុំចូលមកនៅជាមួយនឹងយុនព្រះញាតិ ដែលខំខ្នះខ្នែងខ្លាំងណាស់ ពុំព្រមឲ្យយុនថាន់ ជាគូប្រជែង កេងយកចំណេញក្នុងការបង្ហាត់ខ្ញុំទេ ខ្ញុំ សាកសួរគេខ្លះ លួចមើលគេខ្លះ រហូតដល់អាចចេះដឹង ស្គាល់វិន័យ និង របៀបរៀបរយ ក្នុងវាំង បានយ៉ាងឆាប់រហ័ស ។

ដូចខ្ញុំស្មានមិនខុសមែន សកម្មភាពអ៊ូអរជាងគេ គឺនៅត្រង់ក្រោយប្រាសាទទាំងប្រាំ ដែលបញ្ចេញតែផ្នែកខាងមុខដ៏ល្អឲ្យគេឃើញនេះឯង ។ ផ្លូវតែមួយគត់ដែលនាំឆ្ពោះទៅទ្វារព្រលប់ ដោយកាត់តាមចន្លោះទេវាវិនិច្ឆ័យ និង រោងរបាំនោះ បន្តចូលមកក្នុង កាត់តាមចន្លោះប្រាសាទបាញ់យ៉ុង ទីនាំងទក្សិណា និង មហាមន្ទីរ ដែលជាដំណាក់ហ្លួងគង់នៅរាល់ថ្ងៃ ហើយបន្តរហូតដល់កាត់ខ្វែងគ្នាជាមួយផ្លូវធំមួយទៀត ។ កន្លែងផ្លូវកែងនេះ ជាទីសប្បាយអ៊ូអរជាងគេ មនុស្សមកជួបជុំគ្នាកុះករ ស្រីៗលក់នំចំណីនៅខាងក្រៅ ក៏អនុញ្ញាតឲ្យចូលមកលក់ដល់ទីនេះបានដែរ ។ ផ្លូវតូចៗច្រើនទៀត បន្តចេញពីផ្លូវធំ ឆ្ពោះទៅផ្ទះព្រះអង្គម្ចាស់ អស់អ្នកអស់នាង សាវឡឹកសាវឡយ ដែលម្នាក់ៗមាន កិត្តិយស ឬ ទ្រព្យសម្បត្តិ តិចច្រើន ទៅតាមឋានៈខ្លួន ជាយុន ជាម៉ម... ។ យុនថាន់ អ្នកគាប់ចិត្តហ្លួងជាងគេ បាននៅក្នុងប្រាសាទមេខលា ។ ចំណែក យុនព្រះញាតិ ចៅហ្វាយខ្ញុំ និង ម៉មសួន ជាចាងហ្វាងក្រុមល្ខោនទីបីនោះ នៅក្នុងបន្ទប់ថែវឯណោះទេ ។

យុន ម៉ម អស់អ្នកអស់នាង ទាំងនេះ ម្នាក់ៗមានខ្ញុំបំរើផ្ទាល់ខ្លួនមួយហ្លូង ថែមទាំងដឹកជញ្ជូន ឪពុកម្ដាយ ទាំងសាច់ញាតិប្រាំពីរសន្ដាន មកឲ្យដេកស៊ីលុយហ្លួង ដោយពុំចាំបាច់ធ្វើការអ្វីទៀតផង ។

នរណាមានវ័យចាស់ និង មានឋានៈធំ អាចមានសេរីភាព ចេញ-ចូល ក្នុងវាំង ដើរទៅលេងផ្សារ ឬ ទៅសុំសីលនៅវត្តជិតៗបាន ។ ប៉ុន្តែ ហ្លួងដូចជាមិនសូវរវល់នឹង អ្នកនេះនៅ អ្នកនោះមិននៅ អីប៉ុន្មានទេ យូរៗជួបគ្នាម្ដង ហ្លួងគ្រាន់តែសួរសុខទុក្ខពីកូនពីចៅតែប៉ុណ្ណោះ ។ ឯការជួបគ្នានេះទៀតសោត ទាល់តែត្រូវការសុំនេះ សុំនោះ ទើបគេទៅគាល់ហ្លួង ហើយខ្ញុំកម្រឃើញហ្លួងប្រកែកថាមិនឲ្យណាស់ ។ ឋានៈអ្នកនៅក្នុងវាំង មានច្រើនពេក សាំញ៉ាំមិនដឹងជាស្អីខ្លះទេ ប៉ុន្តែបើនិយាយពីអំណាចត្រួតត្រាលើគេវិញ ស្ថិតនៅក្នុងកណ្ដាប់ដៃមនុស្សបីនាក់ ។ មុនគេបង្អស់គឺ យុនថាន់ ចាងហ្វាងល្ខោន មានអំណាចខ្លាំងជាងគេ និង បន្ទាប់មកគឺ យុនព្រះញាតិ ។ អ្នកទាំងពីរត្រូវចំណាយប្រាក់ច្រើនឥតគណនា ដើម្បីរើសកូនល្ខោនសម្រាប់ក្រុមផ្ទាល់ខ្លួនម្នាក់ៗ ក្នុងចំណោមគ្រួសារអ្នកទីក្រុង ដែលភាគច្រើនមានសុទ្ធតែ ខ្មែរ និង សៀម ចំណែកឯកូនល្ខោនរបស់ម៉មសួន អ្នកគាប់ចិត្តហ្លួងជាទីបីនោះវិញ មានសុទ្ធតែក្មេងស្រីកូនកាត់ចិនយួន សម្បុរសស្គុស ដែលគេយកមកកាត់សក់របៀបសៀម និង ឲ្យស្លៀកពាក់ដូចយើងដែរ ។

យុនថាន់ អាយុចាស់បន្តិចមែន ប៉ុន្តែហ្លួងនៅតែគាប់ចិត្តនឹងគាត់ជាងគេជានិច្ច ព្រោះគាត់ជាមនុស្ស

ស្ទិតស្ទាញក្នុងការងារ ព្រមទាំងមានចិត្តទូលាយ ប្រឹងប្រែងបង្ហាត់សិស្សឥតគិតនឿយហត់ និង ចេះធ្វើឲ្យសិស្សគ្រប់គ្នាគោរពស្រឡាញ់។ នេះជាកំហុសធំរបស់ខ្ញុំ ដែលពុំព្រមទៅនៅជាមួយគាត់តាមព្រះរាជបញ្ជា ហើយក្រាញនៅជាមួយ យុទព្រះញាតិ ដែលជាហេតុនាំឲ្យខ្ញុំជួបប្រទះនឹងរឿងរ៉ាវល្វីងជូរចត់ ហើយសេចក្ដីសង្ឃឹមថា នឹងបានស្គាល់អនាគតភ្លឺស្វាងនោះ ក៏រលត់រលាយអស់ទៅវិញដែរ។

យុទព្រះញាតិ នេះ ប្រសប់អស្ចារ្យខាងនិយាយលើកជើង ឪពុក-ម្ដាយ នៃ ក្មេងស្រីៗ ដែលគាត់ចង់ទាញបញ្ចូលមកក្នុងក្រុមគាត់ ដើម្បីឃាត់ឃាំងកុំឲ្យអ្នកទាំងនោះ យកកូនខ្លួនទៅថ្វាយហ្លួងដោយផ្ទាល់។ ធ្វើយ៉ាងនេះ គាត់អាចកេងយកចំណេញជាប្រយោជន៍ផ្ទាល់ខ្លួន លើប្រាក់រង្វាន់សម្រាប់សិស្សម្នាក់ៗបានយ៉ាងស្រួល, នៅសល់ប៉ុន្មាន គាត់ថែមទាំងយកទៅចងការឲ្យឪពុកម្ដាយ ដែលគ្នាមិនដឹងអីសោះទៀតផង។ ប៉ុន្តែ ទម្រាំនឹងខ្ញុំបានដឹងរឿងរ៉ាវអស់ទាំងនេះ វាហួសពេលអស់ទៅហើយ។ ក្មេងស្រីមួយចំនួនដែលគ្រប់អាយុល្មមទៅគាល់ហ្លួងបាន គេបានអំណាចហ្លួងការពារ មិនចាំបាច់វិលមកហាត់រាំ ក៏អត់មាននរណាហ៊ានថាអីឲ្យដែរ រហូតដល់អ្នកខ្លះឈប់មករាំសោះតែម្ដង ដើម្បីចូលកាន់តំណែងថ្មី ជាអង្គរក្ស និង ជាអ្នកនាំបញ្ជាពីហ្លួង បន្តទៅប្រាប់អ្នកបំរើប្រុសៗនៅខាងក្រៅ។ ខ្ញុំយល់ថា នៅក្នុងវាំងមានតែស្រីអ្នកបំរើហ្លួងនេះទេ ដែលជាមនុស្សមានសំណាងជាងគេ ព្រោះកិច្ចការនេះគ្មាននឿយហត់អីសោះ ឲ្យតែពូកែរណេបរណឺបធ្វើការឲ្យហ្លួងឃើញបន្តិច ច្បាស់ជាបានរង្វាន់ញឹកញាប់ណាស់។

នៅពេលហាត់រាំលើកទីមួយ ខ្ញុំប្រឹងប្រែងយកចិត្តទុកដាក់ជាទីបំផុត។ អ្វីៗដែលខ្ញុំធ្លាប់ហាត់រៀនកាលនៅផ្ទះលោកអ៊ំអគ្គមហាសេនា ខ្ញុំនៅចាំទាំងអស់ ឥតមានភ្លេចចន្លោះត្រង់ណាឡើយ ជាហេតុធ្វើឲ្យអ្នកគ្រូចាស់ៗភ្ញាក់ផ្អើលឆ្ងល់គ្រប់គ្នា។ អ្នកគ្រូសៀមឈ្មោះ សរិត នោះ ឆ្លាស់លេខមួយ ឲ្យតែខុសបន្តិច គាត់ក្ដិចភ្លៅ លើករំពាត់ផ្ដៅកំញើញមួយរំពេច។ កូនសិស្សក្មេងៗ ស្រឡាញ់អ្នកគ្រូគ្រីប និង អ្នកគ្រូល្មុត ជាង ប៉ុន្តែមិនសូវខ្លាច ហើយក៏មិនសូវស្ដាប់បង្គាប់គាត់ដែរ។ ដើម្បីបំភ័យយើង អ្នកគ្រូចាស់ៗទាំងនេះ សម្លុតចង់វាយធ្វើបាបយើង តាមរបៀបដែលគេធ្លាប់ប្រើកាលពីដើម សម្រាប់បង្ហាត់ពួកល្ខោន។

ព្រលឹមស្រាងៗឡើង គេនាំគ្នាចុះប្រសាចទៅក្នុងសួនច្បារ ដើម្បីស្រស់ស្រូបបបរ ឬ ទិញទំផ្សេងៗទៀត ដែលអ្នកលក់ខាងក្រៅនាំយកចូលមក។ បន្ទាប់មក គេពាក់អាវរៀលភ្លៀកពណ៌ប្លែកៗគ្នា ស្លៀកសំពត់ ខៀនផាត់ម្សៅ រួចហើយរត់ប្រញាយសំដៅរោងរបាំខាងក្នុង ដើម្បីប្រជុំគ្នាសមរឿង ឯណាវ ឬ រឿង ស្ដេចដោះ ទុកសម្រាប់រាំថ្វាយហ្លួងទតក្នុងឱកាសបុណ្យខាងមុខនេះ។

កាលណាឃើញអ្នកគ្រូចាប់កាច់ដៃកាច់ជើងពួកម៉ាកណាម្នាក់ ដែលពត់ពេនពុំត្រូវតាមចង្វាក់ភ្លេង ខ្ញុំសប្បាយចិត្តសើចហើកញៀវចំអកឲ្យគេ។ រាល់ព្រឹក មានស្ត្រីទាំងហ្លួងៗ ចូលមកមើលយើងសមរបាំ ដែលជាហេតុធ្វើឲ្យខ្ញុំបារម្ភក្នុងចិត្តក្រៃលែង ខ្លាចតែត្រូវរំពាត់ខ្មាសគេ។

វេលាប្រហែលម៉ោង ១០ យើងឈប់ហាត់ អស់កម្លាំងរមួលពោះស្ទើរបោចពោះវៀន។ យើងប្រញាប់ផ្លាស់សំលៀកបំពាក់ ប្រមូលគ្នាតាមក្រុមទៅងូតទឹកម៉ាស៊ីន ហើយត្រឡប់មកបរិភោគបាយថ្ងៃត្រង់ នៅផ្ទះចៅហ្វាយនាយរៀងខ្លួន ឬ នៅក្នុងបន្ទប់ដេកផ្ទាល់ខ្លួន កាលណាឪពុកម្ដាយយើងយកបាយពីខាងក្រៅមកឲ្យ។

តាំងពីទើបនឹងមកដល់ដំបូង ខ្ញុំអៀសខ្លួនពុំចង់រស់នៅដោយសារបាយចៅហ្វាយនាយទេ។ រាល់ព្រឹក ម៉ែតែងយកបាយមកផ្ញើខ្ញុំឥតដែលខានឡើយ។ ថ្ងៃមួយ ម៉ែយកបាយមកមិនទាន់ពេល ហើយខ្ញុំរមួលពោះខ្លាំងពេកទ្រាំមិនបាន ក៏បង្ខំចិត្តធ្មេចភ្នែកលេបបាយជាមួយគេជាមួយឯងទៅ។ មួយម៉ោងក្រោយមក គ្រាន់តែ



ឃើញម៉ែយួរចានស្រាក់មកដល់ ខ្ញុំមួម៉ៅស្ទុះទៅទាត់ចានស្រាក់ កំពប់បាយសម្លពេញផ្លូវ។

ខ្ញុំឆ្នាស់សម្បើមណាស់! នៅក្នុងវាំង នរណាក៏ឮល្បីឈ្មោះខ្ញុំដែរ។ ក្មេងតូចៗដូចគ្នា ឲ្យតែហ៊ានធ្វើអ្វីប៉ះពាល់ខ្ញុំបន្តិច ខ្ញុំវាយភ្លាម ទាល់តែ យុទព្រះញាតិ ឬ យុទថាន់ មកឃាត់ទើបឈប់។ ម៉ែឱស្សាហ៍វាយខ្ញុំណាស់ដែរ កាលណាមានគេនិយាយប្រាប់គាត់ថា ខ្ញុំប៉ិនដើររករឿងឈ្លោះប្រកែក ប៉ុន្តែវាយឯណាទាន់, គាត់គ្រាន់តែយាររំពាត់ ខ្ញុំរត់ប្រូចពួនបាត់ត្រង់កន្លៀតណាមួយ ពុំងាយរកឃើញឡើយ។

ស៊ុន ជាពួកម៉ាកស្រីម្នាក់ ដែល ឪពុក-ម្ដាយវា មានផ្ទះនៅក្នុងសង្កាត់កំពង់ផែ ក្បែរផ្ទះខ្ញុំដែរ។ ម៉ែឱស្សាហ៍មកសុំយកយើងទាំងពីរនាក់ ទៅលេងផ្ទះណាស់។ បានទំនេរទៅផ្ទះ យើងគិតតែសប្បាយមុជទឹកទន្លេមួយថ្ងៃវាល់ល្ងាច។

កាលនោះ ដីច្រាំងកំពង់ផែពុំទាន់បាក់នៅឡើយទេ ហើយមានឈូរខ្សាច់មួយដែលជាកន្លែងប្រជុំក្មេងៗក្នុងភូមិ មកប្រឡែង ឬ មុជទឹកហើកញៀវយ៉ាងសប្បាយរីករាយ។ នរណាហ៊ានមកធ្វើឲ្យល្អក់ទឹកក្បែរកន្លែងយើងមុជ យើងជេរគេឥតញញើតមាត់, នរណាហ៊ានមកឡេមឡឺមក្បែរទីនាំងផែ យើងដេញទម្លាក់ទឹកភ្លាម។ ស៊ុន មានបងប្រុសម្នាក់ស្លូតណាស់, យើងបានចិត្ត នាំគ្នាធ្វើបាបវាឲ្យយំជារឿយៗ។ ពេល ស៊ីបាយ យើងផ្គាប់ចានចាក់បាយវាចោល យើងប្រអួសប្រទាញច្រានវាទម្លាក់ទឹក ឬក៏ ចាក់រុកវាឲ្យឈ្លោះវាយតប់ជាមួយកូនគេនៅជិតខាង ដែលមកឆាឆៅយើង។ យើងស្លៀកសារុងចងក្បិនកប់ក្រលៀន ខ្លួនទទេ ប្រៀបបាននឹងបិសាចមែនទែន សូម្បីតែក្មេងប្រុសៗក៏ខ្លាចយើងដែរ។

ជួនកាល យើងប្រមូលគ្នាបានមួយក្រុម ច្រឡឹមដូចឃ្មុំកង រត់ចេញប្រសេចប្រសាចពីវាំង ទៅមើលរូបចម្លាក់រឿងរាមកេរ្តិ៍ ឆ្លាក់ជាប់នឹងជញ្ជាំងវិហារវត្តព្រះកែវ ឬក៏ ដើរសម្លុតផ្ទះអ្នកដែលមានដាំផ្កាថា ហ្លួងប្រើយើងឲ្យមកសុំបេះផ្កា ហើយមិនចាំបាច់ម្ចាស់គេថា ឲ្យ ឬ មិនឲ្យ ទេ យើងប្រញាយគ្នាបេះបង្ហិនបង្ហោចរបស់គេភ្លាមមួយរំពេច។ កាលណាយើងជួបនឹងពួកក្មេងប្រុស ស្លៀកពាក់ស ពាក់មួកកន្ទេល និង ពាក់ស្បែកជើងឃ្មុប ដើរចេញពីសាលានៅឯសង្កាត់ខាងជើងនោះមក យើងនាំគ្នាស្រែកជេរគេថា អាក្បត់ជាតិ អាខ្ញុំបារាំង ដែលជាហេតុធ្វើឲ្យគេខឹង រត់ដេញតាមប្រផាប់ចាប់ប្រភឹង រហូតទាល់តែដល់ក្លោងទ្វារវាំង។

ពីរ-បីខែ កន្លងផុតទៅ យើងនៅតែសមរបាំរាល់ថ្ងៃ រហូតដល់ពេលធ្វើបុណ្យតាំងតុ ដែលឆ្នាំនេះក៏ដូចជាឆ្នាំមុនៗដែរ គឺប្រជាពលរដ្ឋក្នុងទីក្រុងសឹងតែទាំងអស់ និង នាម៉ឺនសព្វមុខមន្ត្រី មកពីគ្រប់ខេត្តខ័ណ្ឌ មកប្រជុំគ្នាត្រៀបត្រាកុះករជុំវិញបន្ទប់ខាងក្រៅ។ នេះជាពិធីបុណ្យចំរើនព្រះជន្មចុងក្រោយបំផុតរបស់ ស្ដេច សុវណ្ណកោដ្ឋ ហើយគ្មាននរណាចាប់ភ្លឹកគិតថា មរណកាល នៃ ព្រះអង្គ ជិតធ្វើដំណើរមកដល់នោះទេ។

ក្នុងឱកាសបុណ្យនេះ ខ្ញុំត្រូវចេញរាំនៅចំពោះមុខសាធារណជនជាលើកដំបូងបំផុត ដោយគ្រាន់តែធ្វើជាតួរាយរងប៉ុណ្ណោះ។ សម្លៀកបំពាក់តែងខ្លួនរបស់ខ្ញុំ ពុំអាចយកទៅផ្ទឹមនឹងពួកអ្នកល្បីឈ្មោះចាស់ៗ ដែលគេដើរជាតួឯកនោះបានទេ។

ពួកអ្នកគ្រូលុតជង្គង់ក្បែរយើង រៀបចំស្លៀកពាក់ឲ្យ ទាញខ្ចីបត្រង់ណេះបន្តិច ត្រង់ណោះបន្តិច យកម្ជុលមកចាក់ខ្ទាស់ ឥតរវល់រឿងមុតដល់សាច់ ឬ នរណាស្រែកឈឺអ្វីទាំងអស់។ យើងត្រូវឈរស្លៀកពាក់របៀបនេះពេញមួយល្ងាច បណ្ដាលឲ្យរោយជើងឈរមិននឹង។ ជាពិសេសទៅទៀត យើងត្រូវឈ្លោះប្រកាប់ប្រចាក់គ្នា ដណ្ដើមគ្រឿងអលង្ការក្រៃឡែ និង អង្វរអ្នកគ្រូ ដើម្បីឲ្យបានស្លៀកខោអាវល្មមខ្លួន។

ពុទ្ធោអើយ! តែងខ្លួនរបៀបហ្នឹងមួយថ្ងៃ ខ្ញុំសឹងតែទ្រាំមិនបាន។ ណាមួយមួម៉ៅនឹងអ្នកតែងខ្លួន ដែលរវល់ប្រចុបប្រចែងតែជាមួយអ្នករបាំណា ដែលគ្រូធំៗពេញចិត្តប៉ុណ្ណោះ ចំណែកយើងវិញ គេយកម្ជុលខ្ទាស់

មកចាក់មុតដល់សាច់ កីមិនខ្វីឈឺក្បាលគេផង ។ ពួកស្រីធំៗដែលមានដើមទ្រូងពេញ រឹតតែវេទនាណាស់ទៅទៀត ព្រោះគេយកអាវចង្អៀតណែនក្តន់មកឲ្យពាក់រឹបួតដោះស្ទើរបែក ដើម្បីតែងខ្លួនធ្វើជាប្រុស គេឲ្យស្លៀកខោខ្លីប៉ាក់អង្កាំ សុទ្ធតែក្លែលក្រខ្វក់បន្តគ្នាពីមួយទៅមួយ ពុំដឹងជាប៉ុន្មានជំណាមកហើយ ហើយពុំដែលឃើញបោកគក់ម្តងណាសោះ ។ ថ្ងៃណាមួយខ្ញុំគង់នឹងបានជួបប្រទះ ទុក្ខវេទនារបៀបដូចគ្នានេះមិនខាន ដើម្បីតែងខ្លួនឲ្យបានល្អប្រិមប្រិយ៍ ។

ដូនកាល ស្លៀកពាក់រួចស្រេចបាច់អស់ទៅហើយ សល់តែ លាបម្សៅ គូរចិញ្ចើម រោមភ្នែក លាបបបូរមាត់ បន្តិចបន្តួចប៉ុណ្ណោះ ស្រាប់តែឈឺ បត់ជើងតូច បត់ជើងធំ ខ្លាំងមែនទែន ទ្រាំអត់មិនបាន ក្មេងៗក៏ទ្រហោយំង៉ោងឡើង, នរណាធំប្រកែកតមាត់ជាមួយអ្នកតែងខ្លួន ទាល់តែគេដោះសម្លៀកបំពាក់ចេញស្ទើរតែទាំងអស់ ហើយរត់ប្រាសប្រាលទៅដោះទាល់នៅត្រង់កន្លៀតណាមួយសិន ពីព្រោះបង្គន់នៅឆ្ងាយពេក ពុំអាចទៅមកបានរហ័សទាន់ចិត្តឡើយ... ។

កូនសិស្សខ្លះដែលហាត់ពុំបានស្ទាត់ល្អ ដល់ឮស្គរ ឮភ្លេង ឃើញភ្លើងព្រោងព្រាត ឃើញមនុស្សឈរមើលត្រៀបត្រា វាទៅជាភ័យស្លន់ ឈឺនោមបន្តិច ឈឺជុះបន្តិច អញ្ជឹង តើត្រូវធ្វើម៉េចហ្នំ បើជិតដល់ពេលចេញរាំណាស់ទៅហើយ ? ដល់រាន់ខ្លាំងមែនទែន កូនសិស្សហ៊ានជជែកមាត់ប៉ប៉ែសជាមួយគ្រូ លែងកោតខ្លាចអ្វីទាំងអស់ ។ ហួសពេលទៅហើយ ទម្រាំតែដោះសម្លៀកបំពាក់ និង ស្លៀកមកវិញនោះ ពុំដឹងជាកាលណាទើបបានចេញរាំទេ ។ ម៉្លោះហើយបញ្ហានេះ ត្រូវតែរកផ្លូវដោះស្រាយដោយខ្លួនឯង គឺនរណាទ្រាំទប់ពុំជាប់ ក៏ធ្លាយនោមទឹកខោពណ៌បៃតងខ្ចី ឬ ក្រហមនោះជោក ហៀរដល់កន្ទេល ប្រឡាក់ដល់ជើងអ្នកគ្រូ ដែលអង្គុយបើកភ្នែកធំៗហួសចិត្តរកស្តីមិនចេញ ។ នឹកឃើញអញ្ជឹង ខ្ញុំព្រឺខ្លួនខ្លាចចំលើថ្ងៃសិយរឿងរ៉ាវនេះវាកើតចំពោះខ្ញុំតែម្តង ។

ពេលចេញរាំជិតមកដល់ ខ្ញុំរឹតតែភ័យខ្លាំងឡើងៗ ។ ដូចកាលយប់រាំសមជើងនៅក្នុងវាំងនោះដែរ ខ្ញុំយកធូបមកអុជដាក់ពី មុខមកុដ មុខស្វា មុខយក្ស សុំឲ្យព្រាយល្ខោនជួយកុំឲ្យទន់ដៃទន់ជើង ។ អ្នកគ្រូ សារិត លើកមកុដខ្ញុំឡើង ដាក់កន្សែងយ័ន្តមានចារគាថាលើនោះផងពីខាងក្នុង ទើបបំពាក់ឲ្យខ្ញុំ សម្រាប់ការពារកុំឲ្យភ្លេចក្បាច់ណាមួយនៅកណ្តាលឆាក ។

ដល់វេនខ្ញុំត្រូវចេញ គេចែកគ្នាតាមរបៀប គឺឲ្យខ្ញុំចេញមុនគេ ហើយបន្តគ្នារហូតដល់អ្នកណាអាយុច្រើនជាងគេ ឲ្យនៅក្រោយបង្អស់ ។ កាលនៅផ្ទះលោកអ៊ុំអគ្គមហាសេនា ខ្ញុំធ្លាប់រាំដើរជាតួសំខាន់ៗតែម្នាក់ឯងរួចអស់ទៅហើយ, ម៉្លោះហើយ គ្រាន់តែភ្លេងចាប់ប្រគុំភ្លាម ខ្ញុំក៏ស្ទុះភ្លែតចេញទៅ ដោយខំពត់ពេនចលនាជើងខ្លួន និង អវយវៈ ឲ្យត្រូវតែតខ្វោះតាមចង្វាក់ភ្លេង ។ យាយចាស់ៗដែលអង្គុយបត់ជើងព័ទ្ធជុំវិញឆាក ជជែកគ្នារអ៊ូឡើង ហើយហ្លួងក៏ស្រែកប្រាប់ជាភាសាសៀមទៅកាន់នាម៉ឺនម្នាក់ដែលលុតជង្គង់ក្បែរនោះដែរ ។ ខ្ញុំមិនខ្វីស្តាប់នរណានិយាយថាអ្វីទាំងអស់ រាំទាល់តែគ្រប់មួយជុំឆាក ទើបខ្ញុំត្រឡប់ចូលមកក្នុងវិញ ក្នុងចិត្តគិតស្មានថានឹងបានទទួលពាក្យកោតសរសើរមិនខាន ។ ប៉ុន្តែខ្ញុំបែរជាបានទទួលសំណើចចំអកឡកឡឺយពីអ្នករបាំដូចគ្នា និង រំពាត់ផ្តៅពីអ្នកគ្រូ ជារង្វាន់ទៅវិញ ។ ម៉េចក៏ខ្ញុំហ៊ានចេញទៅមុនពេលគេឲ្យសញ្ញា ? ម៉េចក៏ខ្ញុំចេញទៅតែម្នាក់ឯង ពុំព្រមចាំអ្នកឯទៀតផង ? ខ្ញុំចង់យកមុខយកមាត់តែម្នាក់ឯង ដើម្បីបំបាក់មុខធ្វើឲ្យហ្លួងខ្មាសភ្ញៀវបារាំងឬអ្វី ? គេក្តិចមួលភ្លៅខ្ញុំចេញឈាមទាល់តែខ្ញុំយំ ។ ពេលនោះ យុទថាន់ចូលមកជិតនិយាយលួងលោមខ្ញុំថា ខ្ញុំធ្លាប់តែរាំម្នាក់ឯង បានជាផ្លោះផ្លោយអញ្ជឹង, ចាប់តាំងពីពេលនេះតទៅ ខ្ញុំត្រូវប្រយ័ត្នមើលគេមើលឯងឲ្យមែនទែន ។



ម្តងនេះ ខ្ញុំប្រុងប្រៀបខ្លួនស្រួលបួលចេញរាំជាថ្មីម្តងទៀត ដោយមានគេឯងចេញមកហូរហែតាម ក្រោយហើយបាំបានប្រព្រឹត្តទៅរហូតដល់ចប់ គ្មានការច្រងេងច្រងាងផ្សេងទៀតឡើយ ។ ប៉ុន្តែ ខ្ញុំចងគំនុំនឹងអ្នកគ្រូសារិត ដ៏ផ្តាស់នោះជាប់រហូត ទើបខ្ញុំប្រកែកលែងព្រមហាត់ជាមួយគាត់ ។

ខ្ញុំសំណាក់នៅក្នុងរោងក្បែរផ្ទះយុនព្រះញាតិ ។ ល្ងាចនោះ គេយកព្រូកមកក្រាលលើក្តារ និង ចងមុងធំវែង ដើម្បីឲ្យពួកល្ខោនទទួលទានដំណេកជាមួយគ្នាទាំងអស់តែម្តង ។ ខ្ញុំចូលចិត្តរស់នៅជាមួយគ្នាច្រើនដូច្នេះ ជាងរស់នៅម្នាក់ឯង ព្រោះខ្ញុំខ្លាចខ្មោចណាស់ ។

យប់ឡើង នរណាអស់កម្លាំងក៏ស្រាន់ចូលមុងមុនគេទៅ អ្នកខ្លះទៀតនៅ លេងបៀ ឬ ជក់បារីជជែកគ្នាអែ រហូតដល់យប់ជ្រៅ ។

អ្នកដេកជិតខ្ញុំឈ្មោះ រុន ។ គាត់មានអាយុបងខ្ញុំជាងដប់ឆ្នាំ ហើយបានលះបង់ការរាំរែកជ្រះស្រឡះ ដើម្បីទៅបំរើហ្លួងវិញ ។ មិនយូរប៉ុន្មាន គាត់ក៏ចាប់ចិត្តរាប់អានខ្ញុំ ហើយខ្ញុំក៏ស្រឡាញ់គាត់ដូចជាបងស្រីបង្កើតម្នាក់ដែរ គ្រាន់នឹងបានពឹងពាក់គ្នាទៅវិញទៅមកពេលឈឺថ្កាត់យប់ព្រលប់ ។ ខ្ញុំដេក អោប ឬ គងគាត់ បានតាមចិត្ត ព្រោះគាត់ទម្រក់ដេកណាស់ ទាល់តែកាលណាក្តៅស្អុះ ទើបច្រានខ្ញុំចេញ ។ រាល់យប់មុនពេលដេក យើងជជែកគ្នារអ៊ូៗ ពីរឿងរ៉ាវកំប៉ិកកំប៉ុកក្នុងវាំង ពីកិច្ចការប្រចាំថ្ងៃ និង ពីកិច្ចការសម្រាប់ថ្ងៃស្អែក រហូតដល់ដេកលក់រៀងខ្លួន ។

ព្រឹកមួយនោះ ខ្ញុំភ្ញាក់ពីដេកតាំងពីព្រលឹមខុសធម្មតា ។ ដោយធាតុអាកាសរងាធ្វើទុក្ខខ្លាំងពេក ខ្ញុំក៏ទាញភួយពី បងរុន មកដណ្តប់ម្នាក់ឯង ស្រាប់តែឃើញមានឈាមប្រឡាក់ភួយមួយដុំ ។ ខ្ញុំភ័យស្លន់ ស្មានថា បងរុន ស្លាប់ ឬ ត្រូវរបួស ក៏តាំងស្រែកឆោឡោ ដើម្បីបង្អើលដាស់អ្នកជិតខាង ។ បងរុន ស្ទុះងើបឡើង, ដល់ឮខ្ញុំនិយាយរឿងនេះប្រាប់ គាត់យកដៃខ្ទប់មាត់កុំឲ្យខ្ញុំនិយាយតទៅទៀត ហើយងើបទៅផ្លាស់សំពត់ចេញភ្លាមមួយរំពេច ។ គាត់បបួលខ្ញុំដេកទៅវិញ នាំបន្ទប់និយាយពីរឿងស្រីទៅបំរើហ្លួង ដែលត្រូវបក់ផ្ចិតគក់ច្របាច់ ទាំងយប់ទាំងថ្ងៃ ព្រមទាំងឲ្យដំបូន្មានថា ថ្ងៃណាមួយខ្ញុំត្រូវរកផ្កា ឬ ផ្លែឈើ ទៅថ្វាយហ្លួង ដើម្បីបានរង្វាន់ខ្លះផង ។ គាត់និយាយទាល់តែខ្ញុំដេកលក់ទៅវិញ ។

កន្លងមក ពីរ-បីថ្ងៃ ស៊ុន និង ខ្ញុំ បានច្បាប់ទៅលេងផ្ទះមួយថ្ងៃ, ពុកក៏បានឈប់ធ្វើការ ប្រុងប្រៀបចេញទៅផ្ទះដែរ ។ ខ្ញុំគ្មានលុយមួយសេនជាប់នឹងខ្លួនសោះ ប៉ុន្តែខ្ញុំប្រាប់ពុកឲ្យទៅផ្សារទិញផ្លែឈើល្អៗ សម្រាប់យកទៅថ្វាយហ្លួង ។ ពុកប្រញាប់រត់ទៅផ្សារ ទិញបានផ្លែទទឹមទុំ ព្រមទាំងខ្ចីថាសប្រាក់របស់ ឪពុកម្តាយស៊ុន មករៀបចំដាក់យ៉ាងត្រឹមត្រូវទៀតផង ។ ត្រឡប់មកវាំងវិញ ខ្ញុំប្រថុយចូលទៅក្នុងប្រាសាទមេខលា ដែលនៅក្នុងនោះ ហ្លួងកំពុងផ្ទុំសោយអាហៀនលើគ្រែប្រកបទៅដោយចម្លាក់ក្បាច់ក្បូរល្អប្រណីត ។ ហ្លួងមើលមកឃើញខ្ញុំអង្គុយត្រង់កន្លៀតក្បែរកញ្ចក់ ក៏សួរទៅពួកស្រីអ្នករៀបចំខ្សៀអាហៀន :

~ មីតូចហ្នឹង វាមករកអី ?

បងរុន ដែលកំពុងអង្គុយបក់ផ្ចិតនៅចុងជើងគ្រែនោះ ទូលហ្លួងភ្លាម :

~ ក្រាបទូល, នាងយ៉ែម ចង់យកផ្លែឈើមកថ្វាយព្រះអង្គ ។

~ អឺ ! ឲ្យវាចូលមក ហើយឲ្យគេយកប្រាក់មួយណែនមកឲ្យវាផង ។

ស្រីម្នាក់ដែលទទួលវេនកាន់កូនសោក្នុងថ្ងៃនោះ នាំយកប្រាក់គ្រប់ចំនួនមកឲ្យខ្ញុំ, ខ្ញុំថ្វាយបង្គំហ្លួង សំដែងទឹកចិត្តត្រេកអរឥតឧបមា ។ លោកសម្លឹងមើលខ្ញុំយ៉ាងយូរ ញញឹមបន្តិចព្រមទាំងមានបន្ទូលថា :

~ ម៉េចក៏គេមិនចុះឈ្មោះវាក្នុងបញ្ជីអ្នកមកបម្រើអញ ? ក្មេងហ្នឹងវាឧស្សាហ៍ណាស់ណា !

~ វានៅក្មេងពេកក្រាបទូល (បងរុន ឆ្លើយ) អាយុមិនទាន់គ្រប់ដប់បួនឆ្នាំស្រួលបួលផង ។

~ បើអញ្ចឹង មីតូចឯងទៅវិញចុះ ហើយនែ៎!... ខំស៊ីបាយឲ្យធាប់ធំឡើង! ។

ខ្ញុំដាយមកកន្លែងដេកវិញ យកលុយលាក់ក្នុងហិបនៅក្បាលដំណេក ដើម្បីទុកឲ្យម៉ែ ។ នៅពេលជួបហ្លួងលើកទីពីរនេះ ខ្ញុំមិនស្លុតភ័យដូចកាលមុនពេកទេ ។ ខ្ញុំចាប់ផ្ដើមនឹកថា មុខការរបស់ហ្លួង មានត្រឹមតែចែកលុយមាសពេជ្រ ឲ្យស្រី និង ក្មេងបំរើព្រះអង្គ ប៉ុណ្ណោះ... ខ្ញុំឧស្សាហ៍ហ៊ានប្រថុយដើរទៅឡេមឡឹមក្បែរប្រាសាទមេខលា ដែលឃើញមានអុជភ្លើងភ្លឺ សប្បាយរីករាយអ៊ូអរជានិច្ចទាំងយប់ទាំងថ្ងៃ ហើយដែលនៅក្នុងនោះ ហ្លួងរស់នៅប្រកបដោយក្ដីសុខកាយសប្បាយចិត្តជាអតិបរមា កណ្ដាលចំណោមស្រីបម្រើស្អាតៗ ដែលត្រូវគេផ្លាស់ប្ដូរយកអ្នកថ្មីមកជំនួសជារឿយៗ ។

ស៊ុន និង ខ្ញុំ មានទម្លាប់ទៅលបមើលកិច្ចការក្នុងប្រាសាទមេខលា ឥតមានខានមួយយប់ណាឡើយ ដោយនាំគ្នាពួនក្បែររានហាលខាងក្រោយ ដែលលយចូលទៅដល់ក្នុងសួនច្បារ ងងឹតចាក់ភ្នែកមិនយល់ ។ ខ្ញុំចំអើតមើល ក្បាលស៊ីងតែមិនដល់ក្ដារក្រាលនៃរានហាលនោះផង ប៉ុន្តែបានស្បែងងងឹត ជួយបិទបាំងមិនឲ្យអ្នកដើរទៅមកកាត់តាមនេះ មើលឃើញឡើយ ។

ហ្លួងសោយបាយតិចណាស់ រវល់តែយកស្លាបព្រាចូកបាយជះចោលទៅលើក្ដារ ជានិមិត្តរូបដើម្បីធ្វើឲ្យរាស្ត្រសម្បូរណ៍ស្រូវ-អង្ករ បរិភោគ ។ មួយថ្ងៃៗ ហ្លួងសោយអាភៀន និង ផ្ទុំវាល់ល្ងាច ដល់ព្រលប់ធំ ទើបតើនឡើងដើម្បីសោយព្រះស្ងោយតែម្ដង ។ ព្រះអង្គ ទ្រង់សោយលើតុ ជួនកាលម្នាក់ឯង ជួនកាលមាន ឃុន ឬ ម៉ម ដែលគាប់ចិត្ត មកអង្គុយកំដរផង ។ ស្ត្រីកូនកាត់ ចិនយួន និង ហ្វីលីពីន ក្រងសក់ទម្លាក់ទៅក្រោយ និង ស្លៀកពាក់តាមរបៀបអឺរ៉ុប ជាអ្នកទទួលថាសប្រាក់ដាក់ម្ហូបពីអ្នកបំរើ យកមករៀបថ្វាយហ្លួង ។ ខ្ញុំសង្កេតមើលឃើញម្ហូបទាំងនោះ ជួនកាលធ្វើតាមរបៀបសៀម ជួនកាលតាមរបៀបចិន ឬ របៀបយួន របៀបបារាំង ក៏មានដែរ ។ ប្រពន្ធហ្លួងដទៃទៀត អង្គុយបត់ជើងលើកន្ទេលក្រាបផ្ទាល់នឹងក្ដារ បរិភោគបាយយ៉ាងស្ងៀមស្ងាត់ ។

ដល់ពេលយប់ជ្រៅ ហ្លួងស្លៀកសារុង និង ដណ្ដប់ជាហ៊ី ចូលទៅអង្គុយកណ្ដាលចំណោមស្រីៗ ស្រែកច្រៀងសក្ដវាទីលេងជាមួយគ្នាយ៉ាងសប្បាយរីករាយ ប៉ុន្តែសម្លេងហ្លួងធំគ្រលួ ឮខ្លាំងលុបអស់សម្លេងស្រី ។ ចំណែក នាម៉ឺន និង ស្រីអ្នកបម្រើ ដែលអង្គុយជុំនៅខាងក្រៅនោះវិញ គេនាំគ្នាស្ដាប់ចម្រៀងនេះធ្វើភ្នែកមមីរ ។

យប់នីមួយៗកន្លងទៅដោយក្ដីរីករាយ ក្នុងការច្រៀងរាំ ក្នុងការជក់អាភៀន ឬ បារី ដែលហ្លួងចែកឲ្យគ្រប់គ្នា គ្មាននរណានឹកខ្វាយខ្វល់ព្រួយបារម្ភពីរឿងអ្វីឡើយ ។

យប់មួយនោះ ខ្ញុំអើតឡេមឡឹមតាមមើល បងរុន ឃើញគាត់លួចបាននំពីរនៅក្ដោតគុកហុចមកឲ្យខ្ញុំ ។ ឆ្ងាញ់ទាំងមាត់, ឆ្ងាញ់ទាំងភ្នែក, ខ្ញុំឈរសប្បាយភ្លើតភ្លើនភ្លេចខ្លួន ស្រាប់តែលេចជើងពីរនៅលើរានហាលរីះជាន់ចំក្បាលខ្ញុំ ហើយភ្លាមនោះ ទឹកនោមក៏បាញ់ច្រូចពីលើមក ទទឹកស្មាខ្ញុំអស់មួយចំហៀង រកតែខ្ញុំគេចចេញក៏ពុំទាន់ ។ ខ្ញុំភ្ញាក់ផង ភ័យផង ស្ទុះថយក្លឹងឥតងាកក្រោយ ។ ពេលនោះ ខ្ញុំឮសម្លេងហ្លួងស្រែកឡូឡាឡើងទាំងកណ្ដាលយប់ស្ងាត់ :

~ មីច្រឡឹមអស់ហ្នឹង វាចង់ឲ្យអញនោមច្រាសក្បាលណាស់ទៅឬអី?

សម្លេងស្រីៗសើចសប្បាយហោកញ្ជៀវសាត់មកដល់ត្រចៀកខ្ញុំ នៅពេលដែលខ្ញុំរត់មកដល់កន្លែងដេក ដើម្បីផ្លាស់សម្លៀកបំពាក់ និង យកសាប៊ូទៅមុជទឹកដុះពកដ្ខួនឲ្យជ្រះចង្រៃ ។



ពេលវេលាកន្លងទៅយ៉ាងឆាប់រហ័ស... ពិធីបុណ្យមួយ ហើយមួយទៀត ចេះតែមានបន្តបន្ទាប់គ្នានៅក្នុងវាំង ហើយឲ្យតែដល់បុណ្យម្ដងៗ ហ្លួងតែងចែកប្រាក់ដល់ ស្រីបំរើ និង ពួករបាំ ឥតដែលខាន ។

ថ្ងៃមួយ ហ្លួងនឹកភ្នកចង់ធ្វើជាអធិបតីក្នុងពិធីកាត់សក់ពួកល្ខោនក្មេងខ្លះៗ នៅក្នុងប្រាសាទមេខលា ។ អ្នកដែលមានសំណាងត្រូវបានគេជ្រើសរើសមកឲ្យកាត់សក់នៅក្នុងឱកាសនោះគឺ គីញ, ម៉ាលួន, ម៉ៃឡុន, ចន្ទ, ឡៃសេន និង ខ្ញុំ ។ ហ្លួងមើលឃើញសក់ប្លុងជុករបស់ខ្ញុំធំជាងគេ ក៏ស្រាយទម្លាក់សំយាកទៅក្រោយខ្នង ។ ទទួលពេលនោះ ពួកព្រាហ្មណ៍ក្រយកកាំបិតកោរមាសមកដល់ពេក ហ្លួងក៏ទឹងតឡូងឡើង ទាញយកកន្ត្រៃមកកាត់ច្រិបសក់ខ្ញុំ ដាច់រធិញរធុញអស់រលីង ។ បន្ទាប់មក ពួកបាគួមកដល់ ចាត់ការកោរសក់ខ្ញុំបង្ហើយ និង ផ្ទុំស័ង្ខប្រសិទ្ធី ។ ហ្លួងឡើងឈរលើតានម៉ា យកទឹកមន្តមកច្រូចដាក់លើក្បាលយើងម្នាក់បន្តិច ។

ពុកខ្ញុំរវល់ធ្វើការ ពុំបានមកមើលពិធីនេះទាន់ពេលវេលានឹងគេទេ មានតែម៉ែម្នាក់ឯងគត់ ដែលបានមកប្រមូលសក់ខ្ញុំ យកទៅរក្សាទុកយ៉ាងម៉ត់ចត់ ។ ក្រោយមក ម៉ែប្រាប់ខ្ញុំថា គាត់យកសក់នោះទៅប្រគេនលោក ទុកសម្រាប់ចងសាស្ត្រាទៅហើយ ។

គេសរសើរសំណាងខ្ញុំគ្រប់គ្នា ព្រោះថា គឺហ្លួងខ្លួនឯង ដែលបានកាត់សក់ខ្ញុំជាសញ្ញាបង្ហាញឲ្យឃើញថា ហ្លួងគាប់ព្រះទ័យនឹងខ្ញុំខ្លាំងណាស់ ។ បន្ទាប់ពីកាត់សក់រួចហើយ ឃុនថាន់ ឃុនព្រះញាតិ និង អ្នកឯទៀតដែលអង្គុយព័ទ្ធជុំវិញយើងនោះ នាំគ្នាបង្វិលពពិល ហុចបន្តគ្នាពីមួយទៅមួយគ្រប់បីជុំ ទើបគេយកអំបោះឆៅមកចងរុំក្បាលយើង ព្រមទាំងហាមថា ទាល់តែគ្រប់មួយខែទើបឲ្យស្រាយចេញ ។ ខាងក្រោយខ្នងយើង មានកូននាម៉ឺនធំៗពីរ-បីនាក់ មកសុំកោរសក់ក្នុងឱកាសជាមួយគ្នានេះដែរ ប៉ុន្តែពួកវាគ្រាន់តែបានពួកព្រាហ្មណ៍កោរឲ្យតែប៉ុណ្ណោះ ។

## នាដ្យការី



**យើង**កាន់តែធំពេញរូបពេញរាងបន្តិចហើយ... គេអនុញ្ញាតឲ្យយើងទុកសក់វែង លែងឲ្យកោរដូចមុនទៀតហើយ...។ យាយចាស់ៗអង្គុយជជែកគ្នាអែនៅតាមកាំជណ្ដើរងើណាក់ឲ្យតែឃើញខ្ញុំដើរទៅជិត គាត់និយាយចំអែចំអន់ភ្លាមថា អាយុប៉ុនខ្ញុំល្មមមានប្ដីហើយ! ខ្ញុំមិនសូវរវល់យកចិត្តទុកដាក់ស្ដាប់សំដីអស់នេះទេ ប៉ុន្តែខ្ញុំចាប់ផ្ដើមយល់យ៉ាងច្បាស់ នូវរឿងរ៉ាវដែលបណ្ដាលឲ្យពួកប្រុសកម្លោះ ដើរក្រឡឹងជុំវិញវាំង ប្រឹងតាមសម្លក់ស្រីៗដូចឆ្កែតាមសម្លក់ឆ្អឹងស៊ុប។

ពេលមួយនោះ ម៉ែនាំខ្ញុំទៅលេងនឹងពួកម៉ាកស្រីគាត់ម្នាក់ ជាអ្នកភ្លេងនៅឯវាំងសម្ដេច ឧបរាជ[៤]។ ចាប់តាំងពីពេលលោកអគ្គមហាសេនា អ៊ុម ជាឪពុកធំខ្ញុំស្លាប់ទៅ ខ្ញុំខានមកលេងវាំងខាងជើងនេះយូរហើយ។

វាំងរបស់ស្ដេចទីពីរនេះ មិនដូចគ្នានឹងវាំងចតុមុខទេ មើលទៅឃើញដូចជាវាំង "អ្នកស្រែ" អញ្ចឹង។ សួនច្បារមានស្មៅដុះទ្រុបទ្រុល ព្រោះគ្មានអ្នកថែទាំ គ្រឿងតុបតែងមិនហ៊ឺហា ផ្ទះនីមួយៗចង្អៀតមិនខ្ទួនមិនស្លួច របៀបរបប នៃ ពួកនាម៉ឺន និង ពួករបាំ ក៏មិនសូវត្រឹមត្រូវ ក្រឡេកទៅកៀនកន្លៀតណា ក៏ឃើញតែគគ្រិចស្មោកគ្រោកគួរឲ្យខ្ពើម។

នៅទីនេះ មានក្រុមល្ខោនតែមួយគត់ ដែលដឹកនាំដោយព្រះអង្គម្ចាស់ក្សត្រីយ៍ ដ៏ល្បីល្បាញឈ្មោះ វិមធីតា ជាកូនបង្កើតរបស់ សម្ដេចឧបរាជ។ ក្នុងក្រុមល្ខោននេះ នរណាចង់ធ្វើអ្វីក៏ធ្វើទៅ ព្រោះមួយថ្ងៃៗ ម្ចាស់ក្សត្រីយ៍ ចាងហ្វាងនោះ រវល់តែជក់អាភៀនបង្ហុយដូចឪពុកដែរ ហើយបើនិយាយពីរឿងស្រាវិញ ម្ចាស់ក្សត្រីយ៍ ក៏ពុំមែនអន់ប៉ុន្មានដែរ លេងសុទ្ធតែ "សិច" តែម្ដង។ ដល់មានចៅហ្វាយធំជាអ្នកឲ្យឧទាហរណ៍អញ្ចឹង កូនចៅក៏ចេះតែនាំគ្នា ជក់ ផឹក ឬ លេងបៀរប៉ោ តាមតម្រាប់ចៅហ្វាយ ដែលជាហេតុនាំឲ្យកើតការរាយប៉ាយគ្មានសណ្ដាប់ធ្នាប់យ៉ាងនេះ។

នៅពេលដែលដឹងថា ខ្ញុំមកថ្វាយបង្គំម្ចាស់ក្សត្រីយ៍ ពួកគេស្រាប់តែនាំគ្នាផ្អើលឈ្ងោរជកកចំហមាត់មើលមុខខ្ញុំធ្វើភ្លើ ព្រោះពួកគេកម្របានឃើញអ្នករបាំមែនទែន នៅឯវាំងខាងត្បូងនេះណាស់។ នឹកឃើញដល់ពួកអស់ហ្នឹង ខ្ញុំដូចជាខ្មាសគេផ្ទួស។ ម្ចាស់ក្សត្រីយ៍អង្គុយស្ងៀចលើកន្ទេល និយាយសួរខ្ញុំថា តើខ្ញុំចង់មកនៅជាមួយលោកឬទេ?

ខ្ញុំរកមើលមិនឃើញ សម្ដេចឧបរាជ ទេ ប៉ុន្តែកាលពីពេលមកមុនៗ ខ្ញុំធ្លាប់ឃើញ ធ្លាប់ស្គាល់ លោកច្បាស់ណាស់។ លោកមានវ័យចាស់បន្តិចទៅហើយ ព្រមទាំងមានមោឃធំ និង សម្បុរណ៍សាច់ឈាមជាង

[៤] ឧបរាជ នេះ ជាងាររបស់ព្រះបាទ ស៊ីសុវត្ថិ មុនពេលបានឡើងសោយរាជ្យ។



ស្ដេចបង ដែលជាហ្លួងសោយរាជ្យ។ លោកដាក់ធ្មេញភ្លុកពីក្រាស់យ៉ាងល្អប្រណីត ផ្ញើទិញពីអឺរ៉ុបមកបប្ចូរមាត់ធ្លាក់ សក់សក្បុសដូចសំឡី ភ្នែកមុត។

តាមលេចឮពាក្យចចាមអារាមថា សម្ដេចឧបរាជ ដូចជាឆ្កួតឡប់ម្ដងៗផង គឺមានយប់ខ្លះ លោកស្រាតខោអាវ លបរត់ចេញទៅក្រៅវាំងតែម្នាក់ឯង ទាល់តែពួកនាម៉ឺនដេញតាមចាប់ប្រអូសប្រទាញ ទើបព្រមចូលមកវិញ។ លោកមានវ័យចាស់បន្តិចមែន ប៉ុន្តែកម្លាំងលោកនៅមាំមួនល្អណាស់។ គេនិយាយប្រាប់ខ្ញុំថា ល្ងាចមួយនោះ មានបុរសម្នាក់កាន់ថ្មោងធំ ចូលមកអុកឡុកកូនចៅលោកដល់ក្នុងផ្ទៃវាំង លោកក៏ស្ទុះងើបឡើង ប្រើតែខ្សៀអាភៀនប្រយុទ្ធជាមួយជននោះ វាយវាទាល់តែសន្លប់ ហើយបង្គាប់ឲ្យគេយកទៅកាត់កចោលភ្លាមមួយរំពេច។

គេនិយាយពីមាត់មួយទៅមាត់មួយទៀតថា ថ្ងៃណាមួយ សម្ដេចឧបរាជ នឹងបានឡើងសោយរាជ្យនៅវាំងចតុមុខមិនខាន ហើយពួកអ្នកឡេមឡឺមរកបុណ្យសក្តិ ក៏តាំងនាំគ្នាអែបអបយកគាប់គួរតាំងពីឥឡូវ។ នៅជុំវិញហ្លួងចាស់ដែលធ្លាក់ខ្លួនឈឺនោះ ព្រះអង្គម្ចាស់ នាម៉ឺន មន្ត្រី យុន ម៉ម នាំគ្នាជណ្ដើមក្ដើ បុណ្យសក្តិទុកសម្រាប់ថ្ងៃស្អែករៀងៗខ្លួនស្រេចអស់ទៅហើយ។

ការដែល ទូណាម ជាប្រពន្ធគាប់ចិត្តជាងគេ ដាច់ចិត្តបោះបង់ហ្លួងចោល បានធ្វើឲ្យជម្ងឺព្រះអង្គកាន់តែធុនធ្ងរថែមឡើងទៀតជាលំដាប់ រហូតដល់ហ្លួងខ្លួនឯងក៏ដឹងខ្លួនថា មិនអាចរស់បានយូរតទៅមុខទៀតទេ។

ទូណាម ជាកូនអ្នកស្រែសុទ្ធ ប៉ុន្តែបានមកនៅវាំងតាំងពីក្មេង។ គាត់មិនសូវស្អាតប៉ុន្មានទេ ប៉ុន្តែទឹកមុខមានស្នេហ៍អ្វីម្យ៉ាង គួរឲ្យអ្នកផងស្រឡាញ់រាប់អាន រហូតបានឡើងធ្វើជាតួឯកក្នុងក្រុមល្ខោន នៃ យុនថាន់។ ហ្លួងពេញចិត្តនឹងមើលគាត់រាំឥតចេះធុញទ្រាន់ ហើយប្រទាន មាសពេជ្រ លុយកាក់ បំពោរបំពោកឲ្យតែគាត់ម្នាក់ ច្រើនឥតឧបមា។

ប៉ុន្តែ ទូណាម ស្រឡាញ់តែខ្លួនគាត់ប៉ុណ្ណោះ។ ដោយដឹងថា ហ្លួងជិតអស់បុណ្យ គាត់តែងឆ្លៀតពេលចេញទៅក្រៅវាំង ដើម្បីទៅធ្វើឫកម្ញិកម្ញ៉ក់ឌឺត សម្ដេចឧបរាជ នៅឯវាំងខាងជើងនោះទៀត។ សម្ដេចឧបរាជ ឈ្លក់នឹងសម្រស់ ទូណាម ភ្លេចប្រពន្ធចាស់ឈ្មោះ ប្រឹម ដែលជាស្រីសៀមខ្មៅគគ្រិច ហើយបែរមកគាប់គួរជាមួយ ទូណាម រហូតដល់មានសន្យាថា នឹងលើកដំកើងគាត់ឲ្យមានអំណាចលើគេមួយវាំង កាលណាខ្លួនបានឡើងសោយរាជ្យ ទៀតផង។

និយាយពីហ្លួងវិញ ទោះបីឈឺជាប់ដើរមិនរួចយ៉ាងនេះក្ដី ក៏នៅតែឆ្លៀតស៊ើបសួរពីរឿង ទូណាម ជានិច្ច គ្រាន់តែមិនចេញស្ដីថាដូចម្ដេច សុខចិត្តសម្ងំកើតទុក្ខតែម្នាក់ឯង។ ថ្ងៃមួយ លោកប្រើគេឲ្យទៅហៅ ទូណាម មកគាល់ ប៉ុន្តែគាត់នោះចិត្តស្មើងប្រកែកពុំព្រមមក ដែលជាហេតុបណ្ដាលឲ្យហ្លួងខឹងច្រឡោតតូងឡើង បង្គាប់ឲ្យក្រុមវាំងបួននាក់ទៅចាប់ ទូណាម មកធ្វើទារុណកម្ម ចងដាក់ឲ្យដេកផ្កាប់មុខលើដី ហើយយករំពាត់មកវាយរាត់បែកឈាមឡោក។ ទូណាម ឈឺចាប់ខ្លាំងពេក ស្រែកយំពាទីផ្អើលអស់មួយផ្ទៃវាំង គេចេញមកឈរមើលត្រៀបត្រា។ បន្ទាប់មកគេដាក់ច្រវាក់បណ្ដើរគាត់យកទៅឃុំនៅក្នុងសាលាទាលីយក្ស ដែលជាកន្លែងឃុំឃាំងស្រីមានទោស ស្ថិតនៅឆ្ងាយឯចុងសួនច្បារឯណោះ។

ទារុណកម្មបែបនេះ ឧស្សាហ៍មានញឹកញាប់ណាស់។ អនុស្សាវរីយ៍ឃោរឃៅជាងគេដែលខ្ញុំចាំមិនភ្លេចនោះ គឺថ្ងៃមួយគេចាប់យកស្រីរបាំម្នាក់ឈ្មោះ លន្ធា យកទៅធ្វើទោស។ នាងនោះមានផ្ទៃពោះច្រើនខែហើយ ពុំអាចដេកផ្កាប់មុខកើត គេក៏ជីកដីឲ្យក្រហូងត្រង់ពោះហើយច្រានឲ្យដេក ដើម្បីគេធ្វើទារុណកម្មយ៉ាងអមនុស្សធម៌ក្រៃលែង ឥតមានក្ដីមេត្តាករុណាបន្តិចបន្តួចសោះ។

ការផ្តន្ទាទោសចំពោះនូណាម គឺជាឧទាហរណ៍សម្រាប់បន្ទាចក្មេងជំនាន់ក្រោយ កុំឲ្យយកតម្រាប់តាម។ និកឃើញដល់រំពាត់ផ្តៅផងមាសនេះ ខ្ញុំខ្លាចញ័រសាច់ សូម្បីសព្វថ្ងៃនេះដែលខ្ញុំចេញផុតពីវាំងមកហើយក្តី ក៏ខ្ញុំនៅតែនឹកខ្លាចជានិច្ច។

ជីវភាពនៅក្នុងវាំង ប្រែជាស្រពាប់ស្រពោន លែងមានរាំច្រៀងសប្បាយហ៊ោកញ្ជ្រៀវអ្វីទាំងអស់។ គេឃើញតែព្រះសង្ឃគង់តម្រៀបជាជួរជុំវិញក្រឡាបន្ទំ លើកផ្លិតបាំងភ្នែក សូត្រធម៌ទាំងយប់ទាំងថ្ងៃ។ ទាល់តែដល់ពេលនេះទើបហ្លួងអាច យល់ និង ឃើញនូវសេចក្តីស្មោះត្រង់ពិតប្រាកដ នៃ យុទថាន់ និង យុទព្រះញាតិ ដែលមកចាំគាល់ទាំងយប់ទាំងថ្ងៃ ឥតគិតនឿយហត់។ក្សត្រី, ក្សត្រា, អស់អ្នក, អស់នាង ក៏នាំគ្នាមកជួបជុំភ្នែកសំឡឹងឆ្ពោះទៅក្រឡាបន្ទំឥតប៉ប្រិចដែរ។

ដល់ពេលស្ងួឈាមមែនទែន ហ្លួងបង្គាប់ឲ្យគេលើកលោកដាក់លើគ្រែស្នែង សែងចេញទៅក្រៅទាំងយប់អាធ្រាត្រងងឹតឈឹង ដើរកាត់ស្មៅព្រៃពីមពើមអស់ចិត្ត ទើបបង្គាប់ឲ្យត្រឡប់មករាជមន្ទីរ ហើយឲ្យគេផ្ទេរលើកដាក់ទៅលើកៅអីមានកង់ រុញទៅ រុញមក ឥតឈប់ឈរ។

សភាពស្ងប់ស្ងាត់គ្របដណ្តប់ពេញផ្ទៃវាំងទាំងមូល... គេឮតែសូរសម្លេងព្រះសង្ឃសូត្រគាថា យ៉ាងលន្លង់លន្លោចគួរឲ្យស្រងេះស្រងោចក្រៃលែង និង សម្លេងមនុស្សខ្សិបខ្សៀវគ្នា។ ហ្លួងលើកដៃឡើងប្រាប់ឲ្យគេនៅស្ងៀម ហើយមានបន្ទូលខ្សាវៗថា :

~ អញអត់ភ្លេចទេ !

បន្ទាប់មក លោកហៅម៉មសួន មកប្រាប់ឲ្យទៅយកលុយប្រាំរៀលមកថ្វាយ ប៉ុន្តែម៉មសួន ទើបនឹងចូលទៅជិតដល់គ្រែ លើកជើងពានថ្វាយ ស្រាប់តែហ្លួងទន់ដៃទម្លាក់លុយទៅលើខ្នើយ ហើយមាត់និយាយថាដូចម្តេចក៏ព្រិច ងាកបត់កមកខាងឆ្វេងបន្តិច ហើយផុតដង្ហើមទៅ។

រំពេចនោះ សម្លេងទ្រហោយំក៏ផ្ទុះឡើង ទ្រហឹងអឺងអាប់រកស្តាប់ទិសតំបន់អ្វីមិនឮ។ ចំណែកឯក្មេងៗឃើញតែគៃយំគ្រប់គ្នា មិនយល់រឿងអីសោះ ក៏កើតក្តីភិតភ័យស្រែកយំង៉ាំងនឹងគេដែរ ព្រមទាំងស្រែករក ម៉ែ-ឪជួយ។

យើងរត់ប្រសេចប្រសាចតម្រង់ទ្វារព្រលប់ ប៉ុន្តែភ្លាមនោះទ្វារត្រូវគេបិទជិត ហាមមិនឲ្យចេញជាដាច់ខាត។ ពួកស្រីធំៗភ័យច្រួលច្របល់ជាងគេ រត់ពីកន្លែងមួយទៅកន្លែងមួយ ស្រែកឆោឡោថា :

~ បន្តិចទៀតគេនឹងចូលប្លន់វាំង ហើយស្ត្រី ទាំងក្មេង ទាំងចាស់ មុខជាត្រូវទាហានចាប់រំលោភលើរូបកាយ និង សម្លាប់ចោលទាំងអស់គ្នាមិនខាន។ ប្រហែលជាគ្មាននរណាម្នាក់បានរួចរស់ទៅជួបមុខ ម៉ែ-ឪវិញទេ ពីព្រោះស្តេចសុគតហើយ យើងអត់មានស្តេចគ្រប់គ្រងមើលខុសត្រូវដូចមុនទៀតទេ !។

♥ ♥

♥



ខ្ញុំពុំបានចាំសព្វគ្រប់ថា ក្នុងពេលចលាចលនេះ កើតមានរឿងរ៉ាវដូចម្តេចខ្លះទេ។ តាមឮ គេនិយាយថា ពួកបារាំងបាននាំគ្នាមកគំនាប់សព ស្តេចសុវណ្ណកោដ្ឋ និង យកមកុដរាជ្យពីក្នុងទីនាំងទេវាវិនិច្ឆ័យ ទៅយាង សម្តេចឱបរាជ ពីវាំងខាងជើង ឲ្យមកគង់នៅវាំងចតុមុខវិញ។

គេឲ្យយើងស្លៀកពាក់ស ព្រមទាំងកោរសក់យើងទាំងអស់គ្នា ទាំងអ្នករបាំ, ទាំងអ្នកបំរើផ្ទាល់។ បន្ទាប់មក មានធ្វើពិធីផ្សេងៗទៀត ដែលមានតែចាស់ទុំប៉ុណ្ណោះត្រូវទៅធ្វើ ហើយព្រះសង្ឃសូត្រព្រះធម្ម ទាំងយប់ទាំងថ្ងៃ នៅជុំវិញកោដ្ឋមាស ដែលនៅក្នុងនោះគេបញ្ចុះសពហ្លួង ដោយយកកាំបិតកាត់ផ្តាច់ សរសៃដៃ សរសៃជើង ដើម្បីស្រណុកទាញឲ្យអង្គុយបៀបលុតជង្គង់សំពះ។ កោដ្ឋនេះដឹកលំនៅក្នុងប្រាសាទព្រះធម្មសង្វេគ ទុកសម្រាប់ធ្វើបុណ្យបូជានៅឆ្នាំក្រោយ។

លោកមហាមន្ត្រី អ្នកទទួលភារៈមើលរបៀបរៀបរយក្នុងវាំង បានបើកទ្វារវាំងអនុញ្ញាតឲ្យ ឪពុក-ម្តាយពួកល្ខោន ចូលមកមើលខុសត្រូវ និង ចាត់ចែងរឿងកូនចៅរៀងៗខ្លួន។ ម៉ែចូលទៅគាល់ យុទព្រះញាតិដើម្បីនិយាយចង់យកខ្ញុំទៅនៅផ្ទះវិញ ឲ្យបានទាន់មុនពេលស្តេចថ្មីឡើងសោយរាជ្យ ពីព្រោះខ្ញុំនៅបំរើហ្លួងអស់ពេលជាងមួយឆ្នាំហើយ មិនដែលឃើញបានប្រយោជន៍អ្វីចំពោះខ្លួនឯង ឬ បានប្រាក់កាសគ្រាន់នឹងជួយទប់ប្រាក់ខែបន្តិចបន្តួចរបស់ពុកសោះ។ ប៉ុន្តែ យុទ ប្រកែកញ៉ាញ ពុំព្រមឲ្យខ្ញុំចេញពីវាំងជាដាច់ខាត សុខចិត្តចំណាយលុយហោប៉ៅឯង មួយរយរៀល ឲ្យម៉ែយកទៅជួសជុលផ្ទះ ព្រមទាំងខំលួងលោមអង្វរខ្ញុំទន់ឆ្អឹង។

ហ្លួងសុគតមិនបានប៉ុន្មានផង សម្តេចឱបរាជ ដោយមានកូនចៅនាម៉ឺន និង ពួកបារាំងមួយហ្វូងធំហែរហមជូនដំណើរផង ក៏បើឥវ៉ាន់មកនៅក្នុងវាំងចតុមុខ ដែលជាលំនៅសម្រាប់ហ្លួងសោយរាជ្យនេះវិញ។ សម្តេចឱបរាជ ស្រមៃចង់សោយរាជ្យយូរណាស់មកហើយ ដល់បានសំរេចដូចបំណងអញ្ចឹង វារទៅជាសប្បាយចិត្ត ញញឹមស្ញេញបិទមាត់មិនជិត លេចធ្មេញភ្លុកពីក្រោសមកដូចចង្កូមយក្ស។

បើតាមខ្ញុំស្មានមើលទៅ ពេលនេះប្រហែលជាចូលដល់ខែពិសាខហើយ ពីព្រោះខ្ញុំឃើញដើមស្វាយនៅក្នុងសួនច្បារវាំង ចាប់ផ្តើមមានផ្លែទុំគ្រប់តែដើម។ ប៉ុន្មានថ្ងៃក្រោយដែល ស្តេចសុវណ្ណកោដ្ឋ ចូលទីវង្គតទៅ ស្រាប់តែកើតមានខ្យល់ព្យុះសង្ឃរាដ៏ខ្លាំងក្លាអស្ចារ្យ ដែលមួយអាយុមនុស្សកម្រនឹងមាននរណាបានជួបប្រទះណាស់ ដូចជាប្រផ្នូលប្រាប់ឲ្យដឹងថា នឹងកើតមានចលាចលវឹកវរក្នុងប្រទេសខ្មែរ ចាប់តាំងពីដើមរជ្ជកាលថ្មីនេះទៅតែម្តង។

ពេលនោះ ជាឱកាសដែលគេត្រូវផ្ទេរទឹករងៃហូរចេញពីសពហ្លួងដាក់ក្នុងកោដ្ឋមាសនោះ បញ្ចូលទៅក្នុង

ថ្មមួយបិទជិត ដើម្បីយកទៅចោលកណ្តាលទន្លេប្អូនមុខ ។ ក្បួនដង្ហែរថ្ងៃទឹករីង មានក្បូន នឹង ទូកជាច្រើន ហែរអធិកអធមចេញពីកំពង់ផែទៅ ទោះបីនាម៉ឺនចាស់ទុំមើលឃើញមេឃបែបមិនស្រួល ខំទទូចឃាត់មិនឲ្យចេញទៅយ៉ាងណា ក៏គ្មាននរណាស្តាប់ដែរ ។ ពិធីទម្លាក់ថ្មក្នុងទឹកមិនទាន់ទាំងចប់ស្រួលបួលផង ខ្យល់ព្យុះក៏ចាប់បោកបក់ឡើងពេញមួយកំណាត់ថ្ងៃ ហើយមួយយប់ទៀត បន្តរហូតដល់ស្អែកឡើងទើបស្ងប់ទៅវិញ ។

ទឹកទន្លេដែលទើបនឹងបានទទួលសាច់ឈាមស្តេចខ្មែរថ្មីៗនេះ ក៏ចាប់ផ្តើមហក់កញ្ជ្រោលបោកបាចបង្កើតជារលកធំៗប៉ុនរលកសមុទ្រ វាយផ្ទប់ច្រាំងបាក់ដីទាំងផ្ទាំង ។ កប៉ាល់លិចលង់ ទូកត្រូវខ្យល់វាយខ្ទាតឡើងដល់គោក ស្លាប់ជីវិតមនុស្សអស់ជាច្រើន ។ ទូកធំៗរបស់ហ្លួងដែលកំពុងតែឡើងអ្វូ ក៏ត្រូវខ្យល់ព្យុះវាយពន្លិច ដួលដេករង្វេករណែលពេញឈ្នូរខ្សាច់ដែរ ។

នៅក្នុងវាំង ផ្លែស្វាយពៅខ្ចីនៅឡើយ ជ្រុះបាចសាចដូចគ្រាប់ភ្លៀងមកលើស្មៅ ។ ដើមគគីរដើធំសម្បើមមួយ នៅក្រោយទីតាំងទេវាវិនិច្ឆ័យ រលើងគល់រលំសង្កត់បាក់របងប្រាសាទបាញ់យ៉ុង អស់មួយចំណែក ។ យើងទាំងអស់គ្នាយល់ថា ព្រឹត្តិការណ៍ចម្លែកបែបនេះ ពិតជាកើតឡើងដោយសារកំហឹងព្រះអាទិទេពពិតប្រាកដណាស់ ។

ចាប់តាំងពីពេលនោះមក រៀងរាល់ឆ្នាំ ទឹកទន្លេមេគង្គតែងហូរនាំយកដីច្រាំងទាំងផ្ទាំងៗទៅជាមួយ ដែលជាហេតុធ្វើឲ្យចម្ងាយពីមាត់ទន្លេមកកំផែងសីមា[៤] កាន់តែរួញខ្លីជាលំដាប់ ហើយថ្ងៃណាមួយទន្លេមេគង្គក៏ប្រហែលជានឹងលេបត្របាក់វាំងទាំងមូល ដែលជាជម្រកដ៏សុខសាន្ត នៃ ពពួកស្តេចខ្ជិលច្រអូស និង នាម៉ឺនឡេមឡឺម គិតតែប្រយោជន៍ផ្ទាល់ខ្លួន ដើម្បីជាកិច្ចសងសឹកជួសទឹកចិត្តក្តៅក្រហាយ នៃ រាស្ត្រខ្មែរ ដែលធ្វើវាសនាលើពួកទាំងនោះ ហើយបែរជាត្រូវពួកនោះ នាំឲ្យជួបតែនឹងទុក្ខវេទនាឥតស្រាកស្រាន្ត ។

ជាពិសេសទៅទៀត ក្នុងឆ្នាំរោងនោះ ទឹកទន្លេជន់លិចអស់ដំណាំដាំដុះ ត្រូវនឹងឆ្នាំមុនដែលរីងរាំង ធ្វើស្រែមិនបានផលផង រាស្ត្រក៏រឹតតែវេទនាណាស់ទៅទៀត ។ នៅជុំវិញវាំងដែលពោរពេញទៅដោយមនុស្សខ្វះសមត្ថភាព អំពើអយុត្តិធម៌ អំពើបាប និង ការលបលួចសាហាយស្មន់នឹងគ្នានេះ រាស្ត្រត្រូវរស់នៅវេទនាអត់ឃ្លានដូចសត្វធាតុ ឯការអនាថា គ្មាននរណាមើលខុសត្រូវ ព្រោះហ្លួងប្រចាំថា ឲ្យបារាំងមើលរាស្ត្រ បារាំងថា ហ្លួងទេដែលជាអ្នកត្រូវគ្រប់គ្រងរាស្ត្រ សម្រេចសម្រួចទៅ គ្មាននរណាដឹងឮអ្វីទាំងអស់ ។

ប៉ុន្តែ មុនពេលកើតមានព្រឹត្តិការណ៍អស់នេះ គឺគ្រាន់តែហ្លួងសុគតភ្លាម លោកមហាមន្ត្រីដោយមានបារាំងម្នាក់ ក្បាលទំពែក ភ្នែកធំមូលដូចត្រីស្លោរ ជូនដំណើរផង បានចូលមកក្នុងវាំង បើករឹកកាយទូរដាក់សម្បត្តិហ្លួង ប្រមូលយកមាសពេជ្រ លុយកាក់ទាំងអស់ ហើយប៉ុន្មានថ្ងៃក្រោយមក ស្រាប់តែអ្នកទាំងពីរមានលុយដើរចងការពាសវាលពាសកាលតែម្តង ។

សម្បត្តិហ្លួងមួយចំណែក ត្រូវលោកចែកទៅឲ្យកូនចៅនិងអ្នកបំរើនៃបទិត្យទឹកក្តៅទឹកត្រជាក់ ក្នុងរវាងប៉ុន្មានខែមុនពេលសុគត ។ សំបុត្រចែកកេរ្តិ៍មរតកមួយ ដែលគេយកទៅថ្វាយហ្លួងស៊ីញ៉េនៅពេលដែលលោកកំពុងឈឺជាប់លែងដឹងខ្លួនដឹងប្រាណទៅហើយនោះ ត្រូវគេយកមកអនុវត្តតាមឥតខ្ចោះ ម្ល៉ោះហើយកូនស្តេចខ្លះ និង អ្នកខ្លះទៀត គ្មានជាប់ឈាមព្រះញាតិវង្សានុវង្សអ្វីនឹងគេបន្តិចបន្តួចសោះ ក៏ស្រាប់តែបានទទួលមរតកច្រើនអស្ចារ្យ ចំណែកឯអ្នកខ្លះទៀត បែរជាវិនាសហិនហោចអស់ផ្ទះអស់សម្បែង ជាហេតុបណ្តាលឲ្យកើតមានការច្រណែនឈ្នានីសគ្នាត្រឡប់ត្រឡិន ។ ស្រីបំរើ និង ពួករបាំ ក្តៅក្រហាយណាស់ដោយខ្លួនម្នាក់ៗបានទទួលតែប្រាក់ពីរ-បីរៀល ប៉ុណ្ណោះ ក៏តាំងនាំគ្នាទន្ទេញជាប់នឹងមាត់ថា គេចូលមក

[៤] កំផែងវាំង ។



ប្លន់វាំង ។ ប៉ុន្តែរឿងចលាចលទាំងនេះ ត្រូវស្ងប់ស្ងាត់ទៅវិញ នៅពេលដែលកើតមានរឿងថ្មីមួយទៀត ។

លោកស្មៀនឡៀប កំពៀកសៀវភៅបញ្ជីប្អូនក្បាល ដើរកោះហៅអ្នករបាំទាំងអស់មកសួរ តើនរណាចង់ចេញពីវាំង ? នរណាចង់នៅតទៅទៀត ? ភាគច្រើនសម្រេចចិត្តឈប់នៅ ហើយត្រូវគេលុបឈ្មោះចេញពីបញ្ជីឈប់ឲ្យស៊ីប្រាក់ខែវាំង ។ ចំពោះអ្នកណាព្រមនោះ ថីឡៀប សម្លឹងមើលតាំងពីក្បាលដល់ចុងជើង ទើបគាត់សំគាល់ថា ៖ មាឌធំ, ក្បាលទេវតា, រាងទាប, ដើមទ្រូងកិន្នរី, ស្អីអញ្ចឹងតរហូតមក ។ ដល់វេនខ្ញុំ, ខ្ញុំឆ្លើយថាព្រមនៅ ថីឡៀប ក៏និយាយថា :

~ អ្នករបាំ, ក្បាលព្រហ្ម (ហើយសរសេរពាក្យនេះចុះក្នុងបញ្ជី) ។

សំដីនេះ ធ្វើឲ្យខ្ញុំហ៊ឺហាក្នុងចិត្តមិនតិចទេ ។

តន្ត្រីការិនី




Musiciennes

និយាយពីហ្លួងថ្មីនោះវិញ ហាក់ដូចជាមិនទាន់ជឿថា ខ្លួនឯងបានឡើងសោយរាជ្យជាស្ដេចផែនដី មិនទាន់ជឿថា វាំងចតុមុខនេះជារបស់ខ្លួនផងទេ ។ លោកធ្វើឫករញ្ជាក់រញ្ជ័រគួរឲ្យចង់សើច ឃើញបន្ទប់រៀបចំស្អាតបាត ខំឈរមើលឆ្លុះខ្លួន ឃើញកម្រាលព្រំ ឃើញខ្នើយកំណាត់ស្អាតៗ មិនហ៊ានអង្គុយលើ ខ្លាចប្រឡាក់ ព្រមទាំងចេះតែអើលខ្មាស ខ្លាចខ្មោចហ្លួងសុវណ្ណកោដ្ឋជាបងឯងនោះ តាមលង ។

បន្ទាប់មក គឺកូនចៅម្ចាស់ក្សត្រីវិមធីតា មានស្រីបំរើចាស់ៗគគ្រិចស្មោកគ្រោក ពួករបាំស្លៀកពាក់រយ៉ីរយ៉ៃ ហ្លួងកូនស្ដេច និង អ្នកបំរើ ដែលលើកគ្នាពីវាំងខាងជើង ចូលមកលុកលុយវាំងចតុមុខ ដោយម្នាក់ៗមានវេចស្ពាយកន្ទេលរហែក តុកោអីកញ្ចាស់បាក់បែក និង កន្ត្រៃស្លាក់កំពិតកំពៀរមកជាមួយផង ។ ពួកអស់នេះ គ្រាន់តែឃើញរបៀបតុបតែងវាំង ក៏តាំងនាំគ្នាជញ្ជក់មាត់សរសើរសប្បាយចិត្តរីកថ្លើមប៉ុនចង្អេរ ។ ជួនកាលខ្ញុំដើរជល់កូនស្ដេច ដែលខ្ញុំស្មានថាជាពួកកូនចៅ[៦] កំពុងឈរយាមនោះ ទាល់តែចង់ដួលផ្ងារក្រោយ ឬ ដើរជាន់ដៃកូនស្ដេចតូចៗដែលប្រឡែងគ្នាដេកពេញកណ្ដាលផ្លូវ បណ្ដាលឲ្យវាយំថ្លង់រកស្ដាប់ទិសតំបន់អ្វីមិនឮ ។

យូរណាស់ទម្រាំនឹងពួកអស់នេះ ទម្លាប់ខ្លួនបានជាមួយជីវភាពថ្មី ដែលសម្បូរណ៍សប្បាយជាងកាលរស់នៅឯវាំង សម្ដេចឧបរាជ ។ ហ្លួងថ្មីក៏កាន់តែស៊ាំជាមួយការរស់នៅក្នុងបន្ទប់ថ្មី នៃ ទីនាំងមេខលា និង ប្រាសាទបាញ់យ៉ុងដែរ ។ គេអញ្ជើញ យុនថាន់ ឲ្យចេញពីផ្ទះនៅក្បែរទីនាំងមេខលា ដើម្បីទុកកន្លែងនេះឲ្យម្ចាស់ក្សត្រីវិមធីតា នៅម្ដងវិញ ។ ម្ល៉ោះហើយ យុនថាន់ត្រូវប្រមូលទ្រព្យសម្បត្តិដ៏ច្រើនមហិមារបស់គាត់ចាកចេញពីវាំង ទៅសង់ផ្ទះថ្មីមួយទៀតនៅខាងត្បូងទីក្រុង ត្រង់ម្ដុំក្បែរវត្តស្វាយពពែ ។ នៅទីនោះ គាត់បានចំណាយសម្បត្តិផ្ទាល់ខ្លួនកសាងវត្តមួយ សម្រាប់ជាកុសលទៅអនាគតជាតិ ដោយយកឈ្មោះគាត់ដាក់ជាឈ្មោះវត្ត គឺវត្តថាន់ សព្វថ្ងៃនេះឯង ។

យុនព្រះញាតិ គ្មានសម្បត្តិសម្បូរណ៍ហូរហៀរដូច យុនថាន់ ទេ ម្ល៉ោះហើយផ្ទះគាត់ក៏មិនស្ងៀវហ៊ីហារគួរឲ្យនរណាចង់ដណ្ដើមយកដែរ ។ គាត់ប្រគល់កូនល្មោនផ្ទាល់ខ្លួនទាំងអស់ថ្វាយហ្លួងថ្មី ដើម្បីយកចិត្តកុំឲ្យគេដេញចេញពីវាំង ហើយរស់នៅក្នុងសភាពក្រតោកយ៉ាក គ្មាននរណានឹកនារាប់រករហូតទល់ថ្ងៃស្លាប់ ។ រឿងរ៉ាវ ស្ទើរកំសត់ ស្ទើរកំប្លែង ចេះតែកើតមានប្លែកៗគ្នារាល់ថ្ងៃនៅក្នុងវាំង ។

ពួកបារាំងមាននៅត្រៀបត្រា ចាំជួយជ្រោមជ្រែងហ្លួងឲ្យឡើងកាន់អំណាចជាស្ដេចផែនដី គឺគេយក

[៦] ពួកស្រីៗអ្នកលើកបាយទឹកបំរើហ្លួង ។



ទាហានមកឲ្យយាមការពារ និង ធ្វើឫកជាគោរពកោតខ្លាចហ្លួងខ្លាំងណាស់ ដើម្បីជាកិច្ចលើកទឹកចិត្តហ្លួងក្នុងពេលរង់ចាំទម្រាំដល់ពេលធ្វើបុណ្យរាជាភិសេកតាមទំនៀមទម្លាប់ ។ គេខិតខំពន្យល់ហ្លួងកុំឲ្យដើរលេងជើងទទេ លើកម្រាលព្រំនៅក្នុងបន្ទប់ទទួលភ្ញៀវ គេទិញស្បែកជើងឃ្លុប ស្រោមជើង អាវស ថ្វាយហ្លួង គេពន្យល់ហ្លួងឲ្យឈប់ភ័យពីរឿងជំពាក់ប្រាក់គេ និង ហាមមិនឲ្យទៅជាស់ទ្វារចៅកែចិនខ្ចីលុយទាំងយប់អាធ្រាត្រ ដូចពីមុនទៀត ។ ហ្លួងមិនបាច់ភ័យព្រួយពីរឿងអ្វីទៀតទេ ចាំតែសោយរាជ្យទៅបានហើយ ដល់ពេលដាច់ខែ គេបើកប្រាក់ខែ បួនម៉ឺនរៀល មកថ្វាយរាល់ខែ ។

ឆ្លៀតឱកាសកើតការវឹកវរនៅដើមរជ្ជកាលថ្មីនេះ ពួកអាណាព្យាបាលបារាំង នាំយកសំបុត្រស្នាមជាច្រើន ដែលគេរៀបចំធ្វើតាំងពីច្រើនឆ្នាំណាស់មកហើយនោះ មកសុំឲ្យហ្លួងស៊ីញ៉េ ដើម្បីជាថ្នូរក្នុងការដែលគេជួយជ្រោមជ្រែងឲ្យបានឡើងសោយរាជ្យ ។ សំបុត្រស្នាមទាំងនេះ ហ្លួងស៊ីញ៉េទាំងមិនយល់សេចក្ដីគេថាម៉េចផងទេ ។ មួយថ្ងៃៗ លោករវល់តែបើកកាយ ថតតុ ថតទូ ស្រាប់តែថ្ងៃមួយប្រទះឃើញលិង្គកៅស៊ូមួយ នៅក្នុងថតតុ ដូចបេះបិតនឹងប្រដាប់មែនទែន រឹងគួរឲ្យខ្លាច ប្រកបដោយរោមពណ៌ទង់ដែង មើលមួយភ្លែតស្មានថា របស់នេះត្រូវគេកាត់យកមកពីខ្មោចបារាំងណាម្នាក់ ដែលត្រូវគេសម្លាប់ចោលតាមបញ្ជាហ្លួងចាស់ ។

របស់ចម្លែកអស់នេះ ធ្វើឲ្យហ្លួងសប្បាយចិត្តរកអ្វីមកប្រៀបស្មើគ្មាន ។ លោកខំសួរឲ្យគេពន្យល់ពីរបៀបធ្វើឲ្យដង្កាល់អគ្គីសនីរលត់ ពីរបៀបបើកទឹកម៉ាស៊ីន លោកស្ទាបអង្អែលខ្នើយស្លូត្រ និង អង្គុយទទោកជើងលើកៅអីភ្លើងទិញមកពីអឺរ៉ុប ញញឹមធ្លាក់បបូរមាត់ស្លែស ចេញធ្មេញភ្លុកទាំងពីរក្រោស ។ តើមានប្រយោជន៍អ្វីនឹងមើលសេចក្ដីក្នុងសំបុត្រ ដែលបារាំង "ជានុ ជាម៉ែ" យកមកថ្វាយទៀតនោះ ? ហ្លួងស៊ីញ៉េខ្វាច់ ព្រមទាំងនិយាយថា មែរស៊ី ! ។

ជួនកាល ហ្លួងដូចជាភ្ញាក់ខ្លួន នឿយណាយនឹងពួកបារាំងដែលដណ្ដើមយកអំណាចអស់រលីង ធ្វើអ្វីក៏ចាំតែធ្វើតាមបញ្ជាគេ និង ជាពិសេសទៅទៀត ពួកស្បែកសនេះ ពូកែសុំមិនចេះឆ្អែតឆ្អន់សោះ ។ សូម្បីតែបញ្ចើលុយកាក់ផ្ទាល់ខ្លួន ក៏គេមិនឲ្យកាន់កាប់ខ្លួនឯងដែរ ដាច់ខែ ស្មៀនបើកយកមកថ្វាយគ្រប់ចំនួន ហើយបើចង់ប្រទានរង្វាន់ឲ្យនរណា ឬ ទិញរបស់ប្រើប្រាស់បន្តិចបន្តួច ទាល់តែសុំបារាំងជាអ្នកចាំត្រួតត្រានោះ ឲ្យគេយល់ព្រមសិន ។ ដល់ឃើញអញ្ជឹង លោកនឹកស្ដាយ ចង់ទាមទារយកអំណាចមកវិញខ្លះដែរ ប៉ុន្តែហួសពេលទៅហើយ ។

ទស្សនីយភាពក្នុងវាំងដែលធ្លាប់តែរុងរឿងនោះ ក៏ប្រែជាស្រពាប់ស្រពោនគួរឲ្យអនិច្ចា ! សភាពគគ្រិចស្មោកគ្រោក រាតត្បាតសព្វទីកន្លែង ដែលកូនចៅម្ចាស់ក្សត្រីវិមធីតា រស់នៅ ។ គេស្ដោះទឹកមាត់ញើសសម្បោរ តែពីសតែពាស យកប្រហុកមកទុកដល់ក្រោមបង្អួចប្រាសាទបាញ់យ៉ុង ធំក្លិនស្អុយស្ទើរទ្រាំពុំបាន ។ ស្រីអ្នកល្អជា គេចេញពីវាំងអស់ទៅ ហើយអ្នកនៅសល់ទាំងប៉ុន្មាន បើចង់បានមុខងារថ្លៃថ្នូរនៅក្នុងក្រុមរបាំតែមួយគត់របស់ម្ចាស់ក្សត្រីនោះ ទាល់តែចេះតម្រូវខ្លួនរស់នៅតាមរបៀបថ្មី គឺចេះសរសើរលើកជើងម្ចាស់ក្សត្រី ចេះរៀបចំខ្សៀអាកៀនថ្វាយ ដូចជាថ្វាយហ្លួងបិតាដែរ ឬ ចេះចាក់ស្រា "សិច" បំពេញកែវ ។

ម្ចាស់ក្សត្រី អង្គុយលើកន្ទេល ឬ លើគ្រែ កណ្ដាលរង់ពួកល្មោន និង អ្នកបំរើ ក្នុងផ្ទះយុនថាន់ ដែលប្រែជារាយប៉ាយគ្មានសណ្ដាប់ធ្នាប់ ហើយនាំគ្នា ស៊ី ផឹក ជក់ លេងបៀរ ឬ ប្រឡែងគ្នារបៀបប្លែកគួរឲ្យសង្ស័យ គឺ អង្អែល ច្របាច់ដោះ ពួកក្មេងស្រីជំទង់ ។

បើអង្គុយជិតម្ចាស់ក្សត្រី រហូតសារុងកុំធ្វើដឹងខ្លួន មិនបាច់ពាក់អាវទេ ដណ្តប់តែផាហ៊ុំស្តើងបានហើយ ហើយគិតតែចាក់ស្រាបំពេញកែវថ្វាយទៅ នោះទើបបានគាប់គួរ។ កាលណាគេផឹកស្រាស្រវឹងហើយ គេផ្តួលដេករង្វេករណែលលើកម្រាល រហូតសារុងស្រាតនៅខ្លួនទទេ។ ប៉ុន្តែ ដូចជាស្រួលម្យ៉ាងដែរ ព្រោះថាផ្ទះហ្នឹង នរណាចង់ចេញចូលស្មើណាក៏បាន ទ្វារបើកចំហជានិច្ច មកប្រទះឃើញអី ស៊ីហ្នឹងទៅ ហើយពួកល្ខោនក៏គ្មានរវល់ធ្វើអ្វី ក្រៅពីផ្កាប់ផ្ងួនចៅហ្វាយថ្មីនេះដែរ។

យ៉ាន និង ខ្ញុំ យើងមិនសូវចូលចិត្តទៅរីមរាមក្បែរហ្នឹងទេ។ ខ្ញុំបានទាំងនិយាយប្រាប់ពុកសព្វគ្រប់ពីរឿងរ៉ាវនៅក្នុងវាំងផង ប៉ុន្តែពុកបង្គាប់ថា ឲ្យទ្រាំបន្តិចទៅ ក្រែងលោវាបានធូរស្រាលឡើងវិញ ហើយបើយ៉ាងម៉េចៗ គាត់នឹងមកយកខ្ញុំទៅនៅផ្ទះវិញក្នុងពេលឆាប់ៗនេះ។

ចាប់តាំងពីពេលដែល ស៊ុន គេបែកពីខ្ញុំទៅបំរើម្ចាស់ក្សត្រី ដើម្បីប្រាថ្នាបុណ្យសក្តិនោះមក មានតែ យ៉ាន គួរបាំខ្ញុំទេ ដែលបានក្លាយមកជាមិត្តដ៏ល្អម្នាក់។ វាជាកូនទាយទាហានហ្លួង ប៉ុន្តែកំព្រា ឪពុកម្តាយស្លាប់ចោលតាំងពីតូច គឺធ្លាប់ជាកូនអ្នកមានពូជអំបូរថ្លៃថ្នូរនឹងគេដែរ ម្ល៉ោះហើយវាមិនសុខចិត្តទៅឡូកឡំជាមួយពួកកូនចៅម្ចាស់ក្សត្រីជាដាច់ខាត។ ធ្វើម្តេច គ្នាក្រ គ្មានទីពឹង ចេះតែទ្រាំនៅក្នុងវាំងទៅ។ យ៉ាន ថែមទាំងចេះសន្សំប្រាក់ខែដប់រៀលនោះ ទុកបានយ៉ាងច្រើនទៀតផង។ ចំណែកខ្ញុំវិញ ប្រាក់ខែប៉ុនគ្នាដែរ ប៉ុន្តែខ្ញុំទុកឲ្យម៉ែតែបន្តិចបន្តួចប៉ុណ្ណោះ សល់ប៉ុន្មាន ខ្ញុំចំណាយទៅលើនំចំណីខ្ចៃទាំងអស់ គ្មានដែលសល់មួយរេសទេ។

តើខ្ញុំរវល់ព្រួយសន្សំទុកដាក់ធ្វើអ្វី? សំពត់ផាហ៊ុំ និង កំណាត់គ្រប់បែបយ៉ាង ហ្លួងបញ្ជាឲ្យគេចែកឲ្យយើងច្រើនណាស់ ប្រើមិនអស់ សល់បានទៅដល់ ប៊ុន និង ហ៊ុន ជាបងប្អូនជីដូនមួយខ្ញុំនៅព្រែកថ្មីឯណោះផង។ វាទាំងពីរនាក់ ឧស្សាហ៍មកលេងនឹងខ្ញុំជាញឹកញយក្នុងវាំង ហើយជួនកាលខ្ញុំឃាត់វាឲ្យនៅដេក ពីរ-បី យប់ក៏មាន។ ខ្ញុំចង់នាំវាទៅដេកឯផ្ទះម្ចាស់ក្សត្រីវិមធីតា ឬ ផ្ទះណាមួយក៏បានដែរ ព្រោះគ្មាននរណាត្រួតត្រាទេ ចង់ដេកត្រង់ណាក៏ដេកទៅ។

ថ្ងៃមួយ ស្រាប់តែកើតមានហេតុការណ៍ប្លែកគួរឲ្យខ្ញុំមានសង្ឃឹមថា ក្តីស្រមៃដែលថានឹងបានក្លាយខ្លួនទៅជាតួឯករបាំនោះ គង់នឹងបានសំរេចជាមិនខាន។ ពេលនោះ ខ្ញុំត្រូវរាំសមជាមួយអ្នកឯទៀត មុនពេលចូលឆ្នាំថ្មី ដែលគេតម្រូវឲ្យយើងទៅចេញរាំនៅសួនច្បារវត្តភ្នំ។ ព្រះអង្គម្ចាស់ ដួង មធុរា កូនប្រុសរបស់ហ្លួង និង ជាបងម្ចាស់ក្សត្រីវិមធីតា បាននាំពួកម៉ាកកម្លោះៗជាច្រើន ដើម្បីមកមើលយើងរាំសមនេះ។ លោកតាមសម្លឹងមើលខ្ញុំយ៉ាងយកចិត្តទុកដាក់តាំងពីដើមដល់ចប់ ហើយហៅខ្ញុំទៅអង្អែលស្មាសរសើរ ព្រមទាំងប្រាប់ទៅម្ចាស់ក្សត្រីប្អូន ឲ្យលើកខ្ញុំធ្វើជាតួសំខាន់ឡើង ព្រោះបើតាមលោកមើលទៅឃើញថា ខ្ញុំអាចបំពេញមុខងារនេះបានប្រសើរណាស់។ ម្ចាស់ក្សត្រីទទួលធ្វើតាមបញ្ជា ហើយបញ្ចេញឫកស្ងួតជាមួយខ្ញុំប្លែកសព្វមួយផង។ ប៉ុន្តែឫកពារស្ងួតបូតរបៀបនេះ បែរជាធ្វើឲ្យខ្ញុំខ្លាចទៅវិញ ព្រោះតែកាលណាម្ចាស់ក្សត្រីយ៍សើចម្តងៗ ចេញធ្មេញស៊ីស្លាខ្មៅអ៊ីញ ធ្វើឲ្យខ្ញុំខ្លាចរត់គេចខ្លួនបាត់មួយរំពេច។

នៅក្នុងវាំង ម្ចាស់ក្សត្រីមានឥទ្ធិពលគ្របសង្កត់លើហ្លួងបិតាសម្បើមណាស់។

គេខ្សិបខ្សៀវគ្នាពីមាត់មួយទៅមាត់មួយថា តាមពួកអ្នកបំរើចាស់ៗធ្លាប់នៅវាំងខាងជើងនិយាយថា សម្តេចឧបរាជ បានលបលាក់ស្រឡាញ់គ្នាជាមួយកូនបង្កើតឯងផង។ គេនិយាយទៀតថា នេះជាក្រយៅអាក្រក់តពូជ នៃ ត្រកូលស្តេចសោយរាជ្យ គឺស្តេចស្រីក្មេងៗ ស្រឡាញ់សាហាយស្មន់ជាមួយ ឪពុកមាឯង, ឪពុកឯង ឬ ជីតាឯង ដូចមានរឿងម្ចាស់ក្សត្រីជិបជាដើម ហើយរឿងរ៉ាវអស់នេះ តែងលេចឮទៅដល់



ចំណោមប្រជារាស្ត្រ ដែលកំពុងរស់នៅលំបាកអត់ឃ្លាន ដែលជាហេតុធ្វើឲ្យរាស្ត្រក្តៅក្រហាយក្រៃលែង។

នៅទន្ទឹមគ្នានឹងឥទ្ធិពលដ៏ខ្លាំងក្លា នៃ ម្ចាស់ក្សត្រីវិមធីតានេះ លោកមហាមន្ត្រីទទួលបន្ទុកមើលការខុសត្រូវក្នុងវាំង ក៏ប្រើអំណាចសង្កត់សង្កិនទៅលើហ្លួងខ្លាំងណាស់ដែរ ព្រោះគាត់ចេះនិយាយបារាំង និងមានការទាក់ទងយ៉ាងស្និទ្ធស្នាលជាមួយពួកអាណាព្យាបាលបារាំង។ គាត់ប្រសប់ប្រើឧបាយកេងយកប្រយោជន៍ពីហ្លួងណាស់ ហើយយកសុទ្ធតែគ្នីគ្នាគាត់ឲ្យទៅនៅជិតហ្លួង។ ហ្លួងមិនសូវយល់ពីគោលបំណងពិតប្រាកដរបស់លោកមហាមន្ត្រីទេ ម្ល៉ោះហើយលោកចេះតែព្រួយបារម្ភជានិច្ច។ ក្នុងការនិយាយស្តី គាត់មានប្រៀបលើហ្លួងជានិច្ច អាចសុំឲ្យក្រុមគ្រួសារ ឬ បក្សពួកទៅធ្វើការកន្លែងណាក៏បាន។ កិច្ចការគ្រប់ជំពូកនៅក្នុងវាំង ស្ថិតក្នុងកណ្តាប់ដៃគាត់ទាំងអស់ ព្រោះគាត់ជាខ្មែរចេះបារាំង គាត់ចង់ធ្វើអ្វីបានតាមចិត្ត ពុំចាំបាច់ស្តាប់បង្គាប់បញ្ជានរណាទេ ហើយគេក៏ពុំអាចធ្វើការដោយគ្មានគាត់បានដែរ បើសង្ឃឹមទៅលើស្តេច គឺគ្មានសមត្ថភាពអ្វីបន្តិចបន្តួចទាល់តែសោះ។

ក្រោយគេបំផុត គឺ នួណាម ដែលឆ្លៀតឱកាសប្រើអំណាចខាងផ្លូវចិត្ត ជិះជាន់លើហ្លួងខ្លាំងណាស់ដែរ គាត់រចនាផ្ទៃវាំងទៅតាមតែចិត្តនឹកឃើញ។ គាត់បានឡើងឋានៈជាម៉ម ហើយក្លាយឈ្មោះជាម៉មនួ ដ៏ល្បីល្បាញ មានផ្ទះពីរជាន់សង់នៅចុងផ្លូវធំ ក្បែរប្រាសាទភិមានអាកាស។ ម៉មនួ ស្រឡាញ់រាប់អានខ្ញុំណាស់ ហៅខ្ញុំសុទ្ធតែកូន ព្រមទាំងឲ្យមាសពេជ្រខ្ញុំពាក់ស្រោចខ្លួន រហូតទាល់តែខ្ញុំភ្លេចម្ចាស់ក្សត្រីវិមធីតាឈឹងតែម្តង។

នាដ្យការីវ័យក្មេង



Jeunes danseuses

ច្រើនខែកន្លងទៅ... ការដែលគេលែងរវីរវល់គិតពីរឿងវិន័យរបៀបរៀបរយ បានធ្វើឲ្យវាំងក្លាយទៅជាទីច្របូកច្របល់រកមើលមិនយល់ ។ និយាយពី "ម្ចាស់ផែនដី"វិញ គឺបាត់ខ្លួនតែម្តង កម្រឃើញចេញមកក្រៅណាស់ មួយថ្ងៃៗសម្ងំផ្ទឹ ឬ សោយអាភៀន នៅតែក្នុងប្រាសាទ មេខលា ជួនកាលនៅរាជមន្ទីរ ជួនកាលទៅប្រាសាទបាញ់យ៉ុង ហើយស្រមោលហ្លួងដែលសុគតទៅនោះ តែងមកលងអារម្មណ៍ហ្លួងជានិច្ច ។

អ្នករបាំណាទំនេរ ម្ចាស់ក្សត្រីតែងហៅទៅឲ្យអង្គុយកំដរលោក សោយស្រា ឬ អាភៀន យ៉ាងសប្បាយរីករាយ ។ គេទើបនឹងបង្កើតស្រាថ្មីមួយមុខ ល្អជាងស្រាបារាំង ទិញនៅផ្ទះចិនទៅទៀត ។ គេចាក់ស្រាគ្រប់ពណ៌ គ្រប់ម៉ាក លាយគ្នាបន្តិចៗ និង ដាក់ទឹកកកមួយដុំ ហៅថា "ក្រឡៃ" ហើយផឹកជីបមួយភ្លឹកម្នាក់ បញ្ជូនបន្តពីមួយទៅមួយ រហូតដល់គ្រប់គ្នាមួយជុំ ។ អា "ក្រឡៃ" ហ្នឹង ខ្ញុំក្រេបតែមួយភ្លឹក ក្តៅឆួលបំពង់កស្ទើរប្រកាច់ស្លាប់ ។

ពេលនោះ មានពួកថ្មីដែលភាគច្រើនសុទ្ធតែស្រីកូនអ្នកស្រែ នាំគ្នាមកនៅក្នុងវាំង ដើម្បីបំពេញកន្លែងទំនេររបស់ពួកដែលចាកចេញឈប់នៅវាំង ។ ពួកអស់នេះ រូបអាក្រក់ ដៃជើងគ្រមឹងគ្រមាំង ពិបាកមើលណាស់ ហើយក្រីក្រគ្មានបានរៀនសូត្រផង ខ្លះក៏មកសុំនៅក្នុងវាំងដោយខ្លួនឯង ខ្លះក៏មានគ្រួសារជូនមកដើម្បីឲ្យបាននៅបំរើអស់អ្នកអស់នាងមានអំណាចនៅក្នុងវាំង ។ ពួកនេះ ដៃជើងរឹងធ្វើម្តេចអាចពត់ពេនរាំដូចយើងបាន ? ម្ល៉ោះហើយ គ្មានចង់រាំរែកទេ គ្រាន់តែសុំបំរើគេយកបាយបរិភោគប៉ុណ្ណោះ ។ ខ្លះទៀតទំនេរឥតការធ្វើ ដើរវ៉េរពេញវាំង រង់ចាំទម្រាំថ្ងៃណាមួយម្ចាស់ក្សត្រីនាំយកទៅឲ្យបម្រើហ្លួងនឹងគេ ក្រែងបានកម្រៃខ្លះ ។

ពួកវាមកនៅក្រោយគេ សម្បុរខ្មៅគគ្រិចជាងគេ ប៉ុន្តែមានចិត្តលោភលន់ជាងគេ ខំទៅគាល់បំរើយកចិត្តម្ចាស់ក្សត្រីខ្លាំងណាស់ ដើម្បីឲ្យបានគាប់គួរ ។

ម្ល៉ោះហើយ ពួកយើងក្មេងៗត្រូវបាត់បង់អស់រលីងនូវសេចក្តីសប្បាយរីករាយ ដែលយើងធ្លាប់ស្គាល់ពីមុនមក ។ រាល់ថ្ងៃ ក្រោយពេលឈប់ហាត់រាំ យើងដើរជំនុំគ្នាពីផ្ទះមួយទៅផ្ទះមួយនៅក្នុងវែវ ហើយមួយថ្ងៃៗ យើងទៅមុជទឹក ពីរ-បី ដង ដើម្បីឆ្លៀតរកឱកាសឈ្លោះវាយតប់គ្នា ។ អារឿងវាយតប់ ខ្ញុំស៊ីជាច់គេទាំងអស់ បណ្តាលឲ្យពួកវានាំរឿងទៅទូលម្ចាស់ក្សត្រីជាញឹកញាប់ ហើយម្ចាស់ក្សត្រីក៏តែងតំរាមរកវាយ និងចាប់ខ្ញុំយកទៅដាក់គុកដែរ ។

និយាយពីគុកនោះ ខ្ញុំគ្មានខ្លាចទេ ពីព្រោះខ្ញុំតែងគេចរកកន្លែងស្ងាត់ ទៅដេកជាមួយពួកស្រីមានទោស



ស្ទើរតែរាល់យប់ ទាល់តែសាំទៅហើយ ។ បើវាត់ផ្តៅនោះ ទើបគួរឲ្យខ្លាចមែន ប៉ុន្តែខ្ញុំប្រសប់រកពាក្យដោះសារួចខ្លួនជានិច្ច ហើយដើម្បីសងសឹកនឹងម្ចាស់ក្សត្រី ខ្ញុំលបទៅបើកម៉ាស៊ីនទឹកបង្ហូរចោលរាប់ម៉ោង ។

កាលណាយើងចង់សប្បាយហ៊ឺតហ៊ឺនមែនទែន យើងប្រមូលគ្នាទៅជុះអាចម៍នៅបង្គន់ឯចុងវាំងខាងលិចឯណោះ ។ កន្លែងនោះមានសល់ចន្លោះមួយសម្រាប់ចេញ-ចូល ទៅទ្វារខាងលិច ដែលយូរៗទើបគេបើកម្តងដើម្បីដឹកយកខ្មោចចេញទៅក្រៅវាំង ។ មានជណ្តើរថ្មសម្រាប់ដើរឡើងទៅកាន់បង្គន់ដ៏ធំក្លិនស្អុយអាសោចម៍ ដែលសង់បន្ទើតពីលើដីថ្លុកមួយ ពេញហៀរទៅដោយជង្គររិច ដូចជារបងសម្រាប់ការពារមិនឲ្យនរណាមកត្រេងត្រាងក្បែរវាំងបាន ។ យើងពុំអាចមើលទៅក្រៅឃើញទេ ប៉ុន្តែមានពួកមីច្រឡឹមខ្លះ វាគាស់ក្បឿងដំបូលបង្គន់ ហើយបន្តោងឡើងតាមជញ្ជាំង អើតករហង់មើលទៅក្រៅ ។

ពេលយប់ គ្មាននរណាហ៊ានដើរមកកន្លែងនេះដែលឮតែសូរហ៊ុងយំទ្រហឹង និង ងងឹតចាក់ភ្នែកមិនយល់ គួរឲ្យខ្លាចនោះទេ។ នរណាឈឺជុះយប់ព្រលប់ ទយត្រង់ណាក៏ទយទៅឲ្យតែប្រទះ ។ ហេតុនេះហើយ បានជាយប់មួយ ខ្ញុំប្រហែសមិនបានមើល ជ្រុលជះទឹកមួយផ្តិលទៅលើម្ចាស់ក្សត្រី ដែលកំពុងអង្គុយច្រហោង ដោះទាល់នៅក្រោមផ្ទះយុនថាន់ ។

ទីវាំង ខណ្ឌដាច់ពីទេសភាពខាងក្រៅដ៏ស្រពាប់ស្រពោន និង អាក្រក់មើលក្រៃលែង ដោយសារអន្លង់មួយ ដែលគេជីកនៅក្រោយវាំង ទិសខាងលិច ។ នៅឯច្រាំងម្ខាងនោះ មានផ្លូវដីតូចមួយ ដែលពួកកម្លោះតណ្ហាក្រាស់ តែងដើរមកលេងកំសាន្តពេលយប់ ទាំងភ័យខ្លាចភ្នែកនៅកញ្ជឹងក ដើម្បីស្រែក ឬ ហួចស៊ីញ៉ូពួកស្រីវាំង ក្រែងលោបានទទួលសំបុត្រស្នេហា ឬ កន្សែងបញ្ចាំចិត្តពីអ្នកក្នុងវាំង ទុកជារបស់អនុស្សាវរីយ៍ ។ ប៉ុន្តែគួរឲ្យអាសូរណាស់ ពួកកម្លោះអស់ហ្នឹងអត់ដឹងថា គ្មានក្រមុំខ្វាររកមកចាំស្នេហាជាមួយខ្លួន ហើយបែរជាមានក្មេងច្រឡឹមកំពុងតាមលួចមើលខ្លួនទេ ។ កាលណាយើងមើលស្គាល់នរណាម្នាក់ យើងស្រែកហៅចំឈ្មោះវា ជេរបញ្ចោរ ព្រមទាំងបឺសដុំថ្មគប់ចូលទឹកខ្ទាតកក់ប្រឡាក់ពួកនោះស្រមក ។ កាលណាស្ងាត់អស់ហើយ មុនត្រឡប់មកវិញ យើងមិនដែលខាននឹងអង្គុយច្រហោងក្នុងបន្ទប់បង្គន់មួយម្នាក់ ដែលខណ្ឌគ្នាដោយជញ្ជាំងក្តារ ហើយលបមើល តើអ្នកជិតខាងធ្វើអ្វីខ្លះទេ ។

នេះជាល្បែងក្មេងព្រើលជំពូកអស់យើង ។ ក្មេងស្រីសព្វថ្ងៃនេះ វាឥតចេះលេងផ្តេសផ្តាសដូចយើងទេ ព្រោះតែពេញជំទង់ភ្លាម វាយល់អស់អារឿងកិច្ចការប្តី-ប្រពន្ធ ហើយធ្វើឫកដូចជាមនុស្សក្រមុំអញ្ចឹង ។

ពួកក្រុមវាំងចាស់ៗ គាត់មួម៉ៅនឹងអាកប្បកិរិយាច្រឡឹមខុសបទរបស់យើងខ្លាំងណាស់ ។ ប៉ុន្តែធ្វើម្តេចបើគាត់គ្មានពេលចាំត្រួតត្រាយើងឲ្យបានដិតដល់ ព្រោះមួយថ្ងៃៗ គាត់រវល់តែចាំឃ្លាំដំណើរចេញ-ចូលទៅក្នុងវាំង នៃ មនុស្សប្លែកៗ ដែលមានការមិនចេះអស់មិនចេះហើយជាមួយហ្លួង ។ យើងស្អប់ពួកក្រុមវាំងហ្នឹងណាស់ ព្រោះគាត់ចេះតែគំរាមគំហែងចង់យករឿងយើងទៅទូលម្ចាស់ក្សត្រីឲ្យវាយយើង ។ កាលពីប៉ុន្មានឆ្នាំមុន ដោយសារតែរឿងច្រឡឹមរបៀបក្មេងនេះ ទើបស្រីរបាំម្នាក់ឈ្មោះ កែម នៅជំទង់នៅឡើយ ត្រូវរងគ្រោះរហូតបាត់បង់ជីវិត គឺវាទៅលួចបេះផ្កាម្ចាស់ក្សត្រីឈ្មោះ យ៉ៃ ដ៏ផ្តាស់ផ្តើម ហើយត្រូវគេចាប់បាន យកទៅវាយនឹងដំបងដែក ធ្វើទារុណកម្មវាទាល់តែស្លាប់ ។

ប៉ុន្តែយើងចេះប្រើល្បិច ពុំងាយនរណាចាប់បានឡើយ ជួនកាលយើងថែមទាំងរត់ជាន់ពួកក្រុមវាំង ដែលកំពុងដេកលក់ភ្លេចខ្លួននៅលើកាំជណ្តើរទីតាំងដ៏ស្ងាត់ជ្រងំនោះផង ។ យើងលួចបេះស្វាយ បេះល្មុត បេះផ្កា ឬ លួចដុំកែវ ដុំស្ពាន់មូលដូចគ្រាប់ឃ្លី ដែលគេដាក់លំអលើចង្កៀងដ៏ល្អទិញមកពីអឺរ៉ុប ។ ស៊ុន និង ខ្ញុំ ពិសោធន៍មើលឃើញថា ដុំគ្រាប់ឃ្លីអស់នេះស្រណុកមូលដោះណាស់ ហើយយើងក៏លួចដោះយកមក

ប្រមៀលលេងតាមកាំជណ្ដើរយ៉ាងសប្បាយ ។ ប៉ុន្តែគេពុំដែលរកមុខអ្នកធ្វើអំពើខិលខូចនេះឃើញឡើយ ។

យប់មួយនោះ រិះតែគេចាប់យើងបាន ។ យើងកំពុងតែដើរលបៗឡើងទៅលើរោងហោលទីតាំងតុសិត ប៉ុន្តែក្រុមវាំងឃើញភ្លើងបារីរបស់យើង ក៏លបឡើងមកតាមក្រោយ ដោយកាន់ឈើច្រត់ផងប្រាក់មកជាមួយផង ។ យើងងាកក្រោយឃើញស្រមោលគាត់ ភ្ញាក់ព្រើត ក៏គប់កន្ទុយបារីតម្រង់ក្បាលគាត់ ហើយរត់តម្រង់ជណ្ដើរ ផាយចុះក្រោមទៅសម្ងំពួនក្នុងគុម្ពផ្កាបាត់ឈឹង ។

ក្រោយបន្តិចមក ហ្លួងថ្មីក៏យាងមកទតការសមរបាំ ដែលមាន ម៉មន្ធូ រាំផងដែរ ។ រោងរបាំពេញចង្អៀតទៅដោយអ្នករបាំ និង ទស្សនិកជន ដែលភាគច្រើនសុទ្ធតែព្រះរាជវង្សានុវង្សនៅក្នុងវាំង ។ ថ្ងៃនេះអ្នករបាំគាប់ព្រះទ័យហ្លួង ចង់ផ្កាចម្ប៉ាទម្លាក់មកកៀនត្រចៀក ដៃពាក់កម្រងផ្កាម្លិះ តែងខ្លួនហ៊ឺហា និង ខំរាំពត់ពេនល្អលើសសព្វមួយផង ។ ទាល់តែហ្លួងទ្រាំអត់មិនបាន ដើរកាត់ឆាកល្ខោនទៅអង្អែលថ្ពាល់ដ៏ផូរផង់ នៃស្នំឯក ។ មិនដឹងជាយ៉ាងម៉េច ស្រាប់តែ ម៉មន្ធូ លូកដៃទាញកន្ត្រាក់សារុងសូត្ររបស់ហ្លួង ព្រមទាំងផ្ទុះសំណើចខ្លាំងៗដូចជាសប្បាយចិត្តណាស់ ។ សារុងរបូតហួសក្បាលពោះ ប៉ុន្តែជាសំណាងល្អ ហ្លួងភ្ញាក់ព្រើតស្រវាទប់ទាន់ ហើយស្រែកដោយក្ដីឈឺចាប់ :

– ម៉ែន្ធូ, អួយ! ម៉ែន្ធូ! អាណិតអញផង កុំទាញខ្លាំងដៃពេក!

ពេលនោះខ្ញុំឥតត្រូវចេញរាំទេ ខ្ញុំនៅអង្គុយលាយឡំជាមួយគេឯង ដល់ឃើញរឿងរ៉ាវអញ្ចឹង ខ្ញុំទៅជាខ្មាសលាយភ័យមិនហ៊ានមើល ។ ពួកនាម៉ឺនអង្គុយនៅពីក្រោយខ្ញុំ ងាកមុខចេញគ្រវីក្បាល ហើយនិយាយជំនុំគ្នាថា :

– ម៉មន្ធូ ដូចជាជ្រុលបន្តិចហើយ! ទោះបីគាត់ជាស្នំឯក ក៏គាត់ជាកូនរាស្ត្រសាមញ្ញ មិនគួរហ៊ានលេងសើចជាមួយហ្លួងដល់ថ្នាក់ហ្នឹងសោះ! ។

កាលពីជំនាន់ហ្លួងមុន ឲ្យតែនរណាហ៊ានធ្វើផ្ដេសផ្ដាសកណ្ដាលចំណោមអញ្ចឹង ច្បាស់ជាត្រូវទណ្ឌកម្មទ្រមខ្លួនមិនខាន ។ ហ្លួងថ្មីនេះ ក៏អៀនខ្មាសខ្លាំងណាស់ដែរ ប៉ុន្តែមិនហ៊ានធ្វើអ្វីគេ ក៏ចេះតែទ្រាំធ្វើមុខក្រាស់ទៅ ។ សកម្មភាពផ្ដេសផ្ដាសរបស់ម៉មន្ធូ កាន់តែធ្វើឲ្យហ្លួងឡើយណាយខ្លាំងឡើង រហូតដល់ក្រោយមកមិនយូរប៉ុន្មាន លោកក៏ផ្ដែតផ្ដន់នឹងគាត់មែនទែនតែម្ដង ។

លុះមកដល់ខែ អាសាធ នៃ ឆ្នាំនេះ បារាំងត្រូវធ្វើបុណ្យជាតិគេនៅក្នុងសួនច្បារវត្តភ្នំ ហើយលោកទេសាភិបាល បានមកសុំហ្លួងឲ្យក្រុមល្ខោនទៅរាំក្នុងឱកាសនោះផង ។

ពាក្យសុំរបស់បារាំង ក៏ដូចជាពាក្យបង្គាប់ដែរ ម្ល៉ោះហើយហ្លួងត្រូវតែធ្វើតាមបង្គាប់គេទាំងទើសទាំងទាល់ ប៉ុន្តែមិនឲ្យយកអ្នករបាំល្អៗទៅរាំទេ យកតែពួកមិនដឹងខ្យល់អី ចែកលុយឲ្យពីរ-បីរៀលម្នាក់ ហើយឲ្យចេញទៅរាំទៅ ។ ហ្លួងផ្ទាល់ព្រះអង្គ, ក្សត្រា, ក្សត្រី និង អស់អ្នក-អស់នាង ទាំងអស់ បានទៀបប្រជុំក្នុងរាត្រីសមោសរនោះ ហើយខ្ញុំក៏តាមទៅនឹងគេដែរ ដើម្បីលួចមើលបារាំងឲ្យឃើញច្បាស់ម្ដង ព្រោះខ្ញុំខានដើរទៅលេងឯសង្កាត់បារាំង តាំងពីយូរណាស់មកហើយ ។

ក្នុងរាត្រីដ៏ភ្លឺព្រោងព្រាតដោយពន្លឺភ្លើងចម្រុះពណ៌យ៉ាងនេះ ខ្ញុំមើលមកខ្លួនឯងឃើញដូចជាស្អាត ដូចជាល្អប្លែកសព្វមួយផង ។ មនុស្សគ្រប់សញ្ជាតិយ៉ាងច្រើនកុះករ មកប្រមូលផ្ដុំគ្នានៅពីមុខរោងរបាំ ដែលតុបតែងលំអរទៅដោយ ទង់ជាតិ និង ស្លឹកទន្សែ ។ ក្បែររោងរបាំ មានសង់វេទិកាឈើមួយទៀត ដែលនៅលើនោះពួកស្រីវាំងអង្គុយបត់ជើងត្រៀបត្រា ដោយម្នាក់ៗសុទ្ធតែមានក្មេងបំរើ កាន់ប្រអប់ស្លា និង កន្ថោរស្ដោន នៅពីក្រោយខ្នងផង ។



លោកទេសាភិបាល អង្គុយលើកៅអីលាបទឹកមាសខ្ចីមកពីក្នុងវាំង ប៉ុន្តែគាត់អង្គុយទាបជាងហ្លួងបន្តិច ។ ឫកពាគាត់ហ៊ឺហាថ្លៃថ្នូរមែន ប៉ុន្តែបើមើលមកហ្លួងយើង ដែលពាក់អាវកត្រង់ខ្សែរមាស ស្លៀកសំពត់ចងក្បិនពណ៌បៃតងនោះវិញ ក៏មិនមែនអន់ណាស់ណាដែរ ។

បារាំងមួយហ្វូង អង្គុយខ្លះ, ឈរខ្លះ; ចាស់ក៏មាន, ក្មេងក៏មាន; ទាបក៏មាន, ខ្ពស់ក៏មាន; សក់ផេងក៏មាន; ក្បាលទំពែកក៏មាន ។ ពួកប្រុសៗមានឧធំរាងសង្ហា ហើយហាក់ដូចជាយកចិត្តទុកដាក់នឹងមើលរបាំខ្លាំងណាស់ ។ ចំណែកឯស្រីៗវិញ ពាក់មួកដូចទូលកញ្ជើ គ្រាន់តែកដៃធំជាងកជើងយើងទៅទៀត ។ គេដដែកគ្នាអែ ផ្ដាដៃផ្ដាជើង គ្មានរវល់មើលរបាំរាំម៉េកអ្វីទេ ។ ដល់ពេលគេលើកយក កេសជ្ជៈ និង ចាសនំមកជូន ពួកស្រីៗអស់ហ្នឹងផឹកស៊ីកណ្ដាលចំណោមគ្មានខ្មាសអៀន ហើយបែបគ្មានបណ្ដាក់ពោះផងមើលទៅ ។

ពេលនោះ ស្រាប់តែកើតមានចលាចលនៅចំកណ្ដាលវេទិកា ធ្វើឲ្យយើងស្រឡាំងកាំងគ្រប់គ្នា ។ ស្រីម្នាក់ពាក់អាវបំពង់ខ្មៅវែងហៀរដល់កែងជើង មានឈ្នួលម្នាក់កាន់ស្បែកជើងឈើដើរតាមក្រោយ ដើរកន្លងក្បាល ទាំងស្ដេច ទាំងរាស្ត្រ ជាន់ដៃជាន់ជើងនរណាក៏មិនរវល់ គិតតែវ៉ឹកផ្លូវប្រជ្រៀតឲ្យបានទៅដល់កៅអីផ្លូវមុខ ។ អស់ពីឆ្ងល់ យើងត្រឡប់ជាក្ដៅក្រហាយ នាំគ្នាព្រូតបញ្ចោរមីស្រីឃ្នួនជម្លើយ ព្រមទាំងចាប់ច្រានវាចេញផង ។ ប៉ុន្តែវាបែរជានិយាយខ្មែរប៉ែឡាំៗ ជេរតបមកយើងវិញ :

– ពួកឯងរាល់គ្នាអាងអីក៏សម្បើមម្ល៉េះ? អាងអំណាចស្ដេចហ្នឹងហ្ហែ? ពួកឯងស្គាល់អញជានរណាទេ? អញជាប្រពន្ធលោកទេសាភិបាលណា! ឯងមិនដឹងថាប្ដីអញជាម្ចាស់ស្រុកខ្មែរ ត្រួតត្រាលើក្បាលស្ដេចរបស់ឯងទេឬអី?

ស្អី! មីស្រីស្លៀកពាក់មើលតែអ្នកលក់ទឹកត្រីអញ្ចឹង ហ៊ានអួតខ្លួនថាជាប្រពន្ធទេសាភិបាលបារាំងផង ។ ពួកយើងជជែកឈ្លោះគ្នាទ្រហឹងអឹងអាប់មិនដាច់មិនស្រេចសោះ ។ លោកមហាមន្ត្រី រត់ត្រហេបត្រហបមកឃាត់ទាន់ពេល ដែលស្រីមួយហ្វូងធំកំពុងស្ទុះព្រួ ប្រុងចូលមកជួយគ្នាវា ។ គាត់ខំឃាត់ឲ្យឈប់ឈ្លោះគ្នា ប៉ុន្តែម្ចាស់ក្សត្រី ជីប នៅតែប្រឹងស្រែកជំទាល :

– បើមីហ្នឹងវាថា វាជាប្រពន្ធបារាំង ម៉េចវាក៏មិនមកអង្គុយលើកៅអីមាសជិតប្ដីវាទៅ?

ក្រោយបន្តិចមក របៀបរៀបរយក៏កើតមានឡើងវិញ ប៉ុន្តែរឿងរ៉ាវមិនទាន់ចប់ត្រឹមណេះទេ ។

នៅពេលត្រឡប់មកវាំងវិញ ពួកអស់អ្នក-អស់នាងនាំគ្នាផុកដាន់ឲ្យហ្លួងចាប់ស្រីជម្លើយនោះមកធ្វើទោស ព្រោះវានេះ ពីដើមគ្រាន់តែជាឈ្នួលបំរើនៅក្នុងវាំងប៉ុណ្ណោះ ប៉ុន្តែដំណើររឿងវាបែរជាមានសភាពផ្ទុយទៅវិញ គឺស្រីនោះចូលមកគាល់ហ្លួង ដោយម្ដងនេះស្លៀកពាក់ហ៊ឺហាអស្ចារ្យ ដើម្បីសុំឲ្យហ្លួងស្ដីបន្ទោសពួកយើង ដែលហ៊ានជេរបញ្ចោរវា ។ ជាសំណាងល្អ ខ្ញុំរួចខ្លួន ពុំត្រូវបានគេហៅទៅទទួលទោសជាមួយអ្នកឯទៀតទេ បើសិនជាទៅ ប្រហែលជាខ្ញុំទទួលទោសធ្ងន់ជាងគេផងក៏មិនដឹង ព្រោះក្នុងពេលមានរឿងខ្ញុំជេរបញ្ចោរខ្លាំងដៃណាស់ ។ ហ្លួងអស់សង្ឃឹមទន់ដៃទន់ជើង ប្រគល់កិច្ចការទៅឲ្យលោកមហាមន្ត្រីចាត់ចែងជំនួស ។ ដើម្បីបំពេញចិត្តស្រី គេចាប់ម្ចាស់ក្សត្រី ចិន្តាវង្ស ដែលគ្នាគ្មានដឹងរឿងអ្វីសោះ យកទៅដាក់គុកលេងទទេ ព្រោះគ្នាជាចៅស្ដេចអង្គឌួង សាច់ញាតិឆ្ងាយពីគេ ហើយជាពិសេសទៅទៀត គ្នាកំព្រាគ្មាននរណាជួយការពារផង ។

ខ្ញុំអាយុបាន ១២ ឆ្នាំហើយ ប៉ុន្តែចរិតខ្ញុំ ឃើញហាក់ដូចជាគ្មានប្រែប្រួលប្លែកពីដើមសោះ ។ អ្នកឯមទទួលបន្ទុកខាងត្រួតត្រា ក្រុមចាំយាមបំរើហ្លួង និង បើកប្រាក់ខែឲ្យពួកអស់អ្នក-អស់នាង បានចុះឈ្មោះខ្ញុំទៅក្នុងបញ្ជីក្រុមយាមទីបួន ហើយខ្ញុំក៏ចូលទៅកាន់មុខការថ្មី ចាប់តាំងពីពេលនោះមក ។

ពួកស្រីយាមបំរើហ្លួង មានចែកជាបួនក្រុម ដែលត្រូវចូលមកធ្វើការឲ្យបានទៀងទាត់បំផុត ។ ពួកធំៗក្នុងក្រុមនិមួយៗ ត្រូវចូលទៅគាល់ផ្ទាល់ដល់ក្នុងបន្ទប់ដែលហ្លួងគង់តែម្តង សម្រាប់រៀបចំខ្សៀអាកៀនបញ្ជូនពាក្យបញ្ជាផ្សេងៗមកអ្នកបំរើ និង រៀបចំព្រះស្ងោយថ្វាយហ្លួងសោយលើតុតាមរបៀបអឺរ៉ុប ហើយខ្លួនឯង បរិភោគបាយអង្គុយបត់ជើងផ្ទាល់លើកន្ទេលព័ទ្ធជុំវិញតុ ដោយស្រែកច្រៀងបទមហោរីកំដរជាប់រហូតផង ។ នរណាជាអ្នករបាំ ពុំបានបោះបង់ការហាត់រាំប្រចាំថ្ងៃរបស់ខ្លួនចោលទេ ម៉្លោះហើយមួយថ្ងៃៗគ្មានរវល់ជាប់រហូត រកពេលដើរកំសាន្តមិនបាន ឲ្យតែទំនេរ ក៏តាំងប្រះដេកភ្លាម ព្រោះអស់កម្លាំង អត់ងងុយខ្លាំងពេក ។ ក្នុងរាជ្យហ្លួងមុន តែនរណាបានមកបំរើហ្លួងហើយ ទុកជាមិនបាច់ទៅហាត់រាំ ក៏គេមិនថាអ្វីដែរ ខុសប្លែកពីឥឡូវឆ្ងាយណាស់ ។

ប៉ុន្តែ យើងជាពួកក្មេងតូចៗ គេឲ្យនៅខាងក្រៅត្រង់រានហាល ឬ ក្នុងបន្ទប់ណាមួយក្បែរបន្ទប់ហ្លួងសម្រាប់ចាំជួយធ្វើការពួកធំៗ និង អង្គុយទាញខ្សែបក់ផ្លិតព្យួរនៅពិតាន ឲ្យរហើយក្នុងកន្លែងហ្លួងគង់ ។

មុខការទាញខ្សែបក់ផ្លិតតាមប្រហោងជញ្ជាំងអញ្ចឹង វាមិនគាប់ចិត្តខ្ញុំសោះ ទម្រាំតែផុតយាមម្តងៗខ្ញុំអផ្សុកស្ទើររយះដើមទ្រូង ។ ថ្ងៃមួយខ្ញុំយកខ្សែមកចងបន្តឲ្យបានវែងមែនទែន ដើម្បីចេញទៅទិញនំនៅខាងក្រៅ ស្រាប់តែខ្សែនោះដាច់ប៉ិត ខ្ញុំភ័យស្ទើរលោះព្រលឹង ។ ប៉ុន្តែជាសំណាងល្អ ពេលនោះហ្លួងកំពុងផ្ទំលក់ស្កប់ស្កល់ ពុំបានឃើញកន្ទុយខ្សែរបូតទៅដល់ជិតគ្រែទេ ។

ពេលមួយនោះ យើងកំពុងអង្គុយជុំគ្នាក្នុងបន្ទប់ទទួលភ្ញៀវ រង់ចាំហ្លួង និង ស្នំគាប់ព្រះទ័យទាំងឡាយសោយ និង បរិភោគ បាយល្ងាច នឹងអាលគេរៀបចំឲ្យយើងបរិភោគម្តង ស្រាប់តែឮសូរសម្លេងហ្លួងស្រែកខ្លាំងៗហៅពួកយើងក្មេងតូចៗឲ្យចូលទៅបរិភោគបាយជាមួយពួកគេឯងខាងក្នុង ។

គ្រាន់តែឮអញ្ចឹងភ្លាម ពួកម៉ាកខ្ញុំស្ទុះរត់ប្រូចគេចបាត់អស់ ព្រោះពួកវាខ្លាចហ្លួងផង ខ្មាសគេផងមិនហ៊ានចូលទៅស៊ីបាយជិតគេ ។ ខ្ញុំក៏រៀបរត់ទៅតាមគេដែរ ប៉ុន្តែហ្លួងចូលមកទាន់ ឃើញខ្ញុំតែម្នាក់ឯងក៏គំហកសួរថា :

~ ពួកហ្នឹងវាទៅណាអស់ទៅ ? អញហៅវា វារត់ពួនអញ្ចឹងហ្អែ ! មីក្មេងច្រឡឹមអស់ហ្នឹង សមតែកាត់កចោល... ហើយឯងម៉េចមិនរត់ទៅនឹងគេ ? ឯងឈ្មោះអី ?



~ ក្រាបទូល ខ្ញុំម្ចាស់ឈ្មោះ យ៉ែម (ខ្ញុំឆ្លើយតបទាំងភ័យញើរញ័រ) ។

~យ៉ែម ? មីណាក៏ឈ្មោះ យ៉ែម... យ៉ែមដូចគ្នាទាំងអស់តែម្តង ។ ហ៎ ! ទៅស៊ីបាយទៅ ចាំអញរកឈ្មោះថ្មីដាក់ឲ្យ ។

ខ្ញុំដើរចូលទៅក្នុង ហើយអង្គុយក្បែរ ពួកឃុន ពួកម៉ម ដែលតាមសម្លឹងមើលខ្ញុំដោយញញឹមខ្ញីប ។ ម៉មទួថៅហ្វាយខ្ញុំក៏នៅទីនោះដែរ គាត់អង្គុយក្បែរកៅអីហ្លួង ។ គាត់និយាយឡើងរបៀបម៉ឺកម៉្ញក់ :

~ ខ្ញុំម្ចាស់សប្បាយចិត្តណាស់ ដែលឃើញព្រះអង្គចង់ប្រទានឈ្មោះឲ្យក្មេងនេះ ។ ខ្ញុំម្ចាស់ស្រឡាញ់វាណាស់ ព្រោះវាមានចរិតគួរឲ្យចូលចិត្ត ។

~ ឈប់ ម៉ែទួ, ចាំអញរកឈ្មោះល្អដាក់ឲ្យវា ។

ការបរិភោគបាយបានបន្តទៅទៀត ក្នុងបរិយាកាសសប្បាយរីករាយ ។

ខ្ញុំសង្កេតឃើញពួកបោយប្រុស អាចចេញចូលក្នុងបន្ទប់បានដោយសេរី ដើម្បីលើកម្ហូបអាហារបំរើហ្លួង និង ប្រពន្ធហ្លួង ដែលជាការផ្ទុយស្រឡះកាលពីរាជ្យមុន ។ ពួកបោយនេះ ស្លៀកពាក់សង្ហាអស្ចារ្យ អ្នកខ្លះជាកូននាម៉ឺនធំដុំផង សុខចិត្តមកធ្វើបោយហ្លួង ព្រោះតែចង់នៅជិត អស់អ្នកអស់នាង និង ស្រីរបាំ ។

នៅពីមុខតុហ្លួង គេក្រាលកន្ទេលធំពីរលើកម្រាលព្រំ ហើយរៀបចំ ចានប្រាក់, ដបស្រាបារាំង និង បង្អែម ពោរពាសពីលើនោះ ។ ពួកស្រីបំរើតម្រៀបគ្នាជាជួរ លើកថាសមាសដាក់ បាយអង្ករសក្បុស និង ម្ហូបអាហារផ្សេងៗពីតំណាក់ពិសេស មកហុចបន្តឲ្យបោយប្រុសយកមករៀបចំថ្វាយហ្លួងលើតុ និង រៀបចំដាក់ឲ្យយើងបរិភោគលើកន្ទេល ហើយថយទៅអង្គុយលុតជង្គង់ពីក្រោយខ្នងយើង ចាំបម្រើហុចនេះហុចនោះទៀត ។

ខ្ញុំអង្គុយបត់ជើងផ្អៀងខ្លួនបន្តិចច្រត់ទៅលើដៃឆ្វេងដូចពួកគេធំៗដែរ សល់ទំនេរតែដៃស្តាំមួយ សម្រាប់កាន់ស្លាបព្រា ឬ សម ។ យើងអង្គុយចាំតែស៊ី មានឈ្នួលចាំបំរើ ដួសបាយ ហុចទឹក គ្រប់បែបយ៉ាងទាំងអស់ ។

ស្រីចាស់ទុំអង្គុយផ្អែកខ្នងទល់នឹងជញ្ជាំងជុំវិញបន្ទប់ ចាំយាមបំរើយើង ។ ក្នុងបន្ទប់នេះមានមនុស្សអ៊ូអែរ និង អុជភ្លើងភ្លឺព្រោងព្រាតពេញមួយយប់ទល់ភ្លឺ ។

ខ្ញុំសង្កេតឃើញក្នុងចំណោមពួកស្រីដែលអង្គុយបរិភោគបាយជុំវិញកន្ទេល មានពួកកូនអ្នកស្រែទើបមកនៅវាំងថ្មីៗ ហើយត្រូវហ្លួងហៅមកឲ្យស៊ីបាយជាមួយគេដែរ ដើម្បីលោកនិយាយបង្អាប់បន្តុះឲ្យអស់អ្នកអស់នាង និង អ្នកបំរើ បានសើចលេងជាល្បែង ។ ខ្ញុំយល់ឃើញថា ស្តេចផែនដីផល់ធ្វើអញ្ចឹងទៅ វាដូចជាមិនសូវសមរម្យ ព្រោះវាដូចជាបង្អាប់ស្រីបំរើឲ្យថោកជាងបោយលាងចានទៅទៀត ។ នៅក្នុងរាជ្យថ្មីនេះ អ្វីៗក៏ផ្លាស់ប្តូរទាំងអស់ គឺហ្លួងមិនគ្រាន់តែអនុញ្ញាតឲ្យបោយប្រុស ចូលមកក្នុងបន្ទប់ផ្ទាល់ប៉ុណ្ណោះទេ ថែមទាំងបង្គាប់ឲ្យពួកនោះ និយាយរឿងចំអេសចំអាសនៅនឹងមុខយើងស្រីៗ ដើម្បីសើចលេងទៀតផង ។

ស្អែកឡើង ម៉មទួ ហៅខ្ញុំទៅ លាបម្សៅ, លាបទឹកអប់ ដើម្បីទៅគាល់ហ្លួងសុំឈ្មោះថ្មី ។ ឃើញម៉មទួនាំខ្ញុំមក ហ្លួងញញឹមខ្ញីបងើបអង្គុយលើគ្រែ សំយុងជើងមកជិតយើង ដែលអង្គុយបត់ជើងផ្ទាល់លើកន្ទេល ។ លោកងោក្បាលគិតយ៉ាងយូរ ហើយធ្វើមាត់ជីបអួចៗ សូត្រឈ្មោះដែលបានប្រទានឲ្យគេរួចទៅហើយ ៖ ស៊ីម៉ាឡា, ស៊ីម៉ាប៉េត, កេតស៊ុនី, សុផាស៊ី, សុមីរ៉ាន, កិតសុម៉ុន, សុផាប៉េត, វីឡេឡា, បុប្ផាភួង, សុម៉ារិន, ដួងបូរ៉ា, សយផា, ណារ៉ាកាន, សុម៉នមិត្រ, សយសង្វាន, ម៉ាឡាស៊ី... ។ នៅទីបញ្ចប់ លោកមានបន្ទូលថា :

~ឈ្មោះ សុម៉ាប៉េត វាមិនសមទេ, ស៊ីម៉ាឡា ក៏មិនសម... កាលពីដើមមានស្តេចភូមាមួយអង្គមានប្រពន្ធបី ប្រពន្ធទីមួយឈ្មោះ សារ៉ាម៉ានី, ទីពីរឈ្មោះ សុម៉ាប៉េត និង ទីបីឈ្មោះ ស៊ីម៉ាឡា ។ ស្តេចស្រឡាញ់នាង សារ៉ាម៉ានី ណាស់ ព្រោះនាងចេះថ្នាក់ថ្នម ហើយជាពិសេសទៅទៀត នាងមានកូនប្រុសមួយ ទុកសម្រាប់ស្នងរាជ្យ ដែលជាហេតុធ្វើឲ្យប្រពន្ធចុងទាំងពីរកើតក្តីច្រណែននិន្ទា រកឧបាយសម្លាប់ប្រពន្ធដើមចោលទៅ ។ ប៉ុន្តែបានគុណបុណ្យ នៃ អំពើល្អលោកជួយ នាងក៏បានរស់រានមានជីវិតឡើងវិញ ហើយរស់នៅយ៉ាងសុខសាន្តជាមួយស្វាមីរៀងរហូតមក ។ អញឲ្យឈ្មោះឯងថា សារ៉ាម៉ានី, ឯងទៅប្រាប់ឯម ឲ្យគេចុះឈ្មោះហ្នឹងដាក់ក្នុងសៀវភៅបញ្ជីទៅណា៎! ហើយនែ! អញផ្តាំផ្តាច់ បើអាណាហៅឈ្មោះឯងផ្សេងពីហ្នឹង កុំឆ្លើយឲ្យសោះ ។

ម៉មន្ទ អង្គុយក្រោយខ្នង លួចខ្សឹបប្រាប់ខ្ញុំឲ្យថ្វាយបង្គំហ្លួងបីផង ប៉ុន្តែខ្ញុំថ្វាយបានតែម្តង ក៏ស្រាបរឹងគាំងផ្អឹត រកធ្វើតទៅទៀតមិនកើត ។ លោកមានបន្ទូលតទៅទៀត :

~ឯងបានឈ្មោះល្អអញ្ចឹង ខំបំរើអញឲ្យល្អណា៎ កុំធ្វើឆ្គងដូចពួកមីឯទៀតនោះ អញស្អប់ណាស់ ។

ម៉មន្ទ ដឹកដៃខ្ញុំចេញទៅក្រៅវិញ ដែលនៅទីនោះ មានពួកម៉ាកខ្ញុំកំពុងឈរវង់ចាំកុះករ ដោយចិត្តច្រណែនឈ្នានីសថា ឈ្មោះខ្ញុំល្អជាងវា ។ មីប៉ុនវាបានឈ្មោះថា កេតស៊ីឡែចទៅហើយ ប៉ុន្តែដល់ឃើញឈ្មោះខ្ញុំល្អជាង វាក៏ប្រាប់អ្នកឯមថា ខ្ញុំព្រមដូរឈ្មោះជាមួយវា ឲ្យគាត់ចុះបញ្ជីថាឈ្មោះ សារ៉ាម៉ានី នេះជាឈ្មោះវាវិញ ។ ខ្ញុំទៅទូលហ្លួងពីរឿងនេះ ហើយហ្លួងក៏ហៅ មីប៉ុន ទៅស្តីឲ្យសន្ធឹកសន្ធាប់ ព្រមទាំងហាមមិនឲ្យនរណាដូរឈ្មោះខ្ញុំជាដាច់ខាត ។

ចាប់តាំងពីថ្ងៃនោះមក ខ្ញុំត្រូវបានរួចខ្លួនពីមុខការទាញខ្សែបក់ផ្លិត ប៉ុន្តែដោយខ្ញុំពុំចេះរបៀបរៀបចំខ្សៀអាភៀន គេគ្រាន់តែឲ្យខ្ញុំចាំទទួលយកខ្សៀដែលគេ «ធ្វើ»រួចស្រេច ដើម្បីយកទៅថ្វាយហ្លួងសោយតែប៉ុណ្ណោះ ។ មុខការនេះស្រណុកពេកណាស់ គ្រាន់តែប្រយ័ត្នប្រយែងបន្តិច ក៏គ្រប់គ្រាន់ណាស់ទៅហើយគ្មានចាំបាច់ហាយខ្នងរោយចង្កេះទេ ។ ហ្លួងផ្ទុំសណ្ដូកលើគ្រែដ៏តូចហើយទាប ប្រកបទៅដោយពូកទន់ល្មើយ មានកម្រាលកម្ទី ដែលគេផ្លាស់ប្តូរពណ៌រៀងរាល់ថ្ងៃ ម្តងបែរទៅខាងណេះ ម្តងបែរទៅខាងណោះ ដើម្បីទទួលខ្សៀអាភៀនពីស្រី ពីរ ឬ បួន នាក់ អង្គុយអមសង្ខាងគ្រែ ជាអ្នកចាំហុចថ្វាយយកទៅបឺតបង្ហុយ ។

ហ្លួងមិនសូវនិយាយស្តីអ្វីទេ ម្តងបែរទៅឆ្វេង ម្តងបែរទៅស្តាំ ដើម្បីហុចខ្សៀដែលសោយរួចហើយ ឬទទួលយកខ្សៀថ្មីមកទៀត...... យូរៗម្តង លោកសួរយើងពីចំនួនខ្សៀដែលលោកបានសោយរួចហើយ ។ ខ្ញុំមិនដែលចាំថា ហ្លួងសោយប៉ុន្មានខ្សៀទេ ម្ល៉ោះហើយគេក៏យកពែងមាសមកដាក់ពីមុខយើង កាលណាហ្លួងសោយមួយខ្សៀ យើងត្រូវទម្លាក់គ្រាប់ក្រហមមួយទៅក្នុងពែងនោះ ។ ទោះបីគេធ្វើយ៉ាងហ្នឹង ក៏យើងនៅតែភ្លេចភ្លាំងជាញឹកញយ ដែលជាហេតុញ៉ាំងឲ្យហ្លួងតវ៉ាថា លោកបានសោយ ច្រើនលើសចំនួនដែលយើងរាប់ឆ្ងាយណាស់ ។

ខ្ញុំចាំច្បាស់ថាក្នុងមួយថ្ងៃ យ៉ាងហោចណាស់ក៏ហ្លួងសោយអស់ជាងមួយរយខ្សៀដែរ ។ កាលណាហ្លួងសោយស្រវឹងហើយ លោកមិនរវល់រឿងយើងរាប់ខុសឬត្រូវទេ ប៉ុន្តែលោកជេរបញ្ចោរយើងជាញឹកញាប់ ព្រោះយើងចេះតែលួចបារីលោកចែកគ្នាជក់ និង ឆ្លៀតពេលលោកផ្ទុំលក់ ជជែកគ្នាខ្សឹបខ្សៀវ ឬ ចាក់ក្រឡេកប្រឡែងគ្នា ។

កាលណាហ្លួងសោយអាភៀនអស់កម្លាំង ហើយសម្ងំផ្ទំ ម៉មន្ទ ក៏ឡើងទៅសម្រាន្តលើគ្រែជិតលោកឧបរិតគ្នាទៅវិញទៅមក គ្មានគិតខ្មាសអៀនពួកយើងដែលនៅអង្គុយត្រៀបត្រានេះសោះ ។ ពេលនោះ



យើងនាំគ្នាថយទៅកាន់បន្ទប់មួយស្ថិតនៅជាប់គ្នានឹងបន្ទប់ហ្លួង ហើយប៉ើកមុងប្រះដេកទៅលើពូករនាបដែលគេរៀបចំទុករួចស្រេចសម្រាប់ឲ្យយើងសំរាក ។ យើងប្រះដេកកាលណា ក៏លក់ភ្លាមមួយរំពេច ពីព្រោះយើងពុំដែលគិតខ្វាយខ្វល់ព្រួយបារម្ភពីរឿងអត់ស៊ីមានស៊ីនៅថ្ងៃស្អែកឡើយ ។

យប់ខ្លះខ្ញុំភ្ញាក់ដឹងខ្លួនយប់កណ្តាលអាធ្រាត្រ ស្រាប់តែឃើញហ្លួងស្លៀកសារុងលែងខ្លួនទទេ ចេញក្បាលពោះទ្រយុក ដើរពាសពេញបន្ទប់តែម្នាក់ឯង ឥតមានដាស់នរណាសោះ ។ ជួនកាលលោកដើរមកជិតមុង ឈរមើលពួកយើងដេកយ៉ាងយូរ ហើយទាញជើងមុងរៀបដាក់ឲ្យស្រួលឡើងវិញ ដើម្បីកុំឲ្យមូសចូលខាំយើង ។

កាលណាលោកដើរតម្រង់មកកន្លែងខ្ញុំដេក ខ្ញុំសម្ងំបិទភ្នែកធ្វើហាក់ដូចជាដេកលក់ រង់ចាំទាល់តែលោកចេញទៅផុត ទើបងើបលួចមើលតទៅទៀត ។ ហ្លួងដើរយឺតៗកាត់បន្ទប់នានា ចេញទៅឈរលើរានហាលស្រូបយកធាតុអាកាសត្រជាក់ នៃ រាត្រីកាល ដែលមានសម្លេង ចង្រិត និង រៃ បន្លឺឥតដាច់រយៈ ជាគ្រឿងកំដរសភាពស្ងប់ស្ងាត់ ។ ហ្លួងរាប់ជំហានដើរទៅដើរមកជារបៀបហាត់ប្រាណ ដោយមិនបាច់ចេញទៅក្រៅវាំង ពីព្រោះគេកម្រនឹងអនុញ្ញាតឲ្យលោកចេញពីវាំងណាស់ ហ្លួងរស់នៅសព្វថ្ងៃ ប្រៀបបាននឹងមនុស្សជាប់គុកយ៉ាងនោះដែរ ។ លោកអត់ចេះខ្លាចខ្មោចទេ ហើយឈរភ្លឹកភ្លេចខ្លួន ហាក់ដូចជាគិតទៅវែងឆ្ងាយ ។

ហ្លួងចូលចិត្តមើលយើងដេកណាស់ ប្រហែលពីព្រោះទស្សនីយភាព នៃ យុវវ័យឥតក្តីទុក្ខព្រួយបែបនេះ អាចធ្វើឲ្យលោកទន់ចិត្តអាណិតស្រឡាញ់យើងក៏មិនដឹង ឬមួយក៏លោកមើលប្រយ័ត្នក្រែងនរណាមួយដេកបម្រះរបូតសំពត់ ខ្លាចក្រែងអ្នកបំរើប្រុសវាដើរកាត់តាមនេះ មើលឃើញក្តិតក្តាំងក៏មិនដឹង ។ ម្តងនោះ ខ្ញុំឃើញហ្លួងយកជើងផ្ចេះដាស់ស្រីៗដែលដេកផ្ងារចង្ក្រាងយះជើងឥតអាសូរ ហើយសំពត់របូតមកគ្របក្បាលឯណេះវិញ ។ លោកស្តីឲ្យពួកនោះសន្ធឹកសន្ធាប់ណាស់ ព្រមទាំងប្រាប់យើងទាំងអស់គ្នាថា ក្រោយៗបើឃើញនរណាដេកប្រហែលអញ្ចឹង ឲ្យយកឈើគូសអុជមម៉ិះក្តិតម្តង ទើបរាងរាង ។ របៀបប្រដៅបែបនេះ អាចទម្លាប់ឲ្យយើងចេះរស់នៅក្នុងជំនុំចំណោម ក៏ដូចជាទីស្ងាត់កំបាំងពីភ្នែកអ្នកដទៃដែរ គឺយើងចេះដេកសមរម្យ មិនកន្ទឹងកន្ទាំងផ្តេសផ្តាស ។

ដល់ពេលថ្ងៃសីលម្តងៗ ហ្លួងស្លៀកពាក់ស តមមិនសោយបាយល្ងាច អត់រហូតដល់ព្រឹកស្អែកមួយទៀត ។ ដោយអផ្សុកមិនដឹងធ្វើអ្វី លោកសោយអាភៀនបង្ហុយជាប់រហូត ភ្នែកសម្លឹងមើលទ្រនិចនាឡិកាប៉ោល ដោយក្តីអន្ទះអន្ទែង ហើយសួរច្រំដែលៗតែពីរឿងគេបាញ់កាំភ្លើងព្រឹកព្រហាមហើយឬនៅ? គួរឲ្យធុញទ្រាន់ពេកណាស់! ។

គ្រាន់តែមាន់រងាវមិនទាន់ លោកស្រែកដាស់គេដាស់ឯង នរណាមិនភ្ញាក់ ក៏ស្រែកជេរឡូឡាទាល់តែភ្ញាក់ ។ កាលណារឿងរ៉ាវដ៏អកុសលបែបនេះ ត្រូវធ្លាក់មកចំលើវេនខ្ញុំ ខ្ញុំត្រូវងើបសើងមម៉ើងភ្នែកមមីរ ទៅលាបម្សៅ, លាបទឹកអប់ ហើយចូលទៅអង្គុយគាល់ជាមួយមិត្តភក្តិឯទៀត ។ មួយប៉ប្រិចភ្នែកសោះ ម្ហូបអាហារក៏រៀបចំរួចស្រេច ហ្លួងចាប់សោយដូចឃ្លានដាច់ដាបណាស់ ហើយចេះតែបង្ខំយើងឲ្យធ្វើដូចលោក ប៉ុន្តែយើងធ្វើតាមមិនកើតសោះ ព្រោះវាងងុយដេកជាងឃ្លាន ម្ល៉ោះហើយអ្នកខ្លះដេកលក់អង្គុយក៏មាន ។

ប៉ុន្តែក្រោយពេលបរិភោគហើយ ហ្លួងតែងចែកបារីស៊ីហ្គារធំស្មើរបៀមមិនជាប់ ឲ្យយើងជក់លេងកំសាន្ត និង រង្វាន់ផ្សេងៗទៀត ដែលជាហេតុធ្វើឲ្យយើងសប្បាយរីករាយ រហូតទាល់តែភ្លេចងងុយដេកអស់រលីង ។

នេះជាជីវភាពរបស់ហ្លួង ដែលមានដំណើរប្រព្រឹត្តទៅចាប់តាំងពីពេលថ្ងៃលិចទៅទល់នឹងពេលថ្ងៃរះ ។ នៅខាងក្រៅវាំងឯណោះ ស្គរកាំភ្លើងម៉ោងប្រាំភ្លឺបន្លឺឡើង បណ្តាលឲ្យហ្លួងភ្ញែកដែលកំពុងដេកនៅតាម

ដើមឈើតាតា ក្នុងសង្កាត់កំពង់ផែ ភ្ញាក់ផ្អើលខ្សៀវខ្សា ដើម្បីស្វែងរកចំណីអាហារក្នុងថ្ងៃថ្មីមួយទៀត ។ កាលណាថ្ងៃក្ដៅ ហ្លួងផ្ទំសោយអាភៀនកែអផ្សុកមួយថ្ងៃវាល់ល្ងាច ។ ជាពិសេសក្នុងមួយថ្ងៃ ហ្លួងមុជទឹក ពីរ-បី ផង ដោយមានអ្នកបំពីប្រុសជាអ្នករៀបចំថ្វាយ ហើយលោកលាបទឹកអប់បារាំង ដែលទិញមកទុកទាំងខ្ទូ ឡើងក្រអូបឈ្ងុយឈ្ងប់ ។ ខ្ញុំក៏ឱស្សាហ៍លួចលាបទឹកអប់ហ្នឹងជាញឹកញយដែរ ។

មានតែទេសាភិបាលបារាំងទេ ដែលអាចមករំខានការសំរាកពេលថ្ងៃរបស់ហ្លួងមួយផងមួយយាមបាន ។ កាលណាគាត់ត្រូវការមកជួបហ្លួងម្ដងៗ គេសុទ្ធតែប្រាប់ពួកយើងឲ្យដឹងមុន ហើយនរណាចេះមើលម៉ោង ត្រូវទទួលបញ្ជាចាំដាស់ហ្លួងនៅវេលាម៉ោងបួន ដើម្បីលោកមានពេល មុជទឹក, ស្លៀកពាក់ខោអាវ និង ដកមេអាភៀន ពីរ-បី ខ្សៀសិន ។

ការប្រែប្រួលទម្លាប់ប្រចាំថ្ងៃបែបនេះ តែងធ្វើឲ្យយើងច្រឡំម៉ោងពេលជាញឹកញយ ម្ល៉ោះហើយហ្លួងភ្ញាក់ឡើងហួសម៉ោង ក្រវីក្រវាជេរបញ្ជោប៉ាតណាប៉ាតណីបណ្ដើរ ហៅយើងឲ្យទៅជួយ ស៊កស្រោមជើង, ចងខ្សែស្បែកជើង បណ្ដើរ ។ វល់តែឆ្លេមឆ្លម ក្រុមភ្លេងម៉ានីល[១] នៅក្នុងសួនច្បារ ចាប់ប្រគុំឡើងជាសញ្ញាឲ្យដឹងថា លោកទេសាភិបាលមកដល់ស្រេចទៅហើយ ។ លោកមហាមន្ត្រីចេញមកទទួលភ្ញៀវជាន់ខាងក្រោម ប៉ុន្តែពួកបារាំងដូចជាធុញទ្រាន់ខ្លាំងណាស់ ក្រពាត់ដៃដើរចុះដើរឡើងធ្វើមុខក្រញូវ ។

នៅជាន់ខាងលើឯណោះ ហ្លួងស្លៀកពាក់ ហើយនៅឲ្យគេយកទឹកអប់មកប្រោះលើខោអាវទៀត ។

ឆ្លៀតឱកាសនោះ យើងបានលួចបាញ់ទឹកអប់លាបខ្លួនឯងផងដែរ ។ បន្ទាប់មកហ្លួងអង្គុយចុះ ឲ្យយើងយកផ្លិតមកបក់ក្បាល ដើម្បីឲ្យឆាប់ស្ងួតសក់ ហើយមុននឹងចុះទៅជួបភ្ញៀវ ដែលគេកំពុងតែអង្គុយចាំនោះ លោកឆ្លៀតបឺតអាភៀន ពីរ-បី ហ៊ឺតសិន ។

នៅទីបំផុតហ្លួងចុះទៅដល់ គោរពគ្នាទៅវិញទៅមក ហើយចាប់ចរចាគ្នាដោយមាន លោកមហាមន្ត្រីធ្វើជាអ្នកបកប្រែ ។ យើងនាំគ្នាមកពួនពីក្រោយរនាំង ដែលគេដាក់បាំងទ្វារខាងក្រោយ ដើម្បីលួចមើលឆាកសន្ទនានេះតាំងពីដើមដល់ចប់ ។ ក្រោយពេលភ្ញៀវបារាំងចេញអស់ទៅ តែងមាននាម៉ឺនចូលមកគាល់បន្តបន្ទាប់គ្នា ហើយនៅពេលត្រឡប់មកបន្ទប់វិញ លោកមានទឹកមុខស្រពោនព្រួយបារម្ភអស់មួយយប់ ជួនកាលមានទាំងហៅម្ចាស់ក្សត្រីកូននោះ មកជជែកគ្នាយ៉ាងសម្ងាត់ទៀតផង ។

ពេលធម្មតា មានតែប្រជារាស្ត្រមកពីចុងកាត់មាត់ញក ដើម្បីមកសុំទានព្រះរាជទ្រព្យ ឬ មកសុំមើលព្រះភ័ក្ត្រហ្លួងឲ្យបានច្បាស់ម្ដងតែប៉ុណ្ណោះ ។ ហ្លួងចេញមកឲ្យអ្នកទាំងនោះថ្វាយបង្គំ ហើយប្រទានរង្វាន់បន្តិចបន្តួចឲ្យត្រឡប់ទៅវិញ ។ យើងទទួលភារៈកាន់សោទូ ដាក់លុយ និង គ្រឿងអាលង្ការ មួយវេនម្នាក់ ដែលជាភារៈធ្ងន់ធ្ងរគួរឲ្យខ្ញុំភ័យព្រួយលើសអ្វីទាំងអស់ ពីព្រោះហ្លួងឧស្សាហ៍ ដាក់លុយលើតុ, ដាក់បារីក្នុងជើងពាន ឬ ដាក់ទឹកអប់កន្លែងណាមួយ ហើយធ្វើជាភ្លេចចោល ដើម្បីចាប់ថ្នាក់យើងថាលួចរបស់លោកជាញឹកញយ ។

មុខការខ្ញុំកាន់តែយ៉ាប់ខ្លាំងឡើងៗ ហើយជាពិសេសទៅទៀត ខ្ញុំត្រូវទៅហាត់រាំរាល់ថ្ងៃ ឥតដែលខកខានពីព្រោះអ្នករបាំណាក៏ដោយ ឲ្យតែខកខានហាត់ ច្បាស់ជាធ្លាក់ខ្នងឈើ ចុករោយដៃជើង លែងទន់ភ្លន់ភ្លាមមួយរំពេច ។ រាល់ព្រឹក អ្នកគ្រូច្របាច់ដៃជើង សម្រួលសាច់ដុំឲ្យខ្ញុំ ដែលជាហេតុធ្វើឲ្យរាងខ្ញុំរឹតតែខ្ពង់ឡើង

(១) ក្រុមភ្លេងម៉ានីលនេះ គឺជាក្រុមភ្លេងបែបអឺរ៉ុប ដែលមានមកដល់ប្រទេសយើងមុនគេបង្អស់ សម្រាប់ប្រគុំក្នុងពិធីផ្សេងៗរបស់ហ្លួង ។ ហេតុដែលនាំឲ្យគេហៅថា ក្រុមភ្លេងម៉ានីល ពីព្រោះសមាជិកក្រុមនេះ សុទ្ធតែជាជនជាតិហ្វីលីពីនមកពីក្រុងម៉ានីល ។



ហើយខ្ញុំក៏មិនសូវឈឺថ្កាត់ក្នុងការចាំយាមបម្រើហ្លួងនៅវេនទីបួននេះ ។ ខ្ញុំបានឡើងឋានៈជាអ្នកគាល់បម្រើផ្ទាល់ និង កាន់សោទូព្រះរាជទ្រព្យតែម្ដង ។ វេនមួយៗ មានរយៈពេលដប់ពីរម៉ោងជាប់គ្នារហូត ដល់មានក្រុមថ្មីក្នុងចំណោមក្រុមបីផ្សេងទៀតចូលមកទទួលវេន គឺថាក្នុងរយៈពេល ពីរយប់ពីរថ្ងៃ, សែសិបប្រាំបីម៉ោង យើងត្រូវចូលវេនដប់ពីរម៉ោង ។ ប៉ុន្តែការដែលគួរឲ្យអផ្សុកបំផុត គឺក្នុងមួយអាទិត្យម្ដង ខ្ញុំត្រូវដល់វេនបម្រើហ្លួងសោយអាភៀន ពេញម្ដៃបួនម៉ោង ។ ខ្ញុំស្រកសាច់ចុះស្គមសន្ធឹកណាស់ ដោយសារមិនសូវបានដេកសម្រាកឲ្យពេញភ្នែក ម្ល៉ឹងហើយកាលណាគេហៅខ្ញុំទៅ ច្រៀងមហោរី ឬ សក្រវាទី ជាមួយអស់អ្នកអស់នាង ដែលគេជ្រើសរើសចម្រាញ់សុទ្ធតែជើងល្អឲ្យចូលក្នុងក្រុមតន្ត្រីនោះ ខ្ញុំក៏មិនដែលប្រកែកម្ដងណាឡើយ ។

ប៉ុន្តែ ទោះបីខ្ញុំខិតខំធ្វើការនឿយហត់យ៉ាងនេះក្ដី ក៏ហ្លួងមិនដែលមើលឃើញ សោតឯម្ចាស់ក្សត្រីក៏មិនដែលទូលហ្លួងថាម៉េចដែរ ព្រោះតែខ្ញុំមិនចេះអាររបៀបលុតក្រាបយកគាប់នៅនឹងមុខដូចគេ ។

ចំណែកឯមិត្តភក្តិខ្ញុំវិញ ខ្ញុំសង្កេតឃើញថា គេមានតែជួយជាន់ពន្លិចថែម ដើម្បីយកគាប់គួរសម្រាប់តែខ្លួនគេ ។ ធ្ងាញ់ណាស់ទៅទៀត ថ្ងៃមួយហ្លួងចោទប្រកាន់ថា ខ្ញុំលួចលុយពីររៀល ដែលលោកបានដាក់ក្នុងថាសមាស ទោះបីខ្ញុំប្រកែកថាមិនដឹងយ៉ាងណា ក៏លោកមិនព្រមស្ដាប់ ។ លុះដល់ខ្ញុំទៅខ្ចីលុយម៉ែបានពីររៀល មកសង លោកទទួលយកភ្លាម ថែមទាំងនិយាយថា :

– ហេងមែន! ចំលើពេលអញកំពុងខ្វះលុយផង! តែប៉ុណ្ណេះម៉េចក៏គ្រាន់នឹងចាយបណ្ដើរៗ ទម្រាំដល់ដាច់ខែដែរ ។

ហើយលោកប្រទានលុយឲ្យបោយទៅទិញទឹកកកមកភ្លាមមួយរំពេច ។ រំលងមកបានប៉ុន្មានថ្ងៃ លោកហ៊ាននិយាយដោយឥតអៀនខ្មាសថា លុយពីររៀលនេះគ្មាននរណាលួចទេ គឺលោកយកខ្លួនឯង ប៉ុន្តែលោកចង់បំភ័យយើង ដើម្បីទក់មើលទឹកមុខ តើនរណាខ្លះវាខូច ទម្លាប់មានដៃមានជើង ។ លុយពីររៀលនេះហ្លួងឥតសងខ្ញុំរហូត ។ ប៉ុន្តែក្រោយមកមិនយូរប៉ុន្មាន ម៉ែខ្ញុំបានចូលមកសុំគាល់ហ្លួង ដើម្បីសុំព្រះរាជទ្រព្យខ្លះយកទៅជួសជុលផ្ទះ ព្រោះសសរពុកអស់ទៅហើយ ហើយជញ្ជាំង ជំបូល ក៏រហែកធ្លុះធ្លាយខ្លាំងណាស់ដែរ ។ ក្រោយពីបានស្គាល់ថាជាម្ដាយខ្ញុំ ហ្លួងក៏ប្រទានលុយសែសិបរៀលឲ្យម៉ែដោយផ្ទាល់ដៃ ។

ឃើញហ្លួងដូចជាសប្បុរសយ៉ាងនេះ ខ្ញុំក៏ប្រថុយទូលសុំច្បាប់ទៅលេងផ្ទះបងប្អូនឯស្រែបាន ពីរ-បី ថ្ងៃ។ មិនយូរប៉ុន្មាន សំបុត្រឡាយធ្លាក់មកមាន ទូក, ដឹរ, រទេះ ខ្ញុំជ្រើសរើសយកមួយណាសម្រាប់ធ្វើដំណើរក៏បាន ព្រមទាំងមានក្រុមវាំងជូនដំណើរផង ។ ខ្ញុំជ្រើសរើសយកដឹរ ហើយនៅវេលាព្រលឹមស្រាងៗ នៃ ខែបុស្ស ខ្ញុំចេញដំណើរទៅជាមួយ ពុក និង ម៉ែ ដោយមានក្រុមវាំងចាស់ស្ងួតបួតមាក់ជូនទៅ ។ យើងធ្វើដំណើរតាមបណ្ដោយស្ទឹងព្រែកត្នោតពេញមួយថ្ងៃ ឆ្ពោះទៅកំពង់កន្ទួត ។

សប្បាយអ្វីម្ល៉េះទេ! ខ្ញុំធូរទ្រូងខ្សាកនៅពេលបានចេញមកដកដង្ហើមស្រូបយកខ្យល់អាកាស នៃសេរីភាពនៅខាងក្រៅ ។ ពុក សម្លឹងមើលមកខ្ញុំដោយក្រសែភ្នែកស្រទន់ គាត់ហ៊ឺហាក្នុងចិត្តខ្លាំងណាស់ ដែលមានកូនស្រី ជាអ្នកបំរើហ្លួង ជាអ្នករាំល្ខោនហ្លួង ។ យើងអង្គុយលើកន្ទេលដែលក្រាលលើក្ដបដឹរ ឃ្លេងឃ្លោងយោលខ្លួនប្រៀបបាននឹងជិះទូក ដោយសារចលនាបោះជំហានទៅមុខមួយៗ នៃ ពាហនៈជាជំនិះ ។ ជុំវិញខ្លួនឃើញតែវាលស្រែតជាប់គ្នាឆ្ងាយដាច់កន្ទុយភ្នែក ខ្លះក៏ច្រូតហើយ ខ្លះមិនទាន់ច្រូតនៅឡើយ... ដើមត្នោតដុះ ឯណេះមួយដុំ ឯណោះមួយដុំ ឃើញតែដើមត្រង់ឆ្អឹត និង ស្លឹកមួយកញ្ចុំនៅពីលើ ហើយនៅឆ្ងាយជាប់នឹងជើងមេឃ ស្រមោលជួរភ្នំខៀវស្រងាត់ជាប់គ្នារដឹក ។

យើងមាន ខ្ចប់បាយ និង ម្ហូបគោក ព្រមទាំងបង្អែមផ្លែឈើ មកផង ហើយយើងនាំគ្នាបរិភោគយ៉ាងឆ្ងាញ់

ក្រៃលែង ក្រោមជំនោររហើយ នៃ ហេមន្តរដូវ ។

នៅពេលទៅដល់កំពង់កន្ទួត ផ្អើលតាំងពី មេស្រុក, បាលដ្ឋ, សុភា, រហូតដល់អ្នកស្រុកអ្នកភូមិ មកចោមរោមកុះករទទួលខ្ញុំ ហើយសុំឲ្យខ្ញុំរាំឲ្យគេមើលម្ដងផង ។ អ្នកស្រែខ្មៅក្រញេះ ហៅខ្ញុំសុទ្ធតែម្ចាស់ក្សត្រី ឃើញគ្រឿងអលង្ការដែល ម៉ែមទ្ធ ឲ្យខ្ញុំខ្ចីពាក់មក គេជញ្ជក់មាត់សរសើរគ្រប់គ្នា ។ ម្ដាយមីងខ្ញុំឈ្មោះ ម៉ុម ហៅយើងឲ្យទៅសំណាក់នៅផ្ទះគាត់ ដែលសង់នៅនឹងមាត់ស្ទឹង ប៉ុន្តែហ្វូងអ្នកស្រុកដែលទើបនឹងបានដឹងថា មានពួកលោកឃុនមកក្នុងស្រុកខ្លួនអញ្ចឹង ចេះតែលើកគ្នាមកមើលមិនចេះអស់មិនចេះហើយសោះ ។

♥ ♥

♥

ក្រុមតន្ត្រីរបាំព្រះរាជទ្រព្យ



Orchestre du Palais Royal



ឆ្នាំរោង ជិតនឹងផុតទៅហើយ គឺហ្លួងថ្មីឡើងគ្រប់គ្រងនគរបានពីរឆ្នាំហើយ ។ តាមការគន់គូររបស់តាហោរា និង បាគូ ពិធីបុណ្យអភិសេកហ្លួងឡើងសោយរាជ្យ នឹងត្រូវរៀបចំធ្វើនៅ ដើមឆ្នាំមមីខាងមុខនេះ ។

ជីវភាពរស់នៅក្នុងវាំងកាន់តែប្រែជាយ៉ាប់យ៉ឺនឡើងជាងពេលណាទាំងអស់ ។ ខ្ញុំត្រូវបំពេញមុខការជាធម្មតាផង និង ត្រូវទៅហាត់រាំរៀងរាល់ថ្ងៃមិនដែលខកខានផង ដើម្បីចេញរាំក្នុងឱកាសបុណ្យដ៏មហោឡារិក នៅពេលខាងមុខនេះ ។ យើងទាំងអស់គ្នា កើតមានការព្រួយបារម្ភខ្លាំងណាស់ ពីព្រោះយើងដឹងថា ទេសាភិបាលបារាំងនឹងឡើងមកពីក្រុងព្រៃនគរ ដើម្បីមកបំពាក់មកុដរាជ្យជានិមិត្តរូប នៃ អំណាច ថ្វាយហ្លួង ហើយបើតាមពាក្យចចាមអារាម ដែលគេនិយាយពីមាត់មួយទៅមាត់មួយថា ហ្លួងនឹងត្រូវចេញដំណើរទៅស្រុកបារាំង ឯនាយសមុទ្រឯណោះផង ។

ក្នុង រោងជាង និង ថែវ នៅទីធ្លាខាងក្រៅ ពួកជាងធ្វើការញាប់ដៃញាប់ជើង សង់ជារោងឈើតាំងលំអដោយក្រដាសលាបពណ៌ព័ទ្ធជុំវិញទេវាវិនិច្ឆ័យ និង សង់ជាភ្នំកៃលាសក្លែងក្លាយមួយ ដែលហ្លួងត្រូវឡើងឈរលើកំពូលភ្នំនោះ ដើម្បីទទួលទឹកមន្តពី បាគូបុរោហិត ។ វាំងទាំងមូលអ៊ូអរទាំងយប់ទាំងថ្ងៃ គឺនាម៉ឺនចេញចូលជំនុំគ្នាមិនដាច់មិនស្រេចសោះ ពីរឿងកាត់ខោអាវស្លៀកឲ្យបានហ៊ឺហាក្នុងពេលបុណ្យ ។ លោកមហាទេព និង លោកមហាមន្ត្រី ត្រួតត្រាមើលជាងធ្វើការទាំងខាងក្នុងទាំងខាងក្រៅទេវាវិនិច្ឆ័យ ក្នុងទេវាទក្សិណ មហាមន្ទីរកន្លែងទទួលព្រះរាជវង្សានុវង្ស និង កន្លែងទទួលអស់អ្នកអស់នាងក្នុងវាំង ឲ្យស្បថសម្ដែងភក្ដីភាពចំពោះព្រះមហាក្សត្រ... ។

ពិធីបុណ្យអភិសេក រៀបចំធ្វើឡើងពេញប្រាំមួយយប់ប្រាំមួយថ្ងៃ ហើយក្នុងរយៈពេលនេះ មានភ្ញៀវបារាំង ស្ដេច និង ខ្ញុំរាជការ ចេញចូលក្នុងទេវាវិនិច្ឆ័យ ថ្វាយបង្គំច្រើនកុះករ ។

ព្រះសង្ឃគ្រងចីវរលឿង និមន្តមកសូត្រធម៌គ្រប់ទាំងប្រាំមួយថ្ងៃ ហើយពួកបាគូប្លូងសក់ ពាក់អាវផាយប៉ាក់ឱមាស ដៃកាន់រូបសំណាក ព្រះវិស្ណុ ព្រះសិវៈ ព្រះខាន់រាជ្យ និង ត្រា ជាសញ្ញា នៃ អំណាចគ្រប់បែបយ៉ាង ដែលគេប្រគល់មកឲ្យខ្លួនថែរក្សានោះ ក៏រវល់ខ្វែងដៃខ្វែងជើងខ្លាំងណាស់ដែរ ។

ហ្លួងដូចជារីកមុខរីកមាត់សប្បាយចិត្តរកអ្វីមកប្រៀបឲ្យស្មើពុំបាន ។ លោកភ្លេចអស់គំនិតផ្ដេសផ្ដាសកាលពីមុន គេបង្គាប់ថាឲ្យលុតក្រាបយ៉ាងម៉េចតាមទំនៀមទម្លាប់ ក៏ចេះតែធ្វើតាមគេទាំងអស់ ។ លោកស្លៀកពាក់ស្អាតអស្ចារ្យ ដូរពណ៌ ស្វាយ លឿង ស ឬ ខ្មៅ ទៅតាមថ្ងៃ ព្រមទាំងទ្រង់គ្រឿងអលង្ការដ៏មានតម្លៃកាត់ថ្លៃមិនបាន ។

ប្រជារាស្ត្រ នៅក្នុងរាជធានីខ្លះ មកពីខេត្តក្រៅខ្លះ ឈរប្រជ្រៀតគ្នាណែនណាន់តាន់តាប់ ដើម្បីមើលពិធីនេះ ។

មិនដឹងជាយល់ឃើញយ៉ាងម៉េច បានជាគេយកពួកល្ខោនមកឲ្យរាំក្នុងទេវាវិនិច្ឆ័យ ដែលពោរពេញទៅដោយនាម៉ឺនគ្រប់ជាន់ថ្នាក់យ៉ាងនេះទៅវិញ ។ ខ្ញុំដូចជាចាំថា ក្នុងរាជ្យមុនគេអត់ដែលមានធ្វើអញ្ចឹងទេ ឬមួយគេធ្វើតាមទំនៀមទម្លាប់បុរាណតាំងពីយូរណាស់ហើយក៏មិនដឹង ។ នៅខាងក្រៅក្នុងទីធ្លាក្រាលឥដ្ឋនោះ មានសង់រោងសក្ការៈបួន ដាក់ត្រង់ទិសទាំងបួន ហើយមានអ្នករបាំបួននាក់ឈរយាមប្រចាំការ រង់ចាំតែភ្លេងឲ្យសញ្ញាឡើង នឹងអាលធ្វើពិធីបូជា ជានិមិត្តរូប ។

ក្រុមខ្ញុំមានគ្នាដប់ប្រាំមួយនាក់ ជាក្រុមសំខាន់ជាងគេ ត្រូវរាំនៅក្នុងទេវាតែម្តង ។ ការដែលគេប្រគល់កិត្តិយសយ៉ាងនេះមកឲ្យខ្ញុំ ធ្វើឲ្យខ្ញុំឡើងជំនោរបន្តិចដែរ ប៉ុន្តែបើនិយាយពិតទៅ ខ្ញុំដូចជាខ្មាសខ្លាំងណាស់ ដែលឲ្យមករាំមុខព្រះសង្ឃអញ្ចឹង ពីព្រោះវិន័យសង្ឃហាមផ្តាច់មិនឲ្យមើលរបាំរាំរ៉ែកអ្វីទេ ។ ប៉ុន្តែធ្វើម៉េចបើកាលៈទេសៈវាតម្រូវអញ្ចឹងទៅហើយ ។ យើងមានគ្នា ១៦ នាក់ តម្រៀបជាពីរជួរ, ជួរខាងឆ្វេងប្រាំបីនាក់ដើរតួប្រុស, ជួរខាងស្តាំប្រាំបីនាក់ដើរតួស្រី ។ យើងដើរចូលមកក្នុងឆាក ដែលនៅទីនោះ គេមានតម្រៀបជើងពានដប់ប្រាំមួយជាពីរជួរទុករួចស្រេច ហើយយើងអង្គុយចុះពីមុខជើងពានមួយម្នាក់រៀងៗខ្លួន ។ ភ្លេងចាប់ប្រគុំបទបើកឆាក យើងម្នាក់ៗលូកដៃចាប់ជើងពានរៀងៗខ្លួន ដែលមានដីកល់គ្រឿងបូជាផ្សេងៗ ដូចជាសាច់ជ្រូក, មាន់ស្ងោរ, ផ្លែឈើ និង ចំណីច្រើនមុខទៀត ហើយយើងលើបឈរឡើងធ្វើកាយវិការបូជាទៅគ្រប់ទិសទាំងបួន ។ របាំនេះចប់ទៅ យើងដាក់ជើងពានចុះទៅវិញ ហើយភ្លេងឆាបញ្ចុះក៏ចាប់ប្រគុំឡើងដោយមានភ្លេងរ៉ៅ បន្តរតាមក្រោយយ៉ាងញ័រទទ្រើក ជាសញ្ញាប្រាប់ថា ដល់ពេលចូលទៅក្នុងឆាកវិញហើយ ។ ពេលនោះ ពួកតួប្រុសយកដៃកៀកចង្កេះពួកតួស្រី ហើយបណ្តើរគ្នាមួយគូម្តងៗ ចូលបង្គួសទៅដល់ក្នុងទីតាំងទក្សិណា ។

ពិធីនេះមានធ្វើដដែលៗប្រាំមួយថ្ងៃជាប់គ្នានៅក្នុងទេវាវិនិច្ឆ័យ ហើយក្រោយពេលចប់របាំបួងសួង ខ្ញុំត្រូវចេញទៅរាំរឿងបុរាណឲ្យប្រជារាស្ត្រមើលលេងកំសាន្ត រហូតទល់ភ្លឺទៀតផង ។

ទោះបីនឿយហត់យ៉ាងណាក្តី គឺខ្ញុំពុំដែលទម្រន់ត្អូញត្អែរដល់ម្តងណាឡើយ ពីព្រោះខ្ញុំដឹងខ្លួនថាបន្តិចទៀតខ្ញុំគង់នឹងបានឡើងធ្វើជាតួឯកមិនខាន ហើយការដែលខ្ញុំអាចបំពេញក្តីប្រាថ្នារបស់ខ្លួនឯងបានយ៉ាងនេះ វាអាចធ្វើឲ្យខ្ញុំភ្លេចការនឿយហត់អស់រលីង ប្រសើរជាងរង្វាន់ដែលហ្លួងធ្លាប់ប្រទានឲ្យនោះទៅទៀត ។

ផ្ទុយទៅវិញ មានមិត្តភក្តិតិចណាស់ ដែលមានយោបល់ស្របនឹងខ្ញុំ ។ ហ្លួងឥតរវល់យកចិត្តទុកដាក់មើលរបាំរាំរ៉ែកទេ លោកជាប់ចិត្តតែនឹងគ្រឿងតុបតែងលំអខ្លួន នៃ ប្រពន្ធជាទីគាប់ចិត្តទាំងពីរ គឺ ម៉ម ទួ និង ម៉ម ប្រឹម រហូតដល់យល់ថា គ្មានរបស់អ្វីប្រសើរ និង មានប្រយោជន៍ជាងស្ត្រីទាំងពីរនាក់នេះទេ ។ សិល្បៈពិតប្រាកដ ដែលមានលាក់បង្កប់នូវតម្លៃអាថ៌កំបាំងក្នុងចលនាពត់ពេនទន់ភ្លន់ នៃ ពួកអ្នករបាំ ដែលអាចញ៉ាំងហ្លួងទស្សនិកជន ឲ្យសើច ឲ្យយំ ឲ្យរំភើបញាប់ញ័រ ទៅតាមជម្រៅធាតុពិត នៃ ចលនារបស់ខ្លួននោះ វាពុំអាចធ្វើឲ្យហ្លួងគាប់ចិត្តផងទេ ។ ហេតុនេះ ទើបបានជាសព្វថ្ងៃ គេកាត់ដកស្រង់សាច់រឿងពីនេះបន្តិចពីនោះបន្តិច យកមកបញ្ចូលគ្នាគ្រាន់តែដើម្បីរាំបង្គ្រប់កិច្ចប៉ុណ្ណោះ គេលែងរាំរឿងនីមួយៗហូរហែតាំងពីដើមដល់ចប់ដូចពីមុនទៀតហើយ សូម្បីតែពួកគ្រូក៏លែងត្រួតត្រាមើលឲ្យយើងស្លៀកពាក់ត្រឹមត្រូវ មុនពេលចេញរាំម្តងៗដែរ ។



រឿងរ៉ាវដែលអាក្រក់ហួសពីអាក្រក់ទៅទៀតនោះ គឺសព្វថ្ងៃនេះគេពុំអាចរកពួកល្ខោនណាម្នាក់ ដែលចេះរាំពិតប្រាកដបានទេ ។ ចំណែកឯហ្លួងវិញ កុំសង្ឃឹមថាលោកហ៊ានចំណាយព្រះរាជទ្រព្យ ដើម្បីរៀបចំក្រុមល្ខោនជាថ្មីឡើងវិញឲ្យសោះ ពីព្រោះ លោកមហាមន្ត្រី ទ្រង់សួរីវង្ស និង កូនចៅឯទៀត ដែលជាអ្នកត្រូវបានទទួលកេរ្តិ៍ពីហ្លួង គេឃើញហ្លួងចាស់ជរាជិតចូលទីវង្គត់យ៉ាងនេះ គេមិនព្រមឲ្យលោកយកព្រះរាជទ្រព្យទៅចំណាយឥតប្រយោជន៍ទេ ប៉ុន្តែគេឲ្យលោកយកទៅទិញ ផ្ទះសម្បែង ឬ មាសពេជ្រវិញ សម្រាប់កាលណាហ្លួងសុគតទៅ គេស្រណុកវាយចំណែកចែកគ្នា ។

ចំពោះយើងជាអស់អ្នក-អស់នាងក្នុងវាំង ពេលមានរៀបចំធ្វើបុណ្យដែលគេទាំងអស់គ្នាត្រូវសប្បាយរីករាយយ៉ាងនេះម្តងៗ ផ្ទុយទៅវិញវាជាពេលដែលយើងត្រូវធ្វើការនឿយហត់ក្រៃលែង ម្ល៉ោះហើយយើងបន់មួយថ្ងៃដប់ដង ឲ្យតែបុណ្យចង្រៃនោះឆាប់ចប់ស្រឡះទៅ ។

យើងត្រូវរាំប្រាំមួយថ្ងៃប្រាំមួយយប់ នៅលើឆាកខាងក្រៅកណ្តាលហ្វូងប្រជារាស្ត្រ ដែលឈរមើលប្រជ្រៀតគ្នាកកកុញ ធុំក្លិនស្អុយញើសជះមួយភាយៗមកដល់យើងស្ទើរទ្រាំពុំបាន ទោះបីយើងខំបាញ់ទឹកអប់លាបខ្លួនឲ្យក្រអូបយ៉ាងណាក៏ដោយ ។

មកដល់យប់ទីប្រាំ ខ្ញុំអស់កម្លាំងទប់ខ្លួនពុំជាប់ ទ្រាំខាំមាត់រាំរឿង ឯណាវបុស្បា តទៅទៀតស្ទើរមិនរួច... នៅពេលដែលស្គរខ្ទង់សញ្ញារំលោងនោះ ពិតជាមាន់រងាវ មេឃក្រហមឯកើតស្រេចទៅហើយ ។ ខ្ញុំដើរទ្រេតទ្រោតចូលទៅក្នុងវាំងវិញតាមទ្វារព្រលប់ ទាំងត្របកភ្នែកទន់បើកពុំរួច ។ ទៅដល់ដំណាក់ម្ចាស់ក្សត្រី ខ្ញុំដេកលក់ឈរ បណ្តោយឲ្យគេដោះសម្លៀកបំពាក់ដែលរឹតួតជាប់ខ្លួនខ្ញុំ មួលខ្មៅដោះកងដៃកងជើងតាមចិត្ត ។ គ្រាន់តែដោះសម្លៀកបំពាក់ហើយភ្លាម ខ្ញុំមិនទាំងរវល់លប់មុខ លាងម្សៅយីហ៊ុនផង ខ្ញុំឡើងទៅដល់បន្ទប់ដេកនៅឯជាន់ទីមួយ នៃ អតីតដំណាក់ឃុនថាន់ ហើយប្រះដេកទៅលើគ្រែលក់ភ្លាមមួយរំពេច ។

ខ្ញុំភ្ញាក់ពីដេកយឺតហួសពេលខុសធម្មតា ឃើញក្បួនដង្ហែហ្លួងជុំវិញរាជធានីនោះ ប្រុងរៀបចេញពីវាំងទៅហើយ ។ ស្រីៗណាចង់ទៅតាមក្បួនដង្ហែ គេឲ្យជិះលើរទេះ ប៉ុន្តែខ្ញុំហាក់ដូចជាគ្មានចិត្តគិតចង់ទៅជាមួយគេបន្តិចបន្តួចសោះ ទើបខ្ញុំដើរទៅមុជទឹកសំអាតខ្លួនយឺតៗ គ្មានប្រញាប់ប្រញាល់សោះអ្វីឡើយ ។ ថ្ងៃនេះ ជាថ្ងៃបញ្ចប់បុណ្យ លែងមានរាំរ៉ែកទៀតហើយ អ្នកឯទៀតក៏ចេញទៅក្រៅវាំងទាំងអស់គ្នាដែរ ដូច្នេះខ្ញុំនៅស្ងាត់ម្នាក់ឯង អាចឡើងតាមជណ្តើរទៅដល់កំពូលប្រាសាទបាញ់យ៉ុង ដើម្បីគយគន់មើលទិដ្ឋភាពក្រុងភ្នំពេញ ពីលើទីខ្ពស់មកយ៉ាងសប្បាយរីករាយ ។

ទីធ្លាកិត្តិយសលាតសន្ធឹងនៅពីក្រោមខ្ញុំ ពេញចង្អៀតទៅដោយហ្វូងទស្សនិកជន យួន ចិន បារាំង និង ស្ត្រីខ្មែរ ដែលគេអាចសម្គាល់យ៉ាងច្បាស់បានដោយសារក្រមាពណ៌ឆើតទទូរលើក្បាល ។ នៅក្នុងថែវជុំវិញវាំង នាម៉ឺនធំៗ ក្នុងរាជធានី និង មកពីគ្រប់ខេត្តខ័ណ្ឌ បានរៀបចំតុសម្រាប់មណ្ឌលរបស់ខ្លួនម្នាក់ៗ ដោយមាននាំយករបស់មានតម្លៃផ្សេងៗ មកតាំងលំអក្នុងឱកាសបុណ្យអភិសេកហ្លួងនេះផង ។

ក្បួនដង្ហែដ៏វែងចេញផុតក្លោងទ្វារ ហើយបត់ទៅខាងត្បូង តាមផ្លូវជាប់នឹងរបងវាំង ។ នៅឯម្ខាងកំផែងសីមា ខ្ញុំមើលឃើញស្វេតច្ឆ័ត្រលាបពណ៌មាស និង គ្រែស្នែងដែលមានហ្លួង ពាក់មកុដ និង គ្រឿងអលង្ការមានតម្លៃចាំងផ្លេកៗ អង្គុយត្តុបពីលើនោះ ។ ក្នុងសួនច្បារមាត់ច្រាំងកំពង់ផែ មនុស្សមិនសូវកកកុញពេកទេ ព្រោះគេរវល់តែរត់មកប្រជ្រៀតមើលក្បួនដង្ហែស្តេចសោយរាជ្យ នៅមុខវាំងឯណោះ ។

ខ្ញុំចុះពីលើដំបូលប្រាសាទបាញ់យ៉ុង មកអង្គុយក្នុងដំណាក់ម្ចាស់ក្សត្រី ដើម្បីរង់ចាំទម្រាំក្បួនដង្ហែ

ត្រឡប់មកដល់វាំងវិញ ។ អស់រយៈពេលជាច្រើនម៉ោងក្រោយមក ទើបហ្លួងត្រឡប់ចូលមកវាំងវិញតាមទ្វារខាងជើង ដោយជិះលើដីរ និង ដោះមកុដចេញ ពាក់មួកមាលាជំនួសវិញ ។ លោកយាងចូលរហូតដល់ទេវាវិនិច្ឆ័យ មានទាំងក្បួនហែហមជូនជាប់រហូតមក ។

ឥឡូវ សម្ដេចឧបរាជ បានទទួលអភិសេកជាស្ដេចសោយរាជ្យពេញលក្ខណៈហើយ ប៉ុន្តែការផ្លាស់ប្ដូរនេះ វាពុំបានធ្វើឲ្យយើងខ្វល់ខ្វាយទេ ពីព្រោះខ្ញុំសង្កេតឃើញថា មុនពេលអភិសេក ឬ ក្រោយពេលអភិសេក ហ្លួងនៅតែហ្លួងដដែល គ្មានឃើញប្លែកអ្វីសោះ ។ ហើយគ្រាន់តែពិធីអភិសេកចប់សព្វគ្រប់កាលណា ជីវភាពនៅក្នុងវាំងក៏ចាប់ប្រព្រឹត្តទៅជាធម្មតាដូចកាលមុនដែរ ឥតឃើញប្រែប្រួលបន្តិចបន្តួចសោះទេ ។ ប៉ុន្តែ មិនទាន់បានប៉ុន្មានផង ស្រាប់តែដំណឹងថា ហ្លួងត្រូវយាងទៅស្រុកបារាំង ដែលកាលពីមុនគ្មាននរណារវល់យកចិត្តទុកដាក់គិតគូរសោះនោះ លេចឮឡើងជាថ្មីម្ដងទៀត បណ្ដាលឲ្យយើងភ័ន្តភាំងស្រឡាំងកាំងគ្រប់គ្នា ។

យើងពុំយល់ថា ហ្លួងយាងទៅស្រុកបារាំងដើម្បីប្រយោជន៍អ្វីទេ ប្រហែលជាបារាំងចង់នាំហ្លួងយើងទៅឃុំឃាំងទុកឯស្រុកគេ ដើម្បីគេស្រួលរំលោភយកទឹកដីយើងក៏មិនដឹង ? ប្រសិនបើអញ្ចឹងមែន យើងមិនគួរឆ្លូតទៅតាមហ្លួង ឲ្យជាប់គុកវេទនានៅស្រុកគេ ឆ្ងាយពី ម៉ែ-ឪ ពីស្រុកទេសទេ ។ ពាក្យចចាមអារាមចេះតែមានលេចឮពីមាត់មួយទៅមាត់មួយ មានអ្នកក្រៅវាំងជួយថែមថយបន្តិចបន្តួចទៀត ហើយនរណាភ័យជាងគេ ក៏ចេះតែស្រមៃឃើញអារឿងភ័យ នាំយកមកនិយាយបន្លាចឲ្យជ្រួលច្របល់អស់មួយផ្ទៃវាំង ។ គេនិយាយថា បារាំងអត់ឲ្យស៊ីបាយទេ គេបង្ខំឲ្យយើងស៊ីនំប៉័ងដូចគេអញ្ចឹង យើងត្រូវជិះកប៉ាល់កាត់សមុទ្រធំ មើលកោះមើលត្រើយមិនឃើញ ហើយយើងគង់នឹងកើតជម្ងឺពុលរលក ក្អួតចង្អោរស្ទើរងាប់ស្ទើររស់មិនខាន ។ នៅលើកប៉ាល់ បារាំងហាមផ្ដាច់មិនឲ្យមានមនុស្សឈឺទេ មើលតែនរណាបែបមិនសូវស្រួល គេចាប់បោះទៅក្នុងសមុទ្រ ឲ្យ ឆ្លាម ក្រពើ ស៊ីភ្លាមមួយរំពេច ។ ឮពាក្យសំដីអស់នេះ ខ្ញុំខ្លាចព្រឺសម្បុរគីង្គក់ ! ។

ម្ចាស់ក្សត្រី វិមធីតា ម៉មន្ទ និង ម៉មប្រឹម ត្រូវទទួលភារៈជ្រើសរើសអ្នករបាំសម្រាប់ដង្ហែហ្លួងទៅស្រុកបារាំង ។ ពួកយើងច្រើនគ្នាណាស់បានប្រកែកដាច់អហង្ការពុំព្រមទៅ រហូតដល់អ្នកខ្លះទៀតសុខចិត្តយកជំនូនបន្តិចបន្តួចមកសូក ម៉មន្ទ និង ម៉មប្រឹម ដើម្បីឲ្យគាត់ដាក់ឈ្មោះខ្លួនថាមានជម្ងឺ ពុំអាចដង្ហែហ្លួងទៅបានទៀតផង ។ ពួកអ្នករបាំជើងឆើត និង អស់អ្នកអស់នាងស្អាតៗ សុទ្ធតែប្រកែកពុំព្រមទៅ ផ្ទុយទៅវិញពួកស្រីចាស់ៗ អ្នកបំពីដ៏មានរូបរាងអាក្រក់គួរខ្មាសអៀនោះ បែរជាលើកទ័ពមកសុំចុះឈ្មោះឲ្យបានទៅជាមួយកូនខ្លួន ។

អ្នកខ្លះ ដែលកាលពីដើម មិនដែលទាំងហ៊ានមកឡែមឡឺមក្បែរទ្វារវាំងផង ឥឡូវស្រាប់តែបានមកហែហមម្ចាស់ក្សត្រី ទៅស្រុកបារាំងយ៉ាងក្រអឺត ។ ទ្រាំមិនបានហ្លួងលាន់មាត់ថា :

~ ទេ ! ទេ ! កុំឲ្យមីនេះទៅហ្នំ ! រូបរាងអាក្រក់ម្លឹងៗឲ្យវាដង្ហែអញទៅ អញខ្មាសបារាំងងាប់ហើយ ! ។

ប៉ុន្តែគ្មាននរណាស្ដាប់សំដីហ្នឹងទេ អ្នកមកចុះឈ្មោះចេះតែមានជាបន្តបន្ទាប់គ្នា រហូតដល់ពេលចេញដំណើរ ហើយនៅពេលកប៉ាល់ចេញដំណើរទៅនោះ ស្រាប់តែឃើញមានអ្នកខ្លះឡើងមកសម្ងំពួនតាំងពីយូរហើយផង ។

ចំពោះខ្លួនខ្ញុំ ខ្ញុំដឹងច្បាស់ថា មិនអាចគេចផុតទេ ពីព្រោះខ្ញុំគ្មានជន្ទល់ការពារខ្លួនឲ្យបានមាំមួននឹងគេ ។ ម្ល៉ោះហើយ គេចុចឈ្មោះ ខ្ញុំ និង ពួកម៉ាក ពីរ-បី នាក់ទៀត ឲ្យទៅរាំនៅស្រុកបារាំង មុននរណាទាំងអស់ ។ ទោះបីម៉ែយំស្រែកមិនព្រមឲ្យខ្ញុំយកឆ្អឹងទៅចោលនៅស្រុកគេយ៉ាងណា ក៏ខ្ញុំនៅតែធ្វើស្ងៀង មិនខ្វីឲ្យចាញ់



ចិត្តនរណាដែរ គឺខ្ញុំ ពុំព្រមប្រកែក ពុំព្រមអង្វរម្ចាស់ក្សត្រី អ្វីទាំងអស់ ។

ប៉ុន្មានអាទិត្យមុនពេលចេញដំណើរ ខ្ញុំត្រូវខំហាត់រាំទាំងព្រឹកទាំងល្ងាច ទុកសម្រាប់រាំនៅស្រុកបារាំង ។ គេរៀបចំវាយឡាំងដាក់ សម្លៀកបំពាក់ និង គ្រឿងតុបតែងខ្លួន សម្រាប់ឲ្យយើងស្លៀកពាក់រាំនៅស្រុកបារាំង ។ ចំណែកខាងម្ចាស់ក្សត្រីវិញ រវល់តែភ័យព្រួយ រឿងអត់ស៊ីតាមផ្លូវ និង នៅស្រុកគេ ខំវេចអង្ករត្រីងៀត ព្រមទាំងប្រហុកជាច្រើនពាង យកទៅដាក់លើកប៉ាល់ ទុកសម្រាប់បង្ការពេលអាសន្នអត់ក្រ ប៉ុន្តែក្រោយពេលចេញដំណើរទៅបានប៉ុន្មានថ្ងៃ ប្រហុកនោះវាឲ្យក្លិនខ្លាំងពេក ទ្រាំមិនបាន លោកមហាមន្ត្រីក៏បង្គាប់ឲ្យគេលើកទម្លាក់ចោលក្នុងសមុទ្របាត់ទៅ ។

ចិន ជាងដេរស្បែកជើង នាំយកស្បែកជើងម៉ូតរបៀបអឺរ៉ុបទាំងកន្ត្រកៗមកប្រគល់ឲ្យយើង ប៉ុន្តែស្បែកជើងហ្នឹង ដេរខ្ជីខ្ជាពេកណាស់ មិនគួរជាទីពេញចិត្តសោះ ។

បើយើង ស្លៀកពាក់ និង ពាក់ស្បែកជើង ហើយឆ្លុះកញ្ចក់មើលឃើញរូបខ្លួនឯងបែបគួរឲ្យចង់សើចពេកណាស់ ។

លើសពីអីវ៉ាន់ដែលអ្នករាជការវាំងគេរៀបចំដាក់ក្នុងឡាំងវាយបិទជិតនោះ យើងម្នាក់ៗសុទ្ធតែមានហិបដាក់របស់របរផ្ទាល់ខ្លួន ជញ្ជូនយកមកគរទុករាយប៉ាយពេញក្នុងវាំង ។

ព្រឹកមួយនោះ បារាំងរាងសង្ហា បី-បួន នាក់ ចូលរហូតមកដល់កន្លែងសមរបាំនៅខាងក្នុង ហើយអង្គុយមើលពួកល្ខោនដែលត្រូវដង្ហែហ្លួងទៅស្រុកបារាំង កំពុងហាត់រៀនយ៉ាងយកចិត្តទុកដាក់ ។ ស្រីបារាំងម្នាក់ដែលចូលមកជាមួយពួកប្រុសៗនោះ សម្លឹងមើលខ្ញុំដោយញញឹមខ្ញីប ពុំដឹងជាគាត់ ញញឹមពេញចិត្ត ឬ ញញឹមពេបជ្រាយទេ ។ ម្ចាស់ក្សត្រី និយាយលេងរាក់ទាក់ជាមួយភ្ញៀវទាំងនេះ ដោយមានអ្នកបកប្រែម្នាក់ជាជំនួយ ហើយខ្ញុំសង្កេតឃើញលោកអួតសរសើរប្រាប់បារាំងតែពីរឿង មីសួន កូនចៅលោក អត់មាននិយាយពីរឿងអ្វីផ្សេងទៀតសោះ ចាប់តាំងពីពេលនោះមក មីសួន វាបានចិត្តឡើងចាងរហូត និង រឹតតែខំផ្គាប់ផ្គុនចៅហ្វាយវាលើសដើម ។ មីសួនៈនេះ ពីដើមវាធ្លាប់តែដើរយួរស្បែកជើងតាមខ្ញុំប៉ុណ្ណោះ ឥឡូវវាហ៊ានបំបាក់មុខខ្ញុំនៅកណ្ដាលជំនុំចំណោម គួរឲ្យចុកឈាមណាស់ ។ ប៉ុន្តែទោះបីជាយ៉ាងណា ក៏ពួកបារាំងពុំមែនល្ងើ រហូតដល់បណ្ដោយឲ្យម្ចាស់ក្សត្រី បោកក្បាលគេលេងទទេបានដែរ គឺគេនាំគ្នាគយគន់មើលខ្ញុំយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ។

ក្នុងសភាពច្រួលច្របល់មុនពេលចេញដំណើរ អស់អ្នកអស់នាងជាច្រើន រត់ខ្វៃងដៃខ្វៃងជើង រកខ្ចីលុយគេសម្រាប់ចំណាយទិញរបស់កំប៉ិកកំប៉ុកប្រើប្រាស់ផ្ទាល់ខ្លួន ។ ពួកចាស់ៗនៅក្នុងវាំង ជាសាច់ញាតិនឹងម្ចាស់ក្សត្រី សុខចិត្តឲ្យប្រាក់ពួកនោះខ្ចី ហើយទទួលកាត់ប្រាក់ខែសងវិញ ដោយយកការអារកត្លាក្រៃលែង ។ បើកុំតែខ្ញុំចេះមានគំនិតសុំហ្លួងបាន មួយរយរៀល កុំអីខ្ញុំក៏មិនអាចជៀសមិនជំពាក់គេរណ្ហកបានដែរ ។

ព្រឹកពេលចេញដំណើរមកដល់ហើយ ! យប់នោះ នៅក្នុងវាំងគ្មាននរណាម្នាក់ដេកលក់ទេ ។ យើងជិះរទេះចេញពីវាំងហូរទឹកភ្នែករហាម ខំដកករហង់សម្លឹងរកមើល ឪពុក-ម្ដាយ សម្លឹងសួនច្បារដែលប្រែជាស្ងាត់ជ្រងំ មើលពួក អ្នករាជការ និង ក្រុមវាំង ដែលឈរតម្រៀបគ្នាជារបងអមសងខាងផ្លូវ មើលដើមគគីរធំៗដែលទម្លាក់មែកសំយាកទៅលើដំបូលវាំង ដោយក្ដីស្ដាយស្រណោះរកហាមាត់និយាយមិនរួច ។ ក្បួនដំណើរលឿនទៅមុខតាមចង្វាក់ជើងសេះ តម្រង់ទៅទិសខាងជើង គឺតម្រង់ទៅសង្កាត់បារាំង ដែលជាកន្លែងកប៉ាល់បោះយុថ្កាចាំយើង ។

មនុស្សម្នាមួយហ្វូងធំ ក៏បាននាំគ្នាមកមើលយើងចេញដំណើរនេះដែរ ។ បារាំងចោមរោមនិយាយលេង

ជាមួយហ្លួងនៅលើកប៉ាល់ ហើយម្នាក់នោះមាឌធំដូចយក្ស ភ្នែកខៀវដូចត្រីស្វាយ ទុកពុកមាត់ស្រមាម ត្រូវដង្ហែហ្លួងរហូតដល់ស្រុកបារាំង ។ ដោយសារវាអ្វីអែរថ្លង់ខ្លាំងពេក យើងក៏នាំគ្នាសម្ងំនៅជុំវិញកប៉ាល់ សម្លឹងមើលមកមនុស្សដែលឈរកកកុញនៅលើច្រាំង ក្នុងទ្រូងចង្អៀតចង្អល់រកនិយាយអ្វីមិនចេញ ហូរតែទឹកភ្នែករហាម ។

នៅទីបំផុត កប៉ាល់ក៏លូនចេញពីច្រាំង ចូលទៅដល់កណ្ដាលទន្លេ ហ្លួងពួកបារាំងដែលប្រជុំគ្នានៅលើច្រាំង ក៏បំបែកអស់រលីង ។ ទោះបីកប៉ាល់បើកហួសឆ្ងាយមកហើយក្ដី ក៏ខ្ញុំនៅតែចំណាំបាន កំពូលវាំង កំពូលវត្ត និង ផ្ទះឪពុក-ម្ដាយ ដែលខ្ញុំខំផ្ចិតឲ្យជាប់ក្នុងអារម្មណ៍កុំឲ្យភ្លេច រួចបន្តិចក្រោយមក ផ្សែងអ័ព្ទ នៃ ទន្លេដែលហូរនាំយើងទៅកាន់សមុទ្រនេះ បាំងមិនឲ្យយើងមើលឃើញអ្វីទាំងអស់ ។

ចង្អៀតចង្អល់អ្វីម្ល៉េះទេនៅលើកប៉ាល់នេះ ដែលមានមនុស្សជិះដល់ទៅជាងមួយរយនាក់ ព្រមទាំងឥវ៉ាន់ដទៃទៀតជាច្រើន! ហ្លួងលែងរវល់គិតគូរពីរឿងពួកយើងទៀតហើយ ។ លោកផ្ទុំក្នុងបន្ទប់ សោយអាភៀនធ្វើព្រងើយ ជាមួយស្រីពីរនាក់ នៃ ក្រុមភ្លេងមហោរី ។ យើងអង្គុយលើហិបរៀងខ្លួន ជជែកគ្នាអែប្រមែ ដើម្បីគ្រាន់នឹងលើកទឹកចិត្តគ្នាទៅវិញទៅមក កុំឲ្យភ័យព្រួយខ្លាំងពេក ។ ក្នុងចំណោមអ្នកដំណើរជិះលើកប៉ាល់ដែលត្រូវដង្ហែហ្លួងទៅស្រុកបារាំងនោះ តិចគ្នាណាស់ដែលមានការចាំបាច់ត្រូវទៅខានមិនបាន ភាគច្រើនសុទ្ធតែមនុស្សអត់ប្រយោជន៍ មិនដឹងជាគេសណ្ដោងយោងយកទៅធ្វើអ្វីទេ ។

នៅលើកប៉ាល់ មានក្មួយប្រុសហ្លួងជាច្រើននាក់គឺ អ្នកអង្គម្ចាស់ឥស្សរាវង្ស, អ្នកអង្គម្ចាស់ សូរីវង្ស ជាទីគាប់ចិត្តហ្លួងជាងគេ និង ប្អូនប្រុសមួយទៀតឈ្មោះចិន្តានុវង្ស ដែលគិតតែនិយាយពីរឿងទៅ "លេង" ស្រីបារាំងឲ្យចាស់ដៃម្ដង ដូចជាស្ដេចបងនោះដែរ ។ ព្រះសង្ឃប៉ុន្មានអង្គ ដែលសុំដោយសារតាមកប៉ាល់ទៅសិក្សាឯប្រទេសសេរីលង្កា លោកគង់បត់ជើងដាច់ឡែកឆ្ងាយពីពួកយើង ហើយនៅក្បែរនោះ ពួកក្រុមវាំង និង ពួករាជការវាំង អង្គុយស៊ីស្លាយ៉ាងស្ងៀមស្ងាត់ ភ្នែកសម្លឹងមើលទៅច្រាំងចំការ ស្រុកលើកដែក និង ស្រុកល្វាឯម ដែលរសាត់ហួសទៅជាបន្តបន្ទាប់គ្នា ។

ម៉ែអួន ធ្វើឫកបែបម៉ឺងម៉ាត់និយាយថា គាត់នឹងសរសេរកត់ទុកក្នុងសៀវភៅ នូវរឿងហេតុទាំងអស់ក្នុងពេលធ្វើដំណើរនេះ ប៉ុន្តែយើងរវល់តែព្រួយបារម្ភគ្រប់គ្នា គ្មាននរណាគិតគូរស្ដាប់គាត់ឡើយ សូម្បីតែបាយទឹក ក៏មិននឹកឃ្លានផង ។ ម្ល៉ោះហើយ យើងពីតតែជក់បារីកែអផ្សុក បង្ហុយផ្សែងទ្រលោមទៅលើចាស់ៗដែលអង្គុយធ្វើមាត់ច្រហ ។ បន្ទប់មានតិចពេក ពុំអាចឲ្យយើងដេកគ្រប់គ្នាបានឡើយ ម្ល៉ោះហើយយើងត្រូវនាំគ្នាដេកកណ្ដាលវាលនោះទៅ ប៉ុន្តែជាសំណាងល្អម្យ៉ាងដែរ យប់នោះគ្មានមូសមួយគ្រាប់សោះ ។

បន្ទាប់ពីធ្វើដំណើររបៀបនេះអស់មួយថ្ងៃមួយយប់ ស្អែកព្រឹកឡើងយើងក៏បានចូលមកដល់ទន្លេចង្អៀតពេញពាសទៅដោយកប៉ាល់ខ្ពស់ត្រដែតដូចភ្នំ ។ មើលទៅច្រាំងឃើញអ្វីអែរ ខ្ញុំដឹងថាយើងមកដល់ក្រុងធំមួយហើយ លុះខ្ញុំសួរគេទើបដឹងថា នេះជាក្រុងព្រៃនគរ ដែលអ្នកខ្លះគេហៅថា សៃហ្គុង ។ បើតាមមើលទៅ ក្រុងព្រៃនគរហ្នឹងមិនស្ទើរហ៊ឺហាជាងភ្នំពេញប៉ុន្មានទេ ។ កប៉ាល់យើងចូលទៅអែបជិតកប៉ាល់មួយទៀតធំអស្ចារ្យ ហើយយើងនាំគ្នាយីឥវ៉ាន់ទៅដាក់លើកប៉ាល់ធំនោះវិញ ។

យើងនាំគ្នាជញ្ជូនអីវ៉ាន់ផ្ទាល់ខ្លួនទៅដាក់ក្នុងបន្ទប់តូចចង្អៀតនៅខាងក្រោយកប៉ាល់ ហើយក្នុងបន្ទប់នីមួយៗ យើងត្រូវនៅដល់ទៅប្រាំ ឬ ប្រាំមួយ នាក់ឯណោះ ។ ខ្លះប្រតែងប្រតោងឡើងទៅដេកលើគ្រែដែលគេព្យួរជាប់នឹងជញ្ជាំង ខ្ពស់សឹងតែអើតកមើលមិនដល់ ខ្លះទៀតក្រាលកំណាត់ លើឡាំង ឬ ផ្ទាល់នឹងក្ដារ ដេកតរជើងលើគ្នា ។ ក្នុងបន្ទប់ហ្នឹងគ្មានខ្យល់អាកាសល្អគ្រប់គ្រាន់សម្រាប់ដកដង្ហើមសោះ ជាពិសេស



ទៅទៀត វាថែមទាំងធំក្លិនអាក្រក់ចង់ក្អួត ។ យើងស្រូតស្រូតនាំគ្នាចេញមកកន្លែងវាល ដែលនៅទីនេះមានអ្នកជំនួញបារាំងលក់ គ្រឿងសំអាង និង ស្បែកជើងកែងចោទល្អគួរចាប់ចិត្ត ។ ហ្លួងទិញស្បែកជើងនេះចែកឲ្យយើងមួយគូៗម្នាក់គ្រប់គ្នា ដល់បានថ្មី យើងដោះស្បែកជើងចាស់ដែលចិនភ្នំពេញដេរយកមកឲ្យទុកមួយកន្លែង ឬក៏ ឲ្យទៅយាយចាស់ៗ ដែលខំយកទៅញាត់ទុកក្នុងបង្វិចគាត់យ៉ាងប្រយ័ត្នប្រយែងក្រៃលែង ។

ពីលើកប៉ាល់មក យើងមើលឃើញ បារាំង និង យួន ឈរប្រជុំគ្នាកុះករលើច្រាំង ដើម្បីមើលស្ដេចខ្មែរយាងទៅស្រុកបារាំង ។

ខ្ញុំចង្អើតជើងមើលតាមបង្អួច ឃើញវាលស្រែលិចទឹក ជាប់គ្នារហូតដល់ជើងភ្នំនៅទិសខាងជើង ស្រដៀងគ្នានឹងវាលស្រែកំពង់លែង ដែលខ្ញុំធ្លាប់បានឃើញកាលពីក្មេង ក្នុងពេលពុកដឹកយកអីវ៉ាន់ទៅលក់តាមទន្លេសាបនោះដែរ ។ រវល់តែជ្រួលច្របល់រឿងរៀបចំអីវ៉ាន់ ខ្ញុំភ្លេចគិតឃើញ មិនដឹងជាកប៉ាល់ចេញដំណើរពីថ្មើរម៉ាន ស្រាប់តែមួយភ្លែតក្រោយមក ខ្ញុំមើលទៅក្រោយលែងឃើញអ្វីទាំងអស់ ក្រៅពីរលកទឹកបែកពពុះស្កុល និង ផ្ទៃទឹកធំល្ហល្ហេវ ។

ទស្សនីយភាពដ៏ធំល្វឹងល្វើយ សម្លឹងមិនយល់កោះត្រើយ ដែលពីដើមមកយើងធ្លាប់តែឮគេនិយាយក្នុងរឿងព្រេងបុរាណនោះ ឥឡូវយើងបានឃើញច្បាស់នឹងភ្នែក មិនអាចទប់ចិត្តមិនឲ្យរំភើបញាប់ញ័របានឡើយ ។ យើងឃ្លាតឆ្ងាយពីស្រុកភូមិណាស់ហើយ បណ្ដាលឲ្យចិត្តយើងក្រៀមក្រំស្រពោននឹកថា យើងនឹងត្រូវបារាំងនាំយកទៅនិរទេសចោលនៅស្រុកគេ ជាមួយហ្លួងជាពិតប្រាកដណាស់ ។

ផ្ទុយទៅវិញ កាលណាយើងបែរភ្នែកមកមើលកន្លែងដេកដ៏ចង្អៀតចង្អល់ ទំហំនាវាដ៏ធំសម្បើម ដែលអាចឲ្យយើងដើរលេងទៅមក នឹងដូចឈរលើដី យើងដូចជាមានការកក់ក្ដៅច្រើន ។

នៅប៉ែកខាងក្រោយកប៉ាល់ មានកំណាត់បាំងកុំឲ្យត្រូវកំដៅថ្ងៃ ពួកយើងចង់លេងសើចយ៉ាងម៉េចបានតាមចិត្ត គ្មាននរណាត្រួតត្រាទេ ។ បន្ទប់យើងនៅខាងក្រោមជាប់ៗគ្នា ហើយក្រខ្វក់ដូចធុងសំរាម ពីព្រោះយើងនៅច្រើនគ្នាពេក ចេះតែចោលនេះចោលនោះផ្ដេសផ្ដាស តួលីកប៉ាល់បោសជ្រះសំអាតពុំឈ្នះ ។ ហ្លួងនៅក្នុងបន្ទប់ខាងលើឯណោះ ក្បែរអស់លោកនាម៉ឺនវាំង និង បារាំងមេធំលើកប៉ាល់នេះ ដោយមានតែប្រពន្ធគាប់ចិត្តប៉ុន្មាននាក់ប៉ុណ្ណោះ នៅចាំគាល់បំរើផ្ទាល់ ។ យើងជក់បារីជជែកគ្នា លេងបៀ ឬ រាំច្រៀងលេងតាមចិត្ត ហ្លួងមិនដែលរវល់មកមើលសុខទុក្ខពួកយើងដល់ម្ដងណាឡើយ ។

ម្ចាស់ក្សត្រី ភ័យណាស់ ខ្លាចតែយើងដេកស៊ីទំនេរពេកទៅ វានាំឲ្យធាត់ជុសក្បាលពោះអស់រាងរៅ ម្ល៉ោះហើយលោកឧស្សាហ៍បង្គាប់ឲ្យយើងសមរបាំជាញឹកញាប់ ដែលជាហេតុនាំឲ្យពួកបារាំងដែលជិះលើកប៉ាល់ជាមួយគ្នា មកឈរមើលយើងត្រៀបត្រាយ៉ាងសប្បាយរីករាយ ។

តើដំណើរនេះត្រូវស៊ីពេលអស់ប៉ុន្មាន? ខ្ញុំអត់ដឹងអីទាំងអស់... ប្រហែលជា មួយខែ ឬ ពីរខែ ក៏មិនដឹង? ប៉ុន្តែខ្ញុំជឿជាក់ថា ដំណើរនេះត្រូវប្រើពេលយូរណាស់ ម្ល៉ោះហើយខ្ញុំមិនខ្វល់រាប់ថ្ងៃ រាប់ខែ ធ្វើអ្វីទៀតទេ ។ រាល់ថ្ងៃឃើញតែទឹកសមុទ្រ ឥតកោះត្រើយដដែលៗយ៉ាងនេះ ខ្ញុំវង្វេងលែងស្គាល់ទិសតំបន់អ្វីទាំងអស់ ។ នៅខាងក្រោយឆ្ងាយឯណោះ សត្វស្លាបសហើរតាមរលកកប៉ាល់ ហើយកាលណាមានរលកធំៗរសាត់មកដល់ វាទំបណ្ដែតខ្លួនលើរលក ប្រៀបបាននឹង កុក ឬ ខ្វែក ដែលឈរលើពំនូកខ្សាច់ដុះកណ្ដាលទន្លេក្នុងស្រុកយើងយ៉ាងនោះដែរ ។

ក្នុងចំណោមអ្នកធ្វើការលើកប៉ាល់មានយួន ពីរ-បី នាក់ ក្រៅពីនេះសុទ្ធតែបារាំងទាំងអស់ ដែលធ្វើជា

ត្រូលីជុះលាងសំអាតទឹកមាត់ស្លាលើក្តារកប៉ាល់រៀងរាល់ព្រឹក ។ នៅចុងខាងក្រោយកប៉ាល់ មានបន្ទប់តូចមួយ ធំក្លិនអាសោចិ៍អស្ចារ្យ ជាកន្លែងដេករបស់តាកញ្ចាស់ម្នាក់ ដែលជាអ្នកលក់នំម្សៅ និង សាប៊ូក្រអូប ប៉ុន្តែរូបរាងគាត់អាក្រក់គគ្រិចស្មោកគ្រោកណាស់ ថែមទាំងថ្លង់ទៀតផង ហាមាត់និយាយម្តងៗ ស្អុយមួយយោជន៍ ។

កាលណាគាត់ដេកលក់ យើងនាំគ្នាយកជើងធាក់ទ្វារខ្លាំងៗ ដើម្បីរំខានកុំឲ្យគាត់ដេកលួចបាន ហើយបើឃើញថា គាត់អត់នៅនឹងកន្លែង យើងលួចយកអីវ៉ាន់កំប៉ិកកំប៉ុករបស់គាត់ទៅបោះចោលលេងជាល្បែង ។ ម៉ែថែម អ្នកពូកែលេងសើចច្រើនជាងគេ ឧស្សាហ៍ស្រែកដាក់ត្រចៀកតាជំឡង់ប្រាំពីរសន្តានោះថា ៖ "អូ! ស្អុយមាត់តាប៉ិងឯណាស់!", តាហ្នឹងសើចញញឹមញញែម ប្រហែលជាគាត់ស្មានថា ម៉ែថែមនិយាយពាក្យស្នេហាជាមួយគាត់ហើយមើលទៅ ។

បោយបារាំង ដែលចូលមកបោសជ្រះសំអាតបន្ទប់ និង យកកន្តោរទឹកមាត់ទៅចាក់រាល់ថ្ងៃនោះ វាទុកពុកមាត់វែយៗ និង សិតសក់ស្អាតជានិច្ច, វានៅក្មេងរាងសង្ហា ថែមទាំងខំបំរើយកចិត្តយើងខ្លាំងណាស់ ។ យើងហៅវាថា "អាបារាំងក្បាលពុក" ហើយវានិយាយរដាក់រដុបថាតាមយើង គួរឲ្យចង់សើចក្រៃលែង ។ ម្តងនោះ សារិទ្ធពួកម៉ាកខ្ញុំ ឲ្យចិញ្ចៀនវាខ្ចីពាក់លេង ស្រាប់ដល់ពេលដោះមកវិញ វាចង្អៀតជាប់ម្រាមដៃទាល់តែដាក់ប្រេងទាញចង់ងាប់ទំរាំរបូត ។ ថ្ងៃមួយពួកធំៗប្រជុំគ្នាក្នុងបន្ទប់លេងបៀ ខ្លះអង្គុយលើកន្លែងដេក ខ្លះអង្គុយលើហិប លែងខ្លួនទទេទាំងអស់គ្នា ជណ្តប់តែស្បែស្តើងមួយប៉ុណ្ណោះ ស្រាប់តែទ្វាររបើកឡើង លេចបោយបារាំងដៃកាន់អំបោសប្រួងដើរចូលមក ។ ដល់ឃើញស្រីៗអង្គុយជួបជុំគ្នារបូតសំពត់អាវអញ្ចឹង វាទៅជាស្រឡាំងកាំងធ្វើភ្នែកស្ញឹចំហមាត់ផ្លុង ។

~ កូនមីចោរ! (ម៉ែថែមស្រែកបញ្ឆោរវាដោយយកដៃទាំងពីរខ្ទប់ដោះ) ឯងមិនចេះសុជីវធម៌បារាំងទេហ្អែ? មុននឹងចូល ឯងម៉េចមិនចេះគោះទ្វារ?

~ យីស! (ម៉ែអូនបន្តរតាមក្រោយ) អាហ្នឹងវាឆ្កួតទេ បានជាចូលមកគ្មានធ្វើសញ្ញាឲ្យអាណាដឹងសោះអញ្ចឹង ។

ខ្ញុំដេកទ្រាលលើគ្រែពីលើក្បាលពួកគេអ្នកលេងបៀ, ខ្ញុំមិនរវល់ទឹងអីទេ ពីព្រោះក្នុងវ័យដប់បីឆ្នាំនេះ ខ្ញុំពុំទាន់ចេះអៀនខ្មាសប៉ុន្មានឡើយ ។

ពេលយប់ យើងត្រូវប្រយ័ត្នការពារខ្លួនទល់នឹងកូនស្តេចក្មេងៗ ដែលតែងដើរក្រឡឹងជិតកន្លែងយើង ដើម្បីសម្លឹងមើលឲ្យតែឃើញមីណាមួយបែបឲ្យដៃបន្តិច ក៏តាំងចូលដេកជាមួយមីនោះភ្លាម ។ យប់មួយនោះគេឃើញទាន់ម្ចាស់សុផល្លិកា កំពុងប្រគាក់ប្រគងគ្នាជាមួយ មីស៊ុន ហើយត្រូវម៉ែអូនស្រែកឡូឡាបណ្តេញចេញទៅវិញទាំងកណ្តាលយប់ ។

ទីបំផុត យើងក៏បានមកដល់កោះសេរីលង្កា ដែលចាស់ៗធ្លាប់និយាយប្រាប់ថា នេះជានគរក្រុងរាពណ៍ ដែលវាធ្លាប់យកនាងសិតា មកលាក់ទុកនៅទីនេះ ។ កោះនេះមានភ្នំខ្ពស់ប្រកបទៅដោយទេសភាពស្រស់ផើតឆាយ ដូចដែលយើងធ្លាប់ស្រមៃឃើញតាមពាក្យនិទាន នៃ រឿងរាមកេ្តិ៍ យ៉ាងនោះដែរ ។

ព្រះសង្ឃទិមន្តចុះត្រង់កំពង់ផែក្រុងកូឡុមបូ ។ ហ្លួងនាំយើងឡើងគោកជិះរទេះភ្លើង ដើម្បីទៅមើលព្រះវិហារ ដែលគេតម្កល់ទុកធ្មេញព្រះពុទ្ធ ហៅថាព្រះចង្កូមកែវ ។ ក្រោយពេលត្រឡប់មកពីដើរកំសាន្តយ៉ាងរីករាយនោះវិញ កប៉ាល់យើងក៏បន្តដំណើរឆ្ពោះទៅមុខទៀត ដែលគ្មានឃើញកោះត្រើយដាច់សង្វែងមិនគួរឲ្យសង្ស័យថានឹងបានទៅដល់ ។



រាល់ថ្ងៃយើងនាំគ្នាស៊ីតែត្រីងៀតត្រីឆ្អើរ ដែលយើងនាំយកមកជាមួយប៉ុណ្ណោះ ពីព្រោះយើងមិនចូលចិត្តម្ហូបបារាំងសោះ ប៉ុន្តែបើនិយាយឲ្យចំ គឺយើងខ្មាសគេមិនហ៊ានទៅរៀបឬកតាមរបៀបបារាំង អង្គុយស៊ីបាយលើតុក្នុងបន្ទប់បាយដ៏ធំទូលាយ កណ្តាលជំនុំចំណោមនេះឯង យើងចេះតែនាំគ្នាគេចឲ្យគេលើកបាយយកមកឲ្យដល់បន្ទប់ដេកតែម្តង ។ ខ្ញុំចាំថា នៅពេលមកដល់ប្រទេសសូម៉ាលី ដែលកប៉ាល់ត្រូវចូលចតដើម្បីដាក់ធ្យូងបន្ថែមនោះ មានមនុស្សខ្មៅឃ្លើក ខ្មៅជាងខ្មែរទៅទៀត ហែលទឹកក្រឡឹងជុំវិញកប៉ាល់ ដើម្បីចាំមុជជណ្តើមយកប្រាក់កាក់ដែលយើងទម្លាក់ទៅឲ្យវា ។ ហ្លួងបង្គាប់ម្ចាស់ក្សត្រី ឲ្យយកលុយទៅទម្លាក់ទឹកឲ្យពួកនោះប្រញាយគ្នាមុជទឹកជណ្តើម ដើម្បីបានសើចលេងសប្បាយ ។

បន្ទាប់មកទៀតបានប៉ុន្មានថ្ងៃ ខ្យល់ត្រជាក់ចាប់ផ្តើមបក់មកជាលើកដំបូងបំផុត ។ នរណាម្នាក់បាននិយាយប្រាប់យើងថា ពីយប់មិញនេះកប៉ាល់យើងបានឆ្លងផុតព្រែកជីកធំ[៨] ចូលមកដល់សមុទ្រទ្វីបអឺរ៉ុបហើយ ។ ខ្ញុំស្តាយណាស់ដោយមិនបានឃើញព្រែកជីកនោះ ប៉ុន្តែបើតាមស្តាប់គេនិយាយ វាមិនមែនចម្លែក ឬ ធំជាង ព្រែកពាមផ្លុង[៩] ប៉ុន្មានទេ វាប្លែកតែត្រង់ព្រែកនេះ ជីកកាត់វាលខ្សាច់ប៉ុណ្ណោះ ។

យើងរងាខ្លាំងណាស់... ផ្ទៃសមុទ្រប្រែជាមានរលកធំៗ ហើយសត្វស្លាបសម្បុរស នៅតែហើរតាមក្រោយកប៉ាល់យើងពីចម្ងាយជានិច្ច ។ តើសត្វនេះវាហើរតាមយើងតាំងពីព្រៃនគរមកឬ? ខ្ញុំមិនជឿថាអញ្ចឹងទេ ពីព្រោះវាអាចហើរយ៉ាងច្រើនណាស់បានពីរ-បីថ្ងៃ ក៏អស់កម្លាំងទៅហើយ ដូច្នេះអានេះវាជាសត្វផ្សេងទៀតទេ ។

ពេលនោះ ចឹបកឈ្មោះព្រុំ ចង្អុលប្រាប់ឲ្យយើងមើលស្រមោលអ្វីមួយនៅឆ្ងាយស្លុងៗឯណោះ ហើយគាត់និយាយថា នេះជាភ្នំភ្លើង, ស្រុកណាដែលមានភ្នំព្រួសភ្លើងអញ្ចឹង ធាតុអាកាសត្រជាក់អាក្រក់ណាស់ ។ ខ្ញុំមិនដែលស្គាល់ភ្នំភ្លើងយ៉ាងម៉េចទេ ម្ល៉ោះហើយគេនិយាយថាម៉េចក៏ចេះតែជឿទៅ ។

នៅទីបំផុតសម្រែកថា: "ស្រុកបារាំង, ស្រុកម៉ារ៍សី" រសាត់មកប៉ះនឹងត្រចៀកយើង ជាសញ្ញាប្រាប់ឲ្យដឹងថា ដំណើរយើងចប់ហើយ ។ ទុក្ខវេទនារបស់យើងក៏នឹងត្រូវបញ្ចប់ក្នុងពេលជាមួយគ្នានេះដែរ ។ ខ្ញុំមើលទៅខាងដីគោក ឃើញភ្នំស្រុកបារាំងសស្គុស ឃើញផ្ទះពណ៌ប្រផេះ មានផ្សែងហុយចេញតាមជង្ហុយឃើញដងក្តោងកប៉ាល់ច្រូងច្រាង ឃើញថ្មគេចាក់លយចូលជ្រៅមកក្នុងសមុទ្រ ហើយនៅពីក្រោយនោះកប៉ាល់ចតតម្រៀបគ្នា មានខ្លះធំជាងកប៉ាល់ដែលខ្ញុំជិះនេះទៅទៀត ។ បន្ទាប់មក នៅលើដីទួលមួយនោះមានរូបចម្លាក់លាបទឹកមាសធំអស្ចារ្យ ។ ទស្សនីយភាពនេះប្រៀបបានទៅនឹងនគរយក្ស ដែលយើងធ្លាប់ស្រមៃឃើញក្នុងរឿងព្រេងនិទាន ហើយដែលយើងពុំធ្លាប់សង្ស័យថានឹងបានស្គាល់សោះ ។ ពាក្យដែលចាស់ៗនិយាយទាំងប៉ុន្មាន គឺជាពាក្យភូតភរទាំងស្រុង ពីព្រោះសមុទ្រទោះបីធំយ៉ាងណា ក៏មនុស្សនៅតែអាចឆ្លងកាត់បាន ហើយនៅឆ្ងាយពីប្រទេសយើង មានទ្វីបមួយទៀតដែលលាតសន្ធឹងធំល្វឹងល្វើយ ក្រោមផ្ទៃមេឃដ៏ត្រជាក់ ។

គ្រាន់តែកប៉ាល់អែបចូលតម្រង់ផែ ទាំងគេទាំងយើងរវល់តែងាកមករៀបចំអីវ៉ាន់ ម្ល៉ោះហើយគ្មាននរណាបានគយគន់មើលទិដ្ឋភាពមាត់ច្រាំង នៅពេលកប៉ាល់ចូលចតទេ ។ ពួកយើងស្លៀកពាក់សំពត់អាវក្រាស់ពាក់ស្រោមដៃ និង មានផាហ៊ុំរុំកទៀតផង ប៉ុន្តែខ្ញុំដូចជារកទឹកហ៊ឺហាមិនឃើញសោះ ពីព្រោះសម្លឹងមើល

---

[៨] ព្រែកជីក សុយអេស៍ ។

[៩] ព្រែកពាមផ្លុង ពីដើមស្ថិតនៅមុខចំណតអយស្ម័យយានក្រុងភ្នំពេញ ប៉ុន្តែសព្វថ្ងៃនេះ គេចាក់ដីលុបបំពេញបាត់ទៅហើយ ។

មកគ្នាឯង ឃើញសុទ្ធតែខ្មៅក្រញេះ ។

ប្រសិនបើហ្លួងនាំយកមកជាមួយតែពួកក្មេងស្អាតៗ ម្ល៉េះយើងមិនសូវខ្លាចគេពេបជ្រាយប៉ុន្មានទេ ប៉ុន្តែ អ្នកដង្ហែមក សុទ្ធតែចាស់ហ្វ្រេកធ្មេញគ្រហុប ស៊ីស្លាក្រហមប្រតាកពេញមាត់ ជាហេតុធ្វើឲ្យយើងខ្មាសគេ ងើបមុខមិនរួច ហើយប្រហែលជាបារាំងគេស្មានថា ស្ត្រីខ្មែរសុទ្ធតែគគ្រិចទាំងអស់អញ្ចឹងផងក៏មិនដឹង ។

ហ្លួងយាងចុះទៅកណ្តាលចំណោមបារាំងមួយហ្វូងធំ ដោយមាននាម៉ឺនវាំងហែហមពីក្រោយជាប់ រួចហើយយាងទៅបាត់ជាមួយពួកទាហានបារាំងដែលស្លៀកពាក់ហ៊ឺហាជិះសេះ ទុកយើងចោលលើកប៉ាល់ ជាមួយម្ចាស់ក្សត្រី បណ្តោយឲ្យពួកគូលីកប៉ាល់មករើជញ្ជូនអីវ៉ាន់យើងតាមចិត្ត ។

យើងដូចជាមិនសូវទុកចិត្តសោះ! មេឃស្រទុំជាប់ ហើយខ្យល់ត្រជាក់បក់បោកមកឥតឈប់ឈរ បណ្តាលឲ្យយើងរងាចង់រឹងក្តាម... លុះដល់ពេលល្ងាច គេមកហៅឲ្យយើងចុះពីកប៉ាល់ទៅ ។ ពួកក្រុមវាំង និង ស្មៀនហ្លួង ស្លៀកពាក់ខោអាវក្រាស់ ពាក់មួកហ៊ឺត្រ មើលទៅវាគ្មានឃើញហ៊ឺហាត្រង់ណាឡើយ ប៉ុន្តែ ពួកយើងក៏មិនមែនហ៊ឺហាជាងពួកគាត់ប៉ុន្មានដែរ, យើងប្រជ្រៀតជណ្តើមគ្នាដើរកណ្តាលពពាក់ពពូនដូច ហ្វូងគោ តម្រង់ទៅរករទេះសេះធំៗដែលចតចាំយើង ។ ម្ចាស់ក្សត្រីបង្គាប់ឲ្យគេ លើកកៅអីផ្តៅ បាវអង្ករ ត្រីងៀត និង អីវ៉ាន់ទាំងអស់ដាក់លើដំបូលរទេះ រួចទើបយើងឡើងជិះចេញទៅ ប៉ុន្តែផ្លូវសុទ្ធតែក្រាលថ្ម រដិបរដុប រលាក់ស្ទើរក្រឡុកថ្លើមប្រមាត់ ។

បារាំងឈរប្រជុំគ្នាដង្ហែតាមមាត់ផ្លូវ និយាយឡូឡាហៅចំឈ្មោះហ្លួងយើងតែម្តង ហើយមានអ្នកខ្លះ ថែមទាំងបោះបារីឲ្យយើងជក់ទៀតផង ។ នៅស្រុកនេះស្រណុកមើលដឹង អ្នកមាន អ្នកក្រ ណាស់ គឺអ្នកមាន គេពាក់អាវកខុបចង់ក្រវ៉ាត់ អ្នកក្រអត់មានសម្លៀកបំពាក់អញ្ចឹងទេ ប៉ុន្តែទាំងអ្នកមានទាំងអ្នកក្រ សុទ្ធតែ ពាក់មួក ពាក់ស្បែកជើងឃ្លុបដូចគ្នាទាំងអស់ ។ យើងមើលមកខ្លួនឯងឃើញដូចជាតូចហេងហាង គ្មាន បង្គោលទីពឹងមាំមួន បណ្តោយវាសនាឲ្យរសាត់អណ្តែតទៅតាមជើងសេះ ដែលកំពុងបោះជំហានទៅមុខ ពុំដឹងជាចង់នាំយើងទៅកាន់ទីណាឡើយ ។

ការដែលហ្លួងបោះបង់យើងចោលយ៉ាងនេះ ធ្វើឲ្យយើងទឹកមុខម៉ៅខ្លាំងណាស់ ។ ចំណែកឯម្ចាស់ក្សត្រី វិញ លោករឹតតែព្រួយបារម្ភនឹងរឿងយើងជាងខ្លួនយើងទៅទៀត ហើយលោកមិនសប្បាយចិត្តសោះ ចំពោះ ការដែលបារាំងមិនសូវរាក់ទាក់ទទួល បណ្តោយឲ្យយើងជិះរទេះជាមួយអីវ៉ាន់អញ្ចឹង ។

ពេលមកឃើញបន្ទប់ដែលគេឲ្យយើងដេកនោះ យើងរឹតតែហួសចិត្តណាស់ទៅទៀត ពីព្រោះគេមិនឲ្យ យើងនៅជិតហ្លួងទេ ហើយមិនដឹងជាបានទាហានខ្មែរពីណា យកមកដាក់ឲ្យចាំយាមឃ្លាំមើលយើងដូច មនុស្សជាប់គុក ។

ក្នុងបន្ទប់នេះខ្វះសព្វខ្វះគ្រប់... ម្ចាស់ក្សត្រីបានផ្ទុំក្នុងបន្ទប់មួយមានគ្រែប្រាំ ចំណែកពួកល្ខោនវិញ នាំគ្នាក្រាលពូកដេកលើកំរាលក្តារស្រល់ ដែលមានបិទក្រដាសកាសែតពាសពីលើ ។ កាលណាពួក ស្តេច ឬ នាម៉ឺន ចូលមកឃើញកន្លែងយើងដេក គេញាក់មុខញាក់មាត់ ជាហេតុបណ្តាលឲ្យយើងខ្មាសគេងើបមុខ មិនរួចសើចមិនសម ។

យើងមិនដែលឃើញចានបាយប្រាក់របស់បារាំងដែលគេតែងអួតប្រាប់យើងនោះទេ រាល់ថ្ងៃគេដាក់តែ ចានដីទិញពីចិនលក់អេតចាយនៅព្រៃនគរឯណោះឲ្យយើងស៊ី ។ ចំណែកយួនអ្នកដាំបាយនោះវិញ វាធ្វើម្ហូប ឲ្យ យើងស៊ីខ្ជីខ្ជាជាងម្ហូបអ្នកទោសនៅស្រុកខ្មែរទៅទៀត ហើយយើងមិនអាចរកទិញអ្វីស៊ីបន្ថែមបានឡើយ ។ ម្ចាស់ក្សត្រីច្រឡំវិលក្បាល មិនព្រមចាំសោះពីរបៀបចាយ កាក់មាស កាក់ប្រាក់ របស់បារាំង ។ និយាយពី



ក្រុមវាំងដែលម្ចាស់ក្សត្រីប្រើឲ្យទៅផ្សារនោះវិញ ស្រាប់តែត្រឡប់មកវិញដៃទទេ ភ័យញ័រខ្លួនទទ្រើក ពីព្រោះ លុយឲ្យទៅប៉ុន្មាន ត្រូវចោរឆក់យកអស់រលីង ។ ឮអញ្ចឹងយើងភ័យចង់គ្រុនទាំងអស់គ្នា រអ៊ូរទាំទឹងនឹងខ្លួនឯង មិនគួរឆ្លងមកស្រុកគេឲ្យវេទនាខ្លួនសោះ ។ ចាប់តាំងពីនោះមក យើងលែងហ៊ានចេញទៅទីធ្លាខាងក្រៅ ស្មោះតែម្តង ណាមួយខ្លាចចោរ ណាមួយខ្មាសមនុស្សម្នា ដែលមកប្រជុំគ្នាអើតករហង់មើលយើង ហាក់ដូចជាយើងនេះជាមនុស្សចម្លែកខ្លាំងណាស់ ។

យើងមិនដឹងជាបង្គន់នៅកន្លែងណាទេ ឬមួយ ប្រហែលជាផ្ទះនេះអត់មានធ្វើបង្គន់ក៏មិនដឹង ម្ល៉ោះហើយ មីខ្លះវាជុះអាចម៍ ដាក់ចានដែកសម្រាប់ដាក់ទឹកមុជ ដាក់ចានសម្ល ហើយសើចហាសប្បាយដោយបាន សងសឹកឲ្យបារាំងយកអាចម៍វាទៅចាក់ចោល ។

ពេលស៊ីបាយយើងបិទទ្វារបិទបង្អួចខ្លាចគេឃើញ ពេលយប់យើងដេកឱបដៃរងាស្ទើររឹងពោះលើពូក រនាប ដែលស្ពាយយកមកជាប់ជាមួយតាំងពីស្រុកខ្មែរ ។

ប៉ុន្តែ ស្រុកនេះសម្បូរណ៍រុយអ្វីម្ល៉េះទេ! រុយហើរអ្វីដូចឃ្មុំ រោមមនុស្ស រោមបាយសម្ល ដូចរោមអាចម៍ ហើយបើតាមមើលទៅ រុយនេះវាបែបចង់សម្បូរណ៍ជាងមូសនៅស្រុកខ្មែរផង ។

ថ្ងៃមួយម្ចាស់ក្សត្រីបានប្រាប់ចឹបកឈ្មោះព្រំ ឲ្យយកទឹកផឹកមកថ្វាយលោក ពេលបារាំងនៅចាំបម្រើ យើង វាបែរជាយកកំប៉ុងដូចចានទឹកត្រីយួនមកថ្វាយទៅវិញ ។ ម្ចាស់ក្សត្រីប្រកែកពុំព្រមសោយទឹកនោះ ហើយប្រើស្រីម្នាក់ឲ្យទៅយក ផ្តិលមាស ផ្តិលប្រាក់ មកថ្វាយ រួចលោកប្រាប់ចឹបកឲ្យពន្យល់បារាំងថា លោក ធ្លាប់សោយទឹកសុទ្ធតែក្នុង ផ្តិលប្រាក់ ផ្តិលមាស គេមិនដែលប្រើកំប៉ុងអញ្ចឹងជាមួយស្តេចទេ ។

ជាសំណាងដែរ ការស្នាក់នៅរបស់យើងក្នុងផ្ទះដ៏អភ័ព្វនេះ មានរយៈពេលតែពីរ-បី ថ្ងៃប៉ុណ្ណោះ ។ ម្ចាស់ក្សត្រីបានទៅអង្វរករលោកមេទ័ពទាហានជើងទឹកបារាំង ទាល់តែគាត់រកផ្ទះមួយដ៏សមគួរ មាន សួនច្បារ មានដើមឈើ ឲ្យយើងបាននៅស្រួលជាងមុន ។ ទោះជាយ៉ាងណាក៏យើងមិនសូវបានដើរទៅ មើលស្រុកភូមិគេដែរ ពីព្រោះឲ្យតែឃើញមុខយើងនៅកន្លែងណា ពួកបារាំងចោមរោមមើលអ្វីមួយរំពេច ហាក់ដូចជាយើងនេះជាមនុស្សចម្លែកខុសពីពួកគេអញ្ចឹង ។

នៅពេលដែលយើងត្រូវចេញរាំ តួក៏ខ្វះ សម្លៀកបំពាក់ក៏មិនដឹងជាគេយកទៅទុកនៅឯណា ហើយ ជាពិសេសទៅទៀត រោងល្ខោននោះនៅឆ្ងាយរាប់គីឡូពីកន្លែងដេក គឺគេរៀបចំធ្វើនៅក្នុងវិមានមួយធ្វើពីថ្ម ប្រកបទៅដោយសួនច្បារស្រស់បំព្រង ។

ក្នុងទីនេះ បារាំងរៀបចំធ្វើបុណ្យតាំងតុរបស់គេ ដោយមានតាំងឲ្យមើលនូវរបស់ចម្លែកៗជាច្រើន នាំយកមកពីគ្រប់ប្រទេស ។ របស់ចម្លែកទាំងនោះ យើងគ្រាន់តែក្រឡេកឃើញប៉ុណ្ណោះ ឥតបានមើល ឲ្យសព្វគ្រប់តាមចិត្តចង់ទេ ។ ប៉ុន្មានថ្ងៃក្រោយមក ហ្លួងលះបង់យើងចោលមែនទែន ដោយលោកយាង ទៅទីក្រុងបារីស៍បាត់ នាំយកទៅជាមួយតែក្រុមភ្លេងមហោរីជាងដប់នាក់ប៉ុណ្ណោះ ដែលសុទ្ធសឹងជាមនុស្ស កំជិល គ្មានបានការអ្វីក្រៅពី រៀបចំខ្សៀអាភៀន និង ដេញវាយនាត តាំងពីព្រលឹមទល់ព្រលប់ ។ យើង ដទៃទៀតជាអ្នករបាំ នឿយមួយចប់ វេទនាមួយចប់ បែរជាហ្លួងត្រូវបោះបង់ចោលដូចជាខ្ញុំកញ្ជះគេដាច់ថ្លៃ ទៅវិញ ។ យើងមិនដឹងជាគិតខុស នាំគ្នាហែហមស្តេចឆ្លងកាត់សមុទ្រធំធេង មកដល់ស្រុកគេអញ្ចឹងសោះ ពីព្រោះទោះបីយើងនឿយហត់យ៉ាងណា ខិតខំធ្វើការអស់ពីកម្លាំងចិត្តយ៉ាងណា ក៏ហ្លួងនៅតែមើលមិន ឃើញ ហើយទំនងបែបដូចជាធុញទ្រាន់នឹងពួកយើងទៀតផង ។ ម្ចាស់ក្សត្រី ពីមុនមកធ្លាប់គិតខុស ធ្លាប់មាន គំនិតអាក្រក់ក៏ពិតមែន ប៉ុន្តែក្នុងកាលៈទេសៈនេះ លោកប្រែជាស្រឡាញ់យើង លើសពេលណាទាំងអស់ ។

លោកបានប្រថុយផ្តាំផ្ញើទៅទូលហ្លួងបិតា ឲ្យលោកបានយល់ពីទុក្ខវេទនារបស់ពួកយើង ដែលត្រូវលោកបោះបង់ចោលនេះដែរ ប៉ុន្តែហ្លួងគ្រាន់តែផ្តាំតាមគេមកវិញថា ឲ្យម្ចាស់ក្សត្រីនាំយើងទៅបើកប្រាក់ខែ ពេលដាច់ខែ នៅឯក្រុងបារីស៍តែប៉ុណ្ណោះ ។

រង់ចាំទម្រាំតែដល់ដាច់ខែ យើងខ្វះសព្វខ្វះគ្រប់ ម្ល៉ោះហើយម្ចាស់ក្សត្រី លោកពិបាកចិត្ត គិតតែសោយស្រាដូចគេផឹកទឹក ហើយនិយាយពីរឿងស្រានោះវិញ បារាំងជញ្ជូនយកមកផ្តល់ឲ្យមិនដែលឲ្យខ្វះខាតទេ ។ បើតាមស្មាន នៅស្រុកត្រជាក់ ប្រហែលជាគេត្រូវការផឹកស្រាច្រើន ដើម្បីកំដៅពោះអញ្ចឹងហើយមើលទៅ ។ ធាតុអាកាសត្រជាក់ធ្វើទុក្ខយើងខ្លាំងណាស់ ហើយក្តីព្រួយបារម្ភវាតែងតាមញាំញីយើងជាប់ជានិច្ច ប៉ុន្តែយូរៗទៅ យើងដូចជាធ្លាប់នឹងជីវភាពរបៀបនេះបន្តិចដែរ ។

យើងឧស្សាហ៍ចេញទៅអង្គុយលេងក្នុងសួនច្បារ អង្គុយលេងលើកាំជណ្តើរថ្មជុំវិញអាងទឹក ឬ អង្គុយលេងលើវាលស្មៅជារឿយៗ ហើយមានពួកបារាំងក្មេងៗ មកស៊ីញ៉ៃជើងសុំថតរូបយើង ទុកជាអនុស្សាវរីយ៍ ។

ប៉ុន្តែសាសន៍ស្អីគេហ្នឹងដូចជាចម្លែកណាស់ ស្លៀកពាក់មិនសូវបានត្រឹមត្រូវសោះ គឺគេមិនរវល់បិទបាំងគ្រឿងអៀនខ្មាសដូចយើងឡើយ ។ មានរឿងផ្សេងទៀតដែលប្លែករកគិតមិនយល់ទាល់តែសោះ ដូចជាពេលយប់មានរយៈពេលខ្លីណាស់ ក្រោយពេលបាយល្ងាចហើយ យើងទើបនឹងជក់បារីអស់ពីរ-បីដើម ស្រាប់តែថ្ងៃចាប់រះឯកើតទៀតទៅហើយ រួចព្រះអាទិត្យតែរះហើយ ហាក់ដូចជាពុំព្រមចង់លិចទៅវិញសោះ ។

យើងដាច់សោហ៊ុយទាំងអស់គ្នា សូម្បីតែម្ចាស់ក្សត្រី ក៏ដូចជាអផ្សុកតប់ប្រមល់ខ្លាំងណាស់ដែរ ។ ពួកក្រុមរាំងដ៏អភ័ព្វ ពីដើមគាត់ធ្លាប់ធ្វើជាអ្នកចាំយាមឃ្លាំមើលយើង ឥឡូវត្រូវធ្លាក់ខ្លួនមកជាអ្នកបំរើយើងយ៉ាងស្មោះត្រង់បំផុត ។

កាលណាត្រឡប់មកពីផ្សារម្តងៗ ក្រុមរាំងអស់ហ្នឹងតែងទិញបានរបស់ចម្លែកៗមកផ្ញើយើង ដូចជារូបថ្លុកម៉ាស៊ីនចេះលោត កាលណាគេមួលខ្លៅ បាល់កៅស៊ូ នំ ផ្លែឈើ កំណាត់ស្បៃ ។ របស់ទាំងនេះថ្លៃកប់ពពក ប៉ុន្តែយើងចេះតែខំទិញដាក់ពេញហិបគ្រប់គ្នា ដើម្បីបានយកទៅបង្ហាញឪពុក-ម្តាយ ឲ្យបានស្គាល់របស់ចម្លែកនៅស្រុកគេ ។

ល្ងាចមួយនោះ យើងត្រូវចេញដំណើរឆ្ពោះទៅកាន់ក្រុងបារីស៍ទាំងអស់គ្នា ដោយជិះលើរទេះភ្លើងបើកតាមផ្លូវដែក ដូចកាលនៅស្រុកសេរីលង្កាដែរ ។ បន្ទប់ធ្វើដំណើរក្នុងរទេះនេះទូលាយស្រួល មានកៅអីក្រាលពូកសម្រាប់អង្គុយ មានចង្កៀងឆេះឯងអុជបំភ្លឺ មានបង្គន់សព្វគ្រប់ទាំងអស់ ។ បានធ្វើដំណើរស្រួលអញ្ចឹង យើងដូចជាទុកចិត្តហើយធូរទ្រូងខ្សាក ប្រៀបបានមនុស្សទើបនឹងរួចពីគុក ។ យើងអើតតាមបង្អួចគយគន់មើលដើមឈើ និង ផ្ទះក្នុងផ្ទៃអន្ធការ នៃ រាត្រីកាល ដែលរសាត់ថយក្រោយហ័សស្ទើរមើលមិនទាន់ ។

រំពេចនោះ ស្រាប់តែយើងមើលទៅក្រៅលែងឃើញអ្វីទាំងអស់ គឺរទេះភ្លើងបើកចូលទៅក្នុងរូងដែលជីកទម្លាយជើងភ្នំពីម្ខាងទៅម្ខាង ដោយបញ្ចេញសូរស័ព្ទខ្ទរខ្ទារ ហាក់ដូចជាដីភ្នំរលំសង្កត់មកលើយើង ។

ស្អែកព្រឹកឡើង រទេះភ្លើងនៅតែបើកទៅមុខដដែល ឆ្លងកាត់វាលស្រែពណ៌បៃតងស្រស់ ព្រៃស្បាត និង ឆ្លងស្ពានច្រើនរាប់មិនអស់ ។ ស្រុកស្រែស្រុកចំការនៅស្រុកបារាំង វាខុសគ្នាស្រឡះពីស្រុកយើង គឺគេដាំដំណាំឥតឲ្យសល់ដីទំនេរមួយដុំណាឡើយ ។



ទីបញ្ចប់ នៅពេលយើងមកដល់កន្លែងមួយ ដែលផ្ទៃមេឃប្រែជាខ្មៅអាប់ជាងនៅឯស្រុកម៉ារ៉ីសី ទៅទៀតនោះ មាននរណាម្នាក់ប្រាប់ថា យើងជិតមកដល់ក្រុងបារីស៍ហើយ ។ គឺក្រុងបារីស៍នេះហើយ ដែលគេតែងសរសើរគ្រប់មាត់ថា ជាទីសប្បាយលើសកន្លែងណាទាំងអស់ មើលពីចម្ងាយ ឃើញក្រុងនេះលាតសន្ធឹងលើដីវាលរាបស្មើ ប្រកបទៅដោយផ្សែងខ្មៅគ្របដណ្តប់ពីលើ និង មានផ្ទះថ្មខ្ពស់ៗ សង់ឯណោះមួយដុំ ឯណោះមួយដុំ ។ សូម្បី ជញ្ជាំងផ្ទះ រានហាល ដី ពពក ក៏មានផ្សែងខ្មៅស្ថិតនៅប្រឡាក់លាយឡំដែរ ។

រទេះភ្លើងនីមួយៗ សណ្តោងរ៉ឺម៉ករាប់រយ បើកជៀសគ្នាខ្វាត់ខ្វែងលើផ្លូវដែក, ខ្ញុំភ័យស្ទើរលោះព្រលឹង នឹកអស់គុណម៉ែគុណឪ ព្រោះថាបើមានតែរទេះភ្លើងណាមួយបើកច្រឡំផ្លូវ ច្បាស់ជាបុកគ្នាក្រឡាប់ស្លាប់អស់អ្នកជិះមិនខាន ។ ហើយនៅឆ្ងាយឯណោះ យើងមើលឃើញប្រាសាទដែកមួយ ដែលមានចុងកំពូលលូតខ្ពស់ហួសកំពូលកណ្តាល នៃ ប្រាសាទអង្គរវត្តរបស់ខ្មែរទៅទៀត ។

នៅពេលមកដល់ក្រុងបារីស៍ ខ្ញុំហាក់ដូចជាវិលមុខភ្លេចភ្លាំងអ្វីទាំងអស់ ឃើញតែហ្វូងមនុស្សច្រើនកុះករ សម្លេងអ៊ូអរ និង ក្លិនអាក្រក់ជះមកស្ទើរទ្រាំមិនបាន ។ ផ្លូវថ្នល់ធំទូលាយហើយស្អាតជាងនៅម៉ារ៉ីសីមែន ប៉ុន្តែធុំក្លិនផ្សែងប្រេងសាំង និង មានមនុស្សរាប់ម៉ឺននាក់ប្រជ្រៀតគ្នាឆ្លងកាត់ថ្នល់ទៅមក គួរឲ្យចង់ទស្សនា ។

ជាសំណាងល្អណាស់ដែលនៅទីបញ្ចប់យើងបាន មកជួបមិត្តភក្តិ មកជួបហ្លួងវិញ ។ ហ្លួងគង់នៅក្នុងដំណាក់មួយធំ ប៉ុនគ្នានឹងប្រាសាទបាញ់យ៉ុងនៅភ្នំពេញដែរ ស្ថិតនៅជាប់ផ្លូវធំ មានដាំដើមឈើលើចិញ្ចើមថ្នល់អមសងខាង ព្រមទាំងមានឡានបើកបន្តកន្ទុយគ្នាទៅមកឥតដាច់ ។

យើងស្នាក់នៅក្រុងបារីស៍បានតិចថ្ងៃណាស់ ហើយយើងត្រូវរាំតែពីរដងប៉ុណ្ណោះ ។ ទីមួយរាំនៅផ្ទះលោកប្រធានាធិបតីបារាំង និង ទីពីររាំនៅក្នុងសួនច្បារ ដែលមើលទៅល្អដូចស្ថានសួគ៌យ៉ាងនោះដែរ ។ ហ្លួងបង្គាប់ឲ្យគេនាំយើងដើរលេង ទៅមើលសៀកដែលមានមនុស្សប្រុសស្រីស្លៀកពាក់ស្អាតៗ ហើយនាំគ្នាផែលឡើងជិះសេះ ដែលកំពុងផាយពេញល្បឿន មានមនុស្សឡើងជិះត្រួតលើគ្នាលើកជើងឡើងលើ មានមនុស្សវាយប្រដាល់គ្នា... ។

ម្ចាស់ក្សត្រី ក៏បាននាំយើងទៅមើលប្រាសាទដែកដ៏ធំគួរឲ្យខ្លាច រហូតដល់មានពួកយើងខ្លះ ខ្លាចមិនហ៊ានឡើងមើល សុខចិត្តអង្គុយចាំគេនៅខាងក្រោមរងាឱបដៃកំប្រោន ។ ខ្ញុំប្រថុយឡើងទៅលើជាមួយម្ចាស់ក្សត្រី និង ពួកម៉ាក ពីរ-បីនាក់ រហូតដល់ជាន់ទីមួយ ។ គេឲ្យយើងចូលទៅក្នុងរទេះមួយបិទជិតស្រដៀងគ្នានឹងរទេះដែលដឹកយើងពីម៉ារ៉ីសីមកបារីស៍ដែរ ហើយគេស្រូតសណ្តោងឡើងទៅ ពុំចាំបាច់ឲ្យយើងដើរឡើងតាមជណ្តើរនាំហត់ទេ ។ នៅលើជាន់ទីមួយនេះមាន លក់នំ លក់ស្រា មើលទៅក្រោមឃើញក្រុងបារីស៍លាតសន្ធឹងធំល្វឹងល្វើយ គ្របទៅដោយកំពូលប្រាសាទ និង សសរច្រូងច្រាង ហើយទន្លេមួយហូរកាត់ទីក្រុង មានស្ពានច្រើនរាប់មិនអស់ សម្រាប់ឆ្លងពីច្រាំងម្ខាងទៅច្រាំងម្ខាង ។ ប៉ុន្តែខ្ញុំមិនអាចមើលទៅឆ្ងាយឃើញដល់ជើងមេឃទេ ពីព្រោះផ្សែងដែលហុយចេញមកពីគ្រប់ដំបូលផ្ទះនោះ វាធ្វើឲ្យផ្ទៃមេឃទាំងមូលប្រែជាងងឹតជាស ។

គ្មាននរណាម្នាក់ហ៊ានឡើងខ្ពស់ជាងនេះទៀតទេ ។ នៅពេលចុះមកវិញ គេសម្រូតរទេះលឿនស្ទើរហាក់ដូចជាយើងរបូតធ្លាក់មកឥតមានអ្វីទ្រពីក្រោមជើងដូច្នោះដែរ ដែលជាហេតុនាំឲ្យយើងវិលមុខ រកកលក្អួតចង្អោរ ។

ក្នុងថ្ងៃធ្វើបុណ្យជាតិបារាំង គេយករទេះមកដឹក ហ្លួង និង ពួកយើងជាបរិវារទាំងអស់គ្នា ហើយបរចេញទៅតាមផ្លូវធំទូលាយ និង ស្អាតក្រៃលែង ។ បារាំងមានធំៗ ស្លៀកពាក់ខោអាវក្រហម ពាក់មួកជិះសេះអមសង្ខាងក្បួនរទេះយើងជាប់រហូត ។ គេយាមការពារប្រយ័ត្នប្រយែងម៉្លឹងៗ ប្រហែលជាគេនាំហ្លួងទៅដាក់គុក ឬ នាំទៅសម្លាប់ចោលក៏មិនដឹង ។ យើងខ្ញុំខុស្សាហ៍លួចចោលកន្ទុយភ្នែកមើលទៅពួកជិះសេះទាំងសង្ខាងហ្នឹងជាញឹកញយ មើលយូរទៅរឹតតែខ្លាចខ្លាំងឡើង ខ្លាចរហូតទាល់តែមិនហ៊ានស្អប់! បារាំងរាប់លាននាក់ឈរនៅសង្ខាងផ្លូវ ស្រែកហ៊ោកញ្ជ្រៀវកស្ដាប់មិនយល់ នៅពេលឃើញក្បួនរទេះយើងមកដល់ ដែលជាហេតុធ្វើឲ្យយើងភ័យញ័រទទ្រើក ។

ក្បួនរទេះមកឈប់ក្នុងទីវាលមួយដែលគេមានសង់វេទិកាធំៗ អាចដាក់ទស្សនិកជនបានរាប់ពាន់នាក់ ។ ហ្លួងចុះទៅឈរក្បែរប្រធានាធិបតីបារាំង ប៉ុន្តែខ្ញុំសម្លឹងពីចម្ងាយរកចំណាំមុខគាត់ហ្នឹងមិនបានសោះ ។ ទាហានតម្រៀបជួរដើរស្រុះជើងគ្នាលើវាលស្មៅ បន្ទាប់មកមានអ្នកជិះសេះកាន់ដាវនៅដៃ ធ្វើដំណើរកាត់មុខហ្លួងរាស្ត្រប្រជា ដែលស្រែកអបអរសាទរឡើងទ្រហឹងអឺងអាប់រកស្ដាប់ទិសតំបន់អ្វីមិនយល់ បើកុំតែមានរបាំងដែកបាំងជាប់ កុំអីពួករាស្ត្រមុខតែធ្លាយមកជាន់ទាហានដែលកំពុងដើរនេះមិនខាន ។ ទស្សនីយភាពនេះមានសភាពសម្បើមគួរកោតស្ញប់ស្ញែងក្រៃលែង ។

ល្ងាចនោះ បារាំងអុជកាំជ្រួចនៅកណ្ដាលទន្លេដែលហូរកាត់ក្រុងប៉ារីស៍ ភ្លឺរន្ទាលព្រោងព្រាត ក្មេងប្រុសស្រីស្រែកច្រៀងសប្បាយ ហ៊ោកញ្ជ្រៀវបន្ទរតាមបទភ្លេង ព្រមទាំងបង្ហោះប៉េងប៉ោងចម្រុះពណ៌ ឲ្យហើរពេញផ្ទៃមេឃ ។

ហ្លួងរវល់តែសប្បាយរីករាយថ្លើមនឹងការដែលបារាំងលើកកិត្តិយស សប្បាយទាល់តែភ្លេចគិតដល់ពួកយើង ។ ពួកស្រីក្រុមភ្លេងមហោរី ដែលបានដង្ហែហ្លួងមកក្រុងប៉ារីស៍មុនយើង គេនិយាយរឿងចម្លែកៗស្ទើរជឿពុំបានប្រាប់យើង ប៉ុន្តែសុទ្ធសឹងជារឿងពិតទាំងអស់ ។ សូម្បី ហ្លួង និង អ្នកអង្គម្ចាស់ស្ងួនវង្ស ជាកូនប្រុសបណ្ដូលចិត្តរបស់ហ្លួងនោះ ក៏បាននិយាយប្រាប់យើងដោយឥតលាក់លៀម ពីស្រីបារាំងដែលលោកបាន “ជួប” ហើយលោកបញ្ជាក់ថា ស្រីបារាំងគេចេះ “ម៉េត្វត” ច្រើនបែបណាស់ មិនមែនល្ងង់ដប់គត់ដូចខ្មែរទេ ។

គេដណ្ដើមគ្នាមើលរូបថតដែលអ្នកអង្គម្ចាស់ ស្ងួនវង្ស ទិញមក ឃើញរូបបារាំងប្រុសបារាំងស្រីស្រាតនៃលគកទាំងអស់គ្នា ហើយប្រើរបៀបចំតិតចំតូងប្លែកៗអស្ចារ្យ សូម្បីស្រីសំផឹងនៅស្រុកយើង ក៏គ្មានមីណានឹកឃើញធ្វើដូចអញ្ចឹងដែរ ។ ពួកយើងទើបនឹងមកដល់ក្រុងប៉ារីស៍ក្រោយគេ ហើយបានឃើញរូបថតនេះជាលើកដំបូងបំផុត ខ្លះមិនហ៊ានមើល យកដៃខ្ទប់ភ្នែក ខ្លះភ្លូតចង្អោរនៅពេលបានឃើញឆាកដ៏សែនអាសអាភាសនេះ ។

ខ្ញុំចេះតែនឹកបារម្ភក្នុងចិត្តថា បើយើងនៅក្នុងស្រុកបារាំងតែ ពីរ-បី អាទិត្យ ទៀត ថ្ងៃណាមួយហ្លួងគង់នឹងបង្គាប់ឲ្យយើងចំតិតចំតូងដូចក្នុងរូបថតថ្វាយលោកមិនខាន ។ ពួកយើងចង់តែចាកចេញពីដីស្រុកបារាំងឲ្យបានឆាប់បំផុត ហើយរហូតមកដល់សព្វថ្ងៃនេះក្ដី នៅក្នុងរាំងចតុមុខ ក៏ពួកស្រីៗដែលធ្លាប់បានដង្ហែហ្លួងទៅស្រុកបារាំង នៅតែស្ដាយថា មិនគួរនាំគ្នាទៅស្រុកអាសអាភាសអញ្ចឹងសោះ ។ តាមស្ដាប់សំដីម្នាក់ៗទាំង នាម៉ឺនរាជការ ពួកល្ខោន ឧណាក៏សុទ្ធតែឆ្អែតនឹងស្រុកបារាំងដែរ ។

មានតែហ្លួងមួយអង្គឯងទេ បែបដូចជាខុសគេ កាលណាលោកយាងចេញកំសាន្តទៅណាម្ដងៗ លោកបាចទានលុយទៅលើផ្លូវឲ្យបារាំងដណ្ដើមគ្នារើសដូចឆ្កែ ឲ្យទានរបៀបនេះ បើនៅស្រុកខ្មែរវិញ សូម្បីអត់ឃ្លានយ៉ាងណាក៏គេមិនខ្ជីរើសយកដែរ ហើយពួកបារាំងនេះ មិនមែនរើសតែលុយទេ សូម្បីកន្ទុយបារីដែលយើងជក់ជិតអស់ គ្រវាត់ចោលទៅក្នុងសួនច្បារនោះ ក៏គេរើសយកទៅជក់ នៅស្រុកខ្មែរមិនដែលមាននរណាធ្វើឫកថោកដល់ថ្នាក់ហ្នឹងឡើយ ។

ពេលយប់ កូនស្ដេចក្មេងៗពីរនាក់ បានទៅមើលឃើញគេធ្វើ ស្រា, ស្ករស និង ទំប៉ុង ក្នុងរូងក្រោមដីក្រខ្វក់រកអ្វីមកប្រៀបឲ្យស្មើពុំបាន ។ ចាប់តាំងពីពេលនោះមក ម្ចាស់ទាំងពីរអង្គ ដើរប្រាប់គេប្រាប់ឯងថាលោកសោយតែបាយទេ ឈប់លូកប៉ះពាល់ម្ហូបបារាំងទៀតហើយ ពីព្រោះវាគគ្រិចគួរឲ្យខ្ពើមជាងប្រហុកទៅទៀត ។

បើនិយាយឲ្យខ្លី តាមអ្វីៗដែលយើង បានឃើញ បានដឹង បានឮ យើងអាចសន្និដ្ឋានបានថា របៀបរបបនៅស្រុកបារាំង វាខុសគ្នាស្រឡះពីស្រុកយើង ឥតឃើញមាន សាសនា សេចក្ដីថ្លៃថ្នូរ សីលធម៌ ឥតមានធ្វើបុណ្យប្រាថ្នាស្វែងរកសុខក្នុងបរលោកដូចយើងទេ ។ បារាំងជាយក្ស ជាមនុស្សខ្លាំងពូកែ តែល្ងង់ គិតតែនាំគ្នាធ្វើការនឿយហត់ គិតតែបង្កើតរបស់ប្លែកៗ ប៉ុន្តែមិនអាចរកផ្លូវទៅនិព្វានឃើញឡើយ ។

មនុស្សម្នាត្រូវធ្វើការទាំងយប់ទាំងថ្ងៃ ឥតមានពេលឈប់សំរាក មើលទៅគួរឲ្យវេទនាភ្នែកក្រៃលែង ហើយយើងជាប្រជាពលរដ្ឋខ្មែរ ក៏គង់នឹងត្រូវទទួលរងវាសនាកម្មដូចគ្នានេះដែរ ពីព្រោះយើងកាន់តែធ្លាក់ខ្លួនជាខ្ញុំបារាំងបន្តិចម្ដងៗហើយ! ។

ការចាប់បង្ខំខ្មែរ ឲ្យធ្វើការដូចទាសករ ការតម្លើងថ្លៃពន្ធអាករ ការតម្លើងថ្លៃទំនិញ ពួកបរទេសលើកគ្នាមកនៅក្នុងក្រុងកាន់តែច្រើនឡើងៗ... ទាំងអស់នេះឬ ជាសុភមង្គលដែលបារាំងនាំយកមកឲ្យខ្មែរ ជាថ្នូរនឹងការដែលគេដកហូតយកឯករាជ្យរបស់យើងនោះ ?...

យើងបែកចេញពី ហ្លួង និង ក្រុងប៉ារីស៍ ដោយក្ដីសប្បាយរីករាយក្រៃលែង ដើម្បីត្រឡប់មកកាន់ក្រុងម៉ារ៍សី ដ៏ស្ងាត់ជ្រងំវិញ ដែលយើងអាចធ្វើដំណើរទៅណាមកណាបានតាមចិត្ត ពុំចាំបាច់មានទាហានជិះសេះអមសង្ខាង ដូចមនុស្សទោសទេ ។

ក្នុងពេលធ្វើដំណើរ ពីប៉ារីស៍ មកម៉ារ៍សី ម្ចាស់ ចិន្ដាវង្ស ក៏ធ្វើដំណើរមកជាមួយយើងដែរ ស្រាប់តែវង្វេងបាត់ម្ដាយលើរទេះភ្លើង ក៏តាំងស្រែកខ្សឹកខ្សួលដូចកូនក្មេង ដើររុករកពេញរទេះភ្លើង ប៉ុន្តែនៅពេលចូលមកដល់ក្នុងបន្ទប់យើង ម្ចាស់ខូចនេះបែរជានិយាយរឿងផ្ដេសផ្ដាស កាលពីពេលម្ចាស់ ស្ងួនវង្ស ជាបងនោះ នាំទៅផ្ទះសំផឹងបារាំងទៅវិញ ហើយយើងក៏ចាប់ច្រានចេញទៅវិញភ្លាម ព្រោះយើងមិនចង់ស្ដាប់រឿងអាសអាភាសនេះ ។

មកដល់ម៉ារ៍សី បារាំងលើកគ្នាភ្នាក់ទឹកភ្នាក់ដីមកសុំថតរូបយើងច្រើនណាស់ ហើយពួកនេះមក មិនសូវរើសពេលវេលាផង ជួនកាលមកចំពេលបាយ យើងក៏ត្រូវឈប់ស៊ីបាយសិន ដើម្បីទៅឈរឲ្យគេថត ។

ព្រឹកនៃ ការធ្វើដំណើរវិលត្រឡប់មកកាន់ស្រុកខ្មែរវិញមកដល់ហើយ! យើងរៀបចំឡើងលើកប៉ាល់ជាមួយម្ចាស់ក្សត្រី ហើយទាល់តែថ្ងៃជិតត្រង់ ទើបឃើញហ្លួងយាងមកដល់ ។ បន្តិចក្រោយមក កប៉ាល់ក៏ចាកចេញពីច្រាំង ដឹកនាំយើងមកកាន់មាតុប្រទេស ដែលយើងតែងនឹកគិតឥតភ្លេច ។

កូនស្ដេចជាច្រើនឥតត្រឡប់មកវិញទេ គឺគេនៅរៀនក្នុងស្រុកបារាំង ។ ពួកអស់ហ្នឹងរៀនស្អី? រៀនចម្លងយកទំនៀមទម្លាប់អាសអាភាសមកផ្សាយក្នុងស្រុកខ្មែរឬ?.. ប៉ុន្តែផ្ទុយទៅវិញ នៅលើកប៉ាល់មានមនុស្សថ្មីខ្លះ ដែលយើងពុំដែលឃើញសោះកាលពីពេលទៅ គឺពួកជាងដែលគេដឹកយកមកពីស្រុកខ្មែរតាំងពីយូរណាស់មកហើយ ដើម្បីសង់វិមានថ្មនៅម៉ារ៍សី ជាកន្លែងយើងធ្លាប់ទៅរាំនោះ ។

ពួកអ្នកធ្វើការលើកប៉ាល់ ពុំមែនជាមនុស្សដដែលដែរ គឺប្រាកដជាកប៉ាល់ផ្សេងមួយទៀតហើយ ទោះបីរូបរាងកប៉ាល់នេះដូចគ្នាបេះបិតនឹងកប៉ាល់ដែលយើងជិះមកក៏ដោយ ។

ព្រឹត្តិការណ៍សំខាន់ជាងគេក្នុងពេលធ្វើដំណើរ គឺរឿងដែលគេឃើញ ម៉មន្ទ កំពុងសាហាយជាមួយលោកមហាមន្ត្រី នៅក្នុងបន្ទប់ទឹក ។ រឿងនេះគេខំខ្ទប់លាក់លៀមខ្លាំងណាស់ គ្រាន់តែខ្សិបខ្សៀវអេចអូចពីមាត់មួយទៅមាត់មួយប៉ុណ្ណោះ ។ ហ្លួងក៏បានដឹងរឿងអពមង្គលនេះដែរ ប៉ុន្តែមិនហ៊ានមាត់កថាដូចម្ដេចពីព្រោះសព្វថ្ងៃនេះ លោកមហាមន្ត្រីកំពុងមានអំណាចខ្លាំងណាស់ ។ ប៉ុន្តែទោះជាយ៉ាងណា ក៏លោកកាន់តែជិតដិតនឹង ម៉មន្ទ ខ្លាំងឡើងៗ ។

ចាប់តាំងពីថ្ងៃនោះមក មីវ៉ៃ និង មីស៊ុន ពួកម៉ាកខ្ញុំតាំងពីក្មេងៗមក គេប្រសប់អែបអបយកគាប់គួរក៏បានឡើងឋានៈជាអ្នកគាប់ចិត្តហ្លួង បានត្រួតត្រាមើលក្រុមអ្នកគាល់បម្រើផ្ទាល់ព្រះអង្គ ព្រមទាំងបានទទួលរង្វាន់ជាកិត្តិយស និង គ្រឿងអាលង្ការច្រើនណាស់ ។ មីវ៉ៃ ខ្មៅក្រញេះ បានប្ដូរឈ្មោះជា វណ្ណារតន៍ ហើយបានត្រូវគេទាំងអស់គ្នាគោរពអួតសរសើរ សុទ្ធតែវាហ្នឹងជាស្រីគ្រប់លក្ខណ៍ ហើយម្ចាស់ខ្លួនវានោះទៀត ដល់បានឡើងបុណ្យអញ្ចឹង វាភ្លេចអស់ជាតិកំណើតវាជាផង្វរ ភ្លេចអស់ពួកម៉ាកដែលកាលពីដើមធ្លាប់ស៊ីបាយមួយចានពីរនាក់ ជក់បារីមួយដើមពីរនាក់ ។

ប្រហែលជាទេវតារក្សាសមុទ្រ ចង់ផ្ដន្ទាទោសចំពោះពួកអ្នកដំណើរដ៏មានគំនិតខូចរៀចវេ ហ៊ានសាហាយស្មន់គ្នាលើកន្លែងដែលគេថែរក្សាហើយមើលទៅ! ខ្យល់ខ្លាំងបក់មកពីទិសនិរតី លាន់ឮសន្ធឹកដូចព្យុះសង្ឃរា បង្កើតជារលកធំៗជាងផ្ទះ បក់បោកមកលើកប៉ាល់ បណ្ដាលឲ្យឃ្លេងឃ្លោងរកកលនឹងលិច ។ ទឹកកញ្ជ្រោលបោកឡើងលិចដល់ក្ដារកប៉ាល់ ហើយហៀរចូលតាមបង្អួចបិទមិនជិត លិចទាំងបន្ទប់ដែលយើងដេកនោះផង ។ យើងទាំងអស់គ្នាកើតជម្ងឺពុលរលក ក្ដួតដាក់លើឡាំងឈើលើពូក ប្រឡាក់អស់គ្មានសល់ ។ នរណាដែលពីមុនមកធ្លាប់អួតថាខ្លួនគ្រាន់បើនោះ ក៏លែងអួតក្អេងក្អាង ត្រឡប់ជាវត់រកធូបមកអុជសំបូងសង្រួង នឹកអស់គុណម៉ែ-គុណឪ ហើយអ្នកខ្លះទៀត យំស្រែកទ្រហឹងអឹងអាប់ ។ និយាយពីហ្លួងវិញ ធ្លាក់ខ្លួនឈឺពុលរលកប៉ុណ្ណឹងហើយ នៅផ្ទៀតជេរបញ្ឆោរបារាំង ស្ដីឲ្យអ្នកត្រួតត្រាធំជាងគេលើកប៉ាល់ថា នាំលោកចេញឆ្ងាយពីច្រាំងមកដល់កណ្ដាលសមុទ្រទាល់តែវង្វេងផ្លូវរកទិសតំបន់មិនឃើញ ។ លោកនឹកអស់គុណជីដូនជីតា ព្រមទាំងសារភាពទទួលកំហុសទាំងអស់ដែលលោកបានប្រព្រឹត្ត សុំឲ្យស្ដែចរស់ជីវិតមួយគ្រានេះ ។

ក្នុងពេលនោះ គ្មាននរណាម្នាក់ហ៊ានសង្ឃឹមថា នឹងគេចផុតពីកណ្ដាប់ដៃសមុទ្រទេ ។ យើងម្នាក់ៗនឹកឃើញអស់រឿងសត្វសមុទ្រ ក្រពើ ឆ្លាម ហើយគំនិតយើងរសាត់ទៅដល់មាត់ច្រាំងដីរករាយ ក្រោមរស្មីព្រះអាទិត្យនៃមាតុភូមិរបស់យើង ដែលពេលនេះប្រហែលជា ឪពុក-ម្ដាយ យើង កំពុងអង្គុយលើរានហាលផ្ទះ នឹកព្រួយបារម្ភពីវាសនាយើង ភ្នែកមើលទៅជើងមេឃដ៏ឆ្ងាយឥតព្រំដែន... ។

នៅទីបញ្ចប់ មហាសមុទ្រក៏រាំងាប់ភ្លឹងកំហឹងខ្លួនទៅវិញ... យើងត្រឡប់មកដល់ប្រទេសសិរីលង្កាដោយសុវត្ថិភាព ។ ក្រោយពេលឃ្លាតទៅអស់ពេលបីខែដ៏យូរប្រៀបបានបីឆ្នាំ យើងបានវិលមកឃើញច្រាំងកូសាំងស៊ីន ក្រុងព្រៃនគរ ទន្លេធំ និង ដីចំការស្រុកលើកដែកវិញ ដោយក្ដីសប្បាយរីករាយរកអ្វីមកប្រៀបឲ្យស្មើពុំបាន ។ ទឹកដែលហូរនាំដីល្បប់មក ជន់ឡើងលិចដល់ច្រាំង ទំនងដូចជាចង់លិចដល់សួនច្បារកំពង់ផែផង ។ កប៉ាល់ចូលមកចតចំមុខវាំងតែម្ដង... ទូកច្រើនរាប់មិនអស់ មកចោមរោមជុំវិញកប៉ាល់... ខ្ញុំឃើញ ពុក និង ម៉ែ ឈរស្រែកសាច់ស្គមជាងមុនឆ្ងាយណាស់ ព្រោះគាត់ព្រួយចិត្តខ្លាំងពេក ស្មានថាខ្ញុំ



ស្លាប់មិនបានមកជួបគាត់វិញទេ ។ គេដង្ហែពួកយើងចុះពីកប៉ាល់ ដើរតាមផ្លូវរៀបដល់មាត់ទ្វារកំផែងសីមា ។

ពេលបានមកឃើញផ្ទះឪពុកម្ដាយខ្ញុំដ៏តូចច្រឡឹងក្រោមរស្មីព្រះអាទិត្យនេះវិញ ការតានតឹងក្នុងចិត្តទាំងប៉ុន្មាន ក៏រលាយបាត់អស់ដោយឯកឯង ។

អស់អ្នក-អស់នាង ដែលមិនបានទៅស្រុកបារាំងនឹងគេ ដណ្ដើមគ្នាស្ដាប់យើងនិយាយប្រាប់ ឡើងចំហមាត់ ហើយប្រញាប់គ្នាដណ្ដើមយកអស់របស់របរដែលយើងទិញបានមកទាំងប៉ុន្មាន ឥតមានសល់អ្វីបន្តិចបន្តួចឡើយ ក្រៅតែពីអនុស្សាវរីយ៍ដ៏ល្វីងជូរចត់ ដែលយើងខំបំភ្លេចចោលឲ្យបានឆាប់ជាទីបំផុត ។

♥ ♥

♥

## ក្រុមតន្ត្រីបាំព្រះរាជទ្រព្យ




Orchestre du Palais Royal

ឥឡូវនេះ ខ្ញុំមានការពិសោធន៍គ្រប់គ្រាន់ ខ្ញុំអាចដឹងយ៉ាងច្បាស់ដោយខ្លួនឯងថា ចាប់តាំងពីពេលនេះតទៅ ក្ដីសង្ឃឹមថានឹងបានក្លាយទៅអ្នករបាំមានកេរ្តិ៍ឈ្មោះល្បីក្នុងថ្ងៃណាមួយខាងមុខនោះ រលាយសាបសូន្យអស់ហើយ។ ក្នុងរយៈពេលពីរឆ្នាំចុងក្រោយ នៃ ការរស់នៅក្នុងវាំង ខ្ញុំជួបប្រទះតែនឹងរឿងរ៉ាវគួរអស់សង្ឃឹម គួរឆ្អែតចិត្តផ្សេងៗគ្នា។

ខ្ញុំអាយុបានដប់បីឆ្នាំហើយ គឺខ្ញុំនេះពេញវ័យល្មមគេចាត់ទុកថាជាស្ត្រីម្នាក់ហើយ។ ភ្លៅខ្ញុំប្រែជាមានសាច់ណែនមូលក្លំ ហើយខ្ញុំភ័យណាស់ខំរត់ទៅលបសួរម៉ែនៅពេលឃើញមានដុះរោមត្រឡាចត្រង់ចន្លោះគល់ភ្លៅទាំងពីរ។ ត្រគាកខ្ញុំរីក ហើយដោះខ្ញុំក៏ចាប់ផ្ដើមដុះធំប្រហែលប៉ុនមេដៃប៉ុណ្ណោះ ប៉ុន្តែឈឺពាល់មិនបាន។

ខ្ញុំមិនដែលហ៊ាននិយាយរឿងអស់នេះប្រាប់ពួកម៉ាកទេ ព្រោះពួកមីអស់ហ្នឹងវាសុទ្ធតែស្រួតគ្រប់ការមុនខ្ញុំទៅទៀត។ ប៉ុន្តែពួកវានៅតែប្រវ៉ែងដេញគ្នាពេញសួនច្បារ ស្រែកហ៊ោកញ្ជៀវ ឬ ស៊ីនំកាន់សំរែងដូចកូនក្មេង ឥតឃើញវាផ្លាស់ប្ដូរចរិតត្រង់ណាបន្តិចបន្តួចសោះ។ ចំណែកខ្ញុំវិញ ខ្ញុំលែងហ៊ានទៅងូតទឹកម៉ាស៊ីននៅកណ្ដាលវាលដូចមុនទៀតហើយ ដោយខ្លាចប្រុសៗដូចជា ពោយ ឬ អ្នកធ្វើបាយហ្លួង អ្នកហ្លួងបងប្អូន ឬ ឪពុកម្ដាយពួកល្ខោន ឬ កូនស្ដេចតូចៗក្បាលខូច គេដើរទៅមកឃើញ។

សេចក្ដីអៀនខ្មាសវាតម្រូវឲ្យខ្ញុំលះបង់សេរីភាពខ្លះចោលចេញ គឺខ្ញុំត្រូវប្រយ័ត្នប្រយែងងូតទឹកតែក្នុងបន្ទប់ស្រួលបួល។ ស្រីៗខ្លះបានចូលដល់ក្នុងបន្ទប់ទឹក ក៏តាំងលែងខ្លួនទទេ ស្លៀកតែសារុងចងក្បិនកប់ក្រលៀនដូចប្រុស។ ទោះបីខ្ញុំមានការអៀនខ្មាសខ្លះយ៉ាងនេះក៏ដោយ ក៏ខ្ញុំនៅតែភ្លីភ្លើមិនស្ងៀវដឹងអី នៅតែមានចរិតក្មេងនៅឡើយ។ ពេលទំនេរក្រោយពេលហាត់រាំ នៃ ថ្ងៃណាដែលខ្ញុំពុំត្រូវវេនចូលគាល់បំរើហ្លួង ខ្ញុំចំណាយពេលសម្រាប់ ដេរអាវ ឬ ជ្រលក់សំពត់ មិនឲ្យទំនេរឥតប្រយោជន៍។

ខ្ញុំយកចិត្តទុកដាក់ថែទាំរបស់ប្រើប្រាស់ខ្លាំងណាស់ ហើយមីពួកម៉ាកអស់ហ្នឹង បើខ្ចីសំពត់អាវខ្ញុំយកទៅស្លៀកម្ដងៗ វាស្លៀកពង្រិចពង្រិលទាល់តែ ប្រឡាក់គគ្រិច ឬ រហែកធ្លុះធ្លាយ ទើបវាយកមកសងវិញ ម្ល៉ោះហើយខ្ញុំខ្ជិលយកវិញ សុខចិត្តឲ្យវារហូតតែម្ដង។

ឥឡូវខ្ញុំមានបន្ទប់ផ្ទាល់ខ្លួនតូចមួយ សម្រាប់ដេកម្នាក់ឯងដាច់ឡែកពីគេ នៅក្នុងរោងដែលពីដើមយូនថាន់ គាត់សង់ឲ្យកូនល្ខោនគាត់នៅ។ ផ្ទះនេះធ្វើពីឈើ មានពីរជាន់ សង់ខ្ពស់ពីដីបន្តិច ពិបាកក្រៃលែងក្នុងការលួចចូលបោសសំរាមដែលគរស្អុយរលួយនៅក្រោមផ្ទះ តាំងពីច្រើនឆ្នាំណាស់មកហើយ។ ជណ្ដើរនាំឡើងទៅកាន់ជាន់ទីមួយ ដែលជាកន្លែងដេករបស់ពួកល្ខោន វាយខណ្ឌជាបន្ទប់ដាច់ៗពីគ្នា។



នៅជាន់ខាងក្រោម ក៏ដូចជាជាន់ខាងលើដែរ ពិតានឈើពុកអស់ កាលណាភ្លៀងម្ដងៗ លិចដូចដេកកណ្ដាលវាលអញ្ចឹង។ ពីកន្លែងដេកទៅ ខ្ញុំអាចមើលឃើញ សួនច្បារ ផ្លូវក្រាលថ្ម ដើមឈើធំៗ និង កំពូលប្រាសាទលាបទឹកមាសលឿងឆ្អិនឆ្អៅ ហើយនៅខាងត្បូងឯណោះ ផងទង់ នៃ វត្តព្រះកែវ លូតខ្ពស់ដាច់គេ។

គ្រឿងប្រើប្រាស់ទាំងអស់ សុទ្ធតែជារបស់ផ្ទាល់ខ្លួនខ្ញុំ ដែលពុកទិញយកមកឲ្យ គឺគ្រែឈើមួយ មានមុង ពូកក្រាលកម្រាលខ្មៅ កន្ទេល ខ្នើយ ហិបពីរសម្រាប់ដាក់សំពត់អាវ និង ប្រាក់កាស និង ទូកញ្ចក់តូចមួយ ដែលនៅក្នុងនោះ ខ្ញុំតម្រៀបដាក់ ដបទឹកអប់ កំប៉ុងម្សៅ និង រមៀត សម្រាប់លាបសំអិតសំអាងកាយរាល់ថ្ងៃ។ លើសពីនេះទៅទៀត ខ្ញុំមានរៀប ជរ អំបោះហុង ម្ជុល កន្ត្រៃ សំពត់ ផាហ៊ុំ សារុង បត់តម្រៀបគរលើគ្នា ព្រមទាំងមានដាក់ ផ្កាចម្ប៉ា ផ្កាចេកទុំ ផ្កាវំចេក នៅជាមួយនោះ សម្រាប់អប់សំពត់អាវឲ្យក្រអូប។

ខ្ញុំឧស្សាហ៍មានទទួលភ្ញៀវពីក្រៅ គេមកលេងជាញឹកញយ ប៉ុន្តែខ្ញុំមានកន្តោរស្តោះមួយសម្រាប់ការពារកុំឲ្យភ្ញៀវស្ដោះទឹកមាត់ស្លាដាក់លើក្ដារ។ ពួកភ្ញៀវស្រីអស់ហ្នឹងថាមកលេង ប៉ុន្តែតាមពិតគេតម្រង់មករកសុំសំពត់អាវ ឬ លុយកាក់ទៅវិញទេ ហើយខ្ញុំក៏កម្រប្រកែកថាមិនឲ្យណាស់ ពីព្រោះថ្ងៃណាមួយខ្ញុំនឹងត្រូវពឹងពាក់អ្នកអស់នោះវិញមិនខាន។ ជួនកាលទៀត ភ្ញៀវអស់ហ្នឹងមានរឿងផ្សេងៗ គឺគេលាក់ សាប៊ូក្រអូប ទឹកអប់ស្រុកបារាំង ម្សៅកញ្ចប់ ឬ នំចំណី ដែលសុទ្ធជារបស់មានតម្លៃ យកមកឲ្យខ្ញុំ ហើយសារភាពប្រាប់ថា នេះជាបញ្ញើ របស់អ្នកនេះ របស់អ្នកនោះ ដែលធ្លាប់ឃើញខ្ញុំរាំ ហើយចាប់ចិត្តស្រឡាញ់ខ្ញុំ។ គេសុំឲ្យផ្ញើកន្សែងមួយទៅឲ្យគេវិញ ទោះជាកន្សែងនោះចាស់រហែកយ៉ាងណាក៏ដោយ ឲ្យតែមានជាប់ក្លិនខ្លួនខ្ញុំ! ខ្ញុំធ្វើឫកជាខឹងនឹង ។កមេអណ្ដើកនេះ ដោយនិយាយកំហែងថា នឹងទៅទូលហ្លួងឲ្យចាប់ យកទៅវាយធ្វើបាប យកទៅដាក់គុ..រស់អាយុមិនខាន ប៉ុន្តែទោះជាយ៉ាងណា ខ្ញុំក៏នៅតែទទួលយករបស់ជំនូនដែរ ដើម្បីយកទៅចែកពួកម៉ាកស៊ីសើចលេងសប្បាយ ដោយមានផ្ដាំផ្ញើពាក្យជេរបញ្ចោរឲ្យទៅពួកកម្លោះស្នេហាលុងខួរនោះផង។

ខ្ញុំខំរៀបចំបន្ទប់ឲ្យបានស្អាតជាងបន្ទប់ពួកម៉ាកឯទៀត។ មានតែ កាហ៊ុន ប្អូនស្រីជីដូនមួយខ្ញុំទេ ដែលមកនៅជាមួយខ្ញុំរាល់ថ្ងៃ ជាអ្នកបំរើ ជាពួកម៉ាក ជាអ្នកមើលខុសត្រូវលើទ្រព្យសម្បត្តិខ្ញុំ និង ជាអ្នកនាំដំណឹងពីខ្ញុំទៅផ្ទះ និង ពីផ្ទះមកខ្ញុំ។

រាល់ថ្ងៃ វាពិបាកបំផុតត្រង់អារឿងបោសសំរាម និង រៀបចំអីវ៉ាន់ដែលពួកភ្ញៀវចូលមករើរុះតាមចិត្ត។ ពួកម៉ាកខ្លះនៅក្នុងថែវនោះ ពិបាកពេកវានាំគ្នាម្ដងបួន-ប្រាំនាក់ មកដេកពេញកន្លែងខ្ញុំ ថែមទាំង លេងបៀ ជក់បារី ពង្រាយគួរឲ្យធុញទ្រាន់ក្រៃលែង។ ដើម្បីបណ្ដេញវាចេញទៅវិញ ទាល់តែប្រើកម្លាំងបាយ ឬ ធ្វើចរិតឲ្យកាចឃោរឃៅបន្តិច ប៉ុន្តែខ្ញុំពុំបាននឹកស្មានថា ការដែលខ្ញុំធ្វើដូច្នេះវាអាចជាហេតុនាំឲ្យគេយកទៅទូលហ្លួង ទូលម្ចាស់ក្សត្រី ថាខ្ញុំកាចឆ្នាស់ ដើម្បីដណ្ដើមយកសេចក្ដីគាប់គួរសម្រាប់ខ្លួនវិញសោះ។

ពេលព្រលប់ មានចង្កៀងឆេះឯងព្យួរនៅនឹងពិតានបំភ្លឺពេញបន្ទប់ ហើយមានចង្កៀងមួយទៀតដាក់នៅក្រោមបង្អួចបន្ទប់ខ្ញុំ សម្រាប់បំភ្លឺសួនច្បាររហូតទល់ព្រឹក។ រាល់ព្រឹក ខ្ញុំ និង កាហ៊ុន កាន់អំបោសស្រ៉ក់ផ្លូងមួយម្នាក់ ដើម្បីបោសច្រាសបន្ទប់សព្វអស់កន្លុកកន្លៀត បន្ទាប់មកខ្ញុំងូតទឹកសំអាតខ្លួន ហើយបើចំលើពេលត្រូវវេនចូលបំរើហ្លួង ខ្ញុំត្រូវងូតទឹកយូរជាងសព្វមួយផង។

កាលណាកាហ៊ុន វាទៅយកបាយពីផ្ទះមកទទួលទាន ម៉ែឧស្សាហ៍តាមមកជាមួយវា ដើម្បីមកលេងនឹងខ្ញុំ។ ចំណែកពុកវិញ យូរៗទើបបានមកលេងម្ដង ប៉ុន្តែមកម្ដងណា ក៏ដូចម្ដងណា ពុំដែលបានលុយ

មួយសេនពីខ្ញុំយកទៅផ្ទះទេ មានតែខ្ញុំខ្វះកកាយយកអស់ពីហោប៉ៅគាត់ ហើយបើមានបារីប៉ុន្មាន គាត់បារឲ្យខ្ញុំទាំងអស់ សុខចិត្តអត់ខ្លួនឯង ។

ក្នុងបួនថ្ងៃ ខ្ញុំទំនេរបានបីថ្ងៃ... ក្នុងពេលទំនេរនេះ ខ្ញុំមិនស្ទូវរវល់រឿងសំអាតខ្លួនប៉ុន្មានទេ ហើយខ្ញុំចុះទៅទិញនំដែលគេដាក់លក់នៅក្នុងសួនច្បារ បន្ទាប់មកយើងប្រជុំគ្នាដើរលេងទាំងក្រុមៗ ដោយមាន ម៉មសំអយ, សំអាង, ចែម, ស៊ុន, សូឡាយ អ្នកក្លាហានជាងគេ ជាមេអ្នកដឹកនាំ ។ យើងលួចអស់ មាន់ទា ផ្លែពុទ្រា ផ្លែល្មុត ដែលស្តេចចាស់ៗ និង អស់អ្នកអស់នាង ថែទាំស្រោចទឹកយ៉ាងផ្ចិតផ្ចង់បំផុត ។ កាលណាយើងលួចឆ្អែតឆ្អន់ហើយ យើងនាំគ្នាទៅអង្គុយជជែកលេងនៅកន្លែងកៀនងងឹត ។ ពួកធំៗបង្អាប់គ្នាទៅវិញទៅមកថា មានទាក់ទងជាមួយស្មៀនធ្វើការ នៅប៉ុយ្យ៉ូប៉ីស៊ីដង់បារាំង ឬ នៅប៉ុយ្យ៉ូកុង្ស៊ី ពីព្រោះកាលពីពេលចេញរាំលើកមុន គេសង្កេតឃើញអ្នកនេះលួចឲ្យកន្ទុយភ្នែកអ្នកនោះច្បាស់ណាស់ ។ អ្នកខ្លះទៀត និយាយសារភាពប្រាប់គ្នីគ្នាពីការមិនពេញចិត្ត ចំពោះជីវភាពក្នុងវាំង ចំពោះការដែលហ្លួងមិនស្ទូវរវីរវល់គិតគូរដល់ខ្លួន ព្រមទាំងអួតសរសើរពីការសប្បាយរីករាយ នៃ ជីវភាពដែលពោរពេញទៅដោយសេរីភាពនៅខាងក្រៅវាំង ដែលប្រុសអាចតាមមើលស្រីបានដោយឥតភ័យខ្លាចជាប់គុក ដែលស្រីអាចតែងខ្លួនស្អាតបាតដោយមិនចាំបាច់លាក់លៀមពីភ្នែកពួកក្រុមវាំង ។ គេជជែកគ្នាអែប្រមែរហូតដល់យាមទីពីរ ទើបនាំគ្នាទៅដេករៀងៗខ្លួន ។ ខ្ញុំងងុយដេកធ្ងន់ក្បាល ប្រះដេកភ្លាមក៏លក់ភ្លាម ឥតមានគិតខ្វាយខ្វល់ដល់ពាក្យសំដីដែលពួកធំៗគេនិយាយគ្នានោះទេ ខ្ញុំស៊ីមួយថ្ងៃសម្រាប់រស់មួយថ្ងៃ ឥតមានភ័យព្រួយពីថ្ងៃស្អែក រស់ប្រៀបបាននឹងសត្វយ៉ាងនោះដែរ ។

វិន័យ និង របៀបរៀបរយ នៅក្នុងវាំង ត្រូវគេបោះបង់ចោលទាំងស្រុង ។ វាំងសព្វថ្ងៃ ក៏មិនដូចវាំងកាលពីដើមដែរ ពីព្រោះអ្នកធំចេះតែមានគំនិតបង្កើតរឿងមិនល្អប្លែកៗគ្នាមិនចេះអស់ ម្ល៉ោះហើយអ្នកតូចតាចចាំតែយកតម្រាប់តាម នរណាមិនចូលចិត្តយកតម្រាប់តាមគេទេ ក៏ត្រូវតែចាកចេញពីវាំងទៅនៅក្រៅវិញ ។ មិនបានប៉ុន្មានឆ្នាំផង អស់អ្នកអស់នាង អ្នកភ្លេង អ្នករបាំ គ្រូរបាំ រហូតដល់អ្នកបំរើ សុទ្ធតែផ្លាស់ថ្មីទាំងអស់ ។

កាលពីដើម មានក្រុមល្ខោនបី ឥឡូវនៅសល់តែមួយគត់ ក្រោមកិច្ចដឹកនាំ នៃ ម្ចាស់ក្សត្រី ដែលសំអាងយកអំណាចខ្លួនជាកូនស្រីច្បង នៃ ស្តេចសោយរាជ្យ មកធ្វើជាធំលើសគេទាំងអស់ ។ មុខងាររបស់លោកមានត្រឹមតែជ្រើសរើសស្រីក្មេងៗកូនអ្នកស្រែរំឃឹរឃារ មកបំពេញកន្លែងខ្វះចន្លោះតែប៉ុណ្ណោះ ។ រឿងអស់នេះ ហ្លួងមើលមិនឃើញទេ ពីព្រោះទាំងយប់ទាំងថ្ងៃ លោកសម្ងំនៅតែក្នុងប្រាសាទបាញ់យ៉ុង ។ សូម្បីទិដ្ឋភាពនៅជុំវិញដំណាក់ហ្លួងក៏ប្លែកពីដើមដែរ អ្នកលក់នំចំណី អ្នកសុំទាន ចូលមកដល់ជិតដំណាក់ហ្លួង បង្កើតជាភាពក្រខ្វក់គ្រប់ទីកន្លែង ។

ពួកមីដែលថា មកសុំនៅក្នុងវាំងនៅពេលក្រោយៗនេះទាំងប៉ុន្មាន វាគ្រាន់តែ រៀនលាបម្សៅយីហ៊ុន រៀនពត់ដៃពត់ជើង ដើម្បីធ្វើជាលេសប៉ុណ្ណោះ តាមពិតវាមកលួច សំពត់អាវ មាសពេជ្រ របស់គេឯងរាល់គ្នា យកទៅកប់លាក់ទុកក្នុងកន្លែងណាមួយ រង់ចាំតែយប់ណាមានឱកាសល្អ វានឹងទៅកកាយយករបស់ទាំងនោះ ហើយលួចរត់ចេញពីវាំងទៅបាត់តែម្តង ។ រាល់យប់តែងតែមានមីណាមួយលួចរត់ មិនស្ទូវលោះខានឡើយ ។

ពួកអ្នកធ្វើព្រះស្ងោយហ្លួង និង ពួកកូនចៅ ឧស្សាហ៍និយាយប្រាប់ខ្ញុំថា កាលគាត់ចេញទៅផ្សារ គាត់បានឃើញ មីនេះ មីនោះ ដែលធ្លាប់មកនៅវាំងបានប៉ុន្មានថ្ងៃ ហើយលួចរត់ចេញទៅវិញ ធ្វើឫកដូចជាសំផឹងដើរទាក់ទង ជាមួយចិន ជាមួយបារាំង អួតសុទ្ធតែខ្លួនវាហ្នឹងជាពួកល្ខោនហ្លួង ។



ជំនាន់នោះ មានតែពួកយើងមិនដល់ដប់នាក់ផង ដែលជាអ្នករបាំយកចិត្តទុកដាក់ក្នុងការងារគឺ ល្វេន មិត សំអាង ម៉ាប៉ាន់ យ៉ាន វ៉ៃ ហើយនិង ខ្ញុំ ។ ពួកយើងសុខចិត្តនៅហាត់រៀនជាមួយគ្រូចាស់ៗ ជាជាងឆ្លៀតពេលទំនេរ ដើរអង្គុយលេងឥតប្រយោជន៍ឯដំណាក់ហ្លួង ។ ប៉ុន្តែក្នុងចំណោមអ្នកប៉ុន្មាននាក់នេះ មានតែ យ៉ាន និង ខ្ញុំ ទេ ដែលហាក់ដូចជាលេចមុខខ្ពស់ជាងគេ ។ ទោះបីពាក្យទំនាយរបស់អ្នកអង្គម្ចាស់ផ្លូងមធុរា ដែលលោកទាយទុកថា យើងពីរនាក់នឹងក្លាយទៅជាតារា នៃ ក្រុមល្ខោនហ្លួងនោះ ពុំអាចសំរេចទៅបាន ដោយហេតុកាលៈទេសៈថ្មីវាប្រែប្រួលប្លែកពីដើមយ៉ាងណាក៏ដោយ ក៏ទឹកមុខញញឹមរបស់អ្នកគ្រូសម្តែងសេចក្តីពេញចិត្តចំពោះយើង វាជាកម្លាំងលើកទឹកចិត្តម្យ៉ាងដែរ ពេលណាយើងត្រូវចេញរាំលើឆាកម្តងៗ ។

យ៉ាន និង ខ្ញុំ ត្រូវចេញរាំមុខអ្នករបាំទាំងពីរជួរជានិច្ច ។ យើងមានសៀតកន្សែងសូត្រពណ៌ ក្រហម ឬ ស នៅខ្សែក្រវាត់រៀងខ្លួន ហើយកាលណាយើងចូលមកជិតគ្នា យើងលួចកេះលួចក្តិចគ្នា ទៅវិញទៅមក យ៉ាងពេញចិត្ត ។ យើងពីរនាក់ជាតួរបាំឆើត អាចពត់ពេនទន់ភ្លន់ទៅតាមចង្វាក់ភ្លេងត្រូវឥតខ្ចោះ ប៉ុន្តែឥតមាននរណារវល់យកចិត្តទុកដាក់នឹងយើងប៉ុន្មានឡើយ ព្រោះសព្វថ្ងៃនេះគេរើសយកធ្វើជាតួឯក តែនរណាដែលជាទីពេញចិត្ត របស់ហ្លួង ឬ របស់ម្ចាស់ក្សត្រី ប៉ុណ្ណោះ ទោះបីអ្នកនោះគ្មានលក្ខណៈជាអ្នករបាំក៏ដោយ ។

ពួកអ្នកគ្រូយល់ច្បាស់ណាស់ថា តួ យ៉ាន និង ខ្ញុំ ពុំអាចយកនរណាផ្សេងទៀតមកផ្លាស់ជំនួសបានទេ ប៉ុន្តែគាត់ក៏មិនដឹងធ្វើម៉េចដែរ សុខចិត្តតែនៅស្ងៀមទៅ ពីព្រោះសព្វថ្ងៃ មីសួនវាគាប់ជាងគេ វាត្រូវតែបានឡើងធ្វើតួឯកអញ្ចឹង ។ ពេលចេញរាំម្តងៗ វាពាក់មាសពេជ្រស្រោចខ្លួន ពីព្រោះវាពូកែបញ្ជោរចៅហ្វាយនាយ យកគាប់គួររកនរណាប្រៀបឲ្យស្មើពុំបាន ប៉ុន្តែតាមពិត វាគ្រាន់តែជាអ្នករបាំរាយរងប៉ុណ្ណោះ ។

ហេតុនេះហើយ ទើបបានជាសព្វថ្ងៃគេត្រូវបង្ខំចិត្តជ្រើសរើសយកពួកអ្នកមិនចេះអីសោះ មកដាក់បំពេញកន្លែងហាត់រាំ និង រត់ទៅពឹងអ្នករបាំជើងចាស់ ដូចយ៉ាង ម៉មទូ ម៉មប្រឹម ម៉មសំអយ ជាដើម ដែលគេបំភ្លេចចោលទៅហើយនោះ ឲ្យត្រឡប់មកជួយបង្ហាត់ក្មេងសាក្រោយផង ។

ខ្ញុំនេះល្ងង់ពេកណាស់ ពុំអាចកាត់យល់បានពីអំពើអយុត្តិធម៌ផ្សេងៗ ដែលគេធ្វើមកលើខ្ញុំបានទេ ។ ខ្ញុំចេះតែគិតថា បើខ្ញុំខិតខំធ្វើការបានល្អ គង់នឹងមានគេមើលឃើញ ហើយគេនឹងលើកខ្ញុំឲ្យធ្វើជាតួឯកមិនខាន ។ ពេលចេញរាំម្តងៗ ខ្ញុំមួម៉ៅណាស់ គេឲ្យខ្ញុំធ្វើតែតួរាយរង អត់បានស្លៀកពាក់សំពត់អាវល្អនឹងគេ បានពាក់តែមកុដជ្រលក់ទឹកមាសតែប៉ុណ្ណោះ ។ ជួនកាលខ្ញុំឈឺចិត្តទ្រាំមិនបាន ទាល់តែស្រក់ទឹកភ្នែក នៅពេលឃើញគេប្តូរមិនឲ្យខ្ញុំរាំតួដែលខ្ញុំហាត់រាប់ខែមកហើយ ។ ការខំប្រឹងប្រែងរបស់ខ្ញុំ ពុំបានធ្វើឲ្យម្ចាស់ក្សត្រីពេញចិត្តទេ ប៉ុន្តែលោកហាក់ដូចជាជិនឆ្អន់នឹងខ្ញុំកាន់តែខ្លាំងឡើងៗជាលំដាប់ ។

សូម្បីពួកមីកូនចៅម្ចាស់ក្សត្រី ក៏បញ្ចេញឫកពេបជ្រាយដាក់ខ្ញុំខ្លាំងណាស់ដែរ ដែលជាហេតុធ្វើឲ្យខ្ញុំយល់បានខ្លះថា គំនិតត្រង់ភ្លឹងស្លូតស្លាប់របៀបខ្ញុំនេះ ពុំមែនជាទីពេញចិត្ត នៃ ម្ចាស់ក្សត្រី ឡើយ ពីព្រោះលោកបានសាកល្បងទាញខ្ញុំឲ្យទៅរស់នៅក្នុងចំណោមកូនចៅលោកច្រើនដងណាស់ហើយ ពុំដែលបានសំរេចសោះ ។

យ៉ាន ក៏មិនមែនសប្បាយចិត្តជាងខ្ញុំប៉ុន្មានដែរ ប៉ុន្តែធ្វើម៉េចគ្នាជាកូនកំព្រាគ្មានទីពឹង ចេះតែទ្រាំទៅ ឲ្យតែមានបាយស៊ី មានដំបូលជ្រក ប៉ុណ្ណឹងវាគ្រប់គ្រាន់ណាស់ហើយ វាមិនចង់យកគាប់គួរ ជាមួយម្ចាស់ក្សត្រី ជាមួយហ្លួង អ្វីទាំងអស់ ។

ឥឡូវ ខ្ញុំក៏ខ្លាចហ្លួងណាស់ដែរ បើកុំតែអញ្ចឹងខ្ញុំមិនបាច់ទៅហាត់រាំ នាំតែនឿយហត់អត់ប្រយោជន៍ទេ ចាំមើលតែស្អែកឡើងដល់ពេលចេញរាំ យប់នេះទៅនាយអាយជាមួយហ្លួងមួយសន្ទុះ ច្បាស់ជាបានធ្វើភ្លូងកមិនខាន ។

ហេតុដែលនាំឲ្យខ្ញុំខ្លាចហ្លួង គឺថ្ងៃមួយជាវេនខ្ញុំគាល់បំរើហ្លួង ខ្ញុំអង្គុយជជែកគ្នាលេងជាមួយពួកម៉ាកពីរ-បីនាក់ នៅលើក្បាលជណ្តើរប្រាសាទបាញ់យ៉ុង រង់ចាំទម្រាំហ្លួងភ្ញាក់ពីផ្ទំវិញ ។ ពេលនោះហ្លួងឲ្យគេហៅមីស៊ុននិងមីវ៉ន ចូលទៅក្នុងបន្ទប់ផ្ទាល់ព្រះអង្គ ហើយបិទទ្វារចាក់សោជាប់ ។ ប្រហែលមួយម៉ោងក្រោយមក ទើបឃើញវាទាំងពីរនាក់ចេញមកវិញ ធ្វើឫកបែបអៀនប្រៀន ភ្នែកក្រហម សំពត់ខ្ទិកខ្ទុកខ្ទេចខ្ទីអស់ ហើយវារត់ទៅសម្ងំនៅក្នុងបន្ទប់ដេកបាត់ ។ ពួកធំៗគេនាំគ្នាសើចគិល ដែលជាហេតុអាចឲ្យខ្ញុំកាត់យល់រឿងហេតុសព្វគ្រប់ទាំងអស់បានដោយងាយ ។ បន្ទាប់ពីមានរឿងនេះបន្តិចមក ដល់វេនហ្លួងហៅនាងម៉ាឡា ដែលទើបនឹងគ្រប់ការថ្មីៗឲ្យចូលក្នុងបន្ទប់ម្តង ហើយមួយសន្ទុះក្រោយមក ស្រាប់តែឮហ្លួងស្រែកឡូឡាដេញវាថាឲ្យទៅលាងក្តិតសិន ហើយត្រឡប់ចូលមកវិញ ។ ខ្ញុំពុំដែលគិតថា រឿងរ៉ាវបែបនេះនឹងកើតមានចំពោះខ្ញុំឡើយ ព្រោះខ្ញុំធ្លាប់តែស្រឡាញ់ហ្លួងទុកដូចជាជីតាខ្ញុំយ៉ាងនោះដែរ ម្ល៉ោះហើយខ្ញុំភ្ញាក់ផ្អើលខ្លាំងណាស់ នៅពេលឮពួកធំៗគេនិយាយបំភ័យថាខ្ញុំឆ្កួត ថាកាលណាគេចូលមកបម្រើហ្លួង គេត្រូវតែស្រឡាញ់ហ្លួងដូចស្រឡាញ់ប្តីអញ្ចឹង ។

បន្ទាប់ពីកើតឧប្បត្តិហេតុនេះមក ថ្ងៃមួយ មីពួកម៉ាកម្នាក់ក្បាលខូច វាធ្វើជានិយាយលេងស្រែកខ្លាំងៗពីរឿងខ្ញុំខ្លាចហ្លួង ទាល់តែឮដល់លោក, លោកខំសាកសួររកដើមហេតុ ដែលនាំឲ្យខ្ញុំខ្លាចលោកយ៉ាងនេះ ហើយលោកដូចជាចង់លេងសើចនឹងសភាពល្ងង់ខ្លៅរបស់ខ្ញុំខ្លាំងណាស់ ។ រាល់ថ្ងៃខ្ញុំខំធ្វើការប្រយ័ត្នប្រយែងក្រៃលែង ដើម្បីជៀសវាងកុំឲ្យហ្លួងស្តីបន្ទោស ប៉ុន្តែខ្ញុំពុំបានគិតឃើញថា លោករឹតតែស្អប់ខ្ញុំលើសដើម ដោយហេតុលោកពុំអាចសំរេចបំណង ដែលក្របួចមាត់ប៉ងប្រាថ្នាឲ្យខ្ញុំតាំងពីយូរហើយនោះទេ ។ ជួនកាលលោកគំរាមកំហែងគិតធ្វើបាបខ្ញុំ ជួនកាលលោកបន្ទុះបង្អាប់ដោយប្រើពាក្យមានន័យជ្រៅ គិតទៅឈឺក្បាលទម្រាំយល់ ។ ថ្ងៃមួយខ្ញុំកាន់ខ្សៀអាភៀនយកទៅថ្វាយលោកដែលកំពុងផ្ទំលើគ្រែ ដោយមានអាកប្បកិរិយាភ្លឹក ហាក់ដូចជាកំពុងគិតទៅរឿងអ្វីមួយផ្សេងទៀត លោកក៏លាន់មាត់ថា :

~ ស្តាយណាស់អី មនុស្សមិនគួរស្អាតហើយភ្លើដល់ម្លឹងសោះ! សាវ៉ាម៉ានី ដូចគោអញ្ចឹង ប្រហែលជាវាមានសាហាយនៅឯណា ចង់រត់ចោលអញហើយមើលទៅ......! ។

ខ្ញុំធ្វើជាមិនឮ ព្រោះខ្ញុំមិនយល់ថា ហ្លួងចង់និយាយពីអ្វីទេ ។ នេះជាសំណាងរបស់ខ្ញុំហើយ ដែលទេវតាលោកជួយបិទបាំងមិនឲ្យខ្ញុំយល់អ្វីទាំងអស់ បើកុំតែអញ្ចឹង ម្ល៉ោះសមខ្ញុំនឹងត្រូវធ្លាក់ខ្លួនទៅក្នុងចំណោមប្រពន្ធដ៏ច្រើនរាប់មិនអស់របស់ហ្លួងមិនខាន ។

♥ ♥

♥



**ពេល**វេលាចេះតែធ្វើដំណើរទៅមុខលំដាប់...

ថ្ងៃមួយ ពេលដល់ម៉ោងហ្លួងងើបពីផ្ទំ មីងវ៉ែទតអ្នកលក់ មាសពេជ្រ មកសុំចូលគាល់ ដើម្បីថ្វាយហ្លួងទតគ្រឿងអលង្ការខ្លះ ក្រែងលោកត្រូវការទិញ ។ ហ្លួងអនុញ្ញាតឲ្យគាត់ចូលមក គាត់ក៏អង្គុយរៀបឫកស្រួលបួលរួចហើយ ដាក់ប្រអប់ដែកនៅលើកម្រាលព្រំ ហើយលូករាវយកកញ្ចប់តូចៗច្រើនណាស់ ចេញពីក្នុងស្បោងដែលព្យួរនឹងខ្សែក្រវាត់ទម្លាក់ទៅក្រោមក្បាលពោះគាត់ ។ ហ្លួងក្រពាត់ដៃដើរទៅដើរមកនិយាយថា :

~ មីងវ៉ែទតឯង ចំជាមនុស្សមានទ្រព្យសម្បត្តិច្រើនមែន សូម្បីអាកន្លែងហ្នឹងក៏មានមាសពេជ្រដែរ, នែ! បើមនុស្សធម្មតា លូកទៅកន្លែងហ្នឹង ច្បាស់ជាបានមមិះជាប់ដៃស្រមាមមិនខាន ។

មីងវ៉ែទត ញញឹមមិនរវល់ឆ្លើយតបថាម៉េច គិតតែតម្រៀបកងដៃដាំពេជ្រ ចិញ្ចៀនត្បូងក្រវិល ទំហូដាំពេជ្រ ថ្វាយហ្លួងទត ។

ពេលនេះជាពេលដើមខែ មីងវ៉ែទតគាត់ប្រសប់រើសពេលវេលាល្អណាស់ គឺគាត់មកចំលើពេលដែលហ្លួងកំពុងសម្បូរណ៍លុយ ។ ថ្ងៃនេះជាវេនខ្ញុំកាន់សោ ហ្លួងក៏ប្រើឲ្យខ្ញុំទៅយកកាបូបដាក់ក្រដាសប្រាក់ពេញហៀរមកថ្វាយ ។ ខ្ញុំធ្វើតាមបញ្ជាយ៉ាងប្រយ័ត្នប្រយែងក្រៃលែង ដោយភ័យខ្លាចក្រែងត្រូវហ្លួងជេរបញ្ចោរដូចមីពួកម៉ាកខ្ញុំកាលពីវេនទីបីនោះទៀត ពីព្រោះមីនោះ គេឲ្យយាមមើលខ្ទូ វាមើលតែខ្ទូទេ បណ្តោយឲ្យម៉មប្រឹម លួចយកលុយទៅសងបំណុលគាត់ឯផ្សារអស់រលីង តែមួយរៀលក៏គ្មាននៅសល់ផង ។ ហ្លួងរាប់លុយទិញគ្រឿងអលង្ការ ចេញលុយដល់ដៃឲ្យខ្លះ ខ្វះប៉ុន្មានជំពាក់សិន ។ មីងវ៉ែទត ថ្វាយបង្គំលា ហើយដើរនុនៗចេញទៅវិញ ដាក់ស្បោងលុយលាក់ក្នុងអាវជិតល្អណាស់ ។

ខ្ញុំអង្គុយបត់ជើងក្បែរហ្លួង រង់ចាំក្រែងលោកមានប្រើធ្វើអ្វីផ្សេងទៀត ។ អស់អ្នក-អស់នាងជាច្រើន ខំនាំគ្នាតែងខ្លួនលាប ទឹកអប់ ប្រេង ម្សៅ ក្រអូបឈ្ងុយឈ្ងប់ ដើម្បីចូលមកគាល់ហ្លួង សង្ឃឹមក្រែងបានអ្វីបន្តិចបន្តួចនឹងគេ ។ ហ្លួងសម្លឹងមើលខ្ញុំឥតប៉ប្រិចភ្នែក ហើយហុចក្រវិលមួយគូមកឲ្យខ្ញុំ ប៉ុន្តែនៅពេលដែលខ្ញុំលូកដៃទទួលទាំងចិត្តសប្បាយរីករាយចំពោះរង្វាន់ដ៏ល្អនេះ ស្រាប់តែលោកដកដៃចេញវិញ ព្រមទាំងនិយាយបញ្ឈឺចិត្តថា :

~ ទេ! ឯងនេះខ្ជិលណាស់ កុំអាលយកអី ចាំថ្ងៃក្រោយទៅចាំយក ហើយលោកប្រទានក្រវិលនោះទៅឲ្យមីប៉ុន ដែលវាឆ្លៀតចោលកន្ទុយភ្នែករបៀបចំអកមើលមកខ្ញុំទៀតផង ។ ខ្ញុំឈឺចិត្តស្រក់ទឹកភ្នែកច្រោករត់ត្រឡប់មកកាន់បន្ទប់ដេកវិញ ស្រាប់តែប្រទះឃើញម៉ែដែលមកលេងនឹងម៉មនួ ។ ចាប់តាំងពីពេលត្រឡប់

មកពីស្រុកបារាំងវិញ ហ្លួងមិនសូវរវីរវល់នឹកនាដល់ ម៉មនួ ដូចពីដើមទេ ប៉ុន្តែទោះជាយ៉ាងណា ក៏ម៉មនួ សន្យាថា នឹងជូនខ្ញុំទៅសុំគ្រឿងអលង្ការពីហ្លួងឲ្យបាន ព្រោះគាត់មិនភ្លេចខ្ញុំដែលជាកូនចៅចាស់ ធ្លាប់បម្រើគាត់តាំងពីដើមមកនោះទេ ។

ព្រឹកមួយ ត្រូវវេនគាល់បំរើហ្លួង ខ្ញុំអស់កម្លាំងពេក ក៏ប្រះដេកទៅលើពូកក្នុងបន្ទប់ដែលហ្លួងទើបនឹងងើបចេញទៅក្រោយពីផ្ទុំសោយអាហៀនអស់ពេលដ៏យូរ ។ ពេលនោះ ស្រាប់តែ ម៉មនួ ចូលទៅដល់និយាយថា :

~ ក្រាបទូល ! ខ្ញុំម្ចាស់អាណិត សារ៉ាម៉ានី ណាស់ ព្រោះគ្មានមាសពេជ្រពាក់នឹងគេសោះ ។ វានេះជាក្មួយរបស់ខ្មោចលោកអគ្គមហាសេនា ជាកូនគេអ្នកត្រឹមត្រូវ ហើយធ្វើការម៉ឺងម៉ាត់ល្អណាស់ ។

~ ស្អី ! ធ្វើការម៉ឺងម៉ាត់ ? (ហ្លួងសឹកសំដីមកឲ្យវិញភ្លាម) មើលវា ! គេធ្វើការគ្រប់គ្នា វាទៅសម្ងំដេកបើម្ទឹងៗឲ្យអញស្រឡាញ់វាយ៉ាងម៉េចនឹងកើត ។

លោកអត់និយាយថាម៉េចតទៅទៀតទេ... ម៉មនួ ដើរចេញទៅវិញដោយឆ្លៀតលូកក្ដិចដាស់ខ្ញុំឲ្យភ្ញាក់ផង ប៉ុន្តែខ្ញុំមានដេកលក់ឯណា នរណានិយាយថាអីក៏ខ្ញុំស្ដាប់ឮទាំងអស់ ។

ខែបន្ទាប់មក ដល់ពេលចែកគ្រឿងអលង្ការជាថ្មីម្ដងទៀត ខ្ញុំនឹកទៅដូចជាតូចចិត្តខ្លាំងពេក មិនខ្ចីចង់បានអ្វីទាំងអស់ ទើបមិនរវល់ទៅមើលហ្លួងចែកនឹងគេ ។ ហ្លួងកាន់ក្រវិលពីរគូ មួយគូតូចលោកប្រទានឲ្យ មីយ៉ាន ហើយប្រើគេឲ្យមកហៅខ្ញុំទៅយកអាមួយគូធំ ប៉ុន្តែ មីយ៉ាន វាមានគំនិតខូចទូលហ្លួងថា ត្រចៀកវាធំជាងត្រចៀកខ្ញុំ បើវាបានពាក់ក្រវិលធំទើបសមជាង ហើយលោកក៏ប្រទានអាធំនោះឲ្យវាទៅ ។

ខ្ញុំបានអាតូចឥតពេញចិត្តសោះ ហើយហ្លួងក៏ដឹងថាខ្ញុំមិនពេញចិត្តដែរ ទើបលោកបង្ខំឲ្យខ្ញុំពាក់នៅនឹងមុខលោកតែម្ដង ក្រវិលនេះខ្ញុំពាក់ជាប់នឹងត្រចៀករហូតដល់សព្វថ្ងៃ ឥតដែលដោះដូរទៅណាឡើយ ។ ដល់ពេលចែកចិញ្ចៀន លោកស្ដីឲ្យ កិតសាម៉ៃ ច្រើនណាស់ ព្រោះក្រចកវាមិនស្អាត ។ ដល់វេនខ្ញុំ លោកប្រទានចិញ្ចៀនបីវង់ ព្រមទាំងសរសើរថា ខ្ញុំចេះថែដៃជើងបានស្អាតទៀតផង ។

អ្នកដែលគាប់ចិត្តហ្លួង ពុំមែនសុទ្ធតែបានទទួលរង្វាន់ច្រើនជាងគេនោះទេ គឺជេរបញ្ចោរក៏ញយជាងគេ រំពាត់ក៏ត្រូវញឹកជាងគេ ។

អ្នកដែលបានឡើងជាស្នំគាប់ចិត្តក្រោយពេលដែល ម៉មនួ អស់បុណ្យទៅនោះ គឺ វ៉ន, ស៊ុន និង ស្អាត ប៉ុន្តែតាមចិត្តហ្លួង ស្រឡាញ់ម្ចាស់ក្សត្រីជីប ជាចៅស្រីរបស់លោក លើសនរណាទាំងអស់ ។ នេះហើយ អំពើឆ្កួតលីលារបស់ស្ដេច សមតាមពាក្យដែលប្រជារាស្ត្រតែងនិយាយថា "ស្ដេចក៏ដូចជាឆ្កែដែរ សូម្បីបងប្អូនកូនចៅឯង ក៏ចេះយកគ្នាជាប្ដីប្រពន្ធទៅកើត" ។ ស្នំឯកទាំងនេះគ្មានអំណាចអ្វីជាធំដុំទេ ហ្លួងតែងនិយាយថា :

~ អញមិនមែនភ្លើទេ, ពួកមីអស់ហ្នឹងវាគ្មានស្រឡាញ់អញសោះ, វាស្រឡាញ់តែលុយអញប៉ុណ្ណោះ ។

ដូច្នេះ នរណាក៏យល់ដែរថា តណ្ហារបស់ហ្លួង គ្រាន់តែជាអំពើខូចខិលមួយភ្លែតៗ ម្ដងគាប់នឹងអ្នកនេះ ម្ដងគាប់នឹងអ្នកនោះ រកប្រាកដប្រជាលើនរណាមួយពុំបានឡើយ ។

ចំណែកខ្ញុំ ខ្ញុំមិនដែលត្រូវរំពាត់ទេ ប៉ុន្តែម្ដងនោះខ្ញុំភ័យញ័រទទ្រើក ស្មានថាមិនអាចគេចរួចពីរំពាត់ផ្ដៅហ្លួងឡើយ ។ តើខ្ញុំមានធ្វើអ្វីខុស ? យ៉ាន រត់មកដាស់ខ្ញុំទាំងកណ្ដាលយប់ ពេលដែលខ្ញុំទើបនឹងប្រះដេកលក់លើគ្រែក្នុងបន្ទប់ ម៉ែអួន ហើយទោះបីខ្ញុំជជីកសួរវាយ៉ាងណា ក៏វាអត់ដឹងអីសោះ ។ ខ្ញុំរកគិតមិនយល់សោះ តើមានរឿងអ្វី បានជាហ្លួងខឹងដល់ម្លេះ ? លោកប្រើឲ្យខ្ញុំយកកន្ទេលថ្មីបួនទៅជូន ម៉មនួ ម៉មប្រីម



ម៉មសំអយ និង ម្ចាស់ជីប ប៉ុន្តែខ្ញុំឃើញលោកកំពុងសោយព្រះស្ងោយ ក៏ឆ្លៀតចូលលេងផ្ទះ ម៉ែអួន មួយភ្លែតសិន គិតថាចាំបន្តិចទៀតសឹមយកទៅជូនគេក៏បានដែរ ហើយដោយអស់កម្លាំងពេក ខ្ញុំក៏ដេកលក់មួយស្រឡេតទៅ ។ តើកំហុសនេះល្មមត្រូវរំពាត់ដែរឬអ្វី ?

មីពួកម៉ាកខ្ញុំអង្គុយត្រៀបត្រា វាសប្បាយចិត្តណាស់នឹងឃើញហ្លួងវាយខ្ញុំ វាបួញមាត់ចង្អុលបង្ហាញរំពាត់ដែលហ្លួងផ្អែកទុកនៅកៀនជញ្ជាំង ។

ហ្លួងស្លៀកសារុងទទឹកជោកចេញមកស្រែកសួរគេថា តើខ្ញុំមកដល់ហើយឬនៅ ? គ្រាន់តែក្រឡេកឃើញខ្ញុំភ្លាម លោកជេរបញ្ចោរកប់អាកាស ប៉ុន្តែលុះមកឃើញខ្ញុំក្រាបញាក់ទទ្រើកក្បែរជើង លោកដូចជាអាណិតរកលើកដៃវាយមិនរួច ហើយនិយាយថា :

~ ឯងនេះបានចំជាល្ងង់រកលេខដាក់គ្មាន ! បើគេអ្នកមានប្រាជ្ញាតែបន្តិចបន្តួច គេឃើញអញខឹងអញ្ជឹងមិនបានអីក៏គេចេះសុំទោសដែរ... ។

ទោះបី ចូលចិត្តក្ដី មិនចូលចិត្តក្ដី ក៏ខ្ញុំត្រូវតែធ្វើការបំរើហ្លួងឲ្យបានជិតដល់ជាទីបំផុត ។ ហ្លួងខ្លួនឯងបាននិយាយប្រាប់ខ្ញុំថា :

~ អាល្ងោចហ្នឹងវាបានការអី ? វាមានប្រយោជន៍ដល់ នុ-ម៉ែអញ, ដល់ខ្លួនអញ ត្រង់ណាខ្លះ ? បើឯងខានទៅហាត់រាំ ច្រើនណាស់ម្ចាស់ឯងគេរករឿងបន្តិចបន្តួចប៉ុណ្ណឹង ប៉ុន្តែបើអញរកហៅប្រើមិនឃើញ អាហ្នឹងច្បាស់ជារំពាត់ស៊ីខ្នងហើយ ។

ដើម្បីផ្គាប់ចិត្តចៅហ្វាយម្ដងពីរនាក់អញ្ចឹង ខ្ញុំត្រូវធ្វើការនឿយហត់ទ្វេមួយជាពីរ ជាបី ក្នុងវ័យដប់បួនឆ្នាំដែលគេត្រូវការ សម្រាកច្រើន ដេកច្រើនជាទីបំផុត ម្ល៉ោះហើយខ្ញុំឧស្សាហ៍ធ្លាក់ខ្លួនឈឺជាញឹកញយ ។ យប់ខ្លះដែលពុំត្រូវវេនខ្ញុំយាមសោះ ពេលពាក់កណ្ដាលអាធ្រាត្រកំពុងតែដេកឆ្ងាញ់ ស្រាប់តែមានគេមកដាស់ឲ្យទៅអង្គុយកំដរហ្លួងសោយស៊ុប ខ្ញុំត្រូវដាស់ កាហ៊ុន ឲ្យវាជួយស្លៀកពាក់ ជួយសំអិតសំអាងខ្លួន ហើយទៅអង្គុយកំដរហ្លួងក្នុងបន្ទប់ទទួលភ្ញៀវ នៃ ប្រាសាទបាញ់យ៉ុង អង្គុយជុំវិញកន្ទេលដូចគេឯងទាំងអស់គ្នា រហើយស៊ីធ្វើឫកដូចជាឆ្ងាញ់ ដូចជាសប្បាយណាស់ ប៉ុន្តែតាមពិតខ្ញុំដេកលក់ក្នុងទៅហើយ ។

**ចាប់**តាំងពីពេលទើបនឹងឡើងសោយរាជ្យភ្លាមមកម្ល៉េះ ចិត្តគំនិតហ្លួងប្រែជាស្រពាប់ស្រពោនខ្លាំងណាស់ ។ ខ្ញុំឮគេនិយាយថា លោកកើតមានវិប្បដិសារីចំពោះរឿងអ្វីមួយដែលតាមលងបន្ទាចអារម្មណ៍លោក ទាំងយប់ ទាំងថ្ងៃ ទោះបីលោកខំសោយអាភៀនយ៉ាងណា ក៏ពុំអាចរំលាយអារម្មណ៍ជើរវ៉ាយផ្ដេសផ្ដាសអស់នេះបានដែរ ។ សូម្បីម្ចាស់ក្សត្រីយើង ជាកូនស្រីច្បង និង ម្ចាស់ស្រីវង្សកូនប្រុសសម្លាញ់ចិត្ត ក៏ពុំអាចលួងលោមលោកឈ្នះដែរ ។ ជួនកាល លោកយាងទៅសំរាកឯទីតាំងផែ ឬ ឯរោងបញ្ជា ឬ ជួនកាលទៀត លោកលួចចេញទៅដើរកំសាន្តក្នុងសួនច្បារឯកំពង់ផែ ក្រុមវាំងពីរបីនាក់ទៅចាប់ប្រអូសប្រទាញមកវិញមិនចង់ឈ្នះ ។

លោកមិនមែនជាស្ដេចសោយរាជ្យទេ ប៉ុន្តែជាអ្នកទោស ដែលគេឃាមល្បាតជាប់ ទាំងយប់ ទាំងថ្ងៃយ៉ាងប្រយ័ត្នប្រយែងក្រៃលែង ។ ក្នុងវាំងមិនដឹងជាមានគិញបារាំងប៉ុន្មាននាក់ទេ ពួកអស់នោះយកលេសថាមកមើលត្រួតត្រាកិច្ចការក្នុងវាំង ប៉ុន្តែតាមពិតគឺគេមកឃ្លាំមើលហ្លួងនេះឯង ។

លោកមហាមន្ត្រីប្រសប់លើកជើងបារាំងណាស់ ដើម្បីការពារអំណាចគាត់ ហើយគាត់មកល្បួងលួង-លោមទាល់តែហ្លួងសុខចិត្ត លះបង់ឯករាជ្យ លះបង់ប្រទេសទាំងមូល ឲ្យទៅជនបរទេស ដើម្បីជាថ្នូរយករាជ្យបល្ល័ង្កមកអង្គុយសោយរាជ្យ ត្រួតត្រាលើតែផ្ទៃវាំងមួយក្រវិចតូចប៉ុណ្ណោះ ។

ទុក្ខព្រៀមក្រំគ្របដណ្ដប់លើផ្ទៃវាំងទាំងមូល ដែលប្រែជាគ្មានរបៀបរៀបរយ រកកលតែនឹងធ្លាក់ទៅជាចំណី នៃ ពួកមនុស្សមានគំនិតពុតត្បុតអាក្រក់ ។ ចាប់តាំងពីពេលហ្លួង សុវណ្ណកោដ្ឋ ចូលទីវង្គតទៅពួកយើងរឹតតែហោងហាងរកទីពឹងឲ្យមាំមួនពុំបាន ។ ហ្លួងថ្មីជាមនុស្សគ្មានអំណាច ជាអ្នកទោស គ្មានការទាក់ទងជាមួយរាស្ត្រ គ្មានអំណាចគ្រប់គ្រងលើប្រទេស បណ្ដោយឲ្យជនបរទេសធ្វើអ្វីបានតាមចិត្ត ។ វាំងគឺជាគុកនៅកណ្ដាលទីក្រុង ជាលំនៅ នៃ មនុស្សខ្វាក់ ដែលឥតមើលឃើញដល់ទុក្ខវេទនា នៃ រាស្ត្រប្រជាដែលត្រូវគេជិះជាន់ ។ ហ្លួងខ្លួនឯងក៏ដឹងច្បាស់ថា លោកមានអំណាចធ្វើអ្វីបានតាមចិត្ត តែនៅក្នុងវាំងនេះទេ ។

ម្ល៉ោះហើយហ្លួងមិនដឹងធ្វើអ្វី មួយថ្ងៃៗគិតតែពីផ្ដុំ សោយអាភៀន សោយក្រយា ជជែកលេង ហើយផ្ដុំទៀត... ។

យើងអាចសុំគ្រឿងឈើ ឬ ជាងពីក្នុងវាំង ឲ្យទៅជួសជុលផ្ទះឪពុក-ម្ដាយ យើង ដោយគ្មានភ័យព្រួយខ្លាចហ្លួងបដិសេធឡើយ ។ ប៉ុន្តែហ្លួងទទួលតាមពាក្យសុំហើយ ច្រើនតែថាឲ្យយើងចាំខែក្រោយ ដោយលោកសារភាពប្រាប់តាមត្រង់ថា ខែនេះលោកអត់មានលុយទេ ពីព្រោះមួយខែៗ លោកត្រូវចំណាយច្រើនណាស់



ដើម្បីរៀបចំទទួលភ្ញៀវបារាំង ដើម្បីជូនវត្ថុអនុស្សាវរីយ៍ដ៏មានតម្លៃចំពោះគេ... ។

កាលណាអផ្សុករកគ្នាជជែកមិនបាន លោកនិយាយប្រាប់យើង ពីរឿងកាលលោកនៅក្មេង ទៅរៀនឯក្រុងបាងកក ពីរឿងដែលលោកទើបនឹងចេះលេងស្រីជាលើកដំបូង ដោយឆ្លៀតអួតថា ពេលកំពុងពេញកម្លាំង មួយយប់លោកអាចលេងស្រីដប់នាក់ក៏បានដែរ ។ ដោយឃើញពួកយើងភ័យធ្វើមុខភ្លើ លោកសើចសប្បាយខ្លាំងណាស់ ។

ល្ងាចមួយនោះ ហ្លួងងើបចេញពីតុសោយក្រយា ដើរក្រឡឹងព័ទ្ធជុំវិញអស់អ្នកអស់នាងដែលកំពុងអង្គុយជីកង់បរិភោគបាយនៅលើកន្ទេល ហើយចែកបារីស៊ីហ្គារ៍ឲ្យយើងមួយម្នាក់ៗ ព្រមទាំងនិយាយដោយរីករាយមកកាន់យើងថា :

-វ៉ី! ពួកក្មេងៗ អញតវ៉ាយក ខេត្តបាត់ដំបង និង ខេត្តអង្គរ[១០] ពីសៀមបានមកវិញហើយ អញនាំឯងទាំងអស់គ្នាទៅវាំថ្វាយទេវតារក្សាទឹកដី នៃ ខេត្តទាំងពីរនោះម្ដង... ។

ការធ្វើដំណើរលើកនេះពុំបានធ្វើឲ្យយើងភ្ញាក់ផ្អើលដូចកាលមុនចេញដំណើរទៅស្រុកបារាំងទេ ។ អ្នកដែលធ្លាប់បានធ្វើដំណើរយ៉ាងកំសត់កម្រ ឆ្លងកាត់សមុទ្រធំមិនយល់កោះត្រើយម្ដងរួចហើយនោះ វាហាក់ដូចជាថ្នឹកមិនខ្លាច សព្វបើគ្រាន់តែជិះកប៉ាល់ឆ្លងទន្លេមួយប៉ុណ្ណោះទេ ប៉ុន្តែអ្នកឯទៀតដែលស្ដាយមិនបានទៅស្គាល់ស្រុកបារាំង ម្ដងណេះក៏ប្រថុយដើរមើលឲ្យស្គាល់ស្រុកទេសនឹងគេដែរ ។

ការរៀបចំសម្រាប់ធ្វើដំណើរ ត្រូវចំណាយពេលអស់ជាច្រើនសប្ដាហ៍ សោតឯការសមរបាំ ក៏មានដំណើរប្រព្រឹត្តទៅយ៉ាងសកម្មឡើងវិញដែរ ។ យើងម្នាក់ៗ រៀបចំអីវ៉ាន់ប្រើប្រាស់ផ្ទាល់ខ្លួនយ៉ាងផ្ចិតផ្ចង់ក្រៃលែង ។ ជាងចិនដេរស្បែកជើងម៉ូតបារាំងមកឲ្យយើងទាំងកន្ត្រក ។ ហើយហ្លួងបង្ខំឲ្យយើងពាក់ស្បែកជើង ពាក់ចិញ្ចៀន ធ្វើខ្លួនឲ្យស្អាតដើម្បីទៅបង្អួតអ្នកស្រុកបាត់ដំបង ។ យើងដឹងថា តែងខ្លួនតាមបញ្ជាហ្លួង វាគ្មានស្អាតត្រង់ណាសោះទេ ឬ វានាំឲ្យគេពេបជ្រាយវិញផងក៏មិនដឹង ។

ពេលរៀបចេញដំណើរទៅណាម្ដងៗ វាជួនចំលើតែពេលអត់លុយ យាយម៉ែនត្រូវជាសាច់ញាតិនឹងម្ចាស់ក្សត្រី គាត់សម្បូរណ៍លុយណាស់ នរណាចង់ចងការប៉ុន្មានក៏បាន ប៉ុន្តែទាស់ត្រង់គាត់យកការថ្លៃពេក ។ ខ្ញុំខ្ចីគាត់ហាសិបរៀល ដល់សងវិញ គាត់កាត់យកប្រាក់ខែខ្ញុំអស់ទាំងដប់រៀល ទាល់តែគ្រប់ប្រាំបីខែទើបរួចជំពាក់ ។ ពុក និង ម៉ែ ជួលទូកមួយជិះតាមទៅជាមួយគេឯងដែរ ហើយគេមាននាំយកពួកបំរើប្រុសស្រី ទាហានរក្សាព្រះអង្គ បង្ការក្រែងមានចោរខ្មួញតាមផ្លូវ ក្រុមភ្លេងពិណពាទ្យ និង ភ្លេងបារាំងព្រមទាំងមួបម្ហាគ្រប់មុខ មានតាំងពីទឹកម៉ាស៊ីនជាច្រើនពាង ទៅជាមួយផង ។

ថ្ងៃមួយ នៃ រដូវវស្សា ហ្លួង និង បរិពារទាំងអស់ មានចំនួនច្រើនរយនាក់ ចាកចេញពីវាំង ចុះសំប៉ានចុះទូក ដែលចងសណ្ដោងទៅនឹងកប៉ាល់ធំមួយ ហើយធ្វើដំណើរចេញទៅ ។ ស្ដេច និង នាម៉ឺនធំៗ សុទ្ធតែមានទូកជិះផ្ទាល់ខ្លួន ។ ចំណែកអ្នកណាដែលចង់តាមទៅលេងនឹងគេក្រៅផ្លូវការ ក៏ជួលទូកជិះទៅជាមួយគេដែរ ។ អ្នកបំរើ, ទាហាន និង អ្នកភ្លេង ជិះប្រជ្រៀតគ្នាលើដំបូលកប៉ាល់ មានដាក់ចង្ក្រានឆ្នាំងគ្រប់គ្រាន់ទាំងអស់ ។

ក្បួនទូកចេញពីកំពង់ផែ ក្រោមស្លូវស័ព្ទហោកញ្ជៀវគឹកកង នៃ ហ្វូងប្រជារាស្ត្រ ដែលឈរប្រជ្រៀតគ្នាកកកុញពេញមាត់ទន្លេ ហើយធ្វើដំណើរលឿនស្លេវឆ្ពោះទៅទន្លេសាប ដោយមានខ្សែទឹកជួយរុញច្រានផង ។ ពេលនោះ ព្រលប់ងងឹតខ្លាំងណាស់ទៅហើយ មើលទៅក្រោយខ្នង ឃើញពន្លឺភ្លើងព្រិចៗរាប់ពាន់ នៃ

[១០] ខេត្តសៀមរាប ។

ព្រះរាជធានី ចាំងផ្ទះកណ្ដាលផ្ទៃអន្ធការ ។

ខ្ញុំជិះលើទីតាំងសក្តិក្រសេម ចាំគាល់បំរើហ្លួងជាមួយ អស់អ្នក-អស់នាង ជាងសែសិបនាក់ ស្រីបំរើម្នាក់ និង ក្រុមភាំងម្នាក់ដែលប្រសប់អស្ចារ្យខាងផ្លុំសផុលខ្លៅ កងដៃ កងជើង របស់ពួកល្ខោន ។ ដើម្បីឲ្យបាន កាហ៊ុនទៅជាមួយ ខ្ញុំយកវាទៅលាក់ជាមួយអ្នកបំរើ ។ ពីក្រោយ និង ពីចំហៀងសង្ខាងយើង ឃើញ សុទ្ធតែទូកតូច-ធំ ពាសពេញទន្លេ ហើយបន្តកន្ទុយទៅវែងឆ្ងាយស្ទើរផុតកន្ទុយភ្នែក ។ ទូកតម្រៀបជិតៗគ្នា ល្អណាស់ គេអាចដើរឆ្លងពីមួយទៅមួយបានយ៉ាងស្រួល ។

នៅលើទីតាំងសក្តិក្រសេម ហ្លួងកំពុងសម្ងំផ្ទុំក្នុងបន្ទប់ធំជាងគេ ។ អស់អ្នក-អស់នាង ដេកប្រតាក់ប្រគង លើគ្នាក្នុងមុងធំៗដែលចងលាតសន្ធឹងនៅកណ្ដាលកប៉ាល់ ខ្លះដេកលក់ ខ្លះនៅនិយាយជជែកគ្នាខ្សិបខ្សាវ នៅឡើយ ។ ខ្ញុំអង្គុយក្រៅមុងសម្លឹងមើលទៅច្រាំង ឃើញខ្មៅទទុងក្រោមផ្ទៃមេឃស្រឡះល្អល្អេវ មានពពក ឯណោះមួយដុំ ឯណោះមួយដុំ... យូរៗម្ដង ស៊ីរ៉ែនកប៉ាល់បន្លឺឡើងជាសញ្ញាប្រាប់ឲ្យទូកដែលកំពុងធ្វើ ដំណើរឆ្លងកាត់ទន្លេ ចៀសចេញពីផ្លូវយើង ។

យើងឆ្លងហួសអន្លង់រាជ ដែលជាកន្លែងលាក់ខ្លួនពួនអាត្មា នៃ ត្រីធំៗប៉ុនខ្លួនមនុស្ស... សម្លេងមាន់រងាវ រសាត់តាមរលកទឹកពីខាងលិចភ្នំឧដុង្គ មកប៉ះនឹងត្រចៀកយើងព្ធលើយៗគួរ ស្រងេះស្រងោចក្នុងចិត្ត ក្រៃលែង ។

ធាតុអាកាសត្រជាក់ខ្លាំងណាស់ ! មូសហើរប្រណាំងនឹងទូកតាមខាំយើងជាប់រហូត មានតែផ្សែងបារីទេ ដែលអាចបណ្ដេញវាបាន ។ ខ្ញុំរើកមុងចូលទៅប្រះដេក ដើម្បីយកកម្លាំងទុកសំរាប់ចូលវេនគាល់បំរើហ្លួងនៅ ពេលព្រឹកស្អែក ។ ក្រោមពន្លឺចង្កៀងប្រទីប ខ្ញុំឃើញពួកស្រីៗដេករង្វេលរង្វៃលប្រជ្រៀតគ្នា ។ ល្វេន កេះក្លួយដៃខ្ញុំ ហើយខ្សិបប្រាប់ឲ្យខ្ញុំមើលទៅកៀនក្បែរបន្ទប់ហ្លួងគង់ ។ ខ្ញុំពិនិត្យមើលយូរណាស់ នៅតែ មិនស្គាល់ថាជានរណា ឃើញតែស្រីពីរនាក់ រវួតអាវ រវួតសារុង ចេញអស់ពីខ្លួនស្រាតននល កំពុង ឱបរឹតគ្នា អង្អែលដោះ អង្អែលក្ដិតគ្នា ។

~ ល្វេន ! ល្វេន ! (ខ្ញុំនិយាយតិចៗ) ពួកវាធ្វើអីហ្នឹង ?

~ កុំមាត់ ! ទុកឲ្យគេធ្វើអីក៏ធ្វើទៅ (ល្វេនឆ្លើយតបមកវិញ) សារ៉ាម៉ានឹងឯង មើលមិនស្គាល់ទេហ្អែ ? មីយ៉ាន ហើយនិង បងវា កំពុងលេងគ្នាណាំ !... ។

ស្អែកឡើងយើងមកដល់កំពង់ឆ្នាំង ។ ខ្ញុំខានមកឃើញស្រុកនេះ ប្រាំ ឬ ប្រាំមួយ ឆ្នាំហើយ ប៉ុន្តែ ហាក់ដូចជាគ្មានឃើញប្លែកត្រង់ណាសោះ ចម្លែកតែត្រង់មានដោតទង់ជ័យនៅតាមមាត់ផែ មាននាម៉ឺន រាជការ និង មនុស្សច្រើនកុះករ មកឈររង់ចាំទទួលហ្លួងប៉ុណ្ណោះ ។ ក្រុមភ្លេងអ្នកស្រុកកំពង់ឆ្នាំង ចាប់ ប្រគុំសំដែងពរស្វាគមន៍ថ្វាយហ្លួង ហើយក្រុមភ្លេងភាំងក៏ប្រគុំឆ្លើយតបវិញយ៉ាងសប្បាយរីករាយ ។ នៅលើផែ មានបារាំងរាងក្មេងម្នាក់ ឈរនិយាយផ្កាដៃផ្កាជើងជាមួយចៅហ្វាយខេត្តបស់ហ្លួង ។ ពួកយើងជញ្ជីមគ្នាមើល បារាំងនោះចំហមាត់ ពីព្រោះមានអ្នកខ្លះនិយាយថា ដូចជាធ្លាប់ឃើញគាត់នេះម្ដងនៅឯស្រុកម៉ារ័សី ប៉ុន្តែ ខ្ញុំយល់ច្បាស់ថា នេះគ្រាន់តែជាឫកមាយាធ្វើឲ្យគេកោតថា វាធ្លាប់បានទៅស្គាល់ស្រុកបារាំងតែប៉ុណ្ណោះ ។ ពួកវាស្លៀកពាក់អញ្ចឹង ដើម្បីបង្អួតអ្នកស្រុកឲ្យគេកោតវា ប៉ុន្តែខ្ញុំយល់ថា សម្លៀកបំពាក់នេះពុំមែនជាការ សមរម្យទាល់តែសោះ ហើយវាថែមទាំងអាចធ្វើឲ្យគេមានគំនិតយល់ឃើញមិនល្អ ចំពោះស្រីក្នុងភាំង ទៀតផង ។

ហួសពីកំពង់ឆ្នាំងទៅ កប៉ាល់អត់មានតាមសណ្ដោងទៀតទេ គឺយើងត្រូវបន្តដំណើរដោយចែវនឹងដៃ



ម្ដង ។ នៅត្រង់កន្លែងចូលទៅកាន់បឹងធំ មានភ្នំអមសង្ខាង ហើយភ្នំដែលនៅខាងកើតនោះឈ្មោះថា ភ្នំនាងកង្រី ។

គ្រាន់តែទៅដល់ជើងព្រៃភ្នាម ក្បួនទូកបំបែកគ្នាចេញអស់ ។ ពួកម៉ាឡាយូមាឌមាំ ជូតក្បាលក្រហម ឈរពីមុខពីក្រោយទូក ចែវស្រុះគ្នាដោយស្រែកច្រៀងបន្ទរចង្វាក់ជាភាសាសាសន៍គេថា "ហៃអើម៉ារ៉ាំ" ញ៉ាំងទូករាប់រយឲ្យលឿនទៅមុខ តាមចន្លោះដើមឈើលិចដល់មែកដោយសារទឹកជំនន់ នៃ ទន្លេសាប ។

យើងធ្វើដំណើរតាមទិសខាងជើង វែកផ្លូវកាត់ព្រៃលិចទឹក នៃ ខេត្ត ស្ទោង ជីក្រែង និង សៀមរាប... ដំណើរនេះប្រព្រឹត្តទៅអស់រយៈពេលជាច្រើនថ្ងៃ ហើយពីមួយថ្ងៃទៅមួយថ្ងៃ យើងកាន់តែរំកិលចូលជ្រៅ ឡើងៗ ទៅក្នុងបរិវេណ នៃ ទន្លេសាប ។

ហ្លួងគិតតែសោយអាភៀន ចាក់ម៉ាស៊ីនច្រៀងស្ដាប់ សើចលេងជាមួយស្រីអ្នកគាល់បំរើ ។ ជួនកាល លោកចេញមកក្រៅបន្ទប់ ស្លៀកសារុងសំយេះហួសផ្ចិត ពួកម៉ាឡាយូអ្នកចែវទូក ឱនមុខ ឬ ងាកមុខចេញ មិនហ៊ានមើលដោយក្ដីអៀនខ្មាស ។ ប៉ុន្តែដល់ឃើញគេអៀនខ្មាសមិនហ៊ានមើលអាកប្បកិរិយាអាក្រក់របស់ ខ្លួនយ៉ាងនេះ ហ្លួងបែរជាសើចសប្បាយទៅវិញ ។

ខ្យល់បក់មកមួយរឹប បណ្ដាលឲ្យក្បួនទូកឈ្លងឈ្លោង ញ៉ាំងអ្នកដំណើរឲ្យភ័យញ័រញ៉ូវ ប្រញាប់ ស្ទូត្យូតដំណើរឲ្យឆាប់បានដល់ដើមឈើណាមួយ គ្រាន់នឹងទីពឹងជាបណ្ដោះអាសន្នសិន ។ អស់អ្នក-អស់នាង យំសស្រាក់ រត់ទៅឱបជើងហ្លួងឲ្យជួយ ប៉ុន្តែឲ្យលោកធ្វើម៉េច បើលោកកំពុងតែភ័យភ្នែកនៅ កញ្ជឹងកដែរ ។ មីស្អាត វាក្អួតចាក់ទឹងហ៊ឹងហោង អ្នកខ្លះទៀតធ្លាក់ខ្លួនឈឺដោយផឹកទឹកមិនស្អាត ពីព្រោះទូក អ្នកចុងភៅ ធ្វើដំណើរមិនដែលទាន់គេទេ ។

មកដល់កន្លែង មានដើមឈើច្រើនគួរសម ហ្លួងបែបដូចជាអន់ភ័យបន្តិច ក៏តាំងស្រែកជេរ បញ្ចោរអ្នកធ្វើបាយ ដែលចង់បង្អត់ភូនថៅលោក ឲ្យដាច់ពោះស្លាប់ ។ នៅទីបញ្ចប់ យើងបានមក ឃើញដីគោកមួយកន្លែង គេក៏ផ្លុំត្រែហៅប្រមូល ទូកទាំងអស់ ឲ្យមកជួតជុំសំរាកនៅកន្លែងនេះ សិន ។

ត្រង់កន្លែងឆ្នេរខ្សាច់ដែលយើងចុះចតនេះ យើងអាចមើលទៅគ្រប់ទិស គ្មានទើសទាក់អ្វីទាំងអស់ ។ នៅខាងត្បូងហួសឆ្ងាយពីបឹងទន្លេសាបទៅទៀត ខ្ញុំឃើញភ្នំពោធិ៍សាត់ និងភ្នំក្រវាញ ហើយមាននរណាម្នាក់ ឡើងលើដំបូលទូកមើលទៅខាងជើងឯណោះ ឃើញរហូតដល់ទៅភ្នំគូលែន ។

មិនបានប៉ុន្មានម៉ោងផង ទីដែលធ្លាប់តែស្ងាត់ជ្រងំគ្មានមនុស្សរស់នៅសោះ បានក្លាយទៅជាបុរីហ្លួង អ៊ូអរសប្បាយក្រៃលែង ។ អ្នកចុងភៅ និង បោយ ធ្វើការញាប់ដៃជើង រហូតដល់ហ្លួង និង អស់អ្នក-អស់នាង បានសោយ និង បរិភោគ យ៉ាងឆាប់ទាន់ចិត្ត ។ ក្រោយពេលបាយ ហ្លួងចែកលុយឲ្យយើងប្រាំរៀលម្នាក់ ដើម្បីលេងបៀថ្វាយលោកទតឲ្យសប្បាយភ្នែកម្ដង ។ ខ្ញុំមិនចេះលេងបៀនឹងគេ គិតថាទុកលុយនេះសម្រាប់ ទិញនំបរិភោគនៅពេលធ្វើដំណើរទៅដល់ផែខាងមុខ ប៉ុន្តែហ្លួងមិនព្រមឲ្យខ្ញុំទុកលុយទេ លោកកំហែញថា បើខ្ញុំមិនលេងបៀ លោកយកលុយវិញឥឡូវហ្នឹង ។ ជាសំណាងល្អ កំពុងតែនិយាយ ស្រាប់តែទូកម្ចាស់ ក្សត្រីមកដល់ ហើយហ្លួងរវល់តែបែរទៅគិតរឿងថ្មី ភ្លេចរឿងខ្ញុំស្ងួនឡឈឹង ។

ចាប់តាំងពីពេលទើបនឹងចេញពីភ្នំពេញមក ម្ចាស់ក្សត្រីបានខិតខំខ្លាំងណាស់ ដើម្បីឲ្យមីស្ងួន ជាក្មួយ សម្លាញ់ចិត្តរបស់លោក បានជិះលើទីតាំងជាមួយហ្លួង ដើម្បីប្រជែងយកឈ្នះខ្ញុំ ប៉ុន្តែមិនបានសំរេច ទើបតែ ពេលនេះ ដែលទូកទាំងពីរចូលមកកៀកគ្នា ម្ចាស់ក្សត្រីក៏ថ្វាយបង្គំហ្លួង ហើយនិយាយថា :

~ ក្រាបទូល, ខ្ញុំម្ចាស់យល់សប្តិឃើញខ្មោចម្ដាយខ្ញុំម្ចាស់មកប្រាប់ថា គាត់មកចាប់ជាតិជានាងស្ងួន

ហើយ សុំឲ្យព្រះករុណាជួយមើលខុសត្រូវឲ្យបានស្រួលបួលផង ។

នេះជាពាក្យប្រឌិតយ៉ាងស្ទាត់ជំនាញ ដើម្បីឲ្យ មីសួន បានចូលមកគាល់បំរើហ្លួង នឹងអាលចាប់បានគាប់តួរ ហើយវាក៏ជាកត្តាមួយបង្ហាញឲ្យឃើញនូវលក្ខណៈទន់ខ្សោយ នៃ ចរិតរបស់ហ្លួង ដែលបណ្ដោយខ្លួនឲ្យគេប្រើល្បិចបោកបញ្ឆោតបានយ៉ាងងាយ ។

~ ហា! ហា! (ហ្លួងសើចសប្បាយ) រឺម, កូនឯងយល់សប្ដិឃើញអញ្ជឹងហ្អែ៎ ? អញក៏ធ្លាប់យល់សប្ដិឃើញដូចគ្នាបេះបិទអញ្ចឹងម្ដងដែរ ។ ឯណា នាងសួន, ឲ្យវាឡើងមកលើទូកអញមក៏, វាធំល្មមប្រើប្រាស់បានហើយ មែនទេ ?

ប៉ុន្តែដោយហេតុថ្ងៃនោះ ទីនាំងហ្លួងចង្អៀតខ្លាំងពេក លោកក៏បញ្ជូន មីសួន ឲ្យត្រឡប់ទៅជិះទូកជាមួយម្ចាស់ក្សត្រីវិញ ដែលជាហេតុធ្វើឲ្យម្ចាស់ក្សត្រីក្ដៅក្រហាយក្រៃលែង ប៉ុន្តែលោកពុំមែនអស់សង្ឃឹមត្រឹមនេះទេ ។ ពេលនេះជាឱកាសល្អ គួរណាស់តែខ្ញុំឆ្លៀតយកគាប់នឹងហ្លួងឲ្យបានមុន មីសួន ប៉ុន្តែខ្ញុំឥតទឹកឃើញធ្វើអញ្ចឹងសោះ ពីព្រោះតែកាលណានឹកដល់រឿង មីស៊ុន មីវ៉ន និង ស៊ីម៉ាឡា ខ្ញុំចេះតែភ័យខ្លាចហ្លួងស្ទើរមិនហ៊ានដើរជិតផង ។

នៅលើទូកមួយផ្សេងទៀត គេនាំគ្នាសើចលេងសប្បាយនឹងឆាកស្នេហាររាង ម្ចាស់ផ្លូងមធុរា និង ម្ចាស់ក្សត្រីសិរីវង្ស ។ ម្ចាស់ផ្លូងមធុរា អង្គុយលើទូកស្រែកហៅម្ចាស់ក្សត្រី សិរីវង្ស ដែលកំពុងអង្គុយលើដីខ្សាច់មាត់ទន្លេ សុទ្ធតែប្រើពាក្យអូនបង ដើម្បីឲ្យឡើងមកផ្ទុំជាមួយលោកលើទូក ។ ម្ចាស់ក្សត្រីខ្មាសគេក៏ស្រែកយំ ហើយអ្នកឈរមើលទាំងអស់គ្នាសើចគិលឡើង ដើម្បីលើកជើងម្ចាស់មធុរា ព្រោះនរណាក៏ដឹងដែរពីការទាក់ទងរវាងអ្នកទាំងពីរ ។ បន្តិចក្រោយមក ម្ចាស់ក្សត្រីសិរីវង្ស ក៏សុខចិត្តឡើងទៅតាមតួសង្សារ ហើយបណ្ដើរគ្នាចូលទៅក្នុងបន្ទប់លើកប៉ាល់សម្ងំឈឹង... ។

រាជការស្រុកបានទទួលដំណឹងថា ហ្លួងយាងមកដល់មណ្ឌលខ្លួន ក៏នាំយកម្ហូបអាហារជាច្រើនមកថ្វាយសម្រាប់ទុកធ្វើជាស្បៀងបន្តទៀត ។ ហ្លួងចែកសាច់ជ្រូកឲ្យពួកម៉ាឡាយូអ្នកចែវទូកគ្រប់គ្នា ប៉ុន្តែទោះបីអស់កម្លាំងឃ្លានយ៉ាងណា ក៏គ្នាមិនហ៊ានបរិភោគដែរ ពីព្រោះសាសនាអ៊ីស្លាមហាមផ្ដាច់មិនឲ្យបរិភោគសាច់ជ្រូកទេ... ។

ស្អែកឡើងវេលារសៀល ក្បួនទូកយើងមកដល់ បឹងកន្ទាយកុំ និង ចំការតាយ៉ែម ស្ថិតនៅត្រង់ផ្លូវបំបែកទៅកាន់សៀមរាប ។

នៅកណ្ដាលទីព្រៃលិចទឹក មានភ្នំថ្មមួយផុះលេចឡើងខ្ពស់ផុតពីទឹកប្រៀបបាននឹងកោះ ប្រកបទៅដោយដើមឈើដុះ ឯណេះមួយដុំ ឯណោះមួយដុំ ។ ក្បួនទូកបន្តធ្វើដំណើរតាមជើងព្រៃ ផ្អើលអស់សត្វបក្សាបក្សី, ហ្លួងដើរចេញពីបន្ទប់ ហើយនិយាយថា :

~ នោះ ពួកកែវភីគេមកទទួលយើងហើយ! ។

ពួកកែវភី គឺជាក្មេងស្រីកូនអ្នកស្រុកសៀមរាបច្រើនរយនាក់ជិះលើទូកងវែងៗ ហើយចែវប្រណាំងគ្នាលឿនស្មេរ តម្រង់មកចំយើង ។ លុះចូលមកដល់ជិតគ្នាមែនទែន ខ្ញុំអាចមើលឃើញពួកនោះ មានវង់មុខមូល ជាត់ម្សៅសក្បុស ចងផ្កាព្យួរតែងតោងនៅនឹងត្រចៀក ហើយស្រែកច្រៀងបន្ទរទំនុកខ្ទីរបំពងព្រៃ ។ អស់អ្នក-អស់នាងនៅលើទូកម្ចាស់ក្សត្រីអត្តនារី ស្រែកច្រៀងតទៅវិញយ៉ាងសប្បាយរីករាយ ។ បន្ទាប់មកសម្លេងចម្រៀងបទសក្រវាទីលាន់ឮឡើងពីគ្រប់ទូក ហើយក្បួនទូកក៏កាន់តែរសាត់ចូលទៅជិតច្រាំងណាស់ហើយដែរ... ។ ពេលនោះយប់ងងឹតបន្តិចទៅហើយ ក្រុមភ្លេងពិណពាទ្យនៅនឹងជើងភ្នំក្រោម ចាប់ប្រគុំ



ទទួលដំណើរហ្លួង យ៉ាងស្រងេះស្រងោច ។

ខ្ញុំដល់វេនចូលគាល់បំរើហ្លួងជាមួយអស់អ្នក-អស់នាង នៃ វេនទីបួន ។ យប់នោះ ខ្ញុំថ្វាយខ្សៀអាភៀនឲ្យហ្លួងសោយអស់ប្រហែលសាមសិបខ្សៀ ហើយដៃគូខ្ញុំនៅខាងម្ខាងទៀតនោះ ក៏បានថ្វាយសាមសិបខ្សៀដែរ... ។ ហ្លួងសម្ងំផ្ទំលក់ យើងក៏ថយចូលមកដេកក្នុងមុងធំ ត្រចៀកប្រុងស្ដាប់ជានិច្ច ក្រែងលោកត្រូវការប្រើប្រាស់អ្វីទៀត ។ ស្អែកឡើងហ្លួងសម្រេចថា ចាំត្រឡប់មកពី បាត់ដំបងវិញ សឹមធៀងចូលទៅអង្គរ ហើយយើងក៏ចាកចេញពីដីច្រាំង សៀមរាប ទាំងស្ដាយស្រណោះ ដើម្បីបន្តដំណើរដ៏គួរឲ្យធុញទ្រាន់នេះទៅមុខទៀត ។ អ្នកខ្លះបានឡើងទៅដល់កំពូលភ្នំក្រោម គេនិយាយប្រាប់ថា ពីលើកំពូលភ្នំ គេអាចមើលឃើញផ្ទៃទន្លេសាបទាំងមូល ហើយនៅខាងជើងឯណោះ គេមើលឃើញកំពូលប្រាំ នៃ ប្រាសាទអង្គរវត្ត លូតខ្ពស់ហួសព្រៃព្រឹក្សា... ។

ស្ទឹងសង្កែ ជាដៃទន្លេធំមួយ ហូរកាត់ភូមិស្រុកមានមនុស្សអ៊ូអរ ជួនកាលយើងប្រទះឃើញមានវត្តអារាមនៅជាប់នឹងមាត់ស្ទឹងទៀតផង ។ នៅក្រុងបាត់ដំបង ផ្ទះលោក ផ្សាកាថាថន អតីតចៅហ្វាយខេត្តសៀម ល្អលើសគេទាំងអស់ ប៉ុន្តែសព្វថ្ងៃនេះលោក កាថាថន ត្រឡប់ទៅនៅឯស្រុកសៀមវិញបាត់ទៅហើយ ។

ពេលក្បួនទូកធ្វើដំណើរចូលមកដល់ទីក្រុង គេមានបាញ់កាំភ្លើងទទួលអបអរសាទរ នាម៉ឺន បារាំង និង សៀម ព្រមទាំង ទាហាន និង ប្រជាពលរដ្ឋ ច្រើនកុះករមកឈររង់ចាំសំដែងគារវកិច្ចចំពោះហ្លួង... ។

គេរៀបចំធ្វើបុណ្យលេងសប្បាយច្រើនថ្ងៃណាស់ ។ ខ្ញុំត្រូវរាំជូនទស្សនិកជនមើលកំសាន្តពីរថ្ងៃជាប់គ្នា ហើយបន្ទាប់មក ត្រូវទៅរាំបួងសួងវត្តសក្តិសិទ្ធិ នៅឯប្រាសាទបាក់បែកណាមួយនោះ ដែលគេនិយាយថា ប្រកបទៅដោយគ្រោះថ្នាក់សម្បើមណាស់ ។ ណាមួយខ្លាច ណាមួយអស់កម្លាំង ខ្ញុំក៏ប្រកែកមិនព្រមទៅរាំនៅទីនោះ ប៉ុន្តែមីពួកម៉ាកខ្ញុំដែលទៅរាំទាំងប៉ុន្មាន វាត្រឡប់មកវិញសុខសប្បាយទាំងអស់គ្នា ។

យើងដើរមើលសព្វកន្លុកកន្លៀតក្នុងខេត្ត បាត់ដំបង មើលតាំងពីផ្ទះលោកចៅហ្វាយខេត្តសៀម ដែលគេកំពុងសង់ និង វត្តដីស មើលអ្វីៗទាំងអស់ដែលយើងចង់ឃើញ ។ ស្រីស្រុក បាត់ដំបង ភាគច្រើនស្អាតៗណាស់ ស្អាតជាងអ្នកភ្នំពេញទៅទៀត ។ លើសពីរបស់របរដែលអ្នកស្រុកនាំយកមកថ្វាយហ្លួង គេមានថ្វាយស្រីក្រមុំបីនាក់ឈ្មោះ រួយ, ខួន និង ព្រិល សម្រាប់ធ្វើជាស្នំ ដែលហ្លួងទទួលឲ្យជិះលើទូកជាមួយអ្នកម្នាងម្លិះ ។ ពួកវាមិនអាក្រក់ ប៉ុន្តែក៏មិនស្អាតណាស់ណាដែរ ហើយវានិយាយខ្មែររដឹន ស្ដាប់គួរឲ្យចង់សើច ។

ពុកទិញបាន ទឹកដោះគោកំប៉ុង នំប៉័ង និង ត្រីខប្រអប់ ពីផ្ទះចិនឯផ្សារយកមកផ្ញើខ្ញុំ ប៉ុន្តែមីពួកម៉ាកអត់ឃ្លានដាច់ដាបអស់ហ្នឹង វាដណ្ដើមស៊ីអស់ ខ្ញុំគ្មានបានលេបមួយម៉ាត់ទេ ។

ក្រោយពេលដែលធ្វើបុណ្យនៅនឹងខេត្ត បាត់ដំបង ចប់សព្វគ្រប់ហើយ យើងក៏ធ្វើដំណើរត្រឡប់មកសៀមរាបវិញ វាងតាមចុងខាងលិចបឹងធំ ហើយបត់ក្បាលតំរង់ទៅរកប្រាសាទអង្គរវត្ត ។

ខ្ញុំមិនដែលឃើញស្រុកណាល្អដូចស្រុកនេះទេ! ទឹកស្ទឹងថ្លាឆ្វង់ហូរចាក់ពីភ្នំគូលែនមក ទោះបីក្នុងរដូវវស្សាមានភ្លៀងធ្លាក់ច្រើនយ៉ាងណា ក៏ទឹកឡើងមិនហួសច្រាំងដែលមានស្មៅលាស់ខៀវខ្ចីក្រោមម្លប់ដ៏សែនសុខុម នៃ ដើមត្នោត ដើមដូង និង ដើមស្លា ។

នៅលើច្រាំង រទេះគោបរទៅមុខលាន់ង៉េតង៉ត... តាមបណ្ដោយដងស្ទឹងដ៏មានមនុស្សរស់នៅកុះករដូចនៅ បាត់ដំបង ដែរ ។ អ្នកស្រុកស្លៀកពាក់ស្អាតបាត នាំគ្នាលុតជង្គង់ថ្វាយបង្គំទីនាំងហ្លួង ខ្លះរត់ដើម្បីទៅឲ្យបានដល់ភូមិដែលស្ថិតនៅពាក់កណ្ដាលផ្លូវទៅអង្គរនោះ មុនយើង ។

ដល់កន្លែងរាក់មែនទែនពុំអាចចែវកើត គេក៏ចាប់អ្នកស្រុកឲ្យចុះទៅក្នុងទឹកត្រឹមដើមទ្រូង ដើម្បីអូសទូកឡើងទៅលើ បញ្ច្រាសខ្សែទឹកហូរ។ យើងប្រញាប់ប្រញាល់រៀបចំស្លៀកពាក់ ស្មានថាជិតដល់ហើយ ប៉ុន្តែតាមពិត យើងត្រូវធ្វើដំណើរយឺតៗបែបនេះអស់រយៈពេលជាច្រើនម៉ោង។ មិនដឹងជាចង្រៃអី ខ្ញុំស្រាប់តែឈឺនោម រាក់ចង់លេចស្ទើរទ្រាំទប់មិនជាប់។ កន្លែងបង្គន់នោះ គឺជាធុងឈើមួយមានចោះប្រហោង ដាក់ចងជាប់នឹងចង្កេះទូក លយចេញទៅលើទឹក។ តាមប្រហោងបង្គន់ គេអាចមើលឃើញក្បាលអ្នកអូសទូកច្បាស់ក្រឡែត ហើយបើខ្ញុំចូលទៅបត់ជើងក្នុងហ្នឹង គេងើយមើលពីក្រោមមក ក៏ឃើញច្បាស់ក្រឡែតដូចគ្នា។ ខ្ញុំខំទ្រាំអត់ចង់ខ្យល់ចាប់ នៅតែរកមធ្យោបាយដោះស្រាយមិនរួច។ ម៉ែអួន មុឹងម៉ាត់ណាស់ មើលឃើញទឹកមុខខ្ញុំបែបមិនស្រួល គាត់យល់ការទាំងអស់ ក៏ផ្តល់យោបល់ដ៏ល្អមួយ នៅខាងក្រោយទូកគេមានរៀបចំកន្លែងមុជទឹក ខ្ញុំផ្លាស់សារុងចាស់ ស្រោចទឹកលើខ្លួនធ្វើដូចជាងូតទឹក បន្ទំនោមបានយ៉ាងស្រួល គ្មាននរណាចាប់ភ្លឹកសង្ស័យទេ។

ប៉ុន្តែ ម៉ែអួនខ្លួនឯង កំពុងកើតទុក្ខធ្ងន់ជាងខ្ញុំទៅទៀត គឺគាត់ឈឺជុះអាចម៍។ គាត់ឃ្លេឆ្លាច្រាសច្រាលដូចមាន់រកពង រកកន្លែងដោះទាល់មិនបានសោះ។ គាត់ចូលទៅក្នុងបន្ទប់ហ្លួងបាត់មួយសន្ទុះ ទើបឃើញចេញមកវិញ មានកាន់ទាំងប្រអប់ក្រដាសទទេមួយដែលគេចំណាំដាក់បារីស៊ីហ្គារ៍ មកជាមួយផង។ គាត់ខ្សឹបប្រាប់ខ្ញុំថា:

– កុំទៅឆ្ងួត ពួកឯទៀតគេនោមពាសណាពាសណីដូចតែគ្នាហ្នឹង!

គាត់ចូលទៅក្នុងបង្គន់ បើកចំហរប្រអប់ដាក់លើប្រហោងបង្គន់ ដើម្បីដោះទាល់បានយ៉ាងស្រួល។ រួចហើយគាត់បិទប្រអប់វិញយ៉ាងស្អាត ទើបបោះចោលតាមប្រហោងទៅក្នុងទឹក ប្រអប់នោះអណ្តែតស្តឹងបញ្ជិតស្មាពួកអ្នករុញទូក ប៉ុន្តែគេចាប់មិនបាន វាចេះតែសាត់ចេញទៅដល់ក្បែរទូកមួយទៀត។ ម៉ែអួនកាន់ផ្តិលទឹកឈរជិតខ្ញុំ មុខញញឹមពព្រាយតាមមើលប្រអប់។ បន្តិចក្រោយមក ពួករុញទូកខាងក្រោយចាប់បានស្មានថាប្រអប់បារីល្អ បើកមើលយ៉ាងរហ័ស ដល់ឃើញសុទ្ធតែអាចម៍ ក៏ធ្វើមុខជូរហួញ គ្រវាត់ចោលព្រូស។ ម៉ែអួន និង ខ្ញុំ នាំគ្នាសើចស្ទើររឹងពោះ...។

បន្តិចក្រោយមក ស្ទឹងប្រែជារួមតូចទៅៗ... នៅពីមុខអតីតវសនដ្ឋាន នៃ លោកចៅហ្វាយខេត្តសៀម មន្ត្រីបារាំង, សៀម និង ខ្មែរ នាំគ្នាមកឈររង់ចាំទទួលហ្លួងយ៉ាងច្រើនកុះករ។

គេសង់រោងរបាំក្បែរផ្ទះថ្មមួយ ដែលមានដាក់កាំភ្លើងធំយាមប្រចាំការនៅជុំវិញ ប៉ុន្តែមុននឹងរាំឲ្យអ្នកស្រុក សៀមរាប មើលលេងកំសាន្ត ហ្លួងបានបញ្ជាឲ្យយើងទៅរាំបួងសួងថ្វាយវត្ថុសក្តិសិទ្ធិឯ អង្គរវត្ត ជាមុនសិន។

យើងនាំគ្នាចេញដំណើរទៅកាន់ប្រាសាទបាក់បែកនោះតាំងពីព្រលឹមស្រាងៗ... ពួកក្មេងតូចៗភ័យខ្លាចគេមិនឲ្យទៅមើល អង្គរវត្ត វាខំយំស្រែកតាមអង្វរម្ចាស់ក្សត្រីខ្លាំងណាស់ ទម្រាំលោកព្រមយកវាទៅជាមួយ។

រទេះគោ រទេះក្របី តម្រៀបបន្តកន្ទុយគ្នា វែងអន្លាយតាមបណ្តោយដងស្ទឹង លើផ្លូវដីមានដើមឈើដុះអមសងខាង ចោលជាម្លប់ត្រជាក់ស្រួលក្រៃលែង។ អ្នកស្រុកម្ចាស់រទេះចិត្តបុណណាស់ គាត់សុខចិត្តដើរជើងទទេអូសគោពីមុខ ដើម្បីទុកកន្លែងទូលាយឲ្យយើងបានអង្គុយស្រួល។ ប៉ុន្តែទោះជាយ៉ាងណា ក៏វានៅតែចង្អៀតដដែល ពីព្រោះក្នុងមួយរទេះ យើងត្រូវជិះប្រជ្រៀតគ្នាដល់ទៅ បី ឬ បួន នាក់ឯណោះ។ អ្នកថែមជើងកំប្លែង យកជន្ទួញចាក់ក្តិតគោ បណ្តាលឲ្យវាផ្អើលស្ទុះរត់ត្រណាត់ត្រណែង ខ្ញុំអង្គុយពី



ក្រោយខ្នងគាត់ជាមួយអ្នករបាំម្នាក់ទៀត រលាក់ក្រឡុកស្ទើរបែកថ្លើមប្រមាត់។ ហ្លួងមិនទាន់ចេញដំណើរមកទេ លោកចាំយាងមកតាមក្រោយជាមួយពួកនាម៉ឺនសព្វមុខមន្ត្រី។ ចំណែកខោអាវសម្រាប់ស្លៀកពាក់រាំនោះវិញ គេដឹកផ្សេង យើងពាក់ជាប់នឹងខ្លួនតែគ្រឿងអលង្ការបន្តិចបន្តួចប៉ុណ្ណោះ។

ក្បួនរទេះធ្វើដំណើរទៅមុខយឺតៗ... ស្នូរភ្លៅរទេះសង្កៀតគ្នាលាន់ ង៉េត... ង៉េត... ៗ... ហ៊ឹងត្រចៀក ហើយកង់រទេះនោះទៀតសោត ម្តងទៅឆ្វេង ម្តងទៅស្តាំ យោលប្រៀបបាននឹងជិះទូកយ៉ាងនោះដែរ។ មួយសន្ទុះក្រោយមក ផ្លូវបែកចេញពីមាត់ស្ទឹង មើលលែងឃើញ ច្បារដំណាំ និង ផ្ទះសម្បែងអ្នកស្រុកអ្វីទាំងអស់ ឃើញតែព្រៃស្រោងស្រឹងស្ងាត់ជ្រងំ ហាក់ដូចជាពុំដែលមានមនុស្សដើរទៅមកកាត់តាមនេះឡើយ។

បន្ទាប់មក ផ្លូវរទេះត្រូវឆ្លងកាត់គ្រហុកដីជាច្រើនកន្លែង ហើយរំពេចនោះ យើងស្រែកភ្ញាក់មាត់ស្រុះគ្នាទាំងអស់:

– យី, មើលន៎! មើលឯនោះន៎!

ព្រមទាំងលើកដៃចង្អុលទៅទិសខាងកើត ដែលបង្ហាញទិដ្ឋភាពដ៏ល្អត្រកាលក្រោមផ្ទៃមេឃក្រហមព្រឿងៗនាពេលព្រឹកព្រហាម។ នៅចំងាយប្រហែលម្ភៃជំហានពីផ្លូវ យើងឃើញដុំថ្មពណ៌ខ្មៅប្រផេះ ព័ទ្ធព័ន្ធទៅដោយវល្លិ៍ និង ស្លែ ដាក់តម្រៀបគ្នានៅសងខាងផ្លូវ កន្លែងខ្លះបាក់បែកធ្លាក់ទៅក្នុងអន្លង់ទឹកដ៏ជ្រៅ ដែលគេជីកពីក្រោម។ អន្លង់នេះគ្រាន់តែទទឹងប្រវែងសឹងប៉ុនទន្លេ ប្រកបទៅដោយទឹកនឹងថ្កល់ មានផ្កាឈូក និងភ្ញីជាតិដទៃទៀត ដុះដេរដាសពីលើ បង្កើតបានជាកម្រាលធម្មជាតិមួយបែបដ៏ប្រណិតក្រៃលែង។

នៅច្រាំងខាងម្ខាងឯណោះ រឹតតែល្អជាងនេះទៅទៀត កំពែងថ្មលាតសន្ធឹងកាត់ព្រៃ សសរ និង ក្លោងទ្វារធំៗ មានបន្តុបកំពូលថ្មពីលើ ចាំងឆ្លុះច្បាស់ក្រឡែតពីលើផ្ទៃទឹក ប៉ុន្តែកំពូលថ្មទាំងនេះបាក់បែកស្ទើរតែទាំងអស់ទៅហើយ ឃើញតែដុំថ្មរបូតធ្លាក់មកនៅរាយពាសពេញដី។ បន្ទាប់ពីកំផែងនេះទៅឆ្ងាយជ្រៅខាងក្នុង មានភ្នំថ្មមួយប្រកបដោយកំពូលប្រាំបន្តុបពីលើ កំពូលបួននៅគ្រប់ជ្រុងទាំងបួន និង កំពូលកណ្តាលខ្ពស់ជាងគេ លេចត្រដែតហួសអស់ព្រៃព្រឹក្សាហើយនៅគង់វង់ទាំងអស់ ឥតមានឃើញបាក់បែកត្រង់ណាទេ។

ស្នូររទេះស្ងាត់ទៅវិញម្តងមួយៗជាបន្តបន្ទាប់គ្នា... ក្បួនរទេះឈប់តកន្ទុយគ្នាវែងអន្លាយតាមបណ្តោយមាត់ប្រឡាយទឹកព័ទ្ធជុំវិញអង្គរ ដែលមានស្ពានថ្មធំទូលាយនៅចំកណ្តាល សម្រាប់ឆ្លងពីម្ខាងទៅម្ខាង។ រូបសិង្ហពីរបាក់បែកស្ទើរតែមើលមិនចង់ស្គាល់ទៅហើយ នៅឈរយាមល្បាតនឹងថ្កល់ត្រង់ផ្លូវចូល។ យើងឆ្លងផុតមកដល់ក្លោងទ្វារ ដែលតាមស្មានមើលទៅ កន្លែងនេះពីដើមជាកន្លែងទាហានឈរយាម ប្រកបទៅដោយ ជញ្ជាំង សសរ និង បង្អួច មានក្បាច់ចម្លាក់ឆ្លាក់ដោយដៃវិចិត្រករដ៏ប៉ិនប្រសប់គ្មានពីរក្នុងលោក។ រូបទេពអប្សរ និង អ្នករបាំ ពាក់មកុដជំនាន់បុរាណ ញញឹមពព្រាយហាក់សម្តែងពរស្វាគមន៍ចំពោះយើង។ បន្តពីក្លោងទ្វារនេះ មានផ្លូវក្រាលថ្មមួយទៀត លាតសន្ធឹងវែងរហូតដល់កាំជណ្តើរ អង្គរវត្ត។ រូបនាគវែងដែលគេឆ្លាក់ធ្វើជាបង្កាន់ដៃនោះនៅគង់វង់នៅឡើយ ប៉ុន្តែទ្រេតទ្រោតរកកលនឹងបាក់ធ្លាក់ទៅលើវាលស្មៅនៅខាងក្រោម។ ផ្ទៃប្រាសាទទាំងមូល មានសភាពស្ងប់ស្ងាត់គួរឲ្យខ្លាច ទោះបីពួកយើងនាំគ្នានិយាយឡូឡាយ៉ាងណា ក៏ពុំអាចបង្កើតជាភាពអ៊ូអរបានដែរ នៅតែស្ងាត់ ស្ងាត់គួរឲ្យស្រងេះស្រងោចក្នុងចិត្ត។

យើងដើរមកដល់ជណ្តើរថ្មបួនកាំ ដែលនៅក្បែរនោះមានវត្តមួយសម្ងំពួនយ៉ាងសុខសាន្ត កណ្តាលសភាពស្ងប់ស្ងាត់ក្រោមម្លប់រុក្ខជាតិធំៗស្លឹកត្រសុំត្រសាយ។ អ្នកភ្នំពេញ និង អ្នកបាត់ដំបង ជាច្រើននាក់

បានមកដល់ទីនេះមុនយើងទៅទៀត ហើយគេដើរទៅដើរមកអ៊ូអរពាសពេញ។ ពួកក្រុមរាំងប្រយ័ត្នប្រយែង ខ្លាំងណាស់ គាត់តាមឃ្លាលយើងជាប់គ្រប់ជំហាន ដើម្បីការពារកុំឲ្យស្មៀនក្មេងៗដែលធ្វើដំណើរមកជាមួយ ខាម៉ីនសេព្ញមុខមន្ត្រីនោះ តាមចាប់យើងបាន។ ពួកក្មេងកម្លោះអស់ហ្នឹង ពុំមែនប្រាថ្នាមកមើលអង្គរវត្ត ប៉ុន្មានទេ ប៉ុន្តែតាមពិតគឺគេមកតាមមើលយើងនេះតែម្តង។ នៅពេលដែលយើងនាំគ្នាដើរចូលទៅកន្លែង ងងឹត ខ្ញុំសម្គាល់ឃើញអស់អ្នកអស់នាងជាច្រើន បានខំ ចោលឬក ចោលពារ ដើម្បីឲ្យគេយកតាមខ្លួន ដែល ជាហេតុអាចឲ្យខ្ញុំកាត់យល់បានថា ពួកទាំងនេះសុទ្ធតែធ្លាប់ទាក់ទងគ្នាតាំងពីយូរណាស់មកហើយ ហើយគេ ប្រហែលជាមានសន្យាថានឹងរៀបការជាមួយគ្នាក្នុងពេលណាមួយទៀតផង។ អាររៀប ឲ្យកន្ទុយភ្នែក ឬ ញញឹមស្មីអញ្ចឹង ខ្ញុំមិនរវល់យកចិត្តទុកដាក់មើលទេ ពីព្រោះក្បាច់ចម្លាក់អង្គរវត្តល្អពេកណាស់ មើលហើយ ជក់ភ្នែកចង់តែមើលទៀត! សម្លេងមនុស្សជជែកគ្នាចេកចាចលាន់ឮមកពីគ្រប់ទីកន្លែង ហើយនៅតាមច្រក ងងឹតនោះ ធុំក្លិនស្អុយអាចម៍ប្រចៀវគួរឲ្យចង់ក្អួត។

ជណ្តើរមានគ្រប់កន្លែង ងាកទៅខាងណាក៏ឃើញ មិនដឹងជាឡើងទៅដល់កន្លែងណាខ្លះទេ មកដល់ ក្លោងទ្វារនីមួយៗតែមិនបានប្រយ័ត្នមើលក្រោម ច្បាស់ជាជំពប់ជើងដួលផ្កាប់មុខមិនខាន។ នៅតាមជញ្ជាំង ជើង មានឆ្លាក់រូបល្អណាស់ រូបទេពអប្សរដែលឆ្លាក់ជាប់នៅនឹងជញ្ជាំង សុទ្ធតែមានដោះរលោងស្រិល ពីព្រោះនរណាដើរមកឃើញក៏អង្អែលគ្រប់ៗគ្នា។

មានកន្លែងមួយនោះ ឲ្យតែគក់ទ្រូង លាន់ឮសូរខ្ទ័រឆ្លើយតបមកវិញ។ ហេតុតែចង់ស្តាប់សម្លេងខ្ទ័រនេះ ខ្ញុំគក់ទ្រូងខ្លួនឯងទាល់តែចុក។

ក្រោយដែលដើរលេងនៅកន្លែងងងឹតអស់ហើយ យើងក៏ដើរចេញមកដល់ទីធ្លាមួយភ្លឺច្បាស់ក្រឡែត ដែលមានដុំថ្មធ្លាក់មករាយប៉ាយពាសពេញ។ កន្លែងនេះឥតមានដុះដើមឈើធំៗដូចនៅកន្លែងដទៃទៀតទេ ហើយនៅពីមុខយើង កំពូលទាំងប្រាំលូតខ្ពស់ត្រដូចត្រដឹមគួរឲ្យខ្លាច បន្តពីលើពំនូកថ្មធំសម្បើមប៉ុនភ្នំ។ ជណ្តើរសម្រាប់ឡើងទៅកាន់កំពូលនោះ មានច្រើនណាស់ ជណ្តើរ សម្រាប់ស្រីផ្សេង សម្រាប់ប្រុសផ្សេង មិនច្រឡូកច្រឡំគ្នាទេ។ ម្ចាស់ក្សត្រី អស់កម្លាំងពេកឡើងទៅទៀតមិនរួច សុខចិត្តអង្គុយចាំនៅខាងក្រោម ពួកយើងដោះស្បែកជើងនាំគ្នាឡើងយឺតៗយ៉ាងប្រុងប្រយ័ត្នក្រៃលែង មិនហានងាកក្រោយមើលមកក្រោម ពីព្រោះជណ្តើរនោះចោតសន្ធឹម ប្រកបទៅដោយកាំនីមួយៗតូចជាន់មិនពេញជើង។ បានឡើងទៅដល់លើ យើងអាចមើលឃើញទិដ្ឋភាពផ្ទៃអង្គរវត្តទាំងមូល ដែលល្អប្រៀបបានទៅនឹងប្រាសាទទិព្វផុះចេញកណ្តាល ទ្រូងព្រៃស្រោងស្រឹង ស្ទើរតែពុំអាចជឿថាជាស្នាដៃមនុស្ស។ ខ្ញុំឮគេប្រាប់ថា នៅជិតៗនេះមាន អង្គរធំ, ប្រាសាទលលៃ, ប្រាសាទតាព្រហ្ម និង ប្រាសាទផ្សេងៗទៀតជាច្រើន ដែលខ្ញុំភ្លេចឈ្មោះអស់ទៅហើយ ប៉ុន្តែខ្ញុំរកមើលមិនឃើញមួយសោះ ព្រោះព្រៃដុះគ្របពីលើជិតអស់ទៅហើយ... ឃើញតែព្រៃខៀវស្រងាត់ លាតសន្ធឹងវែង រហូតទៅដល់ទន្លេសាប។

ដោយសារខ្ញុំចេញមុខការពារ កាហ៊ុនវាបានតាមមកជាមួយគេជាប់រហូត វារត់ឡើងជណ្តើរលឿន ដូចកណ្តុរ។ យើងដើរមើល ខាងឆ្វេងបន្តិច ខាងស្តាំបន្តិច រួចនាំគ្នាអុជធូបបួងសួងរូបសំណាកឆ្លាក់ជាប់នឹង ទ្វារមួយនោះ របៀបតជាជញ្ជាំងអញ្ចឹង។

ថ្ងៃខ្ពស់ណាស់ហើយ... យើងក្លូរពោះឃ្លានបាយ ហើយក៏អស់កម្លាំងបន្តិចដែរ ជាពិសេសគឺខ្ញុំនេះឯង ដែលអស់កម្លាំងខ្លាំងជាងគេ ពីព្រោះខ្ញុំមិនរវល់កាច់រាងឲ្យគួសង្ស័យមើលដូចពួកគេឯទៀតទេ។ ខ្ញុំហាក់ដូច ជាឈឺចុកចាប់ពេញខ្លួន ទ្រាំមិនបានក៏ចូលទៅសម្ងំដេកក្នុងរោងស្លឹកដែលគេសង់ទុកសម្រាប់ឲ្យពួកបរិពារ



ហ្លួងចូលឈប់សម្រាកកំដៅថ្ងៃ។ ការនឿយហត់ក្នុងពេលធ្វើដំណើរ ចាប់ផ្តើមធ្វើទុក្ខខ្ញុំខ្លាំងឡើងៗជាលំដាប់ រហូតដល់ពេលថ្ងៃត្រង់ខ្ញុំធ្លាក់ជាបមែនទែន ប៉ុន្តែខ្ញុំទ្រាំរាំថ្វាយ វត្ថុសក្តិសិទ្ធិ និង ទេវតាក្សាទឹកដី ជាមួយ គេឯងទាល់តែចប់ចុងចប់ដើម។

ខ្ញុំផ្ទេចភ្នែកមមើមមាយឃើញតែរឿងផ្តេសផ្តាសគួរឲ្យខ្លាច ហើយមួយសន្ទុះក្រោយមក ខ្ញុំក៏សន្លប់លែង ដឹងខ្លួនសោះតែម្តង... ពេលត្រឡប់មកវិញ គេម្នាក់ៗសង្វាតយោងអាត្មាតែរាល់ខ្លួន គ្មាននរណាគិតគូរ នឹកនាដល់ខ្ញុំដែលដេកលក់ស្តូកស្តឹងតែម្នាក់ឯងនៅលើកន្ទេលក្នុងរោងនោះទេ។ ថ្ងៃនោះបើកុំតែបានពុកម៉ែ ទៅតាមជាមួយ ម្ល៉េះសមគេភ្លេចទុកខ្ញុំចោលកណ្តាលព្រៃមិនខាន។ មកដល់សៀមរាបវិញ ខ្ញុំដេកស្តូកនៅ លើទីនាំងសក្តិក្រសេម រង់ចាំទម្រាំអ្នកឯទៀតត្រឡប់មកពីរាំបួងសួងឯអង្គរធំវិញ នឹងអាលនាំគ្នាត្រឡប់មក ភ្នំពេញ។ ខ្ញុំដឹងថា នេះជាជម្ងឺពេលឡើងខ្លួន ប៉ុន្តែជម្ងឺនេះវាធ្វើទុក្ខខ្ញុំខ្លាំង រហូតដល់រវើរវាយវង្វេងស្មារតី ពុំដឹងជាអស់រយៈពេលយូរប៉ុណ្ណា ស្រាប់តែមាននរណាអង្រួនដាស់ខ្ញុំ សម្លឹងមើលទៅដូចជាមុខយ៉ាន ពួកម៉ាកខ្ញុំ។ វាខ្សឹបប្រាប់ថា ពេលដេកមមើមមាយ ខ្ញុំវាសដៃទៅប៉ះក្បាលម៉មន្ទ ដែលជាហេតុបណ្តាល ឲ្យគាត់ខឹងច្រឡោត ហើយខ្ញុំហាក់ដូចជាស្រមៃឮម៉មន្ទ និយាយល្វើយៗកំពុងទូលពិតហ្លួងថា៖ ខ្ញុំព្រហើន ណាស់ គ្រាន់តែបានចូលវេនគាប់បំរើហ្លួងប៉ុណ្ណឹង ស្រាប់តែឡើងចាងហ៊ានវាយក្បាលគាត់ ដែលមានថាន: ជាម៉ម ព្រមទាំងសុំឲ្យហ្លួងវាយប្រដៅខ្ញុំម្តង កុំឲ្យព្រហើនដាក់គាត់ខ្លាំងពេក។ ខ្ញុំឮសម្លេងហ្លួងឆ្លើយតប មកវិញថា :

ម៉ែន្ទូ អើយ កុំធ្វើបាបវាអី! មិនឃើញជាវាកំពុងឈឺមមើមមាយមិនដឹងខ្លួនទេហ្អែ? ក្មេងអាយុប៉ុណ្ណឹង វាតែងឈឺអញ្ចឹងហើយ ឈប់រអ៊ូរទាំទៅ ទុកពេលឲ្យអញដេកពួនខ្លះផង។

ប៉ុន្តែ ម៉មន្ទូគាត់មិនងាយឈប់រអ៊ូភ្លាមទេ ពីព្រោះគាត់ចងចិត្តស្អប់ពួកយើងក្មេងៗ ដោយសារសព្វថ្ងៃ ហ្លួងសព្វព្រះទ័យនឹងពួកយើងជាងគាត់។

បន្ទាប់ពីពេលកើតឧប្បត្តិហេតុនេះមក ខ្ញុំហាក់ដូចជាបានស្រួលខ្លួនបន្តិចឡើងវិញ... ខ្ញុំមើលតាមបង្អួច ឃើញទីនាំងលឿនលយទៅមុខតាមចង្វាក់ច្រវា កាត់តំបន់ព្រៃលិចទឹកក្នុងស្រុកកំពង់លែង... យើងជិតទៅ ដល់កំពង់ឆ្នាំង ហើយ មកដល់កំពង់ឆ្នាំង ម៉ែអួន ធ្វើជានិយាយទូលហ្លួងថា ខ្ញុំឈឺធ្វើការមិនកើតអញ្ចឹង ឲ្យជិះលើទីនាំងសក្តិក្រសេមនាំតែធ្ងន់ទូកឥតប្រយោជន៍ ដោយសារមធ្យោបាយដ៏ប៉ិនប្រសប់នេះ ខ្ញុំក៏បាន ចុះទៅជិះទូកជាមួយពុកម៉ែ ដើម្បីឲ្យគាត់បានមើលថែទាំខ្ញុំដោយផ្ទាល់។ កប៉ាល់ម៉ាស៊ីន សណ្តោងទូក ទាំងអស់ត្រឡប់មកដល់ភ្នំពេញក្នុងរយៈពេលប៉ុន្មានម៉ោងប៉ុណ្ណោះ ហើយហ្លួងបានអនុញ្ញាតឲ្យម៉ែយកខ្ញុំទៅ មើលនៅផ្ទះ ចាំកាលណាជាស្រួលបួលសឹមត្រឡប់មកធ្វើការវិញ។

ខ្ញុំសប្បាយចិត្តក្រៃលែង ដោយបានវិលមកស្គាល់ជីវភាពគ្រួសារ ដែលខ្ញុំបំភ្លេចចោលតាំងពីច្រើនឆ្នាំ ណាស់ហើយ។ ផ្ទះខ្ញុំផ្លាស់ប្តូរប្លែកពីមុនទាំងអស់។ កាលឆ្នាំទៅ មានភ្លើងឆេះផ្ទះ រាលដាលពេញម្តុំ ខាងជើងកំពង់ផែ បណ្តាលឲ្យពុក-ម៉ែ គាត់ប្រញាប់ជញ្ជូនអីវ៉ាន់និងរុះរើផ្ទះខ្ទេចខ្ទីអស់ ប៉ុន្តែភ្លើងនោះ មិនបានឆេះមកដល់ផ្ទះយើងទេ ណាមួយរៀងរាល់ឆ្នាំ ដីច្រាំងទន្លេចេះតែបាក់ទាំងផ្ទាំងៗធ្លាក់ចុះទៅក្នុងទន្លេ ពុកក៏លើកផ្ទះមកសង់នៅខាងលើឯណោះវិញ ដើម្បីឲ្យបានឆ្ងាយពីមាត់ទន្លេបន្តិច។

ប្រាក់ខែពុកតិចពេក ពុំអាចឲ្យគាត់រកប្រាក់គ្រប់គ្រាន់ល្មមសង់ផ្ទះមួយធំទូលាយ សមតាមចិត្តប្រាថ្នា ម្ល៉ោះហើយផ្ទះថ្មីនេះធ្វើពីស្លឹកដដែល មានពីរបន្ទប់ និង តសំយាកចេញជាផ្ទះបាយ ព្រមទាំងមានរានហាល នៅពីមុខ ដែលពុកដាំផ្កាដាក់តាំងជាលំអផង។ នៅក្រោមផ្ទះមានដាក់របស់ប្រើប្រាស់ផ្សេងៗ ដូចជា

ពាងទឹក ត្បាល់បុកស្រូវ ចង្អេរ កញ្ជើ និង ខុស ជាដើម ។ ពុក កាប់គាស់ដីរៀបចំធ្វើជាសួនច្បារតូចមួយ ខណ្ឌ ផាច់ពីផ្ទះអ្នកជិតខាងដោយសាររបងឫស្សី ដែលនៅទីនោះមានដាំ ដើមចេក ដើមល្ហុង ប្រកបទៅដោយ ផ្លែរយើងរយោងផ្ញើមត្រជាក់ ។ ពុកគិតថា បើយ៉ាងហោចណាស់ក៏ពីរឆ្នាំទៀតដែរ ទម្រាំរាជការដេញឲ្យរុះរើ ផ្ទះនេះ ហើយក្នុងរយៈពេលនេះ គាត់នឹងខំសន្សំលុយទុកសម្រាប់ដើររកទិញដីនៅកន្លែងថ្មីទៀត ។ ខ្ញុំ អាណិតពុកណាស់ !... ខ្លួនគាត់ចាស់សក់ស្កូវសព្រោង ជុះពុកមាត់ស្រមូម ក៏មិនរវល់គិតគូរ គិតយ៉ាងណា ឲ្យតែកូនស្រីតែមួយ បានសប្បាយ បានស្រួល ពីព្រោះតទៅថ្ងៃមុខគាត់សង្ឃឹមថានឹងបាន ខ្ពស់មុខ ខ្ពស់មាត់ ស៊ីពោះលោះកម្លាំងដោយសារកូនស្រីដែលជាអ្នករាំល្ខោនហ្លួងនេះហើយ ។ គាត់ស្រមៃឃើញថា ការដែល គាត់សុខចិត្តលះបង់កូនសម្លាញ់ចិត្តថ្វាយទៅហ្លួង យូរឬឆាប់ គាត់គង់នឹងបានទទួលការតបស្នងពីហ្លួងវិញ មិនខាន ។ កាលណាខ្ញុំត្អូញត្អែរថ្លែងពីសេចក្តីអស់សង្ឃឹមក្នុងការរស់នៅក្នុងវាំង គាត់តែងលួងលោមថា ឲ្យ ខ្ញុំទ្រាំនៅបន្តិចទៀតចុះ យ៉ាងហោចណាស់បើមុននឹងចេញមក ក៏ចាំគាត់រកផ្ទះថ្មីបាននៅស្រួលបួលជាមុន សិនដែរ ។

គាត់បានទិញ ក្ដារខៀនខ្មៅមួយ និង ដីសមួយប្រអប់ សម្រាប់បង្រៀនឲ្យខ្ញុំ ចេះសរសេរ ចេះអាន អក្សរខ្មែរ ពេលណាគាត់ទំនេរ ។ ប៉ុន្តែខ្ញុំខ្ជិលរលួយ មិនចង់រៀនសូត្រសោះ ដែលជាហេតុធ្វើឲ្យពុកអស់ សង្ឃឹមលែងស្តី ។

គាត់គិតតែម្យ៉ាង គឺធ្វើយ៉ាងណាដើម្បីរៀបចំអនាគតខ្ញុំឲ្យបានភ្លឺស្វាងដូចគេឯង ហើយទោះបីគាត់ មិនសូវនិយាយស្តី មិនសូវចេះថ្នាក់ថ្នម ក៏ខ្ញុំនៅតែអាចគាត់ស្មានយល់ដល់ជម្រៅចិត្តគាត់ថា គាត់ស្រឡាញ់ ខ្ញុំ គិតខ្វាយខ្វល់រឿងខ្ញុំជាងខ្លួនគាត់ទៅទៀត ។ ពេលឃើញពុកសន្សំបានប្រាក់បន្តិចបន្តួចសល់ពី ប្រាក់ខែ និង. ប្រាក់រកបានក្រៅដោយសារគាត់ជួយសរសេរពាក្យបណ្ដឹងឲ្យគេ ហើយទិញរបស់កំប៉ិកកំប៉ុកមកទុក ឲ្យខ្ញុំប្រើប្រាស់ ម៉ែនិយាយចំអន់ឲ្យខ្ញុំថា ៖

~ ពុកឯង គិតរៀបចំឲ្យឯងមានប្តីហើយ !

ផ្ទះខ្ញុំស្អាត ហើយសប្បាយរីករាយជានិច្ច... ក្នុងទូកញ្ចក់តូចៗមានដាក់ ថូផ្កា ដបទឹកអប់ និង កំប៉ុង ម្សៅ ជាពិសេសទោះបីខ្វះខាតលុយយ៉ាងណា ក៏គាត់មិនព្រមលក់បញ្ចាំខ្សែក្រវាត់ប្រាក់របស់ខ្ញុំដែរ សុខចិត្ត តែទុកដាក់តាំងសំញែងក្នុងទូ ។

កាលណាអ្នករែកទឹកក្រយកទឹកមកចាក់ឲ្យ គាត់មិនហៅមនុស្សប្លែកឲ្យរែកទឹកចូលហេតរហូតក្នុងផ្ទះ ទេ សុខចិត្តដោះអាវលែងខ្លួនទទេ លីដងរែកទៅត្រងទឹកម៉ាស៊ីនរែកយកមកផ្ទះ មិនរវល់ខ្លាចនរណា គេសើចយំអ្វីទាំងអស់ ធ្វើម៉េចឲ្យតែមានទឹកសម្រាប់ខ្ញុំងូតសំអាតខ្លួន ។

~ ពុកហ្នាំ (ខ្ញុំឃាត់គាត់) ពុកធ្វើអញ្ចឹង ខ្ញុំខ្មាសគេណាស់ ។

ប៉ុន្តែគាត់មិនស្ដាប់ខ្ញុំទេ ហើយកាលណាម៉ែមិននៅផ្ទះ គាត់ថែមទាំងរៀបចំដាំបាយធ្វើម្ហូបម្ហាដោយខ្លួន ឯងទៀតផង ។ គាត់នៅតែសង្ឃឹមជានិច្ចថា ថ្ងៃណាមួយខ្ញុំជួយទូលសុំហ្លួងឲ្យគាត់ បានឡើងបុណ្យសក្តិ ឬ បើយ៉ាងហោចណាស់ក៏សុំព្រះរាជទ្រព្យខ្លះ យកមកសង់ផ្ទះឈើប្រក់ក្បឿងឲ្យបានសមរម្យដែរ ពីព្រោះ អ្នករបាំដទៃទៀត គេធ្លាប់សុំបានច្រើនគ្នាហើយ ។ ប៉ុន្តែគាត់មិនហ៊ាននិយាយប្រាប់ខ្ញុំសោះ ហើយខ្លួនគាត់ ទៀត ក៏ចេះតែគេចវេះមិនដែលចូលទៅគាល់ឲ្យស្គាល់មុខនឹងគេសោះ ។

ថ្ងៃមួយគាត់ទិញផ្លែឈើមួយថាស ថាឲ្យខ្ញុំយកទៅថ្វាយហ្លួង ប៉ុន្តែខ្ញុំលួចស៊ីអស់រលីង មិនបានយកទៅ ថ្វាយហ្លួងឡើយ ។ ក្រោយមកយូរណាស់ ទើបគាត់ដាច់ចិត្តហ៊ានសួរខ្ញុំ ពីរឿងគាត់ពឹងឲ្យទៅសុំហ្លួងនោះ



តើវាបានការយ៉ាងម៉េចទៅហើយ ? ខ្ញុំនឹកស្ដាយក្រោយ និង ខ្មាសខ្លួនឯងយ៉ាងខ្លាំង ដែលពុំបានសងគុណ ឪពុកម្ដាយឲ្យសមតាមទំហំទឹកចិត្ត ដែលគាត់ខំស្រឡាញ់ថ្នាក់ថ្នមខ្ញុំ ។

យើងក្រពិតមែន ប៉ុន្តែយើងមិនដែលខ្វះខាតទេ ។ ពុកត្រូវខំធ្វើការរកប្រាក់ឲ្យបានច្រើនលើសពេលមុន ព្រោះសព្វថ្ងៃនេះខ្ញុំធ្លាក់មកលើបន្ទុកគាត់ទាំងស្រុង ប្រាក់ខែវាំងមួយខែដប់រៀលរបស់ខ្ញុំនោះ ត្រូវកាត់សង លុយជំពាក់កាលខ្ចីគេទៅ បាត់ដំបង សៀមរាប អស់ទៅហើយ ។ ហេតុនេះគ្រួសារយើងចាយត្បិតត្បៀតជា ទីបំផុត ដើម្បីជៀសវាងកុំឲ្យជំពាក់គេ ។

ពុក និង ម៉ែ មួយថ្ងៃៗធ្វើការឥតទំនេរដៃ មួយផ្ទះនៅសល់ទំនេរតែខ្ញុំ ដែលឥតធ្វើការអ្វីទាំងអស់ ក្រៅតែ ពីតែងខ្លួនសំអិតសំអាងកាយ ។ ម៉ែ និង កាហ៊ុន ទៅផ្សារ ដាំបាយ សួស្លុក បោកគក់សំពត់អាវខ្ញុំ គ្រប់ បែបយ៉ាង ។ សុខភាពខ្ញុំបានស្រួលឡើងវិញជាលំដាប់ ប៉ុន្តែឪពុកបែរជាធ្លាក់ខ្លួនឈឺ ម្តងក្តៅ ម្តងរងា គួរឲ្យព្រួយបារម្ភក្រៃលែង ។ តាំងពីត្រឡប់មកពីអង្គរវិញ មួយយប់ៗគាត់ក្អកទល់ភ្លឺ ជួនកាលមានធ្លាក់ឈាម ទាំងដុំមកផង ពេលក្អកម្តងៗទ្រូងគាត់ក្តៅដូចភ្លើង ។ គាត់ស្រក់សៃភ្នែកពោរពេញទៅដោយ ក្តីស្នេហា និង ក្តីព្រួយបារម្ភ សម្លឹងមើលខ្ញុំ សម្លឹងមើលផ្ទះ សម្លឹងមើលម៉ែដែលគិតតែអង្គុយយំ ឥតធ្វើអ្វីកើតទាំងអស់ ។ គាត់ហៅខ្ញុំចូលទៅជិត ហើយខ្សឹបខ្សៀវថា ៖

~ កូនឯងនៅក្នុងវាំងរហូតទៅណា៎ ពីព្រោះបើចេញមកនៅក្រៅ កូនឯងគ្មានបង្គោលទីពឹងមាំមួនទេ ។

យើងពុំបានចាប់ភ្លឹកគិតថា គាត់ឈឺខ្លាំងទាល់តែសោះ ហើយខ្លួនគាត់ប្រហែលជាខំលាក់មិនឲ្យយើង ដឹង ខ្លាចយើងព្រួយចិត្តហើយមើលទៅ ។

គ្រាន់តែមានកម្លាំងបន្តិចឡើងវិញភ្លាម ខ្ញុំមានសេរីភាពពេញបរិបូរណ៍ អាចលេងសើច ឬ ធ្វើអ្វីបានតាម ចិត្ត ព្រោះនៅផ្ទះគ្មានក្រុមវាំងចាំតាមយាមគ្រប់ជំហានដូចនៅវាំង ។ ចាប់តាំងពីពេលធំពេញរូបពេញរាង មក ខ្ញុំសង្កេតឃើញពុកគាត់ប្រិតប្រៀនរឿងខ្ញុំខ្លាំងណាស់ ។ ថ្ងៃមួយគាត់ឃើញទាន់ខ្ញុំកំពុងងូតទឹកនៅ មាត់ទន្លេ ឥតចេះអៀនខ្មាសដល់គេឯងដែលមុជអូអរនៅជិតនេះសោះ គាត់ក៏ដេញឲ្យខ្ញុំត្រឡប់មកផ្ទះវិញ ព្រមទាំងស្តីបន្ទោសខ្ញុំយ៉ាងច្រើន ប៉ុន្តែគាត់ស្តីមួយម៉ាត់ ខ្ញុំឆ្លើយទៅវិញដប់ម៉ាត់ មិនព្រមចាញ់គាត់ទេ ។ ឃើញថាប្រដៅខ្ញុំមិនបាន គាត់ក៏ទៅប្រាប់ម៉ែថា ខ្ញុំនេះឆ្នាស់រកនរណាប្រៀបឲ្យស្មើពុំបាន ហើយចាប់តាំង ពីពេលនោះមក គាត់រឹតតែឃ្លាំមើលខ្ញុំ ប្រយ័ត្នប្រយែងជាងពេលមុនទៅទៀត ។ ខ្ញុំក្លាយខ្លួនទៅជាមនុស្ស ទោសជាប់ឃុំឃាំង ពុំអាចដើរចេញទៅណាមកណាតែម្នាក់ឯងបានឡើយ ហើយខ្ញុំត្រូវតែយល់ថា ការ ប្រុងប្រយ័ត្នរបស់ពុកជាការត្រឹមត្រូវ ពីព្រោះនៅក្នុងទីក្រុងមានមនុស្សប្រុសខូចខិលច្រើនណាស់ ស្រីអាយុ ដំណាលខ្ញុំ ត្រូវចេះការពារខ្លួនឲ្យម៉ឺងម៉ាត់ ដើម្បីកុំឲ្យធ្លាក់ខ្លួនទៅក្នុងអន្ទាក់ពួកវា ។ លើសពីនេះទៅទៀត ខ្ញុំមិនត្រូវភ្លេចថា ខ្លួននេះជាអ្នកបំរើហ្លួង លោកឧស្សាហ៍ប្រើក្រុមវាំងឲ្យមកតាមស៊ើបសួរដំណឹងពីខ្ញុំជា រឿយៗ ឲ្យតែហ៊ានថ្លោះធ្លោយបន្តិច លេចឮទៅដល់វាំង ច្បាស់ជាត្រូវទណ្ឌកម្មធ្ងន់ខ្លួនមិនខាន នេះមិន និយាយពីរឿងគេបណ្តេញឈប់ឲ្យនៅវាំងផង ។

មានកើតឧប្បត្តិហេតុមួយ ដែលជាសញ្ញាព្រមានថា ឲ្យខ្ញុំត្រូវតែប្រយ័ត្នខ្លួនចាប់តាំងពីពេលនេះតទៅ ហើយពុក-ម៉ែ ក៏រឹតតែតឹងតែងខ្លាំងឡើងទៀតដែរ ។ ថ្ងៃមួយខ្ញុំអង្គុយជក់បារី ជជែកគ្នាជាមួយ កាហ៊ុន លើរានហាល ភ្នែកសម្លឹងមើលមនុស្សម្នាដែលដើរមកតាមផ្លូវមុខផ្ទះ ស្រាប់លេចឃើញបារាំងម្នាក់ មុខ ក្រហមងាំង សក់ក្បាលបះកន្ទ្រើង ពុកមាត់ស្រមូម ស្លៀកពាក់ស ពាក់មួកស ដែលជាការចម្លែកពេកណាស់ ពីព្រោះក្នុងភូមិខ្មែរមិនសូវមានបារាំងចេញចូលញឹកញាប់ទេ ។ ក្រឡេកមកឃើញខ្ញុំ ស្រាប់តែវាបត់ក្បាល

ដើរចូលរ៉ូយ តម្រង់មកចំផ្ទះខ្ញុំតែម្ដង ខ្ញុំភ័យស្ទើរលោះព្រលឹង រត់ចូលទៅក្នុងផ្ទះស្រែកឆោឡោ ៖

~ ពុក ! ម៉ែ ! បារាំងចូលផ្ទះយើងហើយ ធ្វើម៉េចទៅ ?

ពុកស្រវាទាញបានរនុកទ្វារ ម៉ែទាញបានជន្ទល់បង្អួច យកមកលាក់ក្រោយខ្នង ចេញទៅឈរពាំងមាត់ទ្វារ ។

~ លោករកអី ? (ពុកសួរទៅបារាំងដែលទើបនឹងឡើងផុតកាំជណ្ដើរ ដើរទ្រេតទ្រោតចូលមក) ។

បារាំងនេះធំក្អិនស្លុយស្រាហ្នឹង វាស៊ើចខ្ជ័រ ព្រមទាំងនិយាយគ្រលរស្ទើរស្ដាប់មិនចង់បាន ៖

~ ខ្ញុំរកប្រពន្ធខ្ញុំ វានៅទីហ្នឹងទេ ?

~ អត់មានប្រពន្ធលោកនៅទីនេះទេ, លោកអញ្ជើញទៅរកកន្លែងណាផ្សេងទៀតទៅ !

ខ្ញុំ និង ហ៊ុន ពួនពីក្រោយជញ្ជាំង លួចមើលតាមប្រហោងជញ្ជាំងភ័យញ័រទទ្រើក ដោយឃើញពុកខ្ពស់មិនដល់ស្មាបារាំងផង ។ ប៉ុន្តែសំណាងល្អ អាបារាំងហ្នឹងវាស្រវឹងស្រាខ្លាំងណាស់ វាព្រមចុះដើរចេញទៅវិញតាមសម្រួល ដោយលូកដៃស្ដាំមកចាប់ដៃពុកជាសញ្ញាលាគ្នាផង ។ រឿងនេះវាធ្វើឲ្យផ្អើលអស់មួយភូមិ គេនាំគ្នាមកសាកសួរ ពុក-ម៉ែ ហើយយកទៅនិយាយសើចលេងពេញម្ដុំកំពង់ផែអស់ ពីរ-បីថ្ងៃ ។

ផ្ទះខ្ញុំឧស្សាហ៍មានភ្ញៀវឡើងចុះណាស់ ហើយក្នុងចំណោមភ្ញៀវទាំងអស់ ខ្ញុំសង្កេតឃើញថាមានប្រុសកម្លោះពីរនាក់ ដែលខ្ញុំធ្លាប់ស្គាល់តាំងពីយូរមកហើយ ដោយធ្លាប់ឮគេនិយាយនៅក្នុងវាំង និង ធ្លាប់ឃើញក្នុងពិធីបុណ្យផ្សេងៗ មួយឈ្មោះ នុន មួយទៀតឈ្មោះ នុរ ជាអ្នកឡើងចុះញឹកញាប់ជាងគេ ។ ជួនកាលវាមកលេងខុសពេលគ្នា ជួនកាលមកជួបគ្នាតែម្ដង ដែលជាការគួរឲ្យធុញទ្រាន់ពេកណាស់ ព្រោះម្នាក់ៗ សុទ្ធតែប្រជែងគ្នាទិញនេះទិញនោះយកមកជូនម៉ែដើម្បីផ្គាប់ផ្គុន, ខ្ញុំក៏មិនមែនខ្លាក់មិនយល់ពីគោលបំណងរបស់វានោះទេ ។ ម៉ែក៏មិនលាក់រឿងនេះនឹងខ្ញុំដែរ គាត់ប្រាប់ខ្ញុំថាឈ្មោះ នុន និង នុរ ជាគូប្រជែងចង់ស្ដីដណ្ដឹងខ្ញុំ ប៉ុន្តែខ្ញុំមិនដឹងជាសំរេចចិត្តស្រឡាញ់មួយណា គឺខ្ញុំស្អប់វាទាំងពីរនាក់តែម្ដង គ្រាន់តែមិនចេញស្ដីឲ្យនរណាដឹង ។

ឪពុករបស់ នុន ជាតាម៉ឺនធំ ស្លាប់តាំងពីយូរណាស់ហើយ ក្នុងពេលច្បាំងជាមួយសៀម ។ សព្វថ្ងៃ នុន រស់នៅជាមួយម្ដាយមេម៉ាយ និង បងប្អូនស្រីច្រើននាក់ទៀត, គ្រួសារគេជាពូជព្រាហ្មណ៍បារគូសុទ្ធ ។ នុន សម្បុរខ្មៅស្រអែម មាឌធំ រាងសង្ហា ចេះគួរសម មិនប្រកាន់ខ្លួន ទោះបីម្ដាយទំរើសកូនប្រុសតែមួយ ទិញនាឡិកា, ខ្សែដៃមាស, កង់យ៉ាងទាន់សម័យ បំពេញចិត្តមិនឲ្យទាស់យ៉ាងណាក៏ដោយ ។ ផ្ទះម្ដាយ នុន ស្ថិតនៅខាងត្បូងវត្តបទុម ពីក្រោយស្រះស្រង់, ធំទូលាយល្អណាស់ ។

នុរ ជាកូនចៅក្រមធំ អាយុស្របាលគ្នានឹង នុន ដែរ ប៉ុន្តែវាជាកូនចៅចិន ហើយជាមនុស្សខ្ជិលខ្ជា មិនសូវគិតគូរពីរឿងអីទេ ។

នុន និង នុរ ធ្លាប់ស្គាល់គ្នាតាំងពីក្មេង ដោយធ្លាប់រៀននៅក្នុងសាលាបារាំងជាមួយគ្នា ឈប់រៀនក៏ដំណាលគ្នា ហើយដល់ពេលបួស ក៏បួសក្នុងវត្តជាមួយគ្នាទៀត ។ លុះសឹកមកវិញ ទំនេរមិនទាន់ចូលធ្វើការ គេក៏រឹតតែរាប់អានគ្នាលើសដើម ដើរទៅណាក៏ពីរនាក់ កម្រឃើញដើរបែកគ្នាណាស់ ។ គេមិនសូវមានតម្រិះជ្រៅជ្រះក៏ពិតមែន ប៉ុន្តែគេអាងសម្បត្តិម៉ែឪ មិនសូវភ័យព្រួយរឿងរកស៊ីធ្វើការ ដូចយើងជាកូនអ្នកក្រឡើយ ។ ខ្ញុំដឹងថាពីមុន នុន ធ្លាប់មានទាក់ទងនឹងពួកល្ខោនម្នាក់ ប៉ុន្តែក្រោយមកបែកបាក់គ្នាទៅវិញ ដោយសារមីនោះលួចសាហាយគ្នាជាមួយស្មៀនលោកកុងស៊ីនៅលើ កប៉ាល់ដែលដឹកយើងត្រឡប់មកពីស្រុកបារាំងវិញ ។ នេះជារឿងចាស់មួយ, ហើយក្រោយមកខ្ញុំសង្កេតឃើញថា កាលណា អស់អ្នក-អស់



នាង ក្នុងវាំងចេញទៅវត្តព្រះកែវម្ដងៗ នុន ផែងឃើញក្មួង [illegible] មាយាម្ចិកម្ចក់របស់នរណាទេ តាមសម្លឹងមើលតែខ្ញុំម្នាក់ប៉ុណ្ណោះ ។

ចំណែក នុរវិញ ក៏មានទាក់ទងស្នេហានៅក្នុងវាំងជាមួយមីម្នាយនោះឈ្មោះ [illegible] ចាស់មេអណ្ដើកបែរជាច្រឡំទៅទាក់ទងនឹងម្នាក់ផ្សេងទៀតឈ្មោះ ពុទ ដូចគ្នាដែរ ។ [illegible] ពីរនាក់ វាឈ្មោះជេរបញ្ចោរគ្នាផ្អើលណាណី ពីព្រោះវាសុទ្ធតែមិនដែលស្គាល់មុខម្ចាស់ [illegible] ដូចគ្នា ។ ចាប់តាំងពីពេលច្រឡំម៉្យយបែកការខ្មាស់គេម្ដងមក នុរ លែងហ៊ានរវើរវាយរឿងនេះសោះតែម្ដង ។

ខ្ញុំចេះតែឆ្ងល់ ហេតុដូចម្ដេចបានជាខ្ញុំទាក់ទងស្គាល់ប្រុសកម្លោះពីរនាក់នេះ ? ខ្ញុំគិតយូរណាស់ទម្រាំតែនឹកឃើញ ។ នុន ប្រហែលជាចាប់ស្រឡាញ់ខ្ញុំបន្ទាប់ពីពេលបានជួបគ្នាដោយចៃដន្យនៅក្នុងទីធ្លាវត្តព្រះកែវ ក្នុងថ្ងៃសីល ដែលខ្ញុំជង្គ្លៃម្ហូបរីក្សត្រីយកចង្ហាន់ទៅប្រគេនព្រះសង្ឃជាមួយ អស់អ្នក-អស់នាង ដទៃទៀត នោះហើយមើលទៅ ។

កាលនោះ នៅក្នុងវាំងមានស្រីកូនស្ដេចម្នាក់កំព្រា មិនដឹងជាកូនចៅស្ដេចណាទេ ឈ្មោះ ចិន្តាវង្ស មានបន្ទប់ដេកនៅក្បែរខ្ញុំ ម្ចាស់នេះនៅជាមួយមីងចាស់ម្នាក់ឈ្មោះយាយ អ៊ូ ដែលស្រឡាញ់រាប់អានខ្ញុំណាស់ ហើយថែមទាំងស្គាល់គ្រួសារ នុន ច្បាស់លាស់ទៀតផង ។ គាត់ត្រូវគេជួលឲ្យលុយយ៉ាងច្រើន ដើម្បីធ្វើមេអណ្ដើក រហូតដល់ហ៊ានលួចជាហ៊ីចាក់ជរពណ៌ក្រហមរបស់ខ្ញុំយកទៅឲ្យ នុន ទាល់តែខ្ញុំគំរាមកំហែងខ្លាំងមែនទែន ទើបគាត់យកមកសងវិញ ។ ឃើញថាទាក់ទងជាមួយខ្ញុំមិនបាន គាត់ក៏បែរទៅទាក់ទងជាមួយ ពុក-ម៉ែ ម្ដង ហើយម៉ែនោះ ចេះតែនៅស្ងៀមរហូត ។ ថ្ងៃមួយគាត់កំពុងមកលេងជាមួយខ្ញុំនៅឯវាំង ស្រាប់តែមានគេមកតាមថា ពុកឲ្យហៅត្រឡប់ទៅផ្ទះវិញជាប្រញាប់ ។ ទៅដល់ផ្ទះគាត់ភ្ញាក់ព្រើត ដោយឃើញមនុស្សមួយហ្វូងធំកាន់ថាសដាក់នំចំណី មានម្ដាយ នុន ជាអ្នកនាំមុខចូលមកចែចូវស្ដីដណ្ដឹងខ្ញុំ ។

ដោយខ្លាចអំណាចគេជាអ្នកមាន ពុកមិនហ៊ានឆ្លើយថាយ៉ាងម៉េចឲ្យច្បាស់លាស់ គាត់យកអំណាចហ្លួងមកដឹកមុខថា មានតែហ្លួងទេដែលអាចសំរេចរឿងប្ដីសី នៃ ពួកល្ខោនរបស់លោកបាន ។ ពុកមិនបានបដិសេធដាច់ស្រេចអញ្ចឹង ទើបបានជា នុន នៅតែទៅមកឡើងចុះផ្ទះខ្ញុំជាញឹកញាប់ ហើយខំយកចិត្ត ពុក-ម៉ែ លើសដើម ។

ថ្ងៃមួយ នុន នាំ នុរ មកលេងផ្ទះខ្ញុំ ដើម្បីបង្ហាញឲ្យម៉ែបានស្គាល់ពួកម៉ាកសម្លាញ់ចិត្តរបស់គេ ហើយចាប់តាំងពីពេលនោះមក នុរ ក៏ឧស្សាហ៍មកលេងតែម្នាក់ឯងជាញឹកញាប់ ដោយសំអាងថា ជាពួកម៉ាកជិតដិតនឹង នុន ប៉ុន្តែតាមពិត អាគាត់ហ្នឹងចង់ដើរខ្សែលើពួកម៉ាកតែម្ដង ។ ឪពុករបស់ នុរ បានជួបជាមួយពុកស្នើចង់ភ្ជាប់សាច់ឈាមរវាងគ្រួសារយើងទាំងពីរផង ប៉ុន្តែពុកក៏មិនបានឆ្លើយឲ្យជាក់លាក់ថាយ៉ាងម៉េចដែរ ។

ថ្ងៃមួយ យាយអ៊ូ មកសុំផ្ទះសំណាក់ ពីរ-បីអាទិត្យ ដើម្បីងាយបញ្ចុះបញ្ចូល ពុក-ម៉ែ ឲ្យបាក់ចិត្តទៅលើ នុន ពីព្រោះគ្រួសារនេះបានចំណាយលុយជួយគាត់អស់ច្រើនណាស់ ដើម្បីសំរេចការឲ្យគេ ។ ម៉ែគាត់ល្ងង់ ហើយចិត្តល្អពេក បណ្ដោយឲ្យគេបង្វិល ទៅឆ្វេង ទៅស្ដាំ បានតាមចិត្ត ទាល់តែពុកបន្ទោសថាគាត់ភ្លើ មិនចេះខ្លាចអ្នកជិតខាងគេពេបជ្រាយថា ឯងដឹកញីបន្ស៊ីឈ្មោលសោះតែម្ដង ប្រយ័ត្នតែរឿងនេះលេចឮទៅដល់ហ្លួង ច្បាស់ជាកើតរឿងរ៉ាវធំមិនខាន ។

បើនិយាយដោយពិត នុរ វាមានលក្ខណៈគួរឲ្យខ្ញុំមិនចូលចិត្តច្រើនជាង នុន គឺវាចេះផឹកស្រា, ចិត្តកាចឆេវឆាវ ហើយស្អប់បំផុតត្រង់វាមានគំនិតខ្វងស៊ីលើពួកម៉ាកឯង ។ ថ្ងៃមួយ ខ្ញុំជួបវាដោយចៃដន្យ ឃើញកំពុងអង្គុយជជែកអែប្រមែជាមួយមិត្តភក្តិពុកជាច្រើនទៀត ខ្ញុំក៏ធុះជៀលថាឲ្យវាច្រើនណាស់ ប៉ុន្តែវានៅតែធ្វើមុខ

ផ្តែ មិនព្រមដឹងខ្លួនសោះ ។

ពុក និង ម៉ែ បានជំនុំគ្នាស្រេចបាច់រួចហើយថា ទោះជាយ៉ាងណាក៏គាត់មិនព្រមលើកខ្ញុំឲ្យទៅ នុរ ដែរ ប៉ុន្តែគាត់មិនហ៊ានប្រាប់វាឲ្យដឹងខ្លួនឡើយ ព្រោះថាតួប្រជែងមានដល់ទៅពីរនាក់ បើមួយដឹងខ្លួនថា គេមិនចូលចិត្តនឹងខ្លួនហើយ វាអាចមានការគុំគួនធ្វើទុក្ខបុកម្នេញគ្រួសារយើងនៅថ្ងៃក្រោយ ។ ខ្ញុំសម្គាល់ឃើញថា ពុកពេញចិត្តនឹង នុន មែន ប៉ុន្តែគាត់ចេះលាក់ទុក ពុំងាយបញ្ចេញឲ្យម្ចាស់ខ្លួនវាដឹងទេ ដើម្បីកុំឲ្យវាបានចិត្ត ។

រឿងណាដែលមានជាប់ទាក់ទងមកក្នុងរឿងនេះ ម៉ែនិយាយប្រាប់ខ្ញុំទាំងអស់ គ្មានលាក់ប៉ុនសរសៃសក់ឡើយ ហើយសំដីព្រោកប្រាជ្ញរបស់ យាយអ៊ួ អាចឲ្យខ្ញុំដឹងអស់សព្វគន្លឹកកន្លៀត ព្រមទាំងអាចឲ្យខ្ញុំរិះរកមធ្យោបាយសម្រាប់ការពារខ្លួនជាមុនបានផង ។ យាយអ៊ួ បន្ទោសខ្ញុំថា មិនគួរធ្វើឲ្យប្រុសៗរងទុក្ខវេទនា ចំបែងចិត្តអញ្ចឹងសោះ ខ្លាចតទៅថ្ងៃមុខគេតាមព្យាបាទដើម្បីសងសឹកនឹងខ្ញុំវិញ ប៉ុន្តែខ្ញុំបានសើកសៀតសំដីឲ្យគាត់វិញធ្ងន់ៗ ទាល់តែគាត់សើចលែងសម ។

ថ្ងៃមួយ ម៉ែចេញទៅផ្សារស្ងួន តាំងពីព្រលឹមស្រាងៗ ពាក់អាវហែក ស្លៀកសំពត់ចាស់ ព្រមទាំងមានកណ្ដៀតកញ្ច្រែងមួយយ៉ាងខ្ជីខ្ជាបំផុត ដោយអាងថាជិតផ្ទះឆាប់ត្រឡប់មកវិញ ។ ទៅដល់កណ្ដាលផ្លូវក្បែរដើមពោធិ៍ ស្រាប់តែជួបវាក់គ្នានឹងពួកកម្លោះមួយហ្វូងជិះកង់មក, គេនាំគ្នាចុះពីលើកង់ ដោះមួកហើយលើកដៃសំពះ :

– មីងអញ្ជើញទៅណាហ្នឹង ? (នុន, នុរ និង មិត្តភក្តិគេទាំងអស់ ឧទានព្រមគ្នា) ។

ម៉ែអៀនខ្លួនរៀបឬកមិនត្រូវនៅចំមុខសេចក្ដីគួរសម នៃ ពួកកូនអ្នកមានទាំងនេះ ណាមួយគាត់ស្លៀកពាក់មិនសូវសមរម្យផង ដែលជាហេតុធ្វើឲ្យអ្នកដើរទៅតាមផ្លូវគេបែរមើលគ្រប់គ្នា ។ ដើម្បីគេចចេញពីពួកនេះ ម៉ែប្រាប់ថាឲ្យពួកវាមកផ្ទះមុនចុះ ហើយគាត់បង្អួសមកផ្សារតែម្នាក់ឯង ។ ម៉ែខំពីរនៅផ្សារយូរណាស់ ដើម្បីឲ្យ នុន, នុរ វាត្រឡប់ចេញពីផ្ទះយើងទៅវិញ ប៉ុន្តែគាត់គន់គូរខុស មកដល់មាត់ទ្វាររបងស្រាប់តែឃើញកង់ផ្អែកត្រៀបត្រា នៅមាត់ជណ្ដើរ និង សរសរផ្ទះ គាត់ហួសចិត្តមិនចេញស្តី សសៀរដើរលបៗមិនឲ្យគេឃើញ យកកញ្ច្រែងត្រីទៅទុកនៅឯចង្ក្រានបាយ ។ ខ្ញុំពួននៅក្នុងបន្ទប់ខាងក្រោយជាមួយហ៊ុន លបមើលតាមប្រហោង ឃើញម៉ែលើកដៃលើកជើងឲ្យសញ្ញាទៅ ពុក ដែលកំពុងអង្គុយកណ្ដាលហ្វូងពួកក្មេងកម្លោះ ។ គាត់និយាយកំបុតៗ បញ្ចេញទឹកមុខមិនសប្បាយចិត្ត ដើម្បីបង្ហាញឲ្យភ្ញៀវជម្លើយឃើញថាគាត់ធុញទ្រាន់ណាស់ ។ ពុកមើលយល់ទាំងអស់នូវកាយវិការ ម៉ែ ដែលមានន័យថាឲ្យបណ្ដេញភ្ញៀវចេញទៅ ដើម្បីឲ្យគាត់មានពេល រៀបចំផ្ទះសម្ប៉ែង ដាំបាយទឹកផង ព្រោះថ្ងៃកាន់តែខ្ពស់ណាស់ទៅហើយ ប៉ុន្តែមើលទំនងហាក់ដូចជាគ្មាននរណាមួយប្រុងងើបសោះ ។ ទ្រាំមិនបាន ពុកក៏សុំទោសភ្ញៀវថា គាត់រវល់ជួសជុលសសរផ្ទះបន្តិច ហើយងើបឡើងទាញយកពូថៅដើរទៅក្រោមផ្ទះបាត់ គាត់សំពងសសរខ្លាំងៗ... រញ្ជួយញ័រតួផ្ទះ ធ្លាក់កំទេចស្លឹកព្រោងព្រាតមកលើក្បាលកម្លោះមុខក្រាស់ ។ ទាល់តែធ្វើអញ្ចឹងទើបពួកវាសំពះលាចេញទៅ ។ មានអាខ្លះលួចសើចសប្បាយទៀតផង ។

ខ្ញុំចេញពីកន្លែងពួនមកវិញ ជេរប្រទេចពួកនោះច្រើនណាស់ ហើយម៉ែក៏ប្រញាប់ប្រញាល់លាងអង្ករដាក់ដាំបាយដែរ ។ ពុកកាន់ពូថៅដើរឡើងមកលើផ្ទះវិញ និយាយរអ៊ូថា :

– ពួកអាច្រឡឹមអស់ហ្នឹង វាចង់បង្អត់បាយកូនស្រីអញដល់ថ្ងៃត្រង់ម្ដង ! ។

ចាប់តាំងពីថ្ងៃនោះមក មិនសូវឃើញ នុន មកលេងញឹកញាប់ដូចមុនទេ ។ យាយអ៊ួ និយាយប្រាប់ម៉ែថា គាត់តែងសង្កេតឃើញ ម្ចាស់កណ្ដៀន មកដុំខ្លួយក្បែរផ្ទះរាល់យប់ គឺប្រាកដជាមកឱតខ្ញុំហើយ ហើយគាត់ធ្វើ



ឫកជាស្អប់ម្ចាស់ហ្នឹងខ្លាំងណាស់ ។

ចំណែកអាផ្ដែ នុរវិញ មុខក្រាស់រកគ្មាន គេធ្វើប៉ុណ្ណឹងហើយនៅមិនដឹងខ្លួនទៀត វានៅតែមកគួរសមជាមួយម៉ែជានិច្ច ព្រោះវាដឹងថាម៉ែស្លូត ។ វាបញ្ចុះបញ្ចូលពន្យល់ម៉ែថា :

– មីងកុំទុកចិត្ត អានុន ពេក ព្រោះវាជាមនុស្សមានពុតត្បុតអាក្រក់ ហើយវាមិនមែនស្រឡាញ់មីងដោយស្មោះទេ ។

ក្រោយមកខ្ញុំបានដឹងថា នុន មានប្រពន្ធមួយឈ្មោះ ខ្វៃន ដែលវាធ្លាប់យកមកនៅលើផ្ទះជាមួយគ្នាអស់រយៈពេលជាច្រើនថ្ងៃ ។ ចាប់តាំងពីពេលនោះមក ពុកសម្រេចថានឹងមិនលើកខ្ញុំឲ្យទៅ នុន ឬ នុរ អ្វីទាំងអស់ ព្រោះពីរនាក់នេះវាគ្មាននរណាគ្រាន់បើជាងនរណាទេ ។ ខ្ញុំបណ្ដេញ យាយអ៊ួ ឲ្យចុះចេញពីផ្ទះ ហើយថែមទាំងពោលពាក្យបញ្ឈឺឲ្យគាត់ទៅនៅជាមួយអាផ្ដែខ្មៅ នុន នោះចុះ ។

ក្រោយបន្តិចមក លេចឃើញ នុន មកដើរក្រឡឹងផ្ទះខ្ញុំរាល់យប់ ប៉ុន្តែយប់មួយនោះងងឹតចាក់ភ្នែកមិនយល់ ស្រាប់តែមានមនុស្សមិនស្គាល់មុខមួយក្រុមព្រួតគ្នាវាយវាបែកក្បាល ហើយរត់គេចខ្លួនបាត់ទៅ ។ ខ្ញុំយល់ច្បាស់ណាស់ ប្រាកដជា អានុរ តែម្ដង ដែលជួលអ្នកលេងឲ្យមកវាយពួកម៉ាកឯង ប៉ុន្តែអានេះប្រសប់ធ្វើដូចជាមិនដឹងអ្វីទាំងអស់ ។

រឿងរ៉ាវវាធ្ងន់ដល់ប៉ុណ្ណេះហើយ ពុកព្រួយបារម្ភណាស់ខ្លាចក្រែងតែគេសងសឹកមកលើខ្លួនខ្ញុំទៀត ។ ស្ទើរតែរាល់យប់ មនុស្សប្រុសទាំងហ្វូងៗ មកប្រជុំគ្នាអ៊ូអែរក្បែរផ្ទះខ្ញុំ ទាល់តែពុកកាន់ពូថៅចុះទៅសម្លុតទើបវាបំបែកគ្នាដើរចេញ ។ ម្ដងនោះ វាលបគប់ដុំថ្មមកលើដំបូលផ្ទះយើងទៀតផង ។ រាល់យប់ ពុកមិនដែលហ៊ានសម្រាន្តទេ ។ គាត់អង្គុយយាមទើសភ្លឺ ហើយគាត់ឲ្យខ្ញុំឡើងដេកលើក្ដារងឿក្រាស់ ដោយខ្លាចក្រែងមានគេលបចាក់ពីក្រោមមកតាមប្រហោងក្ដារ ។

នុន ចង់សម្លាប់ នុរ ឲ្យបាន ដើម្បីសងសឹក ប៉ុន្តែចិត្តវាមិនសូវសឿងដូចមាត់សោះ ។ ជាសំណាងល្អស្ថានការណ៍ធ្ងន់ធ្ងរនេះបានប្រែជាធូរស្រាលឡើងវិញ ដោយលោក អ៊ុម ជាមេទាហាន ត្រូវហ្លួងត្រាស់បង្គាប់ឲ្យទៅការពារសន្តិសុខឯ ខេត្តបាត់ដំបង ដែលទើបនឹងយកបានពីសៀមមកវិញ ហើយគាត់ក៏យក នុន និង នុរ ទាំងពីរនាក់ឲ្យទៅជាមួយ សម្រាប់ធ្វើជាស្មៀន ។

មុនពេលចេញដំណើរទៅ នុន បានមកជំរាបលា ពុក ធ្វើមុខគួរឲ្យអាណិត បង្ហាញឲ្យឃើញថា វាមិនទាន់អស់សង្ឃឹមទេ ។ វាប្រាប់ ពុក ថា ឲ្យប្រយ័ត្ន កុំទុកចិត្ត អានុរ ពេក សំបុត្រផ្ញើមកពី បាត់ដំបង ប្រសិនបើគ្មានវាស៊ីញ៉េ គឺប្រាកដជា អានុរ ផ្ញើមកក្លែងក្លាយហើយ ។ ប៉ុន្តែពុកនិយាយប្រាប់ខ្ញុំថា គាត់បានទៅរកលោកទាយ ខែ ឆ្នាំ នុន និង ខ្ញុំ ឃើញថា វាមិនមែនជាគូព្រេងខ្ញុំទេ ថ្ងៃក្រោយខ្ញុំត្រូវមានប្ដីជាជនបរទេស និងឲ្យពុកប្រយ័ត្នខ្លួនមែនទែន ព្រោះគាត់ជិតដល់ពេលអស់អាយុហើយ ។ ពេលនេះពុកកំពុងឈឺស្រាប់ផងដល់ឮថាគាត់ជិតស្លាប់អញ្ចឹង ខ្ញុំរឹតតែព្រួយចិត្តទ្វេមួយជាពីរ ។

មើលទៅពុក គ្មានឃើញបានធូរស្រាលបន្តិចសោះ សមនឹងកើតមានរឿងពិបាកចិត្តផង គាត់ក៏កាន់តែដាបទៅ ។ ទ្រូងក្ដៅងំដូចគេបំពក់ភ្លើង ភ្នកធ្លាក់ឈាមមកទាំងដុំៗ... ម៉ែដូចជាមិនសូវភ័យព្រួយប៉ុន្មានទេ ដែលជាហេតុធ្វើឲ្យខ្ញុំទុកចិត្តស្លុកថា ពុកគង់នឹងជាសះស្បើយមិនខាន ។ ខ្ញុំឆ្ងល់គិតមិនយល់ ហេតុអ្វីបានជាពុកប្រែប្រួលចរិតប្លែកពីមុនខ្លាំងម្ល៉េះ ? ចាប់តាំងពីពេលធ្លាក់ខ្លួនឈឺមក គាត់ប្រែជាសញ្ជប់សញ្ជឹង ហើយឆាប់ខឹងច្រឡោតណាស់ ។ កាលណាមានមនុស្សប្រុសឡើងមកលើផ្ទះ គាត់ធ្វើមុខមាំភ្លាមមួយរំពេច សម្លឹងសម្លក់មើលខ្ញុំសព្វគ្រប់ តាំងពី សម្លៀកបំពាក់ និង កាយវិការឡើងទៅ ហាក់ដូចជាចាំតែខ្វាមចាប់ទោស

កំហុស។ ម្តងនោះ ភ្ញៀវកំពុងជជែកគ្នាជាមួយពុក ខ្ញុំសម្ងំនៅក្នុងបន្ទប់ពីរនាក់ហ៊ុន ប្រឡែងគ្នាសើចលាន់ឮទៅដល់ក្រៅ លុះភ្ញៀវលាទៅវិញមិនទាន់ចេញផុតរបងផង គាត់ក៏ចូលមកក្នុងបន្ទប់ បើកភ្នែកធំៗហើយនិយាយថា:

~ល្អណាស់ហើយ ស្រីក្រមុំដូចឯង ដែលសើចឲ្យអ្នកក្រៅឮអញ្ចឹងនោះ... ក្រែងម៉ែឯងធ្លាប់ប្រដៅដែរហ្អែថា នៅមុខប្រុសឈ្នោលមិនត្រូវធ្វើឫកអញ្ចឹងទេ ហើយក៏មិនត្រូវធ្វើជាអៀនរត់គេច ចង់ឲ្យគេដើរតាមខ្លួននោះដែរ។ ឯង ចង់ធ្វើឲ្យអញខ្មាស់គេ ចង់ឲ្យគេមើលងាយ ដូចស្រីដើរហ៊ីហាតាមផ្សារអញ្ចឹងហ្អែ។

ខ្ញុំមិនអស់ចិត្តសោះ គ្រាន់តែកំហុសប៉ុណ្ណឹង មិនគួរគាត់ខឹងខ្លាំងដល់ម្លឹងទេ។ ខ្ញុំស្រក់ទឹកភ្នែកច្រោកខឹងញ័រដៃ ក៏គ្រវែងចោលប្រអប់ដែលកាន់នៅដៃ ត្រូវកញ្ចក់ទូបែកខ្ទាយ។ ពុកស្ទុះចូលមកទះស្មារខ្ញុំមួយដៃធាំង! ខ្ញុំងើបឈរនិយាយតឹងសរសៃកទៅរកគាត់វិញ:

~ពុក មិនដែលវាយខ្ញុំទេ មិនដែលស្តីឲ្យខ្ញុំទេ ឥឡូវពុកវាយខ្ញុំ! ពុកជេរខ្ញុំ! ពុកលែងស្រឡាញ់ខ្ញុំហើយឬ? ចាប់តាំងពីថ្ងៃហ្នឹងទៅ ខ្ញុំក៏លែងស្រឡាញ់ពុកឯងដែរ។

ពុកដើរចេញទៅវិញ ទាញទ្វារបិទភ្លាំង មិនចាំស្តាប់ខ្ញុំនិយាយដល់ចប់ឡើយ។ ខ្ញុំខឹងខ្លាំងមែនទែនលែងគិតខុសត្រូវអ្វីទាំងអស់។ ខ្ញុំទាត់បំបែកកញ្ចក់ទូ វាយបំបាក់កៅអី ទាញបណ្តាច់មុង លាន់ឮងគាំងផ្អើលពេញផ្ទះ ដើម្បីសងសឹកនឹងការដែលពុកវាយខ្ញុំ។ បន្ទាប់មក ខ្ញុំគិតថានឹងរត់ទៅនៅភាំងវិញឲ្យបាត់លែងឲ្យម៉ែឪឃើញមុខតែម្តង។ ខ្ញុំបើកហិបឈើប្រមូលយក គ្រឿងអលង្ការ សំពត់អាវ ផាហ៊ី និង របស់ប្រើប្រាស់ផ្ទាល់ខ្លួនទាំងអស់ វេចក្នុងសារុងចាស់មួយ... ប៉ុន្តែខ្ញុំគ្មានលុយមួយសេនសោះ ព្រោះប្រាក់ខែភាំងនោះ ត្រូវគេកាត់យកអស់រាល់ខែ នៅយូរទៅមុខទៀតណាស់ ទំរាំផុតលុយជំពាក់, ធ្វើម្តេចខ្ញុំនឹងរត់ទៅកើត បើអត់មានលុយសោះយ៉ាងនេះ? ខ្ញុំបែកគំនិតរើកកាយថតតុដែលចំណាំឃើញគាត់អង្គុយធ្វើការ រកឃើញប្រអប់ក្រដាសមួយដែលមានដាក់ ប្រាក់កាក់បួន និង លុយបួនរៀល។ ពេលនេះទើបខ្ញុំដឹងច្បាស់ថា ពុកឥតមានសល់លុយច្រើនដូចដែលខ្ញុំធ្លាប់ស្មាននោះទេ។ តើគាត់បានប្រាក់ពីណា សម្រាប់ចិញ្ចឹមខ្ញុំ, សម្រាប់ទិញរបស់ប្រើប្រាស់, ថ្នាំជក់, ទឹកអប់ ដើម្បីបំពេញចិត្តខ្ញុំរាល់ថ្ងៃ។ ខ្ញុំស្រមៃឃើញយ៉ាងច្បាស់នូវសប្បុរសធម៌ដ៏ធំធេងដែលពុកបានធ្វើចំពោះខ្ញុំ ហើយដែលពីមុនមកខ្ញុំពុំធ្លាប់បានដឹងទាល់តែសោះ។ ខ្ញុំនឹកអាណិតគាត់ខ្លោចចិត្ត សុខចិត្តដាក់លុយទៅក្នុងប្រអប់វិញ គ្រវាត់បង្វេចទៅកៀនជញ្ជាំង ហើយប្រះដេកទៅលើគ្រែ យំខ្សឹកខ្សួលនឹកស្តាយមិនគួរធ្វើឲ្យ ឪពុកម្តាយ ពិបាកចិត្តដោយសារខ្លួន។

ល្ងាចនោះ ពូប៉ុល ធ្វើដំណើរពី ព្រែកថ្មី នាំដំណឹងដ៏ក្រៀមក្រំមកប្រាប់ថា ជីតាខ្ញុំឈ្មោះ ស្វាយ នោះស្លាប់ទៅហើយ ដែលជាហេតុធ្វើឲ្យយើងភ្លេចអស់រឿងទាស់ទែងគ្នាក្នុងគ្រួសារ ហើយសំរេចថា ព្រឹកស្អែកនេះ យើងនឹងទៅធ្វើបុណ្យសព តាស្វាយ ទាំងអស់គ្នា ........................................................ ។

យាយកែម អង្គុយធ្វើមុខស្រពោនត្រមង់ត្រមោចតែម្នាក់ឯង ឥតរវល់យកចិត្តទុកដាក់នឹង បងប្អូនញាតិមិត្តដែលមកជួបជុំគ្នាពេញផ្ទះឡើយ។ ឃើញយើងទៅដល់ គាត់ញញឹមស្ងួត ហើយនាំយើងដើរតម្រង់ទៅរកចេតិយដ៏កល់ធាតុគ្រួសារ ដែលគេទើបនឹងយកសំណល់ នៃ សាកសពប្តីគាត់មកទុកនៅទីនេះដែរ។ ខ្ញុំយំអណ្តឺតអណ្តកបណ្តើរ អុជធូបដោតនៅមុខចេតិយបណ្តើរ រួចឡើងទៅលើផ្ទះដើម្បីស្តាប់យាយគាត់និយាយរៀបរាប់ប្រាប់ពីបុព្វហេតុ នៃ មរណភាពរបស់តាស្វាយ។

យើងមកដល់យឺតពេលបន្តិច មិនបានឃើញមុខខ្មោចតាទេ ព្រោះគេបូជាហើយស្រេចតាំងពីម្សិលមិញម្ល៉េះ។ យាយកែម ពឹងគេឲ្យជួយរុះរានហាលផ្ទះ ដើម្បីយកគ្រឿងឈើទៅប្រគេនលោកវត្តកោះអន្លង់ចិន



សម្រាប់ជាកុសលបញ្ជូនទៅឲ្យខ្មោចប្តីគាត់។ យើងសម្រេចចិត្តថានឹងនៅកំដរយាយ ពីរ-បីថ្ងៃ ចាំគាត់អន់ព្រួយចិត្តសិមត្រឡប់មកវិញ។ មរណភាព នៃ ជីតាខ្ញុំ ធ្វើអ្វីៗប្រែប្រួលទាំងអស់ ទីធ្លាដែលធ្លាប់តែស្អាតរលីងនោះ ក៏ប្រែជាមានស្មៅដុះទ្រុបទ្រុល គោក្របីត្រូវគេលែងចោលឲ្យដើរអារ៉ាសែពាសវាលពាសកាល មាន់ដើរកកាយដីគ្មានភ័យព្រួយឡើយ ពីព្រោះគ្មាននរណាមើលថែទាំសំអាតអ្វីទៀតទេ។

ពេលយប់ខ្ញុំដេកជាមួយយាយ ដើម្បីកំដរគាត់កុំឲ្យស្ងាត់ពេក។ ព្រឹកមួយនោះ ខ្ញុំងើបពីដេកឡើងតាំងពីព្រលឹមស្រាងៗដឹងថា ភ្លៅទាំងសង្ខាងត្រជាក់ស្រឹតហាក់ដូចជាទទឹកទឹក លុះស្ទាបមើលឃើញសុទ្ធតែឈាម ខ្ញុំភ័យស្លុតនឹកស្មានថាសត្វអ្វីខាំ ក៏ប្រញាប់ដាស់យាយឲ្យភ្ញាក់ឡើង ដើម្បីប្រាប់គាត់ពីការភិតភ័យរបស់ខ្ញុំ។ យាយបន្ទោសខ្ញុំថាជាក្មេងភ្លើ ហើយគាត់ប្រាប់ឲ្យខ្ញុំនៅស្ងៀមឈប់និយាយ ពីព្រោះខ្ញុំធំពេញក្រមុំហើយ ហើយក៏ដល់ពេលត្រូវ "ចូលម្លប់" ដែរ។ គ្រាន់តែប្រុសៗចុះអស់ពីលើផ្ទះភ្លាម យាយយករឿងនេះទៅប្រាប់ ម៉ែ និង មីង ខ្ញុំ ឲ្យបានដឹងគ្រប់គ្នា រួចបន្ទាប់មកគេលើកកន្លែងខ្ញុំដេកទៅដាក់ក្នុងបន្ទប់ឯខាងក្រោយ ឆ្ងាយពីភ្នែកអ្នកផង។ គេទូន្មានឲ្យខ្ញុំតាំងចិត្តស្លូតបូត កុំឲ្យខ្ញុំចេញពីបន្ទប់នេះក្នុងរយៈពេលមួយខែ កុំឲ្យបរិភោគត្រី សាច់ និង អ្វីៗទាំងអស់ដែលខ្ញុំធ្លាប់ចូលចិត្តកាលពីមុន។ មានតែស្រីៗទេដែលអាចចេញចូលកន្លែងខ្ញុំបាន ប៊ុន និង ហ៊ុន ជាបងប្អូនជីដូនមួយខ្ញុំនោះ មានភារៈត្រូវលើកយក ម្ហូបម្ហា និង ទឹកសម្រាប់ងូត មកឲ្យខ្ញុំដល់ក្នុងបន្ទប់តែម្តង។ ខ្ញុំធ្លាក់ខ្លួនឈឺស្រៀវស្រាញ ពុកទៅរកគ្រូមើលឃើញថាត្រូវខ្មោចធ្វើ គាត់រៀបចំធ្វើ ពែ យកទៅសែនថ្វាយអ្នកតាដើមស្រឡៅ ដែលល្បីថាមានមហិទ្ធិឫទ្ធិខ្លាំងពូកែណាស់។

រស់នៅក្នុងកន្លែងឃុំឃាំងដូចមនុស្សជាប់ទោសអញ្ចឹង ពេលវេលាហាក់ដូចជាធ្វើដំណើរទៅមុខយឺតខុសធម្មតាគួរឲ្យធុញទ្រាន់ស្ទើរប្រេះទ្រូងស្លាប់ ហើយត្រណាមពិបាកទ្រាំជាងគេ គឺការហាមឃាត់មិនឲ្យបរិភោគត្រីសាច់នេះឯង ម្ល៉ោះហើយជួនកាលខ្ញុំចូលទៅក្នុងចង្ក្រានបាយ លួចបានត្រីអាំងយកមកបរិភោគមិនឲ្យនរណាដឹងឡើយ។

ទីបំផុត ខ្ញុំក៏បានរួចទុក្ខទោសចេញពីម្លប់មកវិញ។ ស្ត្រីក្រមុំក្នុងភូមិនាំគ្នាផ្អើលមកមើលខ្ញុំ ហើយសរសើរថាខ្ញុំស្អាតណាស់ ដែលជាហេតុធ្វើឲ្យខ្ញុំអៀនខ្លួនមុខក្រហម រកហាមាត់និយាយថាម៉េចមិនកើត។ គេទូន្មានខ្ញុំជាថ្មីឲ្យបោះបង់ចោលនូវទម្លាប់ឆ្នាសកាចសាហាវ ដើម្បីធ្វើខ្លួនឲ្យបានក្លាយទៅជាស្ត្រីថ្លៃថ្នូរត្រឹមត្រូវនៅពេលអនាគត។ រាល់យប់មុនពេលចូលដំណេក យាយ និង ម៉ែ អុជចង្កៀងបំភ្លឺមើលសាស្ត្រា ច្បាប់ស្រី ច្បាប់កូនចៅ និង ច្បាប់ផ្សេងៗ ឲ្យខ្ញុំស្តាប់ ប៉ុន្តែខ្ញុំឥតរវល់យកចិត្តទុកដាក់ស្តាប់ឡើយ ព្រោះវាគ្មានកន្លែងណាគួរឲ្យពិរោះជក់ចិត្តទាល់តែសោះ។

ម៉ែ ធ្វើដំណើរមកភ្នំពេញបាត់ពីរថ្ងៃ ដើម្បីមកទូលម្ចាស់ក្សត្រីកុំឲ្យលោកទន្ទឹងខ្លាំងពេក ដោយភរលោកថាខ្ញុំឈឺធ្ងន់ណាស់ ហើយពេលត្រឡប់មកវិញ គាត់ថែមទាំងខ្ចី គ្រឿងអលង្ការ និង សំពត់អាវរបាំមួយសម្រាប់មកផ្ញើខ្ញុំផង។ ប៉ុន្តែពុកមានគំនិតមួយ គាត់ទៅប្រាប់តាចាស់ម្នាក់ជាអ្នកចូលរូបអារក្សថា ឲ្យខ្ញុំទៅរាំថ្វាយអ្នកតាដើមស្រឡៅម្តង ព្រោះលោកធ្លាប់បានជួយខ្ញុំឲ្យសះស្បើយជាជម្ងឺ។ អ្នកស្រុកសប្បាយចិត្តណាស់ ឮថាពួកល្ខោនហ្លួងមករាំ គេស្រុះគ្នាសង់រោង បោសសំអាតទីដីជិតខ្ទមអ្នកតា ព្រមទាំងរៀបចំសែនព្រេនតាមទំនៀមទម្លាប់។

តូបអ្នកតា គឺជាខ្ទមតូចមួយសង់បន្តុបលើសសរបួននៅកណ្តាលព្រៃ ដែលគេអាចដើរចូលមកបានតាមផ្លូវតែមួយគត់ កាត់កណ្តាលចំការចេក។ អ្នកភូមិ ព្រែកថ្មី និង ឫស្សីស្រុក នាំគ្នាមកជួបជុំអ៊ូអរពេញព្រៃ លុះឃើញ ពុកម៉ែ និង បងប្អូនខ្ញុំ ដើរហែហមនាំខ្ញុំទៅដល់ គេគយគន់មើលខ្ញុំ ស្លៀកពាក់ជាអ្នករបាំ ពាក់គ្រឿង

អលង្ការ ហើយជញ្ជក់មាត់សរសើរគ្រប់គ្នា ។ នៅមុខខ្ទមអ្នកតា គេកាប់ឈើសង់ធ្វើជារោងរបាំក្បែរដីជំរូក ។ តារូបអារក្សអង្គុយលើកន្ទេល ដៃសំពះ ភ្នែកបិទមមីរ... ខ្ញុំរើកគេរើកឯងចូលទៅដល់មុខ ឃើញគេតម្រៀបគ្រឿងសំណែនច្រើនត្រៀបត្រាពីមុខខ្ទមអ្នកតា ដោយមានដុតធូបហុយទ្រលោម ។ ពួកក្មេងកម្លោះគេស្ម័គ្រចិត្តយកគ្រឿងភ្លេង មកលេងកំដរពិធីលៀងអារក្សនេះ ដោយពុំយកលុយកាក់ឡើយ ។

រូបអារក្សធ្វើមាត់ជិបអូចៗសូត្រមន្តអាគម រាងកាយញាក់ទទ្រើកដូចមនុស្សគ្រុនរងា ។ បន្ទាប់មកភ្លេងក៏ចាប់លេងបទឆាបញ្ចុះ រគេតរគួតគ្មានត្រូវបែបបទបន្តិចសោះ ប៉ុន្តែម៉ែប្រានខ្លាំងពេក ខ្ញុំក៏ចេញរាំទាំងទើសទាល់ ។ ស្រាប់រូបអារក្សស្រែករាស ! ខ្ញុំភ្ញាក់ស្ទើរលោះព្រលឹង ឈរទ្រឹងភ្លេចរាំមួយសន្ទុះធំ... គឺអ្នកតាចូលមកសណ្ឋិតក្នុងខ្លួនតានេះហើយ ។ ភ្លេងលេងរឹតតែញាប់ឡើងៗ ហើយខ្ញុំក៏រឹតតែប្រយ័ត្នប្រយែងខ្លាចខុសណាស់ដែរ ព្រោះតានេះបើកភ្នែកក្រហមព្លែសម្លក់ខ្ញុំឥតប៉ប្រិចសោះ ព្រមទាំងលោតចាក់ក្ដុកក្រមាច់ក្រមើមដូចមនុស្សឆ្កួត ។ មនុស្សដែលឈរមើលទាំងប៉ុន្មាន លើកដៃសំពះសុំស្រណុកសុខសប្បាយ អារក្សនោះក៏និយាយងើរៗថា :

~ មិនអីទេ, កុំភ័យយើងជួយថែរក្សាហើយ !

មួយសន្ទុះក្រោយមក តានេះធ្វើមីងមាំងដូចមនុស្សទើបនឹងងើបពីដេក ហើយនិយាយថា "គេចេញទៅវិញហើយ" ។

លុះចប់សព្វគ្រប់ហើយ យើងក៏លា យាយកែមត្រឡប់មកភ្នំពេញវិញ ។ នៅពេលដើរពីផ្ទះពុកចុះទូកពុកចង្អុលប្រាប់ដីមានដាំដើមស្វាយ ដែលជាចំណែកមត៌កខ្មោចលោកអ៊ុំមហាសេនា ប្រគល់ឲ្យខ្ញុំ ។ គាត់គិតថា កាលណាខ្ញុំឈប់នៅវាំង គាត់នឹងមកសង់ផ្ទះនៅទីនេះវិញ ។

ពូប៉ុល ចែវទូកជូនរហូតមកដល់ភ្នំពេញ ប៉ុន្តែយើងដើរមិនទាន់ដល់ផ្ទះផង ស្រាប់តែជួបនឹងស្រីម៉ាឡាយូម្នាក់ខ្វាក់ភ្នែកទាំងសង្ខាង នៅក្មេងនៅឡើយ ដែលពុកធ្លាប់ជួបនៅជ្រោយចង្វាម្ដង ហើយដែលធ្លាប់ល្បីខាងធ្វើស្នេហ៍ជូនលោកស្រីនៅភ្នំពេញ ។ គាត់ស្ទាបខ្ញុំ ហើយរៀបរាប់រូបរាងខ្ញុំគ្មានខុសត្រង់ណាបន្តិចសោះ ដែលជាការគួរឲ្យឆ្ងល់ពេកណាស់ ។ បណ្ដោយឲ្យគាត់ធ្វើអីតាមចិត្តចង់លមើល តើគាត់ទាយត្រូវឬមិនត្រូវ ។ គាត់និយាយប្រាប់ខ្ញុំថា ស្រីនៅក្នុងវាំងដែលបានគាប់ចិត្តនឹងហ្លួង ក៏ដោយសារបានស្នេហ៍ពីគាត់យកទៅប្រើប្រាស់, ម៉មនូ ដ៏ល្បីល្បាញ ដែលប្រែជាត្រូវហ្លួងស្អប់វិញនោះ ក៏ព្រោះតែ ម៉មនូ ពុំបានឲ្យលុយគាត់ប្រាំរយរៀល ដូចពាក្យសន្យា ។

មីងខ្វាក់បង្គាប់ឲ្យខ្ញុំអង្គុយចុះទៅលើជុំថ្មមានក្រាលកន្ទេលពីលើ យកអំបោះឆៅមកចងកដៃខ្ញុំ ដើម្បីការពារកុំឲ្យខ្មោចព្រាយបៀតបៀនបាន ហើយគាត់អុជ ទៀន ធូប ដាក់លើជើងពាន ព្រមទាំងសូត្រមន្តអាគមខ្សឹបៗ រួចទើបនិយាយមកកាន់ខ្ញុំថា :

~ អ្នកមាន់សត្រូវច្រើនណាស់ ចូរប្រយ័ត្នខ្លួនឲ្យមែនទែន គឺពួក ម៉មយុន នៅក្នុងវាំង គេចង់ឈ្នានីសអ្នកគ្រប់គ្នា ។

គាត់ប្រគល់ ទឹកអប់ និង ម្សៅ ឲ្យខ្ញុំ ព្រមទាំងផ្ដាំថា ចាំដល់វាំងសឹមប្រើ ដើម្បីឲ្យគេអាណិតស្រឡាញ់ ។

ខ្ញុំរៀបចំខ្លួនហៀបនឹងត្រឡប់ទៅវាំងវិញ ស្រាប់តែលេចឃើញ យាយអក ម្នាក់ ដែលម្ចាស់ក្សត្រីបញ្ជូនឲ្យមកមើលខ្ញុំតាមបញ្ជាហ្លួង ។ យាយនេះខ្ញុំស្គាល់គាត់ច្បាស់ណាស់ ហើយនៅពេលឃើញខ្ញុំ គាត់ហាក់ដូចជាសប្បាយរីករាយរកអ្វីមកប្រៀបឲ្យស្មើពុំបាន ។ គាត់អង្គុយលើកន្ទេលជិតខ្ញុំ ហៅខ្ញុំសុទ្ធតែកូន, គាត់លូកដៃអង្អែលជង្គង់ខ្ញុំ, អង្អែលស្មា, លូកស្ទាបរហូតដល់ពោះ, ស្រាប់តែភ្ញាក់ភ្ញាត់មាត់ :



~ កូនអើយ ! មីណាមាត់អាក្រក់វាទៅទូលហ្លួងថា កូនឯងផើម !

យើងស្រឡាំងកាំងគ្រប់គ្នា ទាល់តែយាយនេះនិយាយពន្យល់សព្វគ្រប់ទើបបាត់ឆ្ងល់ បែរជានឹកឃើញហួសចិត្តចង់សើចទៅវិញ គឺមានលេចឮសំដីទៅដល់ត្រចៀកហ្លួងថា ការដែលបាត់ខ្ញុំយូរ មិនឃើញត្រឡប់ទៅវាំងវិញយ៉ាងនេះព្រោះខ្ញុំផើម ចង់លាក់មិនឲ្យគេដឹង ។ រឿងនេះវាកើតឡើងដោយសារតែមានប្រុសកម្លោះចេះតែឈ្លួចឡើងចុះផ្ទះខ្ញុំរាល់ថ្ងៃ ប៉ុន្តែហ្លួងមិនទាន់ជឿ ទើបប្រើគេឲ្យមកមើល ឃើញថាខ្ញុំឥតមានកំហុសដូចគេថាទេ ឲ្យនាំខ្ញុំត្រឡប់ទៅវាំងវិញ ។

♥ ♥

♥

## អ្នកបំរើ




Servantes

ខ្ញុំលាពុកនិងម៉ែ ហើយឡើងជិះរទេះជាមួយយាយអក៍ ដោយយកហ៊ុនទៅតាមជាមួយផង។ មួយសន្ទុះក្រោយមក យើងក៏បានមកដល់ទ្វារព្រលប់នៃ រាជវាំង ដែលផុតពីនេះទៅ គេហាមមិនឲ្យមនុស្សប្រុសចេញចូលជាដាច់ខាត លើកលែងតែ ក្រមវាំងចាស់ៗ និង បោយបំរើហ្លួង។

ខ្ញុំរត់ទៅគាល់ម្ចាស់ក្សត្រី ដើម្បីបង្ហាញខ្លួនឲ្យលោកឃើញថាខ្ញុំមកដល់វិញហើយ លោករាក់ទាក់ទទួលខ្ញុំបន្តិចដែរ។ លោកប្រាប់ខ្ញុំឲ្យរៀបចំខ្លួនដើម្បីចូលវេនគាល់បំរើហ្លួងជាបន្ទាន់ ព្រោះហ្លួងទន្ទឹងផ្លូវខ្ញុំយូរណាស់ហើយ។ ខ្ញុំត្រូវតែចូលទៅកាន់បន្ទប់ដេកមួយភ្លែតជាចាំបាច់ ដើម្បីលុបលាងនិងតែងខ្លួន។ ខ្ញុំងូតទឹក, ផ្លាស់សំពត់, ផ្លាស់អាវ និង លាបទឹកអប់, លាបម្សៅដែលគ្រូម៉ាឡាយូឲ្យមក រួចស្រេចទើបចុះដើរតម្រង់ទៅរកប្រាសាទបាញ់យ៉ុង ទុកហ៊ុនឲ្យនៅបោសច្រាសសំអាតបន្ទប់តែម្នាក់ឯង។

ទៅដល់ក្នុងវាំង មានបោយភ្លីភ្លើម្នាក់ឥតមើលឃើញខ្ញុំទេ ស្មានថាស្ងាត់នៅម្នាក់ឯង វាឆ្ទះកញ្ជក់លើកដៃទំនងដូចជាកាន់ថាស ហើយដើរទៅដើរមក ហាត់រៀនរបៀបលើកទៅថ្វាយហ្លួងឲ្យបានសម គួរឲ្យចង់សើចពេកណាស់។ ខ្ញុំក្អកគ្រហែមពីចម្ងាយដើម្បីឲ្យវាដឹងខ្លួន វាភ្ញាក់ប៉ុនគេចោល ស្រវាចាប់ក្រណាត់មកជូតកញ្ជក់ធ្វើព្រងើយ។ ដល់ឃើញខ្ញុំដើរទៅជិត វាពិតប្រឆ្មៀតខ្លួនជាប់នឹងជញ្ជាំង ដើម្បីទុកផ្លូវឲ្យខ្ញុំដើរ។ លុះខ្ញុំដើរហួសបន្តិច វាកំសៀកខ្លួនរត់គេចទៅណាបាត់។

ខ្ញុំឈប់នៅមុខកញ្ចក់ ឆ្ទះមើលរូបខ្លួនឯងតាំងពីក្បាលរហូតដល់ចុងជើង រួចលូកដៃទៅក្រោយកញ្ចក់ទាញយកក្រដាសចិនពណ៌ក្រហមមកលាបបបូរមាត់ញញឹមស្ញេញស្ញាញតែម្នាក់ឯង ស្រាប់តែលេចឃើញហ្លួងបើកទ្វារ ឈរទ្រឹងស្ងៀមនៅមុខបន្ទប់ ខ្ញុំក៏បែរទៅលុតជង្គង់ថ្វាយបង្គំលោកភ្លាម លោកឈ្ងោកសម្លឹងមើលខ្ញុំយ៉ាងយូរ ទើបប្រាប់ឲ្យខ្ញុំចូលទៅក្នុងបន្ទប់ដែលពេញចង្អៀតទៅដោយអស់អ្នក-អស់នាង ចូលវេនគាល់បំរើ។ លោកនិយាយរបៀបលេងសើចមកកាន់ខ្ញុំថា :

~ នែ ឯងទំនងដូចជាផើមមែនទេ ?

~ ក្រាបទូល ខ្ញុំម្ចាស់អត់ដឹងទេ។

~ ថាឯងកើតដំបៅនោះ តើដំបៅត្រង់ណា ? បង្ហាញអញមើល។

ខ្ញុំទាញលើកសំពត់បន្តិច បង្ហាញស្នាមប្ញសទ្រនិចនៅត្រង់កំភួនជើង។ ហ្លួងសម្លឹងមើលមួយសន្ទុះ ទើបនិយាយបន្តទៅទៀត :

~ ប៉ុណ្ណឹងមិនអីទេ, អញស្មានថាឯងកើតដំបៅរលេះរលួយពេញខ្លួន។

និយាយហើយ លោកឡើងទៅផ្ទំលើគ្រែ បង្គាប់ឲ្យគេរៀបចំខ្សៀអាភៀនថ្វាយ។ ផ្ទិតនៅពីលើក្រឡាបន្ទំបក់ទៅបក់មក សាយភាយក្លិនអាភៀនឈ្ងុយពេញបន្ទប់ដ៏ស្ងាត់ជ្រងំ ហាក់ដូចជាមនុស្សទាំងអស់គ្នានៅក្នុងបន្ទប់នេះ ដេកលក់អស់ទៅហើយ។

ខ្ញុំថយចេញទៅអង្គុយនៅក្រៅបន្ទប់ រង់ចាំក្រែងហ្លួងប្រើឲ្យធ្វើអ្វីទៀត។ មីស៊ុន មីវៃ និង មីស្អាត បានឡើងឋានៈគាប់ព្រះទ័យហ្លួងខ្លាំងណាស់ គេមិនសូវរាក់ទាក់នឹងខ្ញុំទេ ហើយទំនងដូចជាច្រណែនឈ្នានីសនឹងខ្ញុំទៀតផង។ មីស៊ុន ចេញតាមមកនិយាយពេបជ្រាយឲ្យខ្ញុំ :

~ អញកោតឯងណាស់, ហ៊ានបង្ហាញកំភួនជើងឲ្យហ្លួងមើល! ប្រសិនបើអញវិញ អញខ្មាសគេងាប់ហើយ!។

~ ចុះត្រង់ឯងស្រាតសំពត់ឲ្យហ្លួងមើលស្អីៗផ្សេងទៀតនោះ ម៉េចក៏មិនថាខ្មាសគេផង ?

ត្រូវមួយផ្លែ វាបាត់មាត់ដូចគេចុក បើកភ្នែកធំៗសម្លក់ភ្នែរ។

~ មីសារ៉ាម៉ានី! វាទៅពួនឯណាបាត់ទៅហើយ? (ហ្លួងស្រែកសួរពីក្នុងបន្ទប់)។ ខ្ញុំស្ទុះចូលទៅក្នុងបន្ទប់វិញ ព្រមទាំងស្រែកឆ្លើយតប :

~ ព្រះពរម្ចាស់!

~ ណេះ, (ហ្លួងនិយាយ ព្រមទាំងហុចខ្សៀអាភៀនធំមួយឲ្យខ្ញុំ) យកខ្សៀនេះទៅឲ្យ នាងដកម៉ែ គេធ្វើឲ្យស្រួល ហើយចាំយកមកវិញភ្លាមណា!

ខ្ញុំថ្វាយបង្គំរួចចេញទៅវិញ ចាប់ខ្សៀដាក់លីលើស្មា ប៉ុន្តែពេលនោះព្រលប់ធំមេឃងងឹតដាសទៅហើយ ខ្ញុំក៏ហៅក្មេងម្នាក់ឲ្យវាជូនទៅ ពីព្រោះផ្ទះអ្នកដកម៉ែ នៅខាងចុងសួនច្បារឆ្ងាយឯណោះ។ ធ្លើចខ្ញុំយកមកថ្វាយហ្លួងវិញ ស្រាប់តែលោកប្រើឲ្យខ្ញុំយកខ្សៀទីពីរទៅធ្វើទៀត... ហើយខ្សៀទីបី... ហើយខ្សៀទីបួន... រហូតដល់ខ្សៀទីប្រាំ។ ខ្ញុំចេះតែធ្វើតាមបង្គាប់ ដើរទៅដើរមកត្រឡប់ត្រឡិន មិននឹកឃើញហត់ មិនបានចាប់ភ្លឹកឆ្ងល់អ្វីទាំងអស់។ លុះត្រឡប់មកវិញជាលើកទីប្រាំ ខ្ញុំឃើញអស់អ្នក-អស់នាង អង្គុយព័ទ្ធជុំវិញហ្លួងសើចកាច់កាច់សុរងគ្រប់គ្នា មីមួយនោះវាលើកដៃចង្អុលខ្ញុំព្រមទាំងសើចហៀរទឹកភ្នែក មើលទៅហ្លួងអង្គុយលើគ្រែ ដៃលើកខ្សៀអាភៀនសើចសប្បាយជាមួយគេឯងដែរ។ ពេលនេះទើបខ្ញុំភ្ញាក់ខ្លួនដឹងថា ហ្លួងចង់លេងកំប្លែង។ កំប្លែងរបៀបនេះ វាដូចជាជ្រុលបន្តិច! ខ្សៀអត់ខូចសោះ លោកប្រើឲ្យខ្ញុំដើរបួន-ប្រាំត្រឡប់ លេងទទេ ខ្ញុំឈឺចិត្តស្ទើរស្រក់ទឹកភ្នែក ប៉ុន្តែខំទប់ធ្វើជាសើចលេងនឹងគេដែរ។

ក្នុងពេលជាបន្តមកទៀត កាលណាឃើញខ្ញុំ ហ្លួងចេះតែញញឹម ដែលជាហេតុធ្វើឲ្យមិត្តភក្តិទាំងប៉ុន្មានគេរឹតតែច្រណែនឈ្នានីសខ្លាំងឡើងៗជាលំដាប់។ ពេលនេះ បើខ្ញុំចេះឆ្លៀត ខ្ញុំនឹងបានឡើងធ្វើជាតួឯកល្អោនហ្លួងមិនខាន ប៉ុន្តែខ្ញុំដឹងច្បាស់ថា ឋានៈនេះម្ចាស់ក្សត្រីលោករក្សាសម្រាប់តែទុកឲ្យមីសួន ក្មួយសម្លាញ់ចិត្តរបស់លោកម្នាក់ប៉ុណ្ណោះ ម្ល៉ោះហើយខ្ញុំមិនខ្វីរវល់ប្រកួតប្រជែងយកឈ្នះនរណាឡើយ។

ដូច្នេះ ការរស់នៅក្នុងវាំងវាគ្មានប្រយោជន៍អ្វីទៀតទេសម្រាប់រូបខ្ញុំ ហើយដែលខ្ញុំចេះតែទ្រាំនៅតទៅទៀត ក៏ព្រោះតែខ្ញុំធ្លាប់ដឹងជីវភាពនេះ ហើយណាមួយពុក-ម៉ែក៏ចេះតែថាឲ្យខ្ញុំទ្រាំៗសិនទៅដែរ។

ការដែលហ្លួងឧស្សាហ៍លេងសើចជាមួយខ្ញុំ បានធ្វើឲ្យក្រុមអ្នកច្រណែនឈ្នានីសគេសង្ស័យថាខ្ញុំ ប្រើស្នេហ៍ ប្រើមន្តអាគម ទាក់ទាញចិត្តហ្លួងដើម្បីដែងយកឈ្នះអ្នកដែលកំពុងគាប់គួរ។

ថ្ងៃមួយ ខ្ញុំឃើញទាន់មីប៉ុន លបចូលមករុះរើអីវ៉ាន់ក្នុងបន្ទប់ខ្ញុំ យកសំពត់កញ្ចាស់ទៅបោកបក់លើទូ ហើយយកខ្នើយប៉ាក់ជររបស់ខ្ញុំមកជាន់ញីនឹងជើង ដើម្បីបន្សាបស្នេហ៍។ ខ្ញុំធ្វើជា មិនឃើញ មិនដឹង មិនឮអ្វីទាំងអស់ ប៉ុន្តែខ្ញុំសង្កេតឃើញថា ចាប់តាំងពីថ្ងៃនោះមក ហ្លួងមិនសូវលេងសើចនឹងខ្ញុំទៀតឡើយ។

ខ្ញុំហាក់ដូចជារស់នៅត្រមង់ត្រមោចតែម្នាក់ឯងដាច់ឡែកពីគេ, កាហ៊ុន ប្អូនជីដូនមួយខ្ញុំនេះ វានៅក្មេងពេក មិនអាចយល់ទុក្ខធុរៈខ្ញុំបានទេ ។ មិត្តភក្តិទាំងអស់ សុទ្ធសឹងជាមនុស្សអាត្មានិយម គិតតែប្រយោជន៍ផ្ទាល់ខ្លួនម្នាក់ៗ ម្ល៉ោះហើយខ្ញុំជឿថា គ្មាននរណាមួយគេរាប់អានខ្ញុំដោយស្មោះត្រង់ឡើយ ។ ខ្ញុំឃើញពួកគេប្រជុំគ្នាជាក្រុមតូចៗ ជក់អាភៀន លេងបៀ ជជែកគ្នាព្រោកប្រាជ្ញ ពីរឿងប្រុស ពីរឿងរៀបការ, សូម្បីមីក្មេងតូចៗមិនទាន់ដុះដោះនៅឡើយ ក៏វាចំណាប់ណាស់ដែរ ។ បើនិយាយពីដំណាក់ម្ចាស់ក្សត្រីវិញ ខ្ញុំញញើតលែងហ៊ានទៅរៀត ព្រោះកន្លែងនោះនរណាចង់ធ្វើអីក៏បានស្រេចនឹងចិត្ត ហើយបើទុកជាខ្ញុំទៅ ក៏គេមិនសូវរាក់ទាក់រកខ្ញុំប៉ុន្មានដែរ ។ បើនរណាមួយចង់ឲ្យម្ចាស់ក្សត្រីជួយ ទាល់តែហ៊ានឲ្យលោកចំណោញ ដូចជាព្រមឲ្យលោកកាត់យកប្រាក់ខែមួយចំណែក ឬ ប្រគល់របស់អ្វីដែលហ្លួងប្រទានមក ឲ្យទៅលោក ។

ពេលនោះមានស្រីម្នាក់ដែលពីមុនមកខ្ញុំពុំធ្លាប់យកចិត្តទុកដាក់សោះ បែរមករករាប់អានខ្ញុំយ៉ាងស្មោះត្រង់បំផុត ។ វាឈ្មោះ រឿង មិនចេះរាំរ៉ែកអ្វីទេ មួយថ្ងៃៗឃើញតែដើរត្រេតត្រតពេញវាំង ចាំក្រែងលោមាននរណាគេប្រើឲ្យធ្វើអ្វីបន្តិចបន្តួចប៉ុណ្ណោះ ។ វា គ្មានបង្គោលទីពឹង និង គ្មានសង្ឃឹមថា បានក្លាយខ្លួនទៅជាអស់អ្នក-អស់នាង អ្វីនឹងគេឡើយ ។ រឿង មានចរិតស្លូតបូត មិនចេះលោភលន់ ហើយមានមាឌធំមាំ ទំនងជាអាយុវាច្រើនជាងខ្ញុំទៅទៀតក៏មិនដឹង ។ ពេលហាត់រាំរាល់ព្រឹក រឿង តែងមកអង្គុយស្ងៀមស្ងាត់តែម្នាក់ឯង នៅកៀនជញ្ជាំងឆ្ងាយពីទស្សនិកជនដទៃទៀត សម្លឹងមើលខ្ញុំឥតព្រិចភ្នែក ឥតរវល់យកចិត្តទុកដាក់នឹងនរណាផ្សេងទៀតទេ... ។

បន្ទាប់មក វាតែងដើរយីរក្បែរបន្ទប់ខ្ញុំដេក ឧស្សាហ៍រាក់ទាក់ជាមួយខ្ញុំ និង ទិញនំចំណីផ្តាប់ផ្គន ហ៊ុន ខ្លាំងណាស់ ហើយយើងក៏ចាប់ស្គាល់គ្នាតាំងពីពេលនោះមក ។ វាត្អូញត្អែរប្រាប់ខ្ញុំថា វានៅដេកក្នុងថែវជាប់នឹងរបងវត្តព្រះកែវនោះពិបាកណាស់ វាសុំមកនៅជាមួយខ្ញុំផង ។ ខ្ញុំក៏យល់ព្រមឲ្យវាមកនៅដោយសុទ្ធចិត្ត ព្រោះបន្ទប់ខ្ញុំទូលាយគួរសមដែរ ណាមួយបានវាគ្រាន់ជាគ្នាជួយកំដរកុំឲ្យស្ងាត់ពេក ។ វាជញ្ជូន មុង កន្ទេល និង បង្វិចខោអាវ មកដាក់នៅក្នុងបន្ទប់ ដែលជាហេតុធ្វើឲ្យអ្នកឯទៀតគេផ្អើលមកមើលគ្រប់គ្នា ខ្លះថែមទាំងនិយាយចំអែចំអន់របៀបផ្តេសផ្តាសទៀតផង ។ មិនដឹងជាចង្រៃអ្វី ខ្ញុំចេះតែនឹករង្កៀសចិត្ត ចំពោះការទទួលឲ្យ រឿង មកនៅជាមួយ ខ្ញុំហាក់ដូចជាដឹងថា ពាក្យចំអែចំអន់របស់មិត្តភក្តិទាំងនេះ ពិតជាមានសំអាងទៅលើអ្វីមួយជាក់លាក់ ។

ល្ងាចនេះមិនត្រូវវេនខ្ញុំគាល់បំរើហ្លួងនៅឯប្រាសាទបាញ់យ៉ុងទេ ។ ហ៊ុន ក៏ទៅយកបាយពីផ្ទះមកឲ្យខ្ញុំបរិភោគ ហើយ រឿង ក៏ចុះទៅទិញបង្អែមមកទុកឲ្យខ្ញុំលាងមាត់ទៀតផង បន្ទាប់មកវាថយទៅអង្គុយត្រង់មាត់ទ្វារបន្ទប់ដូចឆ្កែចាំផ្ទះ ទុកឲ្យខ្ញុំបរិភោគបាយតែម្នាក់ឯង ។

ភ្លើងអគ្គីសនីឆេះឡើង... ខ្ញុំងើបទៅអង្គុយនៅមាត់បង្អួច អុជបារីមួយជក់ ភ្នែកគយគន់មើលទៅបរិយាកាសខាងក្រៅដែលប្រែជាងងឹតស្លុង ក្រោមស្បៃខ្មៅ នៃ រាត្រីកាល ។ ខ្ញុំងុយដេក ក៏ពិបាកដេក ពីព្រោះទើសទាល់នឹង រឿង ណាមួយខ្ញុំធ្លាប់រស់នៅតែម្នាក់ឯងតាំងពីយូរមកហើយ ដល់មកដេកជាមួយអ្នកដទៃអញ្ចឹង ដូចជាអផ្សុកណាស់ ។

ពួកម៉ាកដេកនៅក្នុងបន្ទប់ក្បែរខ្ញុំ គេនិយាយគ្នារសិបរសៀវ ហើយឮស្នូរជើងច្បាស់ ទំនងជាពួកវាដើរមកបន្ទប់ខ្ញុំតែម្តង ខ្ញុំស្ទុះទៅបិទភ្លើងភ្លាម ដើម្បីកុំឲ្យវាចូលមករំខាន ។ ប៉ុន្តែហួសពេលទៅហើយ មីសំអាង មានឧធំគម្រាំងដូចប្រុស ដើរចូលមកធ្វើជាសុំភ្លើងអុជបារី ជក់បឺតបង្ហុយផ្សែងទ្រលោម ហើយនិយាយធ្វើហីថា :



- មីរឿង វាអង្គុយធ្វើអីនៅមាត់ទ្វារ ?

- អញមិនដឹងវាអង្គុយធ្វើអីទេ (ខ្ញុំឆ្លើយ តាមនិស្ស័យ ឬ ជាមនុស្សត្រង់) ។

- ម៉េចក៏ឯងមិនហៅវាមក ? ឯងមិនដឹងទេឬអី ឯងមានឫកពារដូចជាប្រុស បើឯងធ្វើ (ប្អូន) វាមិនសមទេ កុំឲ្យអ្នកក្រៅគេដែល... ដោះស្រាយចាប់ឡើង ឲ្យគេដឹងថា នរណាធ្វើ (បង) នរណាធ្វើ (ប្អូន) ។

ខ្ញុំឧស្សាហ៍ឮស្រីៗគេហៅគ្នាថា (បង) ថា (ប្អូន) អញ្ចឹងជាញឹកញាប់ ប៉ុន្តែខ្ញុំយល់ន័យពាក្យនេះបានតែពាក់កណ្តាល ក៏ធ្វើជាភ្លើមិនដឹងសោះតែម្តង ដើម្បីស្រួលឈ្លេចសួរវាឲ្យអស់សេចក្តី :

- គ្មាននរណា បង គ្មាននរណា ប្អូន អីទេ, ម៉េចក៏ឯងសួរអញអញ្ចឹង ?

- អូ ! ឯងមិនដឹងថា មីរឿង វាចង់អីទេ ? (សំអាង និយាយតិចៗ) ។

- ទេ ! អញមិនដឹងអីទេ !

- វានិយាយប្រាប់គេឯងដឹងគ្រប់គ្នា... ឯងចង់ឲ្យអញបង្រៀនឬ ?

- អើ !, និយាយទៅមើល... អញស្បថចុះថា អញមិនដឹងមែនណាំ... (ខ្ញុំនិយាយទាំងរំជើបរំជួលក្នុងចិត្ត) ។

ក្នុងក្រសែភ្នែក សំអាង ខ្ញុំអាចស្មានបាននូវសេចក្តីពិតមួយចំណែកតាំងពីមុន ហើយស្តាប់សេចក្តីពន្យល់របស់វាទៅទៀត ។ ប៉ុន្តែខ្ញុំស្តាប់ពាក្យពន្យល់របស់ សំអាង យ៉ាងយកចិត្តទុកដាក់ជាទីបំផុត ទោះបើរឿងនេះវាធ្វើឲ្យខ្ញុំអៀនឡើងក្រហមមុខយ៉ាងណាក៏ដោយ ។ ខ្ញុំដូចជា ខឹងបន្តិច ចង់ដឹងបន្តិច... ខ្ញុំមិនចង់ធ្វើជាប្អូននរណាទាំងអស់ ។ សំអាង វានិយាយរៀបរាប់ប្រាប់ខ្ញុំសព្វគ្រប់អស់ពេលយ៉ាងយូរ ហើយវាបញ្ជាក់ថា ការនេះជាការចាំបាច់ ដែលគ្មាននរណាអាចជៀសវាងបានឡើយ ។

វាបង្គាប់ឲ្យខ្ញុំកាត់ក្រចកដៃឆ្វេងរិលអស់រលីង រួចលាចេញទៅវិញដោយផ្តៀតខ្នាន់ជាចុងក្រោយបំផុតថា :

- អាណិតវាផង ហៅវាមក !

ខ្ញុំងើបឈរឡើង បេះដូងលោត ឌីប... ខាក់ៗ... ស្ទើររយះដើមទ្រូង ហើយញ័រជង្គង់ស្ទើរឈរមិននឹង ។ កាហ៊ុន កំពុងជជែកគ្នារអ៊ូសៗជាមួយ រឿង នៅខាងក្រៅ, ខ្ញុំស្រែកប្រាប់ឲ្យ កាហ៊ុន វាទៅរកកន្លែងដេកឯណាឯណីឲ្យបាត់ទៅ ខ្ញុំប្រឹងស្រែកទាំងសម្លេងញ័រ :

- រឿង ហា៎ !

វាងើបដើរចូលមកក្នុងបន្ទប់ ព្រមទាំងនិយាយតិចៗសួរថា តើខ្ញុំហៅវាមានការអ្វី ? ។

ខ្ញុំច្រានទ្វារបិទ, អុជបារីមួយជក់បង្ហុយ ដើម្បីបន្លប់ចិត្តកុំឲ្យញាប់ញ័រខ្លាំងពេក ។ បើកុំតែមានពន្លឺភ្លើងនៅក្នុងសួនច្បារចាំងចូលមកព្រាលៗតាមបង្អួច ម្ល៉ោះសមបន្ទប់ខ្ញុំងងឹតចាក់ភ្នែកមិនយល់ទេ ។

- តស់, យើងរកដេក ! (ខ្ញុំនិយាយរបៀបម៉ឺងម៉ាត់ ហើយដើម្បីឲ្យចំណេញពេលបន្តិច ខ្ញុំធ្វើជាឈរផ្ទៀងផ្ទង់ លាបទឹកអប់ លាបម្សៅ មួយសន្ទុះធំ) ។

វាឈរចាំខ្ញុំស្ពាក់ស្ពើរមិនព្រមបើកមុងចូលសោះ ទាល់តែខ្ញុំបើកច្រានវាចូលទៅ ។

- នែ លឿនឡើង !

ខ្ញុំហុចផ្ចិតឲ្យវា ហើយឡើងទៅដេកដោយរៀបដាក់ជើងមុងក្រោមពូកយ៉ាងផ្ចិតផ្ចង់ ។

រឿង ដេកប្រកៀកទៅកៀន បែរខ្នងមករកខ្ញុំ ។ ខ្ញុំអង្គុយច្រត់ដៃសម្លឹងមើលវាយ៉ាងយកចិត្តទុកដាក់ ។ រឿង ស្លៀកសំពត់ លែងខ្លួនទទេ មានតែផាហ៊ុំស្ងួតព្រណាំលឿងមួយប៉ុណ្ណោះ ។ ខ្ញុំប្រះដេកពីក្រោយខ្នងវា

លូកដៃស្តាំទៅដាក់ពីក្រោមក្បាលវា និង លូកជង្គង់ទៅសើកខ្លាស់យកស្ថានភាពប្រយុទ្ធ ។ វាស្រមុកតិចៗធ្វើឫកជាដេកលក់... ខ្ញុំថើបវាសើរៗត្រង់កញ្ចឹងក ក៏វានៅតែមិនកម្រើក ខ្ញុំក៏ចាប់ទាញឲ្យវាដេកផ្ងារ រួចឡើងជិះជាប់ពីលើ ។ វាធ្វើជាភ្ញាក់ រអ៊ូតិចៗថា :

~ ធ្វើអីហ្នឹង ?

ខ្ញុំឈ្ងោកដាក់មុខផ្ទាល់ទៅលើស្មាវា... វាលូកដៃមកអង្អែលដោះខ្ញុំ ប៉ុន្តែខ្ញុំក្តិចម៉ាត់ ដែលជាហេតុធ្វើឲ្យវាភ្ញាក់ព្រើត ។ ខ្ញុំនិយាយខ្សិបដាក់ត្រចៀកវាថា :

~ នៅឲ្យស្ងៀម អញមិនចូលចិត្តឲ្យ លូកលាន់អញទេ ។

វាមិននិយាយតបថាដូចម្តេចឡើយ... ខ្ញុំដើរតួធ្វើប្រុស លូកដៃកៀសផាហ៊ុំចេញ ស្ទាបអង្អែលដោះវាដែលប្រែជាក្តៅឧណ្ហៗ... ខ្ញុំអាចស្តាប់ឮចង្វាក់បេះដូងយើងទាំងពីរលោតញាប់រន្ថើន ។ ហាក់ដូចជាមានភ្លើងដុតរោលទ្រូងខ្ញុំឲ្យក្រហល់ក្រហាយ ញ៉ាំងចិត្តខ្ញុំឲ្យរឹតតែក្លាហានថែមឡើងទៀត ។ ខ្ញុំ ឱបរឹត ថើបញាក់ញីប៉ុន្តែ ហឿង ចេះតែលាក់មុខ ប្រានខ្ញុំចេញ ព្រមទាំងនិយាយថា :

~ បងឯងធ្វើអីអញ្ចឹង ?

ខ្ញុំមិនឆ្លើយ គិតតែពីរាវស្រាតសំពត់វាអស់រលីងពីខ្លួន ។ ហឿង យំអណ្តឺតអណ្តក់ ជាហេតុធ្វើឲ្យខ្ញុំរឹតតែក្រពុលមុខខ្លាំងឡើង ។ ខ្ញុំលូចដៃដែលទើបនឹងកាត់ក្រចកហើយថ្មីៗ ទៅអង្អែលយោនីវា ចាប់ច្បូតរោមទន់ល្មើយដូចសរសៃសូត្រ ដោយកាយវិការញ័រទទ្រើក តាមកម្លាំងតណ្ហាដែលកំពុងឆេះរោលរាលពេញបន្ទុកក្នុងទ្រូង ។

ត្របកភ្នែកខ្ញុំបិទបើកយ៉ាងញាប់ ចិត្តអន្ទះអន្ទែង ហាក់ដូចជាកំពុងរង់ចាំព្រឹត្តិការណ៍មួយដ៏ចម្លែក ដែលនឹងកើតមានឡើងក្នុងពេលបន្តិចទៀតនេះ... តើ សំអាង វានិយាយពិតមែនឬ ?

សូរសម្លេងចាប៉ីសាត់មកពីឆ្ងាយ លាយឡំនឹងសម្លេងពួកក្មេងស្រីជំទង់នៅក្នុងសួនច្បារ ដែលស្រែកច្រៀងបន្ទរតាមភ្លេង ពិរោះគួរចាប់ចិត្ត ។ ខ្យល់ជំនោរបក់នាំក្លិនផ្កាដែលទើបនឹងរីកដោយសារទឹកសន្សើមមកផ្សព្វផ្សាយគន្ធពិដោរ ឲ្យក្រអូបឈ្ងុយពេញបន្ទប់ខ្ញុំ... ។

ចាប់តាំងពីរាត្រីដ៏ឆ្កួតលីលានោះ ហឿងរឹតតែស្រឡាញ់ និង គោរពខ្ញុំ ថែមឡើងទៀត ។ វាបំរើខ្ញុំយ៉ាងស្មោះត្រង់បំផុត ខ្ញុំទៅណាមួយជំហាន ក៏វាទៅតាមជាប់ជានិច្ច គឺវាប្រចណ្ឌខ្ញុំណាស់ ហាក់ដូចវានេះជាប្រពន្ធខ្ញុំមែនទែនអញ្ចឹង ។ មិនយូរប៉ុន្មាន រឿងនេះក៏ល្បីសុះសាយពេញវាំង ថែមទាំងលេចឮទៅដល់ ម៉ែ និង យាយកែម ទៀតផង ។ គាត់រលះរលាំងធ្វើដំណើរមកវាំងដើម្បីទូន្មានខ្ញុំ ហើយគាត់ព្រមានថា បើខ្ញុំនៅតែធ្វើផ្តេសផ្តាសអញ្ចឹងទៀត គាត់នឹងយកខ្ញុំទៅផ្ទះវិញ ឈប់ឲ្យនៅវាំងរហូត ។

ឥឡូវខ្ញុំអាចមើលឃើញច្បាស់ថា ស្ត្រីនៅក្នុងវាំងសុទ្ធតែលេងល្បែងស្នេហាភូនជីងនេះទាំងអស់គ្នា កម្រមាននរណាជៀសវាងផុតណាស់ ។ ពួកអ្នកលេងភូនជីងនេះ គ្រាន់តែក្រឡេកភ្លាម ក៏អាចស្គាល់ភ្លាម ពីព្រោះម្នាក់ៗតែងមានឫកពារទៅតាមការដែលគេប្រកាន់ធ្វើ ជាប្រុស ឬ ជាស្រី ។

ស្រីណាដែលដើរតួជារធ្វើជាស្រី មានឫកពារទន់ភ្លន់ ចេះផ្គាប់ផ្គុនគក់ច្របាច់ ឯស្រីដែលធ្វើជាប្រុសវិញគេធ្វើឫកសង្ហាដូចប្រុសមែនទែន ប្រើអំណាចទៅលើប្រពន្ធ គេចង់ទៅដេកនៅជាមួយប្រពន្ធណាមួយក៏បាន មានស្រីមួយជំពូកទៀតដែលដើរតួចម្រុះ ចង់ធ្វើជាស្រីក៏បាន ជាប្រុសក៏បាន ។ ម្ចាស់ក្សត្រីស្ថិតនៅក្នុងចំពូកនេះឯង លោកចង់ធ្វើបង ឬ ធ្វើប្អូន ស្រេចតែចិត្តលោកនឹកឃើញ គឺថាខ្លួនលោកនេះតែម្តង ដែលជាអ្នកផ្តល់ឧទាហរណ៍អាក្រក់ឲ្យយើងយកតម្រាប់តាម ។ ហេតុនេះហើយបានជាពួកអ្នករបាំក្មេងៗ ដែលនៅ



ហាត់រាំជាមួយលោក ឆាប់គ្រប់ការណាស់ ។ ដូចយ៉ាង មីប៉ោ ជាដើម វានៅក្មេងល្អក់ ហើយស្អាតដូចទេវតា, រាល់យប់តែងដើរក្រឡឹងមកជិតកន្លែងខ្ញុំដេក ដើម្បីបង្ហាញឲ្យឃើញថាវាអាច... បានហើយ ។ ប្រសិនបើខ្ញុំចង់ ខ្ញុំអាចហៅប្រពន្ធប៉ុន្មាននាក់ឲ្យមកដេកកំដរក៏បានដែរ ហាក់ដូចខ្ញុំនេះជានាម៉ឺនធំ មានប្រពន្ធច្រើនរាប់មិនអស់អញ្ចឹង ។

រឿងរ៉ាវមិនល្អវាកើតសាយភាយពេញវាំងទាំងមូល ស្តេចស្រីអាយុដប់ពីរឆ្នាំ ក៏ដូចអាយុសែសិបឆ្នាំ អ្នករបាំ អ្នកចម្រៀង រហូតដល់ស្នំហ្លួង សុទ្ធតែលេងភូនជីងទាំងអស់គ្នា ពីព្រោះទំនៀមទម្លាប់នេះ នាំពីស្រុកសៀម មកដល់វាំងស្តេចខ្មែរតាំងពីច្រើនឆ្នាំមកហើយ ។ ពួកកម្លោះៗនៅក្នុងទីក្រុង ដែលបានដឹងចរិយាមារយាទស្រីក្នុងវាំង គេពេបជ្រាយខ្លាំងណាស់ ។

ហ្លួងក៏មានការសង្ស័យក្នុងរឿងនេះបន្តិចបន្តួចដែរ ប៉ុន្តែលោកមិនសូវរវីរវល់ ព្រោះលោកចាស់ជ្រុលទៅហើយ បើនិយាយដោយខ្លី យើងគ្មានភ័យខ្លាចនរណាមកឆាឆៅទេ ម្ចាស់ក្សត្រីជាអ្នកឲ្យឧទាហរណ៍ យើងគ្រាន់តែជាអ្នកយកតម្រាប់តាមប៉ុណ្ណោះ ។

ប៉ុន្តែ មានមីឆ្កួតម្នាក់ឈ្មោះ ចាន់ជៀប វាធ្វើឲ្យបែកការណ៍រឿងនេះ បណ្តាលឲ្យចលាចល ផ្អើលណាផ្អើលណី ។ ចាន់ជៀប នេះ ជាអ្នកបំរើសាសន៍ព្នង វាឆ្កួតមែន ប៉ុន្តែមិនដែលបង្កើតឲ្យមានគ្រោះថ្នាក់អ្វីជាធំដុំ ទើបគេចេះតែទុកឲ្យវានៅក្នុងវាំងរហូតមក ។ ថ្ងៃមួយ វាទៅឃើញទាន់ ម្ចាស់ក្សត្រី និង សំអាង ជាអ្នកផ្តើមគំនិតបង្រៀនខ្ញុំ ស្រាតនេលទាំងពីរនាក់ កំពុងឱបរឹតគ្នានៅក្នុងមុង វាក៏នាំយករឿងនេះទៅរ៉ាយរ៉ាប់ប្រាប់ ក្រុមវាំង និងអ្នកបំរើ គ្រប់គ្នា ។ ចំពេលនោះ លោកមហាមន្ត្រីដើរត្រួតត្រាមើលទាហានយាមល្បាតមកដល់ឮមីឆ្កួតវាកំពុងបរិហាររឿងយ៉ាងនេះ គាត់ក៏ប្រើទាហានឲ្យចាប់យកទៅថ្វាយម្ចាស់ក្សត្រី ។

តាមពិត ក្នុងចិត្តលោកមហាមន្ត្រី គាត់រីករាយណាស់ដែលឱកាសហុចឲ្យគាត់មានពេលនឹងយករឿងអាក្រក់ទៅទូលហ្លួង ក្នុងបំណងកាច់ផ្តួលម្ចាស់ក្សត្រី ដើម្បីនៅសល់តែគាត់ម្នាក់ឯងជាធំ ត្រួតត្រាវាំងទាំងមូល ។ ម្ចាស់ក្សត្រីខ្លាច លោកមហាមន្ត្រី និង ប្រពន្ធគាត់ ជាងហ្លួងទៅទៀត ពីព្រោះសព្វថ្ងៃនេះ គឺអ្នកទាំងពីរនេះហើយ ដែលមានអំណាចត្រួតត្រាលើអស់ស្រីក្នុងវាំង ។ លោកខឹងនឹងគេ ប៉ុន្តែធ្វើអីគេមិនកើត ក៏បែរជាស្រោចកំហឹងមកលើមនុស្សឆ្កួត ប្រើពួកខ្ញុំបំរើលោក ឲ្យវាយធ្វើបាបគ្នាស្ទើរស្លាប់ស្ទើររស់ ។

គេវាយធ្វើបាបស្រីអភ័ព្វនៅជាន់ខាងក្រោមបន្ទប់ខ្ញុំ ពួកស្រីពេជ្ឈឃាតធ្វើទារុណកម្មយ៉ាងឃោរឃៅ ឥតមានចិត្តត្រាប្រណីបន្តិចបន្តួចសោះ គឺប្រាកដជាគេចង់វាយសម្លាប់គ្នាតែម្តង លុះវាសន្លប់បាត់ស្មារតី គេនាំគ្នាចេញអស់ទៅវិញ ទុកចោលស្រីរងគ្រោះឲ្យនៅដេកស្តូកស្តឹងម្នាក់ឯងលើក្តារ ។ ខ្ញុំរង់ចាំមើលរហូតដល់ថ្ងៃត្រង់ មិនឃើញមាននរណាត្រឡប់មកវិញ ក៏ដួសបាយមួយចានកាន់ចុះយកទៅឲ្យវាបរិភោគ ។ វាញញឹមទទួលខ្ញុំធ្វើមុខស្លឹ ហើយបរិភោគបាយឃ្លុមៗ ហាក់ដូចជាគ្មានដឹងរឿងហេតុអ្វីទាំងអស់ ។ មួយសន្ទុះក្រោយមក ម្ចាស់ក្សត្រីត្រឡប់មកវិញ ឃើញមនុស្សទោសនៅរស់នៅឡើយ លោកក៏ស្រែកឡូឡាសួរថា នរណាហ៊ានយកបាយមកឲ្យវាស៊ី ស្រាប់តែមានមីមួយនោះលបមើលឃើញ វាទូលម្ចាស់ក្សត្រីថា ខ្ញុំជាអ្នកយកបាយឲ្យអ្នកទោសស៊ី ។

~ អីយ៉ា ! មីសារ៉ាម៉ានី វាហ៊ានដល់ម្លឹង ? (ម្ចាស់ក្សត្រីច្រឡោតតូង ប៉ុន្តែលោករម្ងាប់កំហឹងបាន ដើរចេញទៅវិញធ្វើមុខក្រញូវ) ។

ពេលនោះ បងប្រុសម្ចាស់ក្សត្រី គឺ ម្ចាស់ដួងមធុរ៉ា ត្រូវស្លាប់បាត់បង់ជីវិតទាំងវ័យក្មេងល្អក់ ។ នេះគឺជាការបាត់បង់បង្គោលទីពឹងមួយទៀតសម្រាប់រូបខ្ញុំ ពីព្រោះម្ចាស់មធុរ៉ា តែងស្រឡាញ់រាប់អានខ្ញុំដូចកូនលោក

បង្កើត ហើយលោកថែមទាំងបានទូន្មានម្ចាស់ក្សត្រីជាច្រើនលើកច្រើនគ្រា ឲ្យលើកខ្ញុំធ្វើជាតួឯងផង ។ លោកស្លាប់ដោយជម្ងឺចម្លែកមួយដែលទើបនឹងឆ្លងចូលមកដល់ស្រុកខ្មែរក្នុងពេលថ្មីៗនេះ ហើយដែលបារាំងហៅថា ជម្ងឺប៉េស្ត៍ ។ លោកប៉ុស៊ីដង់បារាំង បង្គាប់ឲ្យពេទ្យបារាំងវះកាត់សាកសពពិនិត្យមើល ទោះបីម្ចាស់ក្សត្រីតវ៉ាយ៉ាងណា ក៏គេពុំព្រមស្ដាប់ ។ ពេលនោះ ម្ចាស់ក្សត្រី និង បក្សពួក នាំគ្នាទៅនិយាយបញ្ចុះបញ្ចូលខ្មែរនៅម្ដុំខាងត្បូងវាំង ឲ្យលើកគ្នាមកជួយតវ៉ាថែមទៀត ។ ខ្ញុំរត់ឡើងទៅលើរានហាលជាមួយមិត្តភក្ដិជាងដប់នាក់ ដើម្បីមើលប៉ុស៊ីដង់បារាំង អញ្ជើញមកសម្រុះសម្រួលបាតុករ ។ ម្នាក់នោះហៅខ្ញុំឲ្យចូលទៅជិតវា ហើយចង្អុលប្រាប់ថា :

– សារ៉ាម៉ានី ! មើលទំ បារាំងនោះនៅក្មេងសោះ ប៉ុន្តែខ្ពស់ចង្រ្គាង គាត់ហ្នឹងអាយុយ៉ាងច្រើនណាស់ត្រឹមដប់ប្រាំឆ្នាំប៉ុណ្ណឹង ។

ខ្ញុំអើតមើលទៅខាងក្រោមតាមដៃគេចង្អុល ហើយនេះជាលើកទីមួយដែលខ្ញុំបានឃើញលោក[១១] ពេលដែលលោកឈរយ៉ឺរនៅមុខប្រាសាទដំកល់ព្រះខ័នរាជ[១២] ។ គ្រាន់តែឃើញលោកភ្លាម ទ្រូងខ្ញុំប្រែជាញាប់ញ័រ ខ្លួនប្រាណប្រែជាស្លាំង ដូចគ្មានឈាមមួយដំណក់នៅក្នុងខ្លួន ។ ខ្ញុំប្រញាប់គេចថយមកក្រោយវិញ និយាយរឿងនេះប្រាប់ សំអាង ស្រាប់តែវាផ្ទុះសំណើច ព្រមទាំងនិយាយខ្លាំងៗថា :

– អឺ ! អានេះគេហៅថាប្រផ្នូល ! សារ៉ាម៉ានីឯង ប្រាកដជាបានប្ដីបារាំងហ្នឹងហើយ ។

ពួកគេបានពាក្យនេះ នាំគ្នាចំអន់បង្អាប់ខ្ញុំ ពីរ-បី ថ្ងៃ បន្ទាប់មកគ្មាននរណានឹកឃើញដល់រឿងនេះទៀតឡើយ ។

## នាដ្យការីក្មេងៗ



[១១] សូមមិត្តអ្នកអានកុំភ្លេចថា ដំណើររឿងតាំងពីដើមរហូតមកដល់នេះ គឺជារឿងដែល សារ៉ាម៉ានី និយាយប្រាប់ប្ដីនាងជាជាតិបារាំងឈ្មោះ កម្លោះ ។

[១២] សូមមិត្តអ្នកអានកុំភ្លេចថា ដំណើររឿងតាំងពីដើមរហូតមកដល់នេះ គឺជារឿងដែល សារ៉ាម៉ានី និយាយប្រាប់ប្ដីនាងជាជាតិបារាំងឈ្មោះ កម្លោះ ។



**ពេល**វេលាចេះតែកន្លងទៅមុខឥតអាក់ ដោយគ្មានកើតព្រឹត្តិការណ៍អ្វីជាសំខាន់ឡើយ.. រដូវភ្លៀង នៃ ឆ្នាំវក ក៏កន្លងផុតទៅ ។

ចាប់តាំងពីថ្ងៃមួយកើត នៃ ខែកត្តិក ខ្យល់បក់មកពីខាងជើងរហើយត្រសៀក ក្រោមផ្ទៃមេឃស្រឡះល្អល្អេវ ទឹកទន្លេធំក៏ចាប់ផ្ដើមហូរត្រឡប់ទៅកាន់សមុទ្រវិញ ។

រៀងរាល់ឆ្នាំ តែដល់ពេលនេះ យើងនាំគ្នាចុះទៅក្នុងទីនាំងផែ ដើម្បីប្រារព្ធធ្វើពិធីបុណ្យអុំទូក និងសំពះព្រះខែ ។ ពួកអស់អ្នក-អស់នាង ដើរជាក្រុមតូចៗ មាន យាយចាស់ទុំ និង ក្រុមវាំង តាមអមជូនដំណើរជាប់ជានិច្ច ។ ផ្លូវពីមាត់ទ្វារវាំងទៅកំពង់ផែ ប្រវែងមួយចំអាមសោះ ប៉ុន្តែមនុស្សម្នាភាគច្រើនសុទ្ធតែប្រុសៗនាំគ្នាប្រជ្រៀតឈរអមសង្ខាងផ្លូវ ដើម្បីមើលស្រីក្នុងវាំងឲ្យឃើញច្បាស់នឹងភ្នែកម្ដង ព្រោះម្នាក់ៗសុទ្ធតែធ្លាប់ឮគេនិយាយ ថាអញ្ចេះ ថាអញ្ចុះ ប៉ុន្តែកម្រមាននរណាបានឃើញណាស់ ។ នរណាគេទាក់ទងមានគូសង្សារនៅក្រៅវាំង គេឆ្លៀតឱកាសនេះដើរទៅដើរមក ថែមទាំងកាច់ឫកកាច់រាង ដើម្បីទាក់ទាញចិត្តគូសង្សារគេ ។ ចំណែកស្រីត្រឹមត្រូវដូច យ៉ាន និង ខ្ញុំ ជាដើម យើងមករស់នៅក្នុងវាំង ព្រោះស្រឡាញ់ចង់បានកិត្តិយស ពុំមែនដើម្បីមកដើរបង្អួតសាហាយទេ ។ កាលពីរាជ្យហ្លួង សុវណ្ណកោដ្ឋ គេយកកំណាត់មកពាសបាំងសង្ខាងផ្លូវ តាំងពីទ្វារវាំងរហូតដល់មាត់ទន្លេ ហើយមានដាក់ទាហានឲ្យឈរយាមទៀតផង ។ ប្រុសៗនៅពីក្រោយផ្ទាំងកំណាត់ ត្រូវអង្គុយលុតជង្គង់ឱនមុខចុះ មិនឲ្យងើបមុខមើលពួកយើងជាដាច់ខាត ។ ប៉ុន្តែក្នុងរាជ្យថ្មីនេះ ប្រុសច្រឡឹមឈរដង្ហែលើចិញ្ចើមថ្នល់ វាគយគន់មើលយើងឥតកោតញញើត មើលទាល់តែយើងអៀនមិនហ៊ានងើបមុខ ។

យើងដើរចុះតាមច្រាំងទន្លេ ដែលទឹកស្រកចុះអស់ច្រើនណាស់ទៅហើយ... មើលទៅម្ខាង ឃើញដំបូលផ្ទះខ្ញុំលេចលើមៗ បន្លំនឹងស្លឹករុក្ខជាតិ ។ សសរជងកើទ្រេតទ្រោត ហាក់រកកលនឹងរលំធ្លាក់ទៅក្នុងទន្លេ... យើងដើរឆ្លងស្ពានទៅដល់លើទីនាំងផែ ដែលជាកន្លែងពិសេស គេរក្សាទុកសម្រាប់តែពួកយើង ។

បន្ទប់ហ្លួងស្ថិតនៅចំកណ្ដាលផែ ពាសជញ្ជាំងធ្វើពីឈើបេងរលោងស្រិល មានទុកចន្លោះធំល្មមអាចដើរក្រឡឹងជុំវិញបាន ។ សាឡុងធំស្ថិតនៅចំពីមុខបន្ទប់ បែរមុខទៅខាងកើតឆ្ពោះទៅរកផ្ទៃទន្លេ ដែលប្រកបទៅដោយទឹករលកបោកបាចឥតឈប់ឈរ ។

បុណ្យអុំទូក ប្រព្រឹត្តទៅបីថ្ងៃបីយប់ជាប់គ្នា ហើយត្រូវបញ្ចប់ក្នុងថ្ងៃពេញបូណ៌មី នៃ ខែកត្តិក ។ វេលារសៀល នៃ ថ្ងៃនោះ ការប្រណាំងទូកង បានទាក់ទាញរាស្ត្រនៅក្នុងខេត្តជិតខាងរាជធានី ឲ្យមកប្រជ្រៀតគ្នាពេញមាត់ទន្លេ ដើម្បីមើលទស្សនីយភាពប្រចាំឆ្នាំដ៏ត្រកាលនេះ ។ ពួកបារាំងអង្គុយលើទីនាំងរូបនាគ ចត

ក្បែរទីនាំងផែ ដែលនៅលើនោះ មានក្រុមតន្ត្រីប្រគុំជាប់រហូត ដល់ពេលព្រលប់ធំទើបឈប់ ។

ទូកចែវបញ្ច្រាសទឹក កាត់តាមមុខទីនាំងផែឡើងទៅកាន់ដើមទីប្រណាំង, មួយសន្ទុះក្រោយមក ឃើញត្រឡប់មកវិញម្ដងមួយៗ ចែវលឿនស្លេវដោយមនុស្សប្រុសមាឌធំមាំ ។ អ្នកខ្លះប្រើច្រវ៉ាវែងឈរចែវ, ខ្លះអង្គុយអុំ, ទូកនីមួយៗផ្ទុកមនុស្សហាសិបនាក់ ឬច្រើនជាងនេះផងក៏មាន បណ្ដាលឲ្យទូកធ្ងន់ពៀបស៊ីងនឹងលិច ។ ក្បាលទូកងស្មើត មានមេក្រុមអង្គុយលើនោះ លើកដៃ លើកជើង ជាចង្វាក់ និង នៅកណ្ដាលទូកមានតួកម្នាក់លោតចាក់ក្បាច់ក្រមាច់ក្រមើម ញាក់មុខញាក់មាត់ ដាក់ហ្លួង ដាក់ពួកនាម៉ឺន និង ដាក់ពួកយើង ។ ពេលធម្មតា គេមិនអនុញ្ញាតឲ្យនរណាចាក់តួកធ្វើឫកច្រឡឹមបែបនេះជាមួយហ្លួងជាដាច់ខាត ប៉ុន្តែពេលនេះជាពេលបុណ្យទាន ទើបហ្លួងលើកលែងទោសមិនប្រកែប្រកាន់ ។ ខ្ញុំឃើញពួប៉ុលអង្គុយទំលើក្បាលទូកវត្តកោះអន្លង់ចិន កំពុងចាក់ក្បាច់ខ្លាំងដៃសម្បើមណាស់ ។ ស្នូរច្រវ៉ាគោះទឹកលាន់ឮស្នូរព្រឺបៗ ធ្វើចង្វាក់លាយឡំនឹងចម្រៀងស្រែកបន្ទរ ហៃអើ! ហៃអើ!... ។

ចុងក្រោយគេបង្អស់ គឺទូកមួយធំដាក់មនុស្សពេញព្រៀប ស្រែកហោកញៀវលាន់ខ្ទរមកដល់ច្រាំង ចែវទៅមុខឡើងរង្គើទឹក ដូចត្រូវព្យុះបក់បោក ។

បន្ទាប់មក ទូកទាំងអស់តម្រៀបបន្តកន្ទុយគ្នា តាមបណ្ដោយទីនាំងរូបនាគ ចាំទទួលយកអំណោយហ្លួងដែលនាម៉ឺនរាំងគេនាំយកទៅចែកឲ្យគ្រប់ៗគ្នា ។ ទស្សនិកជនបំបែកគ្នាវិលទៅកាន់គេហដ្ឋានរៀងៗខ្លួន ឯពួកបារាំងក៏ត្រឡប់ទៅផ្ទះគេវិញដែរ ។ កប៉ាល់ហ្លួងដែលចតនៅពីមុខទីនាំងផែ និង កប៉ាល់ជាច្រើនទៀតរបស់ពួកនាម៉ឺនសព្វមុខមន្ត្រី ចាប់អុជប្រទីបថ្លាលាភ្លឺព្រោងព្រាត មានតាក់តែងលំអជារូបផ្សេងៗ រហូតដល់សសរដងកើ ក៏មានអុជភ្លើងបំភ្លឺតាំងពីក្រោមរហូតដល់ចុងកំពូល ។ កាំជ្រួចភ្លឺទៀនផ្ទុះក្ទុម! ក្ទាំង! ភ្លឺខ្ពាលអស់មួយចំហៀងមេឃ ហើយកប៉ាល់ប្រទីបក៏ចាប់ផ្ដើមធ្វើដំណើរទៅមុខយឺតៗ ប្រកបដោយភ្លើងតាក់តែងលំអយ៉ាងត្រកាល កណ្ដាលស្បែងងឹតនៃរាត្រីកាល ។ អស់អ្នក-អស់នាងជាច្រើនរូប រួមទាំងខ្ញុំផង យើងនាំគ្នាឆ្លងទៅកាន់ទីនាំងរូបនាគ និង ទូកដទៃទៀត ដែលចតនៅជាប់គ្នា ។ គេចែកផាវចែកកាំជ្រួច ឲ្យយើងអុជលេងយ៉ាងសប្បាយរីករាយ ប៉ុន្តែដោយជិតដល់ពេលចូលវេនគាល់បំរើហ្លួងទៅហើយ ខ្ញុំក៏ត្រឡប់មកកាន់ទីនាំងផែវិញ ។ អង្គុយជជែកគ្នាលេងនៅត្រង់សាឡុង ដែលហ្លួងគង់ទតមើលការប្រណាំងទូកកាលពីថ្ងៃ ។

នៅទិសខាងកើតឆ្ងាយឯណោះ ព្រះចន្ទពេញវង់នៃខែកត្តិក រះឡើងមូលក្រឡង់ ចោលកំទេចរស្មីស្រទន់ត្រជាក់ពណ៌ប្រាក់ ចាំងឆ្លុះលើផ្ទៃទន្លេ... ។

ហ្លួងចេញមកមើលកប៉ាល់លយប្រទីបតែមួយភ្លែត ក៏ត្រឡប់ចូលទៅក្នុងបន្ទប់វិញ ហើយបង្គាប់ឲ្យគេរៀបក្រយាពេលល្ងាចថ្វាយ ។ ក្រុមភ្លេងពិណពាទ្យចាប់ប្រគុំបទបើកឆាក ហើយស្រីៗដែលតែងខ្លួនស្រស់បំព្រង អង្គុយត្រៀបត្រានៅក្នុងសាឡុងធំនោះ ក៏ស្រែកច្រៀងបទសក្រវ៉ាទឹក យ៉ាងពិរោះលន្លង់លន្លោចកណ្ដាលសភាពស្ងប់ស្ងាត់ នៃ រាត្រីកាល ។

ហ្លួងផ្ដើសោយអាហៀននៅក្នុងបន្ទប់ មានស្រីស្អាតៗចាំបំរើ មានសម្លេងទិព្វច្រៀងបទសក្រវ៉ាទឹកបំពេ ផ្សំនឹងទីនាំងផ្អៀងទៅផ្អៀងមកតាមកម្លាំងទឹករលកដូចគេយោលអង្រឹងនោះផង លោកប្រែជាងោកងុយធ្វើភ្នែកមមីរ ។

បទសក្រវ៉ាទឹកចប់ទៅ ដោយអ្នកចម្រៀងត្រូវសំរាក បរិភោគនំចំណី និង ផឹកស្រាកំដៅពោះបន្តិចសិន ពីព្រោះពេលនេះខ្យល់ជំនោរត្រជាក់បក់បោកមកឥតឈប់ បណ្ដាលឲ្យរងាព្រឺសម្បុរគីងគក់ ។

នៅលើទូកមួយផ្សេងទៀត ប្រុសៗសម្លេងគ្រលរស្រែកច្រៀងជាទំនុកឆ្លើយឆ្លងនឹងយើង ហើយបន្ទាប់



មក សម្លេងប្រុសស្រីស្រែកច្រៀងចម្រុះគ្នាលាន់ឮចេញពីគ្រប់ទូកពួកនាម៉ឺនហ្លួង ។

ហ្លួងចេញមកត្រង់សាឡុងជាថ្មីម្ដងទៀត សម្លឹង មើលព្រះចន្ទ មើលទឹក មើលដី មើលស្រីក្មេងៗដែលនៅគាល់ត្រៀបត្រា ។ លោកសម្លឹងមើលពួកយើងមួយត្រួស ឃើញខ្ញុំអង្គុយលាយឡំជាមួយអ្នកចម្រៀងដទៃទៀត ក៏សួរថា :

~ យី, ឯងច្រៀងដែរឬ ? អញធ្លាប់តែឮគេថា ឯងខិលច្រអូសណាស់, រួចម៉េចក៏ឯងចេះធ្វើការដែរ ?

ថាហើយលោកដើរក្រឡឹងមួយជុំ ទើបបង្គាប់ឲ្យគេលើកយកអំបុកមកថ្វាយ ។ គេយកអំបុកច្រើនណាស់មកឲ្យយើងបរិភោគ យើងខំទំពារទាល់តែរោយថ្គាមទាំងរងាញាក់ទទ្រើក ទោះបីយើងមានជាហ៊ឺដណ្ដប់គ្រប់គ្នាយ៉ាងណាក៏ដោយ ។ អំបុកសម្រាប់ហ្លួង ធ្វើឡើងដោយស្រូវពិសេស ធុំក្លិនឈ្ងុយគួរឲ្យស្រក់ទឹកមាត់ ។ យើងបរិភោគអំបុកហើយ ផឹកស្រាបារាំងកំដៅពោះ និង ជក់បារីស៊ីហ្គារ៍ផង ។

ខ្ញុំអង្គុយច្រៀងមួយយប់ទល់ភ្លឺ ដើម្បីបំពេរឲ្យហ្លួងផ្ទំលក់ស្រួល ។ អស់លោកជំទាវ លោកស្រីប្រពន្ធនាម៉ឺន នាំគ្នាឡើងមកលើទីនាំងផែដើម្បីកំដរយើង នាំជជែកពីនេះពីនោះពេលយើងឈប់ច្រៀងម្ដងៗ ។ យ៉ឿង វ៉ាតាមសម្លឹងមើលខ្ញុំជាប់ជានិច្ច ទំនងដូចជាប្រច័ណ្ឌ ពេលឃើញខ្ញុំនិយាយព្រោកប្រាថ្ងជាមួយស្រីៗដទៃទៀត ។ វ៉ាយកស្ករគ្រាប់មកឲ្យខ្ញុំបរិភោគ ហើយបង្ខំឲ្យខ្ញុំទទួលយកទាល់តែបាន ដែលជាការគួរឲ្យរង្កៀសចិត្តពេកណាស់ ។

ទូកនីមួយៗ ច្រៀងជាបន្តបន្ទាប់គ្នា ដល់ទីបញ្ចប់ក៏បានមកដល់វេនពួកខ្ញុំច្រៀងម្ដងទៀត ។ ព្រះចន្ទយាងជ្រេហួសទៅទិសខាងលិច កប់បាត់ឯជើងមេឃ... កាំភ្លើងពេលព្រឹកបាញ់ក្ទាំង! ក្ទាំង! ឮសម្លេងយ៉ាងច្បាស់រសាត់មកដល់យើង ។ ផ្កាយរលត់បាត់រស្មីម្ដងមួយៗ ផ្ទៃមេឃក៏ប្រែជាភ្លឺស្រឡះម្ដិចឡើងវិញដែរ ។

អ្នកចម្រៀងប្រុស-ស្រី ដែលមកច្រៀងលេងជាមួយយើងពេញបីយប់ជាប់គ្នានោះ ក៏លាត្រឡប់ទៅវិញ នាំយកទាំងក្ដីស្ដាយស្រណោះមិនអាចគណនាបាន ទៅជាមួយផង ។

ការសប្បាយរីករាយត្រូវចប់ត្រឹមនេះហើយ ប៉ុន្តែហ្លួងដូចជាពេញចិត្តនឹងរស់នៅលើទីនាំងផែ ទើបលោកសម្រេចថា នឹងបន្តស្នាក់នៅទីនេះបន្តិចទៅទៀត ។ នរណាអស់កម្លាំងដោយមិនបានដេកពេញបីយប់នោះ គេឡើងមករាំងដេកសម្រាកយកកម្លាំងបន្តិចសិន ។ ខ្ញុំក៏ឡើងមកជាមួយគេឯងដែរ គ្រាន់តែមកដល់បន្ទប់ប្រះដេកភ្លាមក៏លក់ភ្លាម ទាល់តែព្រលប់ធំ កាហ៊ុនវ៉ាដាស់ឲ្យងើបបរិភោគបាយ ទើបភ្ញាក់ដឹងខ្លួន ។ ខ្ញុំឥតឃ្លានសោះ ប៉ុន្តែចេះតែខំលេបបង្ការកុំឲ្យឃ្លានយប់ព្រលប់ ហើយមុននឹងចុះទៅចូលវេនគាល់បម្រើហ្លួងឯទីនាំងផែវិញ ខ្ញុំឆ្លៀតបោសច្រាសបន្ទប់ និង គ្រែពូកដេកបន្តិចផង ។ កំពុងតែរៀបចំបន្ទប់ ខ្ញុំស្រាប់តែនឹកភ្នកឃើញរឿងអ្វីមួយ ញាំងចិត្តឲ្យគិតភ័យញាប់ញ័រដោយមិនសមហេតុសមផល ។ ឃើញអញ្ចឹង កាហ៊ុនវ៉ាធ្វូល់បើកភ្នែកធំៗ... តើខ្ញុំភ័យពីរឿងអ្វី ? ខ្ញុំគិតមិនយល់ទាល់តែសោះ... តាមបង្អួច ខ្ញុំមើលឃើញព្រះអាទិត្យលិចបាត់ឯជើងមេឃទិសខាងលិចទៅហើយ សល់កំទេចរស្មីដែលចាំងឆ្លុះលើដំបូលផ្ទះប្រាសាទពណ៌មាស ។ ខ្យល់ជំនោរបក់បោករហើយត្រសៀក នាំសម្លេងខ្លែងឯកពីទីឆ្ងាយឮល្វើយៗ ញាំងចិត្តខ្ញុំឲ្យស្រងេះស្រងោចក្រៃលែង ។ ក្អែកមួយហ្វូងហើរស្រែកកោកកាកមកទំលើដើមគគីរ ស្រែកបួលឆ្លងឆ្លើយគ្នាទ្រហឹងអឺងអាប់ កណ្ដាលបរិយាកាសស្ងប់ស្ងាត់នៅក្នុងរាំង ។

សម្លេងយាយកែម ដាស់ខ្ញុំឲ្យភ្ញាក់ពីក្ដីស្រមៃ ខ្ញុំងាកទៅក្រោយឃើញយាយស្លៀកពាក់ស ឈរនៅត្រង់មាត់ទ្វារ មានទឹកមុខស្រពាប់ស្រពោន ។ គាត់និយាយមកកាន់ខ្ញុំថា :

~ ចៅ! ឪពុកឯងមិនស្រួលខ្លាំងហើយ វាចង់ឃើញមុខចៅឯងណាស់ ។ ចៅឯងសុំច្បាប់ហ្លួងទៅផ្ទះ

ដើម្បីមើលថែទាំវា ពីរ-បីថ្ងៃ បានទេ ?

ខ្ញុំដើរតាមយាយរហូតដល់ផ្ទះ ទាំងចិត្តក្ដុកក្ដួលស្ទើរទប់ទឹកភ្នែកមិនឲ្យស្រក់ចុះមកមិនបាន ។ ខ្ញុំឡើងទៅលើផ្ទះឃើញ ញាតិមិត្តអ្នកជិតខាងខ្លះ និង ម៉ែ អង្គុយព័ទ្ធជុំវិញពុក ដែលគេដាក់ឲ្យសំរាន្ត ភ្នែកបិទជិត ដកដង្ហើមញាប់ដង្ហក់ ដៃលើកដាក់ប្រណម្យលើដើមទ្រូង ។ គាត់បើកភ្នែកឡើងឃើញខ្ញុំ ក៏ប្រឹងញញឹម ហើយពោលខ្សាវៗ :

~ កូនមកដល់ហើយឬអី ? ពុកដឹងខ្លួនថាមិនស្រួលខ្លាំងហើយ, កូនឯងទៅសុំច្បាប់ហ្លួងលមើល បើលោកឲ្យឈប់ក៏ឈប់ បើលោកមិនឲ្យទេក៏ហីទៅ ប៉ុន្តែ... ពុកចង់បានកូនឯងមកនៅជិតឲ្យបានទាន់ដង្ហើម ពីព្រោះពុកមិនដឹងជាស្លាប់ពេលណាទេ... ។

ខ្ញុំរាវចូលទៅជិតពុក ច្របាច់ជើងគាត់ថ្នមៗ... មេឃងងឹតបន្តិចហើយ ម៉ែអុជចង្កៀងតូចមួយ យកមកដាក់ជិតពុក រួចលុតជង្គង់ លើកដៃសំពះធ្វើមាត់ជីបអួចៗ ។ ខ្ញុំចេញក្រៅដោយយ៉ាងលឿនសំដៅផែ ទាន់ឃើញហ្លួងកំពុងស្លៀកពាក់ខោអាវ ។ ខ្ញុំអង្វរ មីវ៉ែន ឲ្យវាជួយសុំហ្លួងឲ្យខ្ញុំបានទៅផ្ទះផង ពីព្រោះវាពូកែសីដីលែបខាយជាងខ្ញុំ វាក៏យល់ព្រមជួយដោយសុទ្ធចិត្ត ។ វាថ្វាយបង្គំរៀបរាប់ទូលហ្លួងបន្ថែមបន្ថយតាមដែលនឹកឃើញ ហ្លួងក៏ឆ្លើយតបវិញថា :

~ អើ ! បើឪពុក សារ៉ាម៉ានី ឈឺ ឲ្យវាទៅផ្ទះមើលឪពុកវាចុះ !

ខ្ញុំប្រញាប់ត្រឡប់មកផ្ទះវិញយ៉ាងរួសរាន់ ។ ពុកបម្រាស់ទៀលលើកខ្នេល ក្អួតធ្លាក់ឈាមទាំងដុំៗ ពួកប្រុសៗគេខំជួយទប់គាត់ណាស់ដែរ ប៉ុន្តែគាត់ចេះតែមីបំរះ ព្រមទាំងពោលពាក្យមិនសមរម្យជេរគ្រូចាស់ម្នាក់, ដែលថាមកព្យាបាលគាត់ឲ្យជាសះស្បើយ តែកាលពីល្ងាច បែរជាឲ្យគាត់លេបថ្នាំអ្វីម្យ៉ាង ដែលធ្វើទុក្ខក្ដៅអន្ទះអន្ទែងទ្រាំមិនបាន ។ ទោះបីឃើញគាត់ឈឺធ្ងន់យ៉ាងនេះក៏ដោយ ក៏ខ្ញុំពុំបានគិតថា ពុកនឹងស្លាប់ក្នុងពេលខាងមុខនេះសោះ ។

ដល់ពេលពាក់កណ្ដាលអាធ្រាត្រ គាត់ដូចជាបានសម្ងំខ្លះ ។ យាយ ម៉ែ ព្រមទាំងញាតិខ្លះទៀត គេស្ម័គ្រចិត្តនៅជួយកំដររហូតដល់ភ្លឺ ។ ចំណែកខ្ញុំ អត់ងងុយកាលបុណ្យអុំទូកនោះ មិនទាន់មានកម្លាំងស្រួលបួលឡើងវិញផង ក៏ទៅប្រះដេកលក់យ៉ាងស្រួលនៅលើគ្រែ ។ ខ្ញុំភ្ញាក់ពីដេក ថ្ងៃមិនទាន់រះពេញនៅឡើយ ។ ពុកច្រតដៃប្រឹងងើបដើម្បីពិសារទឹកថ្នាំក្ដៅហុយ ហើយនៅពេល ឃើញចង្កៀង ឃើញព្រះអាទិត្យរះ គាត់ដកដង្ហើមធំនិយាយថា :

~ យ៉ាងយូរណាស់ពីរម៉ោងទៀតខ្ញុំនឹងស្លាប់ហើយ ម៉ែវា, កូន និង បងប្អូនទាំងអស់ សូមឲ្យបងប្អូនជួយមើលខុសត្រូវប្រពន្ធកូនខ្ញុំផង ។ ខ្ញុំស្ដាយណាស់មិនគួរស្លាប់ ទាំងពេញកម្លាំង ទាំងមិនទាន់បានរៀបចំអនាគតកូនស្រីឲ្យបានស្រួលបួល ស្លាប់ចោលប្រពន្ធឲ្យនៅរស់លំបាកវេទនា... ។

ឮគាត់និយាយអញ្ចឹង យើងទាំងអស់គ្នាក្ដុកក្ដួលក្នុងចិត្ត ស្រក់ទឹកភ្នែកច្រោកៗ ។ ម៉ែទ្រហោយំគក់ទ្រូង រួចស្រវាអោបជង្គង់ពុក អង្វរឲ្យគាត់ឈប់និយាយ ប៉ុន្តែពុកមិនព្រមឈប់សោះ ។ បន្តិចក្រោយមក គាត់ប្រឹងត្រដររងើបអង្គុយ ប្រាប់ឲ្យយើងជួយងូតទឹកសំអាតខ្លួនគាត់បន្តិច ។ ពួកប្រុសៗជួយលើករំកិលដាក់គាត់មកលើក្ដារ ស្រោចទឹក ដុសសាប៊ូ ដុះក្អែលសព្វមុខមាត់ដៃជើង រួចហើយគេផ្លាស់ឲ្យគាត់ស្លៀកសំពត់ថ្មីមួយទៀត ។ ប៉ុន្តែមុននឹងសំរាន្តទៅវិញ គាត់ទារឲ្យគេសិតសក់ ទារយកទឹកមកខ្ពុលមាត់ ។ លុះស្អាតស្រួលបួលហើយ គាត់ញញឹមបន្តិចសំដែងការពេញចិត្ត រួចទារឲ្យគេផ្ដេកគាត់ទៅកន្ទេលវិញ ។

យាយកែម អង្គុយធ្វើទឹកមុខមាំ ផ្អែកខ្នងនឹងសសរ ។ ក្នុងចំណោមយើងទាំងអស់គ្នា មានតែគាត់



ម្នាក់ឯងគត់ដែលមិនយំ ពីព្រោះកាលពីខ្មោចតាស្លាប់ គាត់បានចំណាយទឹកភ្នែកយំស្ដាយស្រណោះអស់ច្រើនណាស់ ឥតមានសល់ទឹកភ្នែកសម្រាប់យំចំពោះមរណភាព នៃ កូនប្រសានេះទៀតទេ ។ គាត់បោយដៃហៅគេម្នាក់ឲ្យចូលទៅជិត ហើយប្រាប់ថា ឲ្យទៅនិមន្តលោកវត្តឱណ្ណាលោម មកសូត្រធម៌កំដរអ្នកជម្ងឺ កុំឲ្យស្ងាត់ផ្ទះពេក ។

ពុកស្ដួលឈាមម្ដងទៀត រញ្ជាក់រញ្ជ័រត្រដរខ្យល់ គាត់ខំប្រឹងលេចសរសៃវាំមជុំវិញបំពង់ក ដើម្បីហាមាត់និយាយ ប៉ុន្តែ យាយកែម យកដៃសង្កត់ដើមទ្រូងក្ដៅដូចរងើកភ្លើង ប្រាប់ពុកឲ្យសម្រាន្តទៅវិញ ។ នរណាម្នាក់និយាយសួរពុកថា :

~ បងហា ! កាលពីក្មេង បងឯងមានធ្លាប់មកលេងជល់មាន់ទេ ?

ពុកងក់ក្បាលសំដែងការយល់ស្រប និង និយាយបន្ថែមថា :

~ ខ្ញុំដឹងថា ខ្ញុំបានប្រព្រឹត្តអំពើអបាយមុខច្រើនណាស់ ខ្ញុំបានចាប់សត្វឲ្យជល់គ្នា ខ្ញុំបានសម្លាប់មនុស្សជាពិសេសសម្លាប់យួនអស់ច្រើនណាស់ ។ សូមអ្នកដែលខ្ញុំធ្លាប់បានធ្វើអំពើល្អទៅលើគេ គេជួយស្រោចស្រង់ឲ្យខ្ញុំបានជួបប្រទះតែនឹងសេចក្ដីសុខក្នុងសុគតិភព ។

យាយកែម ឈ្ងោកសម្លឹងមើលមុខកូនប្រសារដោយក្រសែភ្នែកស្រទន់ ពោរពេញទៅដោយសប្បុរសធម៌ ។ គាត់កាន់ជង្គង់ពុកជាប់ ហើយពោលមួយៗថា :

~ យិន ! កូនឯងកុំគិតពីរឿងទុក្ខព្រួយធ្វើអ្វី គិតតែតាំងចិត្តឲ្យជ្រះថ្លាក្នុងព្រះធម៌ឡើង ។ កុំគិតពីអ្នករស់នៅ មានម៉ែ មានញាតិមិត្តបងប្អូននៅជួយមើលថែរក្សា ជាភ្នែក ជាច្រមុះ ជំនួសឯងហើយ ។ ឯងទន្ទេញធម៌ឲ្យចាំជាប់ក្នុងចិត្តជានិច្ច ដើម្បីសំអាតចិត្តឲ្យស្អាត ពីព្រោះមានតែព្រះធម៌នេះហើយ ដែលអាចជួយយិតយោងឯងឲ្យបានស្គាល់ សេចក្ដីសុខ សុភមង្គល ក្នុងលោកខាងមុខ ។

~ ខ្ញុំទន្ទេញចាំហើយម៉ែ (ពុកខំឆ្លើយតបទាំងហត់ដង្ហក់) ។

ព្រះសង្ឃបីអង្គនិមន្តមកដល់មាត់ទ្វាររបង, យាយរលះរលាំងងើបទៅថ្វាយបង្គំនិមន្តលោកឡើងលើផ្ទះ ។ ពុកសម្រាន្តស្ដូកស្ដឹង បាត់មាត់បាត់ក គាត់ឥតស្ដាប់ឮជាលោកសូត្រធម៌ពីអ្វីខ្លះទេ ។ ស្រាប់តែគាត់ចាប់ផ្ដើមត្រដរខ្យល់ម្ដងទៀត ប្រកាច់រម្ងរនប ននៀលខ្ទេចខ្ទីអស់កន្ទេល គាត់ស្រវាកវក់យាយ ព្រមទាំងស្រែកខ្លាំងៗថា :

~ យាយ ! យាយ ! ម៉ែ កុំទៅណាចោលខ្ញុំ ! កុំទៅណាចោលខ្ញុំ ! កុំទៅណាចោលខ្ញុំ ! ។

គេចាប់រូតវាំងននយ៉ាងរហ័ស ដើម្បីបាំងកុំឲ្យព្រះសង្ឃដែលកំពុងគង់សូត្រធម៌នៅខាងម្ខាងនោះ មើលឃើញអ្នកជម្ងឺ ។

ខ្ញុំចាប់ផ្ដើមយល់ថា ក្នុងពេលបន្តិចទៀតខាងមុខនេះ ពុកនឹងបែកចេញពីយើងទៅអស់កាលជានិច្ច ឥតត្រឡប់មកវិញឡើយ ។ ខ្ញុំពុំធ្លាប់ឃើញសេចក្ដីស្លាប់ជាក់ច្បាស់នឹងភ្នែកដូចម្ដងនេះទេ ។ មុខពុកប្រែជាស្លេកស្លាំងគួរខ្លាច, ខ្លាចទាល់តែខ្ញុំមិនហ៊ានទៅជិត មិនហ៊ានទាំងមើលគាត់ទៀតផង ។

សម្លេងព្រះសង្ឃសូត្រធម៌ មានសភាពលន្លង់លន្លោចស្រងេះស្រងោចពេកណាស់ ញ៉ាំងចិត្តយើងឲ្យរឹតតែអស់សង្ឃឹមខ្លាំងឡើងថែមទៀត ។ ពុកដូចជាបានធូរបន្តិច គាត់សម្លឹងមើលមុខយើងដែលអង្គុយព័ទ្ធជុំវិញ ដំណេកគាត់ម្ដងមួយៗហើយទាររកភួយដណ្ដប់ ពីព្រោះខ្យល់ជំនោះព្រឹកព្រហាមត្រជាក់ណាស់ ។

~ ឯម ហ្ហាំ ! (ពុកស្រែកហៅម៉ែដោយសម្លេងខ្សាវៗ) ឯង, ឯងកុំគិតដល់អញធ្វើអ្វី គិតតែ ខ្លួនឯង និងកូនស្រីទៅ បានហើយ ។ ឯងមិនចាំបាច់លក់មាសប្រាក់កូន ដើម្បីធ្វើបុណ្យខ្មោចអញឲ្យអធិកអធម្មទេ

ពីព្រោះបើទុកជាធ្វើបុណ្យធំដុំ ក៏វាគ្មានបានប្រយោជន៍អ្វី ក្រៅតែពីនាំឲ្យខាតលុយឥតប្រយោជន៍នោះឡើយ ។ ឯងកុំលក់ផ្ទះណាំ យ៉ាងម៉េចៗក៏នៅសល់ដីបួលគ្រាន់ជ្រកនឹងគេដែរ... ឯណាកូនយើង ? កូនមកជិតពុកបន្តិចមើល...

ខ្ញុំដើរចូលទៅជិតទាំងរាងកាយញ័រចំប្រប់ដោយក្តីភ័យខ្លាច លុះប៉ះនឹងដៃគាត់ត្រជាក់ស្រឹតដូចទឹកកក ខ្ញុំក៏ស្ទុះថយក្រោយវិញភ្លាម ។

~ កូន... (ពុកនិយាយ ព្រមទាំងដកដង្ហើមធំ) ។

យាយប្រាបខ្ញុំចូលមកវិញ ហើយបន្ទោសថា :

~ ចៅឯង អីក៏ចិត្តអាក្រក់ម្លេះ ឪពុកមិនទាន់ស្លាប់ផង ឯងខ្លាចប៉ុណ្ណឹងទៅហើយ ធ្វើយ៉ាងនេះគេហៅថាកូនកតញ្ញូកើតដែរឬទេ ?

ខ្ញុំអង្គុយឆ្ងាយល្មមតែពុកឈោងដៃចាប់មិនដល់ ឱនមុខជ្រប់យំអណ្តឺតអណ្តក់ទាំងមិនយល់ថា ខ្លួនឯងយំពីរឿងអ្វីផង ។

~ កូន ! (ពុកនិយាយម្តងទៀតដោយលើកដៃដាក់ប្រណម្យលើដើមទ្រូង) កូនស្តាប់សំដីពុកឲ្យច្បាស់ណាំ ពីព្រោះនៅលើដីនេះមានតែឪពុកទេដែលស្រឡាញ់កូន... ថ្ងៃណាមួយកូនគង់តែយល់ជម្រៅចិត្តពុកមិនខាន...។ អត់ពីឪពុកទៅ កូនកុំទុកចិត្តនរណាឲ្យសោះ ក្រៅតែពី ខ្លួនឯង និង ម្តាយឯង ពីព្រោះ មាមីងបងប្អូន ក៏ដោយ ក៏គ្មាននរណាគេស្រឡាញ់ឯងដូចម្តាយឪពុកដែរ ។ កូនរៀនតាំងចិត្តឲ្យចេះ ចង់មានចង់បាន ហើយនៅបំរើហ្លួងយកចិត្តទុកដាក់ធ្វើការខ្ជាប់ខ្ជួន កុំឈប់ទៅរាំងឲ្យសោះ ពីព្រោះក្នុងរាំងកូនមានដីបួលជ្រក និង មិនភ័យព្រួយពីរឿងអត់ឃ្លានមានស៊ី...

ម្យ៉ាងទៀតបើឯងមកនៅក្រៅ ខ្លាចក្រែងប្រុសឈ្នោលវាមើលងាយ ដោយឯងគ្មានឪពុកនៅជាបង្គោលសម្រាប់ការពារមើលខុសត្រូវ ។ ...កូនចងចាំដំបូន្មានពុកចុះ មិនខុសទេ ។ ពិសេស កូនត្រូវដឹងគុណម្តាយ កុំធ្វើបាបម្តាយមេម៉ាយឲ្យពិបាកចិត្ត ឯងធំហើយត្រូវចេះកែគំនិតមាយាទឲ្យសមតាមអាយុ ឯងមិនមែនក្មេងទៀតទេ... ពុកមានតែពាក្យប៉ុណ្ណេះជាបណ្តាំចុងក្រោយបំផុតទុកឲ្យកូន មុននឹងលាកូនស្លាប់ បើកូនធ្វើតាមបណ្តាំឪពុក ពុកសប្បាយចិត្តណាស់ស្លាប់បិទភ្នែកជិតហើយ ! ។

គាត់សម្រាន្តស្ងួកស្ងឹង បើកភ្នែកប្រឹងសម្លឹងមើលខ្ញុំ ហាក់ដូចជាគាត់ប្រុងនឹងស្ទុះមកស្រវាអោបខ្ញុំ ។

~ ហ៊ឺ ! យិនវាស្រឡាញ់កូនណាស់, យាយកែមរអ៊ូតិចៗ ហើយប្រាបខ្ញុំឲ្យខិតចូលទៅជិតពុកបន្តិចទៀត ប៉ុន្តែពុកមើលឃើញយាយបង្អើបខ្លួន ស្មានថាគាត់ប្រឹងងើបដើរទៅណា ក៏ស្រែកអង្វរ :

~ ម៉ែ,កុំទៅណាចោលខ្ញុំ ! កុំទៅណាចោលខ្ញុំ ! ម៉ែ, កុំទៅណាចោលខ្ញុំ !

~ អរហំ ! (យាយស្រែកខ្លាំងៗ ព្រមទាំងចាប់ដៃពុកឲ្យលើកប្រណម្យដាក់លើដើមទ្រូង)...

~ អរហំ ! យិនឯង ទន្ទេញឲ្យចាំជាប់ក្នុងចិត្តទៅកូន !

~ អរហំ... (ពុកទន្ទេញតាមយាយ) ។

យើងទាំងអស់គ្នាស្រែករកពុទ្ធោ ដោយលើកដៃសំពះខ្ពស់ហួសក្បាល ។

ពុកផ្ងារក្បាលទៅក្រោយប្រួង់ត្រដរខ្យល់ម្តងទៀត... ប៉ុន្តែបង្ហើមផុតត្រឹមនេះទាំងភ្នែកបើកក្រឡែតនៅឡើយ ។ ដៃដាក់ប្រណម្យជាប់លើដើមទ្រូង ម្រាមដៃប្រឹងក្តាប់លេចសរសៃរវាម ។ ម៉ែយំបោកខ្លួនលើទ្រូងពុក, យាយយកដៃទាញបិទភ្នែកសព, ចំណែកខ្ញុំខំប្រជ្រៀតទៅកៀនគ្រែ ដោយមិនដឹងពីទំហំ នៃ ក្តីទុក្ខវេទនាដែលនឹងគ្របសង្កត់មកលើខ្ញុំឡើយ ។



ពុកសម្រាន្តនៅកន្លែងដដែល ប៉ុន្តែគេនិយាយថាគាត់ស្លាប់ទៅហើយ... ប្រហែលជាបន្តិចទៀតគាត់នឹងភ្ញាក់ឡើងវិញ... គាត់នឹងក្អក... គាត់នឹងនិយាយ... គាត់នឹងស្រែកហៅខ្ញុំក៏មិនដឹង ។ ឱ ! ប្រសិនបើយ៉ាងនេះមែន ខ្ញុំនឹងស្ទុះទៅអោបគាត់ដូចកាលខ្ញុំនៅក្មេង ដែលគាត់ធ្លាប់តែលើកបីបំពេរដាក់លើភ្លៅយ៉ាងនោះដែរ ! ពុក, ពុក, ខ្ញុំយំអណ្តឺតអណ្តក់នៅកៀនជញ្ជាំងតែម្នាក់ឯងឥតមាននរណាឃើញឡើយ ប៉ុន្តែពុកនៅស្ងៀមដដែល ។ នេះជាលើកទីមួយ ដែលគាត់មិនឆ្លើយតបនឹងសម្លេងខ្ញុំហៅគាត់ ដែលជាហេតុធ្វើឲ្យខ្ញុំចាប់ផ្តើមយល់ថា ពុកឃ្លាតពីខ្ញុំទៅហើយ ឃ្លាតឥតមានពេលត្រឡប់មកវិញឡើយ ។

ក្រោយដែលព្រះសង្ឃសូត្រធម៌ខ្មោចចប់ស្រួលបួល ម៉ែរៀបចំចង្ហាន់ប្រគេនលោកឆាន់ មានទាំងប្រអប់ម្លូ-ស្លា សម្រាប់លោកឆាន់លាងព្រះឱស្ឋទៀតផង ។ ឆាន់រួចហើយ លោកនិមន្តត្រឡប់ទៅវត្តវិញ ទើបយើងចាប់ផ្តើមរៀបចំសំអាតបុគ្គល ។ សពពុកស្អាតថែសដោយទើបនឹងមុជទឹកហើយ សាច់សស្លាំង ។ អ្នកភូមិជាច្រើននាក់ នាំគ្នាជួយជ្រោមជ្រែងម្នាក់មួយដៃមួយជើង... គ្មាននរណាជឿថាពុកស្លាប់សោះ ទាល់តែមកឃើញច្បាស់នឹងភ្នែកទើបជឿ លាន់មាត់ស្តាយ ។ អ្នកដែលបានឃើញតាអាចារ្យលាយថ្នាំឲ្យពុកពិសាកាលពីម្សិលមិញ គេនាំគ្នាចោទប្រកាន់ថា គឺគាត់នេះឯងដែលយកថ្នាំផ្តេសផ្តាសមកឲ្យឪពុកខ្ញុំពិសាទាល់តែស្លាប់ ។

គេម្ងរកន្ទេលកណ្តាលផ្ទះចេញ ប្រុសៗជួយលើកខ្មោចដាក់អង្គុយសណ្តូកជើងតងទៅលើជង្គង់ម៉ែ ចំណែកខាងចុងជើងដែលត្រជាក់ស្រេបនោះតងលើជង្គង់ខ្ញុំ ។ នេះជាករណីយកិច្ចចុងក្រោយបំផុតដែលខ្ញុំត្រូវបំពេញ ដើម្បីតបស្នងសងគុណឪពុក ។ យើង ស្រោចទឹក ដុសក្អែល រួចលាបទឹកអប់ ហើយយកកំណាត់ទេសឯក ស មករុំព័ទ្ធ ក្រោយដែលម៉ែយកប្រាក់កាក់មួយមកបង់ក្នុងមាត់សព ។ បន្តិចក្រោយមក ម៉ែនាំខ្ញុំទៅកាន់ដំណាក់ផែ ដើម្បីទូលហ្លួងឲ្យបានជ្រាបពីដំណឹងដ៏ក្រៀមក្រំនេះ ។ ពេលនោះស្រាប់តែមិត្តភក្តិទាំងអស់គេបង្ហាញសមានចិត្តចំពោះខ្ញុំគួរអោយរំភើបក្រៃលែង ។ វ៉ែនវាទទួលភារៈទៅទូលហ្លួងជំនួសខ្ញុំម្តងទៀត ។ ហ្លួងកំពុងផ្ទំសោយអាហៀន លោកប្រទានប្រាក់ឲ្យខ្ញុំ ហុកសិបរៀល ព្រមទាំងបង្គាប់ទៅក្រុមវាំងម្នាក់ ឲ្យចំណាយព្រះរាជទ្រព្យ ធ្វើម្ឈូស យកភ្លេង ទិញកំណាត់ទេសឯក និង ដេរគម្របម្ឈូស សម្រាប់ប្រើក្នុងពេលបុណ្យខ្មោចផង ។ ហ្លួងបង្គាប់មិន ឲ្យខ្ញុំកោរសក់ និង ឲ្យខ្ញុំស្លៀកពាក់ស ក្នុងរយៈពេល មួយខែ ឬ ពីរខែ ។

ខ្ញុំនាំម៉ែត្រឡប់មកផ្ទះវិញ ដោយហ្លួងសន្យាថា ស្អែកនេះម្ឈូសនឹងធ្វើចស្រេច ហើយគេនឹងដឹកយកមកឲ្យដល់ផ្ទះតែម្តង ។ ផ្ទះខ្ញុំមានមនុស្សអ៊ូអរឡើងចុះតាំងពីព្រលឹមទល់ព្រលប់ ពីព្រោះម៉ែសំរេចថា នឹងតំកល់សពទុកពីរថ្ងៃទៀត ។ ទោះបីពុកបានផ្តាំផ្ញើម៉ឺងម៉ាត់យ៉ាងណាក៏ដោយ ក៏ខ្ញុំមិនចង់ទុកគ្រឿងមាសប្រាក់មានតម្លៃធ្វើអ្វីដែរ ។ ខ្ញុំលក់ប្រអប់ប្រាក់ពីរ យកលុយមកបង្គ្រប់ជាមួយលុយហុកសិបរៀល ដើម្បីទុកសម្រាប់ចំណាយផ្សេងៗក្នុងពិធីបុណ្យ ។ គ្រឿងប្រើប្រាស់របស់ពុកទាំងប៉ុន្មាន ខ្ញុំចែកចាយឲ្យបងប្អូនអស់រលីង មានតាំងពី ខ្សៀបារី ឈើច្រត់ប្រាក់ សម្លៀកបំពាក់ រហូតដល់តុ ទូ ទៀតផង ។ រាល់ព្រឹកយើងនិមន្តលោកមកសូត្រធម៌ ទាល់តែឆាន់ព្រឹករួច ទើបលោកនិមន្តត្រឡប់ទៅវិញ ។ អស់អ្នក-អស់នាង ក្នុងវាំង និង កូនស្តេចខ្លះយក អង្ករ លុយ ទៀន ធូប មកចូលកុសល ហើយមានពួកកម្លោះខ្លះដែលខ្ញុំមិនធ្លាប់ស្គាល់ទាល់តែសោះ ក៏យករបស់ផ្សេងៗមកចូលនឹងគេដែរ ។

ថ្ងៃទីបី ជាថ្ងៃដង្ហែសពពុកទៅបូជានៅក្នុងវត្តបុទុម ក្បែរស្រះស្រង់ ។

ចាប់តាំងពីពេលពុកស្លាប់ដោយពិសាថ្នាំតាត់នោះមក អាចារ្យគ្រូផ្សំថ្នាំគាត់ពួនសម្ងំបាត់មុខ ខ្លាចក្រែងម៉ែរករឿងប្តឹងផ្តល់ ប៉ុន្តែ យាយ ព្យាយាមពន្យល់ខ្ញុំកុំឲ្យចងពៀរនឹងតានោះធ្វើអ្វី ធ្វើម៉េចពុកបានជាស្លាប់ទៅហើយ បើទុកជាប្តឹងរកខុសត្រូវទាល់តែគាត់ជាប់គុកច្រវាក់ ក៏ពុកមិនអាចរស់មកវិញដែរ ។ ខ្ញុំប្រើគេឲ្យទៅ

ហៅគាត់មក ហើយនិយាយប្រាប់ថា ៖

~ តាឯង យកថ្នាំផ្តេសផ្តាសមកឲ្យឪពុកខ្ញុំពិសាទាល់តែស្លាប់ ជាការត្រឹមត្រូវគួរតែខ្ញុំប្តឹងផ្តល់រកឲ្យឃើញសខ្មៅ ប៉ុន្តែខ្ញុំចាត់ទុករឿងនេះថាជាសំណាងអាក្រក់របស់ឪពុកខ្ញុំទៅចុះ ប្រហែលពីជាតិមុនឪពុកខ្ញុំធ្លាប់បានសម្លាប់តាឯងហើយមើលទៅ បានជាជាតិនេះតាឯងតាមសងសឹកសម្លាប់គាត់វិញ ។ ណ្ហើយចុះ តាកុំភ័យអី ខ្ញុំមិនប្តឹងទេ ប៉ុន្តែតាឯងធ្វើជាអាចារ្យស្រាប់ ជួយមើលចាត់ចែងបុណ្យខ្មោចឪពុកខ្ញុំផង ឮទេ ?

តាអាចារ្យទទួលយល់ព្រមដោយចិត្តរីករាយ ។ គាត់រៀបចំក្បួនដង្ហែ ប៉ុន្តែពួកភ្លេងភាំងមកយឺតពេលពេក យើងមិនអាចចាំយូរតទៅទៀតបាន ក៏ដាច់ចិត្តហែរចេញទៅទាំងអត់ភ្លេង ។ អាចារ្យដើរពីមុខក្បួន ខ្ញុំដើរជាប់ពីក្រោយ គាត់ស្លៀកពាក់ស ទទូរសំពត់ស ដៃឆ្វេងកាន់ផ្តិលដាក់លាជលាយជាមួយប្រាក់កាក់ ដៃស្តាំល្ងកចាប់បាចហ្វូរហែតាមផ្លូវ ដោយមានក្មេងមួយហ្វូងដើរតាមចាំដណ្តើមរើសយកលុយ ។ ខាងក្រោយខ្នងខ្ញុំ ពួកអ្នកងារសែងត្រែស្នែង ដែលនៅលើនោះ មានដាក់ម្ឈូស និង មានព្រះសង្ឃពីរអង្គគង់អមសង្ខាង ។ មិត្តភក្តិក្នុងភាំងខ្លះដូចជា សំអាង រឿង ឯម ឬ ភុំ ជាដើម ក៏បានមកជួយហែដែរ វាដើរខាងក្រោយជាមួយម៉ែ ។ ឮ នងប្អូនបង្កើតរបស់ពុក ជាអ្នកបួសមុខភ្លើង ។

នៅទីបញ្ចប់ យើងក៏បានមកដល់វត្តបុទុម ឃើញមានគេរៀបគនុសទុកហើយស្រេច ។ យើងដើរប្រទក្សិណាបីជុំ លើកម្ឈូសដាក់ទៅលើគំនរឧស បន្ទាប់មក តាអាចារ្យ និង អ្នកភ្លុក ចាប់ដុតភ្លើង ហុយផ្សែងខ្មៅទ្រលោមទៅក្នុងលំហអាកាស ។ ខ្ញុំបែរខ្នងចេញ មិនអាចទ្រាំមើលទស្សនីយភាពដ៏ខ្លោចផ្សានេះបានឡើយ... ម៉ែអង្គុយលើស្មៅស្រែកយំក្តែងៗ... ។

លុះដុតសុះអស់ ខ្ញុំបែរមកមើលឃើញនៅសល់តែ កំទេចឆ្អឹងលាយឡំជាមួយផេះ និង រងើកភ្លើងប៉ុណ្ណោះ ។ ព្រះសង្ឃនិមន្តត្រឡប់ទៅវត្តវិញ ចំណែក ញាតិមិត្តទាំងអស់ និង ខ្ញុំ នាំគ្នារើសឆ្អឹងប្រមូលដាក់ក្នុងកោដ្ឋមួយ ដើម្បីយកទៅដឹកល់ទុកក្នុងចេតិយឯព្រែកថ្មី ។



លុះធ្វើបុណ្យខ្មោចពុកចប់ស្រួលបួលហើយ ម៉ែអង្វរខ្ញុំថាឲ្យឈប់នៅភាំង មកនៅជាមួយគាត់វិញ គ្រាន់បានជាគ្នាជួយរកស៊ីចិញ្ចឹមជីវិត ។ ប៉ុន្តែខ្ញុំរំលឹកគាត់ថា ពុកបានផ្តាំផ្តាច់មិនឲ្យខ្ញុំចេញពីភាំង ម្យ៉ាងទៀតនៅក្នុងភាំងខ្ញុំមានប្រាក់ខែបន្តិចបន្តួចដែរគ្រាន់នឹងចិញ្ចឹមខ្លួន ដោយមិនបាច់រកស៊ីលក់ដូរនាំឲ្យនឿយខ្លួន ។

ចាប់តាំងពីថ្ងៃនោះមក ហ្លួងហាក់ដូចជាមានសមានចិត្តអាណិតខ្ញុំច្រើន ។ លោកបង្គាប់ឲ្យខ្ញុំដណ្តប់ផាហ៊ុសជាសញ្ញាកាន់ទុក្ខឲ្យបានយូរ និង សន្យាថា លោកនឹងឲ្យគេសង់ផ្ទះក្បឿងបីខ្នងមួយសម្រាប់ម្តាយខ្ញុំ ។ ក្រោយមកបន្តិច លោកប្រទានប្រាក់ទៅម្ចាស់ក្សត្រី ឲ្យយកទៅចែកអស់អ្នក-អស់នាង ក្នុងភាំងទាំងអស់ ហើយលោកសួរខ្ញុំថា តើមានបានទទួលប្រាក់រង្វាន់ ប្រាំរៀល ដូចគេឯងដែរឬទេ ? ខ្ញុំឆ្លើយថា បានទទួលតែបីរៀល ទេ ពីព្រោះខ្ញុំបានតែ បីរៀល មែន ហើយអ្នករបាំឯទៀតៗក៏គេឆ្លើយដូចខ្ញុំដែរ ។ តើប្រាក់នៅសល់ទាំងប៉ុន្មាន ម្ចាស់ក្សត្រីយកទៅចែកចាយឲ្យ កូនចៅលោក ឬ យ៉ាងណា ?... រឿងនេះធ្វើឲ្យហ្លួងមិនសប្បាយព្រះទ័យ ក៏ស្រែកឡូឡាថា ៖

~ រ៉ាមវាគិតយ៉ាងម៉េចហ្នឹង ? បើសិនជាវាខ្វះខាតលុយ មកសុំអញ អញមិនដែលថា មិនឲ្យម្តងណាសោះ រួចម៉េចក៏ចាំមកកេងចំណេញលើប្រាក់បន្តិចបន្តួចរបស់ក្មេងក្មាងទៀត ? ធ្វើអញ្ចឹងនាំឲ្យអ្នកមិនដឹងគេយល់ច្រឡំថា អញនេះជាមនុស្សខូចទៅវិញ ហើយម្យ៉ាងទៀតវានាំឲ្យ ស្រីត្រឹមត្រូវ និង អ្នករបាំល្អៗ គេមិនសប្បាយចិត្តរត់ចោលអញអស់ ។

និយាយចប់ហើយ លោកប្រទានប្រាក់ ប្រាំរៀលថែមទៀតឲ្យខ្ញុំ ដែលជាហេតុធ្វើឲ្យពួកឯទៀតគេច្រណែនគ្រប់គ្នា ។

ដល់ពេលដាច់ខែ ប្រាក់ខែខ្ញុំនៅតែត្រូវ យាយម៉ែន មេបំណុល កាត់យកអស់ដដែល គាត់ថាខ្ញុំមិនទាន់សងការប្រាក់គាត់គ្រប់ចំនួននៅឡើយ ។ ស្លៀតគាត់ប្រសើរមែន ពីព្រោះគាត់មានកូនប្រុសម្នាក់ធ្វើការនៅកន្លែងបើកលុយស្រាប់ ណាមួយគាត់ជាសាច់ញាតិនឹងម្ចាស់ក្សត្រី ចង់ធ្វើអ្វីក៏បានតាមចិត្ត ឥតមានកោតញញើតនរណាទេ ពីព្រោះម្ចាស់ក្សត្រីបើកដៃឲ្យហើយ ។ ប៉ុន្តែឥឡូវនេះ ខ្ញុំមិនមែនល្ងង់ដប់គត់ដូចពីដើមឯណា, ខ្ញុំមិនព្រមឲ្យនរណាប្រើស្លៀតបន្លំ រកស៊ីបិទភ្នែកខ្ញុំជាដាច់ខាត ។ ខ្ញុំទៅសួរមើលថាតើប្រាក់ខែខ្ញុំ មានបានឡើងដល់ម្ភៃរៀល ដូចគេរាល់គ្នាដែរឬទេ ? ព្រោះកាលទើបនឹងត្រឡប់មកពី បាត់ដំបងវិញភ្លាម ខ្ញុំឮហ្លួងបង្គាប់ឲ្យតម្លើងប្រាក់ខែយើងទាំងអស់គ្នា ។ អ្នកឯម មេឃ្លាំងប្រាក់ បើកបញ្ជីមើលឃើញថា ប្រាក់ខែខ្ញុំនៅតែ ដប់រៀល ដដែល ។ នេះប្រាកដជាគេភ្លេចសរសេរចុះក្នុងបញ្ជីដោយចេតនាតែម្តង ដើម្បីស្រួល

*កេងបន្ថំលើប្រាក់ខែខ្ញុំ ។ ខ្ញុំដល់ចិត្ត ប្រថុយទៅទូលហ្លួងម្ដងទៀត លោកក៏ប្រើឲ្យគេទៅហៅឯមមកគាល់ ។ ប៉ុន្តែសិយណាស់ ថ្ងៃនោះអ្នកឯមមិននៅនឹងកន្លែង តាមរកមិនឃើញសោះ ។ ដើម្បីជាការលួងចិត្ត ហ្លួងប្រទានប្រាក់ម្ភៃរៀលឲ្យខ្ញុំ ហើយរឿងនេះត្រូវចប់ត្រឹមណោះ គឺប្រាក់ខែខ្ញុំនៅតែត្រឹមដប់រៀលរហូត ។*

*ខែបន្ទាប់មក ខ្ញុំទៅតវ៉ានឹងអ្នកឯម ពីរឿងប្រាក់ខែម្ដងទៀត គាត់និយាយថាខ្ញុំច្រឡំហើយ ប្រាក់ខែខ្ញុំឥតត្រូវឡើងទេ ។ ខ្ញុំទៅទូលម្ចាស់ក្សត្រីឲ្យជួយរកយុត្តិធម៌ ប៉ុន្តែលោកធ្វើព្រងើយមិនដឹងមិនឮ ។ ខ្ញុំអាចទៅទូលហ្លួងក៏បាន ប៉ុន្តែខ្ញុំមិនមែនចង់យករឿងផ្ទាល់ខ្លួនទៅរំខានលោក សុខចិត្តឲ្យគេកាត់ប្រាក់ខែមួយខែនេះទៀតចុះ ។*

*លុយខ្ញីតែ ហាសិបរៀល សោះ គេកាត់ប្រាក់ខែយកអស់រាល់ខែ ។ មួយឆ្នាំកន្លះហើយ ក៏នៅតែមិនទាន់រួចលុយបំណុល ហើយមិត្តភក្ដិខ្ញុំដទៃទៀត ក៏ត្រូវគេប្រើស្បៀតអារកហុតឈាមដូចគ្នានេះដែរ ។ ខ្ញុំមិនចាំបាច់ឆ្ងល់ទេ ទោះបីខ្ញុំតវ៉ាយ៉ាងណា ក៏ម្ចាស់ក្សត្រីនៅតែ ធ្វើគ ធ្វើថ្លង់ ជានិច្ច ពីព្រោះមធ្យោបាយរកស៊ីចងការប្រាក់នេះ វាអាចនាំឲ្យសាច់ញាតិលោកឆាប់បានធាត់ធំ ។ ពិចារណាសព្វគ្រប់ទៅ ខ្ញុំដូចជាចាញ់ប្រាជ្ញគេ គួរឈឺចិត្តពេកណាស់ ។*

*រាល់ថ្ងៃ ម៉ែរស់នៅដោយសារបានឮខ្ញុំជួយផ្ដល់ប្រាក់កាសបន្តិចបន្តួច ដល់យូរៗទៅ គាត់ជំពាក់គេច្រើនពេក ក៏លក់ផ្ទះនៅកំពង់ផែដើម្បីយកប្រាក់សងគេ ។ គាត់អង្វរខ្ញុំឲ្យឈប់ទៅវាំង មកជួយរកស៊ីចិញ្ចឹមគាត់ផង ហើយនៅទីបញ្ចប់ ខ្ញុំក៏យល់ព្រមតាមពាក្យអង្វររបស់គាត់ទាំងបង្ខំចិត្ត ។*

*ទោះបីខ្ញុំមានការជិនធ្មន់នឹងអ្នកធំអ្នកតូចខ្លះនៅក្នុងវាំងក៏ដោយ ក៏ខ្ញុំលាចាកពីវាំងទៅទាំងទឹកភ្នែក ដោយក្ដីស្ដាយស្រណោះរបាំ ដែលខ្ញុំជាប់ចិត្តស្រឡាញ់តាំងពីក្មេងមក ។ ពេលនេះហ្លួងហាក់ដូចជាពេញចិត្តនឹងខ្ញុំណាស់ ប៉ុន្តែវាហួសពេលទៅហើយ ពីព្រោះសព្វថ្ងៃ អ្នកប្រកាន់ចិត្តស្អប់ច្រណែនឈ្នានីសខ្ញុំ ក៏មានចំនួនច្រើនណាស់ដែរ ថ្ងៃណាមួយពួកគេអាចនឹងប្រឌិតរឿងនាំឲ្យខ្ញុំមានទុក្ខទោស ត្រូវគេវាយធ្វើបាបនឹងរំពាត់ផ្ដៅ គេចាប់យកទៅឃុំឃាំងក្នុងសាលានាលិយក្សមិនខាន ។ ខ្ញុំសំរេចចិត្តរួចស្រេចហើយថា ជាការល្អគួរតែខ្ញុំឈប់នៅវាំងឲ្យបានទាន់ពេលវេលា ។*

*ខ្ញុំរក្សារឿងនេះទុកជាសម្ងាត់រហូតទល់ថ្ងៃចុងក្រោយបំផុត មានតែ យ៉ាន ម្នាក់គត់ ដែលខ្ញុំប្រាប់ឲ្យដឹង ។ ប៉ុន្តែវាមិនព្រមជឿសោះ ចេះតែថាខ្ញុំនិយាយលេង ។ ចំណែកនាងរឿង "ប្អូន" ខ្ញុំនោះវិញ តាំងពីឮថាខ្ញុំជិតឈប់នៅក្នុងវាំងមក វាស្រងូតស្រងាត់លែងរីករាយសោះតែម្ដង ។ ខ្ញុំខំនិយាយលួងលោមវាថា :*

*– នែ រឿង, ឯងគិតឲ្យហ្មត់ចត់ទៅមើល តើសេចក្ដីស្នេហារវាងស្រី និង ស្រី នេះ វាបានន័យថាម៉េច ? យើង ស្រីដូចគ្នា ប្រដាប់ក៏ដូចគ្នា តើឯងចង់ឲ្យអញធ្វើម៉េចឯង ? ឯងស្មានថាអញនៅតែធ្វើជាប្ដីឯងអញ្ចឹងរហូតទៅឬ ?*

*ប៉ុន្តែ រឿង និយាយពន្យល់ខ្ញុំវិញយ៉ាងច្បាស់លាស់ ពីសេចក្ដីស្នេហារបស់វាចំពោះខ្ញុំ :*

*– ទេ ! សារ៉ាម៉ានី, អ្នកយល់ខុសហើយ ខ្ញុំមិនមែនស្រឡាញ់អ្នកតាមរបៀបស្នេហាចំកួតនោះទេ ខ្ញុំស្រឡាញ់អ្នកពិតប្រាកដយ៉ាងស្មោះអស់ពីដួងចិត្ត ស្រឡាញ់ ទាំងខ្ញុំខ្លួនឯងមិនដឹងថា ស្នេហានេះវាបណ្ដាលមកពីអ្វីផង ។ ទោះបីអ្នកត្រូវចេញពីវាំង ទៅមានប្ដីស្រួលបួលត្រឹមត្រូវក៏ដោយ ក៏ខ្ញុំសុំទៅតាមនៅជាមួយអ្នកជានិច្ច ក្នុងឋានៈជាអ្នកបំរើម្នាក់ស្មោះត្រង់ ។*

*វានិយាយត្រង់មែន គឺវាសុខចិត្តឈប់នៅវាំងមកតាមខ្ញុំ ហើយ លោក*(១៣) *ក៏ធ្លាប់ស្គាល់វាដែរ មែន*

(១៣) គឺ បារាំងជាប្ដីនាង ដែលនាងកំពុងនិយាយរឿងប្រាប់ ។



*ទេ ? ពីព្រោះកាលយើងទើបនឹងរៀបការគ្នាហើយថ្មីៗ វានៅជាមួយខ្ញុំនៅឡើយ ប៉ុន្តែក្រោយមក វាអស់សង្ឃឹមក្នុងចិត្ត ដោយឃើញខ្ញុំស្រឡាញ់លោកច្រើនជាងវា ទើបវាឈប់នៅជាមួយខ្ញុំ ។ ទៅបានប្ដីនោះអភ័ព្វទៀត ប៉ះលើមនុស្សប៉ោយខ្សែ គេធ្វើបាបវេទនាខ្លាំងណាស់ ។*

*ខ្ញុំសំរេចចិត្តរួចហើយថា ត្រូវតែឈប់នៅវាំង ។ ខ្ញុំជួលក្រុមវាំងម្នាក់ ឲ្យលុយគាត់ពីររៀល ដើម្បីឲ្យគាត់ជួយសរសេរសំបុត្រថ្វាយបង្គំហ្លួង ។ ខ្ញុំបត់សំបុត្រជាបួន រួចតែងខ្លួនយ៉ាងស្អាតបាត ចូលទៅក្នុងដំណាក់ហ្លួងទាំងចិត្តរំភើបញាប់ញ័រក្រៃលែង ។ ពេលឃើញខ្ញុំ ហ្លួងញញឹម ហើយបង្គាប់ខ្ញុំឲ្យអង្គុយជាមួយមិត្តភក្ដិដទៃទៀតដែលត្រូវគាល់បំរើក្នុងវេនទីបួន នៅចុងជើងគ្រែ ដើម្បីរៀបចំខ្សៀអាភៀន ។ ខ្ញុំលើកខ្សៀដែល ស៊ុន វាដាក់អាភៀនរួចស្រេចថ្វាយលោក ប៉ុន្តែលោកឆ្លៀតលេងកំប្លែងបន្តិចមុននឹងទទួលយកទៅសោយ ។ ខ្ញុំគិតឃើញថា ពេលនេះមិនគួរនឹងថ្វាយសំបុត្រដល់លោកទេ ទើបសឹកវាលាក់ទៅក្រោមកន្ទេលសិន ។*

*ហ្លួងផ្ទឹសោយអាភៀនដោយឆ្លៀតនិយាយចំអន់លេងពីសប្ដិឲ្យយើងស្ដាប់ អំពីមនុស្ស គម កើតស្រែង ឬ អ្វីទៀតតាមតែលោកនឹកឃើញ ។ លោកនិយាយថា ស៊ុន លបសាហាយនឹងក្រុមវាំង ចំណែកខ្ញុំមានសាហាយម្នាក់ ជាអ្នកលេងនៅផ្សារថ្មី ។ ស៊ុន យកក្បួយដៃបុកខ្ញុំ ហើយខ្សឹបថា :*

*– សារ៉ាម៉ានី ឮទេ ? ហ្លួងនិយាយលេងជាមួយឯងដូចជាស្ញុំគាប់ព្រះទ័យដែរ... កុំអាលចេញទៅណាអីទ្រាំនៅវាំងមួយឆ្នាំទៀតទៅ ។*

*ខ្ញុំធ្វើជាមិនឮ មិនខ្វីសើចនឹងពាក្យកំប្លែងរបស់ហ្លួងទៀតផង ។*

*ហ្លួងទំនងជាសង្ស័យអ្វីម្យ៉ាងក៏ឈប់និយាយ បែរទៅសោយអាភៀនធ្វើមុខមាំ ។ ចាំដល់លោកសោយបានពីរខ្សៀ ទើបខ្ញុំហូតយកសំបុត្រពីក្រោមកន្ទេលថ្វាយទៅលោក ។ លោកជ្រួញចិញ្ចើម ហាក់ដូចជាដឹងសេចក្ដីក្នុងសំបុត្ររួចស្រេចអស់ទៅហើយ ។ ខ្ញុំឱនមុខចុះញាប់ញ័រអស់ខ្លួនប្រាណ ។*

*– សំបុត្រអ្វីហ្នឹង ? (លោកសួរខ្ញុំ ព្រមទាំងលាសំបុត្របញ្ចាំងមើលនឹងពន្លឺភ្លើង) ។*

*– ក្រាបទូល ! (ខ្ញុំឆ្លើយតបទាំងអួលដើមកស្ទើរនិយាយមិនចេញ) ខ្ញុំម្ចាស់សុំច្បាប់ឈប់ ។*

*– ថាម៉េច ? (លោកស្រែកខ្លាំងៗព្រមទាំងស្ទុះងើបអង្គុយលើគ្រែ) ឈប់ទៀតហើយ ! បន្តិចឈប់ៗ, វាមានរឿងអីទៀតហើយហាំ ?*

*– ទេ ក្រាបទូល ! ខ្ញុំម្ចាស់ សុំឈប់ធ្វើការ សុំឈប់នៅវាំងរហូតតែម្ដង ។*

*ខ្ញុំមិនហ៊ានងើបក្បាលទេ ហ្លួងងើប ដើរចុះ ដើរឡើង ដោយចិត្តអន្ទះអន្ទែង ហើយនិយាយរៀបកាចថា :*

*– មានរឿងតែប៉ុណ្ណឹងទេហ្អេ៎ ? ប៉ុន្តែ មិនអីទេមីនាង ចេញទៅចុះ ឲ្យលោកមហាមន្ត្រីយកសំបុត្រលុបឈ្មោះមក ចាំអញស៊ីញ៉េឲ្យ... ហ៊ឹះ អញអាណិតឯង ព្រោះដឹងថាឯងកំព្រាឪពុក អញសន្យា ថានឹងសង់ផ្ទះឲ្យ ថាតម្លើងប្រាក់ខែឲ្យ ប៉ុន្តែឯងបែរជារត់ចោលអញទៅវិញ ។ អញមិនឃាត់ឃាំងឯងទេ ពីព្រោះវាជារឿងផ្ទាល់ខ្លួនរបស់ឯង... អម្បាញ់មិញអញនិយាយលេងថា ឯងមានសាហាយ មិនស្មានថា ឯងលបមានសាហាយនៅខាងក្រៅអញ្ចឹងសោះ ។*

*លោកត្រឡប់មកផ្ទឹលើគ្រែវិញ លែងមាត់ លែងក ធ្វើមុខស្រងូត ។ លោកសោយអាភៀនច្រើនណាស់ សោយហើយសោយទៀត ។ វេនខ្ញុំផុតទៅហើយ ប៉ុន្តែចង់បង្ហាញឲ្យឃើញជាចុងក្រោយបំផុត នូវទឹកចិត្តស្និតស្នាលក្នុងការងារ ទើបខ្ញុំមិនទាន់ចេញមកភ្លាមជាមួយគេឯង សុខចិត្តទ្រាំនៅអង្គុយគាល់ឲ្យយូរបន្តិច ។*

*អស់អ្នក-អស់នាង ដែលបានទទួលដំណឹងថា ខ្ញុំសុំឈប់នៅវាំង គេនាំគ្នាមកប្រជុំអួរនៅមាត់ទ្វារ... អ្នកច្រណែនឈ្នានីសនឹងខ្ញុំ គេហួចសប្បាយចិត្ត ពីព្រោះគេដឹងច្បាស់ថា ខ្ញុំឈប់នៅវាំងចំលើពេលដែលហ្លួង*

កំពុងសព្វព្រះទ័យនឹងខ្ញុំ ។ អ្នកខ្លះទៀតនឹកគិតក្នុងចិត្តថា ខ្ញុំឈប់នៅវាំងព្រោះមានតួកំណាន់ចិត្តនៅខាងក្រៅ ។

ស្អែកឡើងខ្ញុំត្រឡប់មកជំណាក់ម្តងទៀត សង្ឃឹមថានឹងបានទទួលសំបុត្រអនុញ្ញាតិឲ្យចេញមិនខាន ។ ហ្លួងមើលឃើញខ្ញុំដែរ ប៉ុន្តែលោកបែរជាហុចបារីស៊ីហ្គាមួយដើមមកឲ្យខ្ញុំ ធ្វើឫកហាក់ដូចជាមិនដឹងរឿងអីសោះ ។ ខ្ញុំខំទ្រាំអត់ ចាំដល់ស្អែកមួយទៀត នៅតែមិនឮលោកថាម៉េចដដែល ក៏ប្រថុយទូលលោកថា អីវ៉ាន់ តុ ទូ ទាំងប៉ុន្មាន ខ្ញុំរៀបចំរួចស្រេចអស់ទៅហើយ នៅចាំតែព្រះរាជានុញ្ញាតប៉ុណ្ណោះ នឹងអាលជញ្ជូនអីវ៉ាន់យកទៅផ្ទះ ស្រាប់តែលោកធ្វើជាភ្ញាក់ :

~ អើ, ល្អហើយអញ្ចឹង ! ចាំស្អែកមកយកសំបុត្រពីអញទៅណា !

ល្ងាចនៃថ្ងៃនោះ ទាយទាហានក្រុមវាំងម្នាក់ដែលជាមនុស្សទំនុកទុកចិត្តរបស់ហ្លួង តាមមករកខ្ញុំដល់បន្ទប់ ហើយនិយាយថា :

~ អ្នក, ពេលនេះព្រះករុណាកំពុងសព្វព្រះទ័យនឹងអ្នកណាស់ មិនគួរអ្នកឈប់នៅវាំងសោះ... លោកប្រើខ្ញុំឲ្យមកប្រាប់ថា បើអ្នកព្រមនៅបំរើលោកតទៅទៀត លោកនឹងតម្លើងប្រាក់ខែជូន ។ ស្តាយណាស់ អ្នកមិនគួរបដិសេធសប្បុរសធម៌របស់ព្រះករុណាទេ ។

~ ហួសពេលទៅហើយ, (ខ្ញុំប្រកែកដោយទាញហេតុផលមកវែកញែកយ៉ាងសមរម្យ) ខ្ញុំមិនអាចផ្លាស់ប្តូរគំនិតបានទេពេលនេះ បើខ្ញុំព្រមនៅតទៅទៀត ហ្លួងពិតជាមិនអាចបំភ្លេចរឿងនេះបានទេ ហើយលោកថែមទាំងគុំគួនស្អប់ខ្ញុំទៀតផង ថាខ្ញុំមិនស្មោះត្រង់នឹងលោក ព្រមនៅវាំងព្រោះតែចង់បានប្រាក់ខែច្រើន... ។

មួយម៉ោងក្រោយមក គេនាំយកសំបុត្រដែលហ្លួងស៊ីញ៉េរួចស្រេចមកឲ្យខ្ញុំ ហើយខ្ញុំក៏ប្រញាប់រៀបចំអីវ៉ាន់ដើម្បីស្អែកឲ្យបានចេញដំណើរពីព្រលឹម ។ ខ្ញុំមិនប្រាប់នរណាឲ្យដឹងថា ខ្ញុំនឹងជញ្ជូនអីវ៉ាន់ចេញនៅម៉ោងប៉ុន្មានជាពិតប្រាកដ ពីព្រោះរឿងអ្នករបាំដែលធ្លាប់រស់នៅក្នុងវាំងតាំងពីក្មេងមក ហើយបែរជាឈប់ទៅវិញយ៉ាងនេះ គឺជារឿងចម្លែកមិនដែលមានទាល់តែសោះ វាអាចធ្វើឲ្យគេភ្ញាក់ផ្អើលខ្លាំងណាស់ ។ ម៉ែ និងបងប្អូនពីរបីនាក់ មកជួយជញ្ជូនគ្រែ ពូក កន្ទេល ទូ និង តុតូចតាច ដោយក្រុមវាំងម្នាក់ឈរចាំត្រួតពិនិត្យមើល ក្រែងខ្ញុំមានយកដោយរបស់អ្វីមួយដែលពុំមែនជារបស់ខ្ញុំ ។ អីវ៉ាន់ខ្ញុំពុំទាន់បីយកចេញពីបន្ទប់ផង មីស្នូរវាជញ្ជូនរបស់វាយកមកដាក់ភ្លាមមួយរំពេច ហើយចាប់តាំងពីថ្ងៃនោះមក វាបានផ្លូវឈ្មោះជាវីឡៃ ឡើងឋានៈជាស្នំឯក គាប់ព្រះទ័យហ្លួងលើសគេទាំងអស់ ។ ខ្ញុំមិនច្រណែននឹងវាទេ វាសនាមនុស្សម្នាក់ៗសុទ្ធតែទេវតាលោកចារមក្បួចស្រេច គ្មាននរណាអាចប្រកែកប្រណាំងពុំព្រមទទួលបានឡើយ ។

ខ្ញុំចេញពីព្រះរាជវាំងតាមទ្វារព្រលប់ ចេញរហូតឥតមានពេលវិលត្រឡប់មកវិញឡើយ... ក្នុងវាំងនរណាក៏ដឹងដែរ រឿងហ្លួងទទូចអង្វរឲ្យខ្ញុំនៅវាំង ហើយរឿងនេះវាធ្វើឲ្យខ្ញុំនឹកភ័យព្រួយជាប់ក្នុងចិត្តជានិច្ច ទោះបីខ្ញុំឈប់នៅវាំងហើយក្តី ។ រទេះមួយដឹកអីវ៉ាន់ឆ្ពោះទៅកាន់ផ្ទះថ្មី នៅក្បែរផ្សារដែលម៉ែទើបនឹងជួលបាន ក្រោយពេលលក់ផ្ទះឯកំពង់ផែ ។ បន្ទប់ម៉ែជួលស្ថិតនៅជាន់ខាងលើ ចំណែកពូខ្ញុំម្នាក់ឈ្មោះ សើត រកស៊ីធ្វើជាងកាត់សក់ ជួលនៅជាន់ខាងក្រោមជាមួយប្រពន្ធគាត់ ។ គាត់មានកូនស្រីម្នាក់ឈ្មោះ ផ្ការ ដែលខ្ញុំអាចប្រើប្រាស់បានតាមចិត្ត ជាជំនួស កាហ៊ុន ព្រោះ កាហ៊ុន វាត្រឡប់ទៅនៅព្រៃកប្បិវិញបាត់ទៅហើយ ។

ខ្ញុំខ្លាចទីក្រុងស្ទើរមិនហ៊ានអើតមើលទៅក្រៅតាមមាត់បង្អួចផង ជាពិសេស ពូ គាត់លាក់បំបាំងខ្ញុំណាស់ ។



ប៉ុន្តែ មិនបានប៉ុន្មានផង ស្រាប់តែលេចឃើញប្រុសកម្លោះដើរទៅមកប្រសេចប្រសាចតាមផ្លូវ អាអាក្រក់ក៏មាន អាល្អក៏មាន ។ គេចេញចូលឈ្ងួចរេតដាច់មកឲ្យពូខ្ញុំកាត់សក់ ហើយអ្នកដែលធ្លាប់ស្គាល់ម៉ែបន្តិចបន្តួច ក៏ខំទាក់ទងរាប់អាន ធ្វើឫកជាអាណិត ទិញរបស់របរមកជូនម៉ែជារឿយៗ ដែលជាហេតុអាចញ៉ាំងស្ថានភាពគ្រួសារយើង ឲ្យធូរស្រាលបានមួយកំរិតធំ ។ ពេលនោះស្រាប់តែលេចឃើញ នុរ ជា "សម្លាញ់អាប់" របស់ នុន ត្រឡប់មកពី បាត់ដំបងវិញ ដឹងថាខ្ញុំឈប់នៅវាំង វាសប្បាយចិត្តរីកមុខប៉ុនចង្អេរ ។

វានិយាយប្រាប់ថា នុន មានប្រពន្ធអ្នកបាត់ដំបង រួចវាលួចសរសេរសំបុត្រទៅប្រាប់ នុន ថាកុំឲ្យនឹកមកខ្ញុំធ្វើអ្វី ពីព្រោះបានរៀបចំការនឹងខ្ញុំហើយ ។ អានេះចំជាខូចមែន ! ។

ក្នុងពេលជាមួយគ្នានេះ ក៏មានអ្នកផ្សេងទៀតជាច្រើនចូលមកស្តីដណ្តឹងខ្ញុំដែរ ម្ល៉ោះហើយបរិយាកាសក្នុងគ្រួសារ ប្រែជាអាប់អួររកផ្លូវដោះស្រាយមិនរួចសោះ ។ យើងមិនដែលហ៊ានចេញដើរ ទៅណា មកណាឡើយ ដោយខ្លាចពួកកម្លោះឈាមរាវអស់នោះព្រួតគ្នាចាប់ធ្វើបាប ។ ម៉ែនាំយកខ្ញុំមកលាក់នៅផ្ទះបងប្អូនម្នាក់ ធ្វើជារាជការហ្លួងនៅក្នុងវាំង ។ គាត់នោះចាស់បន្តិចមែន ប៉ុន្តែប្រពន្ធគាត់នៅក្មេងល្អក់ ឈ្មោះ មីងថែម ។ បានមកនៅផ្ទះថ្មីនេះ ខ្ញុំដូចជាធូរទ្រូងច្រើន ។

មេក្រុមវាំងឈ្មោះ ទុយ នាំដំណឹងពីក្នុងវាំងមកប្រាប់ខ្ញុំដល់ផ្ទះ មីងថែម ថាហ្លួងឥតភ្លេចខ្ញុំទេ លោកឧស្សាហ៍សាកសួរគេឯងជារឿយៗពីសុខទុក្ខខ្ញុំ ហើយលោកថ្ងូលខ្លាំងណាស់នៅពេលឮគេនិយាយថា ខ្ញុំមិនទាន់មានប្តីនៅឡើយ ។ ថ្ងៃមួយចៅហ្វាយខេត្តម្នាក់ទើបនឹងរៀបការប្រពន្ធហើយថ្មីៗ នាំគ្នាទៅថ្វាយបង្គំហ្លួង ស្រាប់តែលោកនិយាយលេងរបៀបកំប្លែងថា បើចង់រកប្រពន្ធ ឲ្យមកដណ្តឹងខ្ញុំវិញ ពីព្រោះ "សារ៉ាម៉ានី" វាក្រ ហើយកំព្រាឪពុកផង ។ លោកចៅហ្វាយខេត្តប្រហោងពោះធ្លុង ប្រកែកញាប់មាត់ថា គាត់មិនអាចលែងប្រពន្ធដែលទើបនឹងរៀបការនេះបានទេ ។

ក្រោយបន្តិចមកទៀត ម្ចាស់ស្រីវង្ស កូនប្រុសច្បងរបស់ហ្លួង ដែលល្បីខាងខូចខិលរកលេខដាក់គ្មានមួយថ្ងៃៗគិតតែញ៉ែជាមួយ ប្រពន្ធស្តេចឪពុក និង ស្រីរបាំអារាត់អារាយនោះ ក៏តាមរកទាល់តែឃើញផ្ទះខ្ញុំដែរ ។ លោកសួរខ្ញុំថា សព្វថ្ងៃរកស៊ីធ្វើការអ្វី ហើយថាលោកចង់នាំខ្ញុំឲ្យទៅនៅផ្ទះជាមួយលោក ខ្ញុំឆ្លើយថា មិនហ៊ានទៅទេ ពីព្រោះថាលោកមិនមែនជាសាច់ញាតិនឹងខ្ញុំ បើធ្វើល្អនឹងខ្ញុំពេកទៅខ្លាចក្រែងអ្នកផងគេសើច ។ លោកមិនចាំឲ្យខ្ញុំនិយាយបានច្រើនទាន់ ប្រញាប់លាចេញទៅវិញភ្លាម ដោយឆ្លៀតញាក់ចិញ្ចើមរបៀបខូចបន្តិចផង ។

ទោះបីម៉ែខំបំរើងដានលាក់បំពួនយ៉ាងណា ក៏ពួកកម្លោះៗតាមរកទាល់តែឃើញ ហើយម្នាក់ៗខិតខំយកចិត្តយកថ្លើមម៉ែតែរៀងខ្លួន ។ នរណាធ្វើអីក៏ធ្វើទៅ នរណានិយាយថាម៉េចក៏ម៉ែចេះតែអ៊ឺអើ ប៉ុន្តែគាត់មិនហ៊ានសម្រេចថាលើកខ្ញុំឲ្យទៅនរណាឡើយ ពីព្រោះថាបើឲ្យទៅអ្នកមួយ អ្នកឯទៀតច្រណែនតាមព្យាបាទឈ្នានីសមិនខាន ។ ចំពោះខ្លួនខ្ញុំផ្ទាល់ ខ្ញុំនឹងស្រឡាញ់បុរសណាដែលអាចយកឈ្នះលើគូប្រជែងទាំងអស់បាន, ទាល់តែអ្នកដែលមានប្រាជ្ញាឈ្លាសវៃលើសគេ ទើបសមធ្វើជាប្តីខ្ញុំ ។ សភាពល្វីងជូរចត់ នៃ ជីវិត បានធ្វើឲ្យខ្ញុំកើតទុក្ខតប់ប្រមល់ស្គមខ្លួន នឹកស្តាយកាលរស់នៅក្នុងវាំង ព្រោះកាលនោះសេរីភាពខ្ញុំហាក់ដូចជាទូលំទូលាយជាងសព្វថ្ងៃបន្តិច ។

ពេលនោះក្រុមវាំងម្នាក់មកជួបនឹងម៉ែជាថ្មីម្តងទៀត ដើម្បីប្រាប់ថា បើខ្ញុំមិនទាន់មានប្តីទេ ហ្លួងឲ្យហៅខ្ញុំទៅនៅវាំងវិញ លោកសន្យាថានឹងមើលថែទាំខ្ញុំដូចពីដើម ហើយលោកនឹងបំភ្លេចចោលរឿងដែលខ្ញុំគេចឈប់នៅវាំងនេះ ។ ខ្ញុំមិនឆ្លើយថា ព្រម ឬ មិនព្រម ទេ ប៉ុន្តែខ្ញុំកាន់តែយល់ច្បាស់ហើយថា ទោះបីអត់ឃ្លាន

*មានស៊ីយ៉ាងណា ក៏ការរស់នៅរបស់ខ្ញុំសព្វថ្ងៃ វាមានឯករាជ្យភាពពេញលេញបរិបូណ៌ច្រើនជាងនៅក្នុងវាំងដែរ ។*

*យប់មួយ ខ្ញុំដេកយល់សប្តិ៍ឃើញពស់មួយសម្បុរ សស្គុស ចេញតាមចិកខ្ញុំជាប់ ។ ខ្ញុំភ័យភ្ញាក់ដឹងខ្លួន និយាយរឿងនេះប្រាប់ម៉ីងចែម ស្រាប់តែគាត់សើចញ៉ឹមៗហើយទាយទុកថា ខ្ញុំដល់ពេលជួបគូព្រេងហើយ គូព្រេងនោះ ជាមនុស្សសម្បុរ ស ។*

*ចាប់តាំងពីពេលយល់សប្តិ៍នោះមកមិនទាន់បានមួយអាទិត្យផង ថ្ងៃមួយម៉ែនាំទៅលេងផ្ទះសម្លាញ់គាត់ ខ្ញុំក៏ប្រទះឃើញលោក ដែលគ្រាន់តែឃើញភ្លាម ខ្ញុំអាចស្គាល់ភ្លាមថា លោកប្រាកដជាកូនបារាំងដែលខ្ញុំធ្លាប់ជួបនៅក្នុងវាំងម្តងកាលពីឆ្នាំទៅនោះហើយ ។ សម្លាញ់ម៉ែនិយាយប្រាប់គាត់ថា លោកស្រឡាញ់ខ្ញុំ ចង់ចូលស្តីដណ្តឹងរៀបការត្រឹមត្រូវតាមទំនៀមទម្លាប់ប្រពៃណីខ្មែរ ម៉ែនាំយករឿងនេះមកពិគ្រោះជាមួយបងប្អូន គេក៏យល់ស្របទាំងអស់គ្នាព្រមលើកខ្ញុំឲ្យមកកូនបារាំងឈ្មោះ កម្លោះ ពីព្រោះហេតុការណ៍ទាំងប៉ុន្មានដែលកើតមានក្នុងពេលនេះ វាត្រូវតាមពាក្យទំនាយពីមុនមកឥតខ្លោះ ។*

*ជាសំណាងល្អ ខ្ញុំបានមកភពប្រសព្វនឹងលោក ដែលជាមនុស្សមានធម៌ជួយស្រោចស្រង់ខ្ញុំឲ្យចាកផុតអស់ទុក្ខវេទនាផងទាំងពួង ។ លោកជាអ្នកមានអំណាចលើសគេ ជាអ្នកឈ្នះលើគូប្រជែងទាំងអស់ ដែលបានចូលមកស្តីដណ្តឹងខ្ញុំ ! ... ។*

♥ ♥

♥

ដំរីរៀបចំសំរាប់ដំណើរប្រមាញ់




Eléphants harnachés pour la chasse



**កម្លោះ** *ទ្រោបខ្លួនទៅជិតចង្កៀងធ្វើភ្នែកមមី ហាក់ដូចជាងោកងុយដោយសារស្តាប់រឿងដ៏ហួរហែវែងអន្លាយរបស់ភរិយា ។ តុកកែពីរនៅជំបូលផ្ទះ វាបួលឆ្លើយឆ្លងគ្នា... ខាងក្រៅផ្ទះ ស្លឹកឈើបក់រវិចតាមកម្លាំងខ្យល់ ប៉ះទង្គិចគ្នាលាន់ឮប្រាវៗ !*

*ខ្យល់ដំនោរបក់នាំសម្លេងពិណពាទ្យដីសែនពិរោះលន្លង់លន្លោច មកបំពេរបំបោសអង្អែលសង្កាត់កំពង់ផែ ឲ្យគេដេកលក់ស្ងាត់ជ្រងំ ។ សារ៉ាម៉ានី ស្ទុះងើបឈរបង្ហាញរាងកាយទន់ល្វតល្វៃសមឥតខ្ចោះប្រៀបបានកិន្នរីក្នុងរឿងព្រេងបុរាណខ្មែរ ហើយឧទានថា :*

*~ លោក ! ស្លៀកពាក់ឆាប់ឡើង, ពេលនេះជិតពាក់កណ្តាលអាធ្រាត្រទៅហើយ... លោកជូនខ្ញុំទៅមើលពួកក្មេងថ្មីៗរាំម្តងណា !*

*និយាយរួច នាងបោះជំហានញាប់ស្មេតម្រង់ទៅរកបន្ទប់ទឹកបាំងស្លឹកនៅក្បែរចង្ក្រានបាយ ។*

*ពន្លឺចង្កៀងចាំងចូលព្រាលៗ ស្ទើរងងឹត ស្ទើរភ្លឺ ទៅក្នុងបន្ទប់តូចនេះ ហាក់ដូចជាជួយបិទបាំង ពុំចាំបាច់ឲ្យនាងប្រយ័ត្នប្រយែងខ្លួនប៉ុន្មានឡើយ ។ ដៃកាន់ផ្តិលប្រាក់ នាងដងទឹកពីក្នុងពាងមកចាក់បង្ហូរស្រោចស្រប លើដងខ្លួន ហៀរស្រក់ទៅលើក្តារកំរាល ហើយដុះសាប៊ូសព្វសព៌ាង្គកាយយ៉ាងញាប់ដៃ ទំនងជាប្រញាប់រួចស្រោចទឹកម្តងទៀត ដើម្បីលាងសំអាតខ្លួនឲ្យជ្រះសាប៊ូ ។*

*ហ៊ីងមួយនៅក្រោមផ្ទះ ស្រែកបញ្ចេញក្តីសប្បាយរីករាយ ដោយត្រូវទឹកត្រជាក់ធ្លាក់ទៅលើខ្លួន ហើយសម្លេងមួយទៀតដូចគ្នាបេះបិត បន្លឺឆ្លើយឆ្លងគ្នាចេញពីក្រោមផ្ទះអ្នកជិតខាង... ប្រជៀវហើរចាបទង្គិចនឹងស្លឹកចេកលាន់ឮសូរចម្លែកគួរព្រឺក្បាល ។*

*សារ៉ាម៉ានី ដាក់ផ្តិលទៅលើគម្របពាង ទាញយកសារុងស្ងួតមកផ្លាស់ ដើម្បីទាញយកសំពត់ទទឹកចេញពីខ្លួន បន្ទាប់មកនាងបើកទ្វារបន្ទប់ទឹកដើរកាត់តាមចង្ក្រានបាយចូលមកក្នុងផ្ទះជាវិញបណ្តើរ ជូតខ្លួននឹងក្រមាសូត្របណ្តើរ :*

*~ អូយ ! អូយ ! (នាងនិយាយទាំងរងារញ័ររណ្តំធ្មាម) ទឹកត្រជាក់ណាស់លោក ! ខ្ញុំស្លៀកសំពត់អីហ៎ ? មីកាហ៊ុន ឆាប់ឡើង, បើកហិបយកសំពត់មកឲ្យអញស្លៀក ហើយយកចង្កៀងចូលក្នុងផ្ទះទៅ !........ ។*

# ~ ចប់ ~

រៀបចំបោះពុម្ពឡើងវិញដោយទស្សនាវដ្តី**អង្គរវត្ត**នៅក្រុងប៉ារីសខែសីហា២០០៥